ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-
ព្រឹទ្ធសភា និងអធិការកិច្ច

# របាយការណ៍បូកសរុប
# ការងារ ឆ្នាំ២០២២
# និងទិសដៅ ឆ្នាំ២០២៣

# មាតិកា


**អារម្ភកថា**...........................................................................................................១

**ជំពូក ១. សេចក្ដីផ្ដើម**...............................................................................................៥

**ជំពូក ២. សមិទ្ធផលការងារ**.......................................................................................៩

**១-សកម្មភាពការងាររដ្ឋបាលកិច្ចការទូទៅ**.........................................................................៩

១-១-ការងាររដ្ឋបាល ...........................................................................................................៩

១.២.ការងារបុគ្គលិក និងធនធានមនុស្ស.................................................................................១០

១.៣.ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់ .......................................................................................១២

១.៤.ការងារផែនការ និងស្ថិតិ...............................................................................................១៤

១.៥.ការងារសហប្រតិបត្តិការអន្តរជាតិ.....................................................................................១៦

**២.សកម្មភាពការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា**...................................................១៧

២.១.ការងារនីតិកម្ម ..........................................................................................................១៧

២.២.ការងារអប់រំផ្សព្វផ្សាយច្បាប់ .........................................................................................១៧

២.៣.ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា.............................................១៩

**៣.សកម្មភាពការងារអធិការកិច្ច**......................................................................................១៩

៣.១.ការងារអធិការកិច្ច (វិស័យសេដ្ឋកិច្ច រដ្ឋបាល និងសង្គមកិច្ច) ..............................................១៩

៣.២.ការងារតាមដានការអនុវត្តច្បាប់ ......................................................................................៣៣

៣.៤.ការងារទទួលពាក្យបណ្ដឹង និងអង្កេតស្រាវជ្រាវ....................................................................៥២

**៤.សកម្មភាពការងារសវនកម្មផ្ទៃក្នុង**...................................................................................៦១

**៥.សកម្មភាពការងារវិទ្យាស្ថានជាតិអធិការកិច្ច**......................................................................៦១

**៦.សកម្មភាពការងារផ្សេងៗ**..............................................................................................៦២

៦.១.សកម្មភាពការងារយេនឌ័រ ...............................................................................................៦២

៦.២.សកម្មភាពការងារចងសម្ព័ន្ធមេត្រីភាព .................................................................................៦៣

៦.៣. សមាគមសង្គហមិត្តភាព....................................................................................................៦៤

៦.៤.សកម្មភាពការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង ....................................................៦៤

៦.៥.សកម្មភាពការងារក្រុមការងារសង្រង់ព័ត៌មាន និងខ្លឹមសារអនុសាសន៍របស់សម្ដេចតេជោ នាយករដ្ឋមន្ត្រី និងឥស្សរជនជាន់ខ្ពស់ ..................................................................................................៦៤

៦.៦.សកម្មភាពការងារគេហទំព័រ MONASRI.GOV.KH និង MONASRI App ..................................៦៦

៦.៧. ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ FMIS.......................................................................................................................៦៧

**ជំពូក ៣. បញ្ហាប្រឈម**...................................................................................................៧១

**១. កម្ពុជ្ជាលិខិតបទដ្ឋានគតិយុត្ត** ........ ៧១
**២. កម្ពុជ្ជាមធ្យោបាយ សម្ភារៈ** ........ ៧១
**៤.ក្រមសីលធម៌មន្ត្រីអធិការកិច្ចនៅមានកំរិត** ........ ៧២
**៥.ភាពស្មុគ្រស្មាញ និងឧបសគ្គមួយចំនួនដែលរារាំងការងារ** ........ ៧២
**ជំពូក ៥. ទិសដៅការងារឆ្នាំ ២០២៣** ........ ៧៥
**១. រដ្ឋបាលកិច្ចការទូទៅ** ........ ៧៥
១-១-ការងាររដ្ឋបាល ........ ៧៥
១-២-ការងារបុគ្គលិក និងធនធានមនុស្ស ........ ៧៥
១-៣-ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ........ ៧៥
១-៤-ការងារផែនការ និងស្ថិតិ ........ ៧៦
១-៥-ការងារសហប្រតិបត្តិការអន្តរជាតិ ........ ៧៦
**២-ការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា** ........ ៧៧
២.១.ការងារនីតិកម្ម ........ ៧៧
២.២.ការងារអប់រំផ្សព្វផ្សាយច្បាប់ ........ ៧៧
២.៣.ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា-ព្រឹទ្ធសភា ........ ៧៧
**៣.ការងារអធិការកិច្ច** ........ ៧៨
៣.១.ការងារអធិការកិច្ច( លើវិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច ) ........ ៧៨
៣.២.ការងារតាមដានការអនុវត្តច្បាប់ ........ ៧៩
៣.៣.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ........ ៨០
**៤.ការងារសវនកម្មផ្ទៃក្នុង** ........ ៨០
**៥.ការងារវិទ្យាស្ថានជាតិអធិការកិច្ច** ........ ៨០
៥.១.ការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ ........ ៨០
៥.២. ការងារផែនការ និងស្រាវជ្រាវ ........ ៨០
៥.៣. ការងារបណ្តុះបណ្តាល ........ ៨១
៥.៤. ការងារទំនាក់ទំនងសាធារណៈ ........ ៨១
**៦.ការងារផ្សេងៗ** ........ ៨២
៦.១.ការងារយេនឌ័រ ........ ៨២
៦.២.ការងារចងសម្ព័ន្ធមេត្រីភាព ........ ៨២
៦.៣.ការងារសមាគមសង្គហមិត្តភាព ........ ៨២
៦.៤.ការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង ........ ៨២
៦.៥.ការងារគេហទំព័រ MONASRI.GOV.KH និង MONASRI App ........ ៨៣

៦.៦. ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈនិងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS ..... ៨៣

**ជំពូក ៥. សេចក្តីសន្និដ្ឋាន** ..... ៨៧

**ជំពូក ៦. ឧបសម្ព័ន្ធ** ..... ៩១

**ឧបសម្ព័ន្ធ ទី១. កម្មវិធីសន្និបាត** ..... ៩១

**ឧបសម្ព័ន្ធ ទី២. របាយការណ៍សង្ខេប** ..... ៩៤

**ឧបសម្ព័ន្ធ ទី៣. របាយការណ៍បូកសរុបលទ្ធផលសន្និបាត** ..... ១១១

**ឧបសម្ព័ន្ធ ទី៤. សុន្ទរកថាបើកសន្និបាត** ..... ១១៥

**ឧបសម្ព័ន្ធ ទី៥. សុន្ទរកថាបិទសន្និបាត** ..... ១២១

**ឧបសម្ព័ន្ធ ទី៦. កម្រងរូបថតអនុស្សាវរីយ៍** ..... ១២៦

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ឧត្តុង្គឧត្តម និងចក្ខុវិស័យដ៏វែងឆ្ងាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**បានទទួលសេចក្តីសុខ សន្តិភាព កិត្យានុភាព និងការអភិវឌ្ឍន៍លើគ្រប់វិស័យ។ អត្រាភាពក្រីក្រត្រូវបានកាត់បន្ថយជាលំដាប់ នៅពេលដែលកម្រិតជីវភាពប្រជាពលរដ្ឋទូទាំងប្រទេសកាន់តែធូរធារ។ កម្ពុជាដែលធ្លាប់ជាសមរភូមិ នៃការប្រទាញប្រទង់ពីសំណាក់មហាអំណាច និងសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ ជាវាលពិឃាតនៃរបបប្រល័យពូជសាសន៍ បានប្រែក្លាយទៅជាទីផ្សារ វិនិយោគដ៏ទាក់ទាញជាម្មណីយដ្ឋាន និងទីផ្សារទេសចរណ៍ដ៏ល្បីល្បាញលំដាប់ពិភពលោក និងជាប្រទេសមួយមានមោទនភាពជាតិស្មើមុខស្មើមាត់ជាមួយប្រទេសដទៃលើពិភពលោក។

ដើម្បីសម្រេចបានគោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជាប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ របបប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបសេដ្ឋកិច្ចបែបទីផ្សារសេរី និងបើកចំហ ដោយធ្វើការកែទម្រង់ស៊ីជម្រៅ និងដាក់ចេញយុទ្ធសាស្ត្រ ផែនការ និងគោលនយោបាយជាច្រើន ជាពិសេសយុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងបានធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់ និងពិភពលោក។

ដោយឡែក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលបានអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនក្នុងការងារចំបងគឺទំនាក់ទំនង សម្របសម្រួល រវាងរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ការចូលរួមតាក់តែង សេចក្តីព្រាងច្បាប់ ការអប់រំផ្សព្វផ្សាយច្បាប់ ការទទួល និងដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ការតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងធ្វើអធិការកិច្ចលើគ្រប់វិស័យសំដៅបង្ការ ទប់ស្កាត់ កែលម្អ និងមានវិធានការ ដើម្បីប្រឆាំងនឹងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា ដើម្បីពង្រឹងអភិបាលកិច្ចល្អ ការពារសិទ្ធិរបស់ប្រជាពលរដ្ឋ និងការពារសុវត្ថិភាពសាធារណៈ និងរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម។

ទោះជានៅឆ្នាំ ២០២២ ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាប្រទេសនានា ក្នុងពិភពលោកទើបតែងើបឡើងសន្សឹមៗ ពីវិបត្តិនៃការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ដែលបានអូសបន្លាយពីឆ្នាំ ២០១៩ មក និងបានធ្វើឲ្យរាំងស្ទះដល់ការអភិវឌ្ឍន៍ និងបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ច និងសង្គមជាតិទាំងមូលក្តី ក៏សេដ្ឋកិច្ចកម្ពុជាបានវិលត្រឡប់ទៅកាន់ការអភិវឌ្ឍ និងប្រក្រតីភាពវិញ គួរឱ្យមោទនៈ។ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្រោយពីជួបប្រទះការប្រឈមខ្លះ ដោយការរិតត្បិត ការជួបប្រជុំ និងការកាត់បន្ថយការចំណាយលើខ្ទង់មួយចំនួនដែលបណ្តាលឱ្យប៉ះពាល់ដល់លទ្ធផលការងារក្តី ក៏បានដំណើរការឡើងវិញ លើគ្រប់មុខព្រួញ និងទទួលបានលទ្ធផលការងារគួរឱ្យកត់សំគាល់។

ក្នុងនាម ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងទាំងអស់ ខ្ញុំពិតជាមានមោទនភាព និងសូមសម្តែងនូវអំណរសាទរ ចំពោះជោគជ័យ ដែលគ្រប់អគ្គនាយកដ្ឋាន គ្រប់មន្ទីរ អង្គភាពក្រោមឱវាទ ក្រសួងទាំងអស់បាន ខិតខំបំពេញការងារប្រកបដោយការទទួលខុសត្រូវ និងសម្រេចបានជោគជ័យ និងសមិទ្ធផលជាច្រើន ក្នុងការបំពេញភារកិច្ចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន។ ក្រសួងប្តេជ្ញាចិត្តបន្តការខិតខំបំពេញការងារ ឱ្យកាន់តែមាន ប្រសិទ្ធភាព និងទទួលបានជោគជ័យថ្មីៗថែមទៀត។

សមិទ្ធផលទាំងអស់ពិតជាមិនអាចកើតឡើងបានដោយចៃដន្យនោះទេ តែបានមកដោយសារមានការដឹកនាំដ៏ត្រឹមត្រូវ មានផែនការ និងយុទ្ធសាស្ត្រច្បាស់លាស់ មានជំនាញវិជ្ជាជីវៈពិតប្រាកដ និងការចូលរួមអនុវត្តយ៉ាងសកម្មពីថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលសុទ្ធតែជាតួអង្គសំខាន់ៗមិនអាចខ្វះបាន និងមានការគាំទ្រ និងកិច្ចសហការពីក្រសួង-ស្ថាប័ន និងអង្គភាពនានា ដែលតែងតែគោរព និងឱ្យតម្លៃដល់ការងារក្រសួងយើង។ ខ្លឹមសារស្ទើរតែទាំងស្រុងនៃរបាយការណ៍នេះបានមកពីលទ្ធផលនៃអង្គសន្និបាតប្រចាំឆ្នាំរបស់ក្រសួងដែលបានប្រារព្ធនៅថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០២៣កន្លងទៅ នៅសណ្ឋាគារសុខាភ្នំពេញ។

ខ្ញុំសូមកោតសរសើរ និងថ្លែងអំណរគុណ ចំពោះគណៈកម្មាការរៀបចំសន្និបាត ដែលដឹកនាំដោយឯកឧត្តមរដ្ឋលេខាធិការប្រចាំការ **ឆេង សារឿន** រួមជាមួយលោកជំទាវ **សុភ័ក្ត្រ ថាវី** ឯកឧត្តម **ហួត ហាក់** និងឯកឧត្តម **ចាប សុថារិទ្ធ** ដែលជាអនុប្រធាន និងជាប្រធានអនុគណៈកម្មាធិការ រួមជាមួយសមាជិកគណៈកម្មាធិការ ទាំងអស់ដែលបានបំពេញការងារយ៉ាងសកម្ម ធ្វើឱ្យសន្និបាតឆ្នាំនេះប្រព្រឹត្តទៅបានល្អប្រសើរ ជាពិសេសអនុគណៈកម្មាធិការឯកសារ ដែលបានប្រមូលផ្តុំ និងចងក្រងឯកសារបានគ្រប់ជ្រុងជ្រោយ។ ខ្ញុំសូមថ្លែងអំណរគុណជាពិសេស ជូនដល់ឯកឧត្តម **ចាប សុថារិទ្ធ** ដែលបានខិតខំចងក្រង និងរចនាសៀវភៅរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួង ឆ្នាំ ២០២២-២០២៣ និងឆ្នាំកន្លងមក បានល្អប្រសើរ។

ក្នុងឱកាស ឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ នេះ ខ្ញុំសូមប្រសិទ្ធពរបវរសួស្តី សិរីមង្គល វិបុលសុខ និងជោគជ័យថ្មីៗ ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់ និងសូមបួងសួងដល់ទេវតាឆ្នាំថ្មី ព្រះនាម **កិមិរាទេវី** សូមប្រោសព្រំប្រទាននូវសុខសន្តិភាព និងវឌ្ឍនភាពដល់ព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃអង្គារ ១៣ រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមេសា ឆ្នាំ ២០២៣

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន**

# ផ្នែកទី ១-សេចក្តីផ្តើម



# ជំពូក ១. សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ឧត្តុង្គឧត្តម និងចក្ខុវិស័យដ៏វែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានទទួល សេចក្តីសុខ សន្តិភាព កិត្យានុភាព និងការអភិវឌ្ឍន៍លើគ្រប់វិស័យ។ កម្ពុជាដែលធ្លាប់ជាសមរភូមិ នៃការប្រទាញប្រទង់ពីសំណាក់មហាអំណាច និងសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ ជាវាលពិឃាតនៃរបបប្រល័យពូជសាសន៍ បានប្រែក្លាយទៅជាទីផ្សារ វិនិយោគដ៏ទាក់ទាញ ជារមណីយដ្ឋាន និងទីផ្សារទេសចរណ៍ដ៏ល្បីល្បាញលំដាប់ពិភពលោក និងជាប្រទេសមួយមានមោទនភាពជាតិស្មើមុខស្មើមាត់ជាមួយប្រទេសដទៃលើពិភពលោក។

ដើម្បីសម្រេចបានគោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជា បានប្រកាន់យករបបនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបសេដ្ឋកិច្ចបែបទីផ្សារសេរី និងបើកចំហ ដោយធ្វើការងារកំណែទម្រង់ស៊ីជម្រៅ និងដាក់ចេញយុទ្ធសាស្ត្រ ផែនការ និងគោលនយោបាយជាច្រើន ជាពិសេសយុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងបានធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់ និងពិភពលោក។

ឆ្នាំ២០២២ កន្លងទៅនេះ ជាឆ្នាំពិសេស និងដ៏មមាញឹក មានអត្ថន័យជាប្រវត្តិសាស្ត្រ សម្រាប់ព្រះរាជាណាចក្រកម្ពុជា។ កម្ពុជាបានសម្រេចភារកិច្ចដ៏មមានញឹក និងមានអត្ថន័យយ៉ាងជ្រាលជ្រៅ ក្នុងតួនាទីជាម្ចាស់ផ្ទះ និងជាប្រធានប្បូរវេននៃ **កិច្ចប្រជុំកំពូលអាស៊ានលើក ទី ៤០-៤១** ព្រមទាំង កិច្ចប្រជុំកំពូលពាក់ព័ន្ធ និង**មហាសន្និបាតអន្តរសភាអាស៊ាន (អាយប៉ា AIPA) លើកទី ៤៣** ដែលមហាព្រឹត្តិការណ៍ទាំងពីរបានប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ ដ៏ត្រចះត្រចង់ជូនជាតិមាតុភូមិ។ ថ្នាក់ដឹកនាំកំពូលៗ នៃប្រទេសមហាអំណាច និងប្រទេសជាមិត្តនៅក្នុង តំបន់ និងសកលលោកបានចូលរួមព្រឹត្តិការណ៍ខាងលើ និងកោតសរសើរកម្ពុជា ចំពោះការទទួលបដិសណ្ឋារកិច្ច និងការរៀបចំដែលទទួលបានលទ្ធផលល្អប្រសើរ។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ បាននាំមកនូវកេរ្តិ៍ឈ្មោះដ៏ឧត្តុង្គឧត្តមមហាកិត្តិយសមោទនភាពជាតិ កិត្យានុភាពជាតិដ៏ថ្លៃថ្លា និងភាពល្បីរន្ទឺក្នុងតំបន់ និងអន្តរជាតិ សម្រាប់ប្រជាជនកម្ពុជាទាំងមូល ព្រមទាំងរួមចំណែកដល់ការផ្សព្វផ្សាយ អំពីកម្ពុជា នៅលើឆាកអន្តរជាតិ ជាពិសេសមនុញ្ញផលនេះ នឹងផ្តល់នូវសក្តានុពលយ៉ាងសំខាន់ ដល់ព្រះរាជាណាចក្រកម្ពុជានាពេលខាងមុខ។ ជោគជ័យខាងលើបានមកក៏ដោយសារកត្តាសន្តិភាព សន្តិសុខ និងការធានាគ្រប់គ្រងបាននូវការរាលដាល នៃជំងឺកូវីដ១៩ផងដែរ។

ដោយឡែក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ក្នុងការងារចម្បង គឺការទំនាក់ទំនង សម្របសម្រួល រវាងរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ការចូលរួមតាក់តែង សេចក្តីព្រាងច្បាប់ ការអប់រំផ្សព្វផ្សាយច្បាប់ ការទទួល និងដោះស្រាយពាក្យបណ្តឹង របស់ប្រជាពលរដ្ឋ ការតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋាន គតិយុត្តនានា និងធ្វើអធិការកិច្ច លើគ្រប់វិស័យ សំដៅ បង្ការ ទប់ស្កាត់ កែលម្អ និងមានវិធានការ ដើម្បីប្រឆាំងនឹងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា ដើម្បីពង្រឹងអភិបាលកិច្ចល្អ ការពារ

សិទ្ធិរបស់ប្រជាពលរដ្ឋ និងការពារសុវត្ថិភាពសាធារណៈ និងរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។

ដើម្បីសម្រេចបានភារកិច្ចខាងលើ ក្រសួងមានគោលបំណងគោលនយោបាយ៖ លើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈការអប់រំ បង្ការ ទប់ស្កាត់បាតុភាពអសកម្ម បង្កើនគណនេយ្យភាព ប្រសិទ្ធភាពការងារ និងពង្រឹងនីតិរដ្ឋ។

ក្នុងការអនុវត្តថវិកា ក្រសួងមានកម្មវិធីមួយគឺ ៖ បង្កើន និងពង្រឹងប្រសិទ្ធភាព វិស័យទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលក្នុងនោះរួមមាន អនុកម្មវិធី ចំនួន៤ គឺ៖

អនុកម្មវិធីទី១៖ «ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអប់រំផ្សព្វផ្សាយច្បាប់»

អនុកម្មវិធីទី២ ៖ ការងារអធិការកិច្ច

អនុកម្មវិធីទី៣ ៖ សេវាគាំទ្រទូទៅ និង

អនុកម្មវិធីទី៤ ៖ ការងារទំនាក់ ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ថ្នាក់រាជធានី-ខេត្ត។

សមិទ្ធផលការងារ ការប្រឈម របស់ក្រសួង និងសេចក្តីសន្និដ្ឋាននឹងមានចែងក្នុងជំពូកក្រោយជាបន្តបន្ទាប់។

# ជំពូក ២. សមិទ្ធផលការងារ



# ជំពូក ២. សមិទ្ធផលការងារ

ក្នុងឆ្នាំ២០២២ នេះ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានសម្រេចនូវសមិទ្ធផលនានា ជាច្រើនដូចខាងក្រោម៖

## ១-សកម្មភាពការងាររដ្ឋបាលកិច្ចការទូទៅ

### ១-១-ការងាររដ្ឋបាល

-បានទទួលលិខិតចូលពីក្រសួង-ស្ថាប័ននានាចំនួន១,៤៦១ច្បាប់ និងបញ្ជូនលិខិតចេញចំនួន១,៣២៦ច្បាប់។

-បានថតចម្លងរាល់លិខិតចេញ-ចូលក្នុងក្រសួងតម្កល់ទុកជាឯកសារ។

-បានរៀបចំប្រជុំតាមកម្មវិធីប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង នៅទីស្តីការក្រសួង។

-បានរៀបចំតាំងបដាពាក្យស្លោក ទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ ក្នុងពិធីបុណ្យជាតិ-អន្តរជាតិ នៅទីស្តីការក្រសួង។

-បានរៀបចំ និងបញ្ជូនសារលិខិតថ្វាយព្រះពរព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថសីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល និងផ្ញើសារលិខិតជូនពរថ្នាក់ដឹកនាំកំពូលរបស់ជាតិ ក្នុងពិធីបុណ្យជាតិ-អន្តរជាតិ និងពិធីខួបកំណើត។

-បានរៀបចំលិខិតបង្គាប់ការចាត់មន្ត្រីរាជការ ចូលរួមពិធីបុណ្យជាតិ-អន្តរជាតិ និងទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេសមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។

-បានរៀបចំបូកសរុបរបាយការណ៍របស់អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ និងរបាយការណ៍ក្រសួងប្រចាំខែ ត្រីមាស ឆមាស រយៈពេល៩ខែ និងប្រចាំឆ្នាំសម្រាប់ជូនទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ។

-បានចូលរួមពិធីបុណ្យជាតិ-អន្តរជាតិ សន្និបាតបូកសរុបលទ្ធផលការងារ ពិធីបើក-បិទកីឡាជាតិលើកទី៣ ពិធីមីទ្ទីញ សម្ពោធសមិទ្ធផលនានា សិក្ខាសាលា និងចូលរួមពិធីទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេសមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា

-បានគ្រប់គ្រងសរសេរខ្លឹមសារ និងថតសកម្មភាពការងារថ្នាក់ដឹកនាំ និងមន្ត្រីរាជការបញ្ចូលក្នុងគេហទំព័រផ្លូវការរបស់ក្រសួង។

-បានត្រួតពិនិត្យ និងថែទាំម៉ាស៊ីនមេ (Server) និងស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍។

-បានតាមដានរាល់សកម្មភាពព័ត៌មានដែលចេញតាមវេបសាយក្រសួង និងតាមប្រព័ន្ធFacebook page។

-បានចូលរួមប្រជុំគណៈកម្មការ និងអនុគណៈកម្មការសន្និបាត ស្តីពីការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅទីស្តីការក្រសួងចំនួន១លើក ។

-បានចូលរួមប្រជុំស្តីពីការត្រៀមចាត់មន្ត្រីរាជការចូលរួមពិធីបើក និងបិទកីឡាជាតិលើកទី៣ឆ្នាំ ២០២២ នៅពហុកីឡាដ្ឋានជាតិមរតកតេជោចំនួន១លើក។

-បានចូលរួមប្រជុំពិគ្រោះយោបល់ លើសេចក្តីព្រាងច្បាប់ស្តីពីសេវាប្រៃសណីយ៍ តាមប្រព័ន្ធអនឡាញ (ZOOM)ចំនួន១លើក។

-បានចូលរួមប្រជុំស្តីពីការត្រៀមរៀបចំពិធីបុណ្យជាតិ-អន្តរជាតិ និងទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេសមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា នៅគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិចំនួន១០លើក។

## ១.២.ការងារបុគ្គលិក និងធនធានមនុស្ស

-បានធ្វើសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការឡើងថ្នាក់ ឋានន្តរស័ក្តិជូនមន្ត្រីរាជការសម្រាប់ឆ្នាំ២០២២។

-បានធ្វើសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការទ្រទ្រង់មូលនិធិគន្ធបុប្ផា ប្រចាំក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានធ្វើសេចក្តីជូនដំណឹងស្តីពីការជ្រើសរើសមន្ត្រី ជាប់កិច្ចសន្យាឱ្យចូលបម្រើការងារនៅទីស្តីការក្រសួង និងមន្ទីររាជធានី-ខេត្តសម្រាប់ឆ្នាំ២០២៣។

-បានធ្វើប្រកាសស្តីពីការតែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការចំនួន៥១រូប ការទទួលយកក្របខ័ណ្ឌមន្ត្រីរាជការមកពីក្រសួង-ស្ថាប័នផ្សេងចំនួន៧រូប ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការទៅក្រសួង-ស្ថាប័នផ្សេងចំនួន២១រូប ការផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន៨រូប ការលុបឈ្មោះមន្ត្រីរាជការចំនួន ៥រូបចេញពីក្របខ័ណ្ឌក្រសួង និងធ្វើប្រកាសស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចំនួន ២រូបស្ថិតនៅក្រៅក្របខ័ណ្ឌដើម។

-បានធ្វើលិខិតចាត់បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសចូលរួម ក្នុងកិច្ចប្រជុំអន្តរក្រសួងកម្រិតនយោបាយ ដើម្បីពិនិត្យ និងផ្តល់ការឯកភាពលើសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្តផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ)២០១៩-២០២៣។

-បានធ្វើលិខិតស្នើសុំនិយ័តថ្នាក់ ឋានន្តរស័ក្តិជូនមន្ត្រីរាជការចំនួន១រូប ប្រធានការិយាល័យ នៃមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តព្រៃវែង។

-បានធ្វើលិខិតស្តីពីសំណើសុំចាត់បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចំនួន៣រូប ដើម្បីចូលរួមក្នុងកម្មវិធី ផ្សព្វផ្សាយពីវឌ្ឍនភាពគម្រោងFMIS និងបង្ហាញពីគោលដៅសំខាន់ៗនាជំហានទី៣ តាមប្រព័ន្ធអនឡាញ(ZOOM)។

-បានធ្វើផែនការទិន្នន័យស្ថិតិបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិល
និងក្របខ័ណ្ឌមន្ត្រីរាជការដែលទើបប្រឡងជាប់ថ្មី
សម្រាប់ឆ្នាំ២០២២-២០២៣។

-បានធ្វើលិខិតណែនាំស្តីពីវិសមតភាពក្នុងការបំពេញមុខងារសាធារណៈ និងការប្រកបវិជ្ជាជីវៈជាមេធាវី របស់មន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានធ្វើលិខិតស្តីពីការចាត់បញ្ជូនមន្ត្រីរាជការចំនួន២រូប ចូលរួមសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលបឋមនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០២១-២០២២។

-បានធ្វើលិខិតស្តីពីការចាត់បញ្ជូនថ្នាក់ដឹកនាំ ចាប់ពីរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង និងប្រធាននាយកដ្ឋានចំនួន៧រូប ចូលរួមសិក្ខាសាលាស្តីពីរដ្ឋាភិបាលឌីជីថល។

-បានធ្វើលិខិតស្តីពីការស្នើសុំនិយ័តថ្នាក់ប្តូរក្របខ័ណ្ឌមន្ត្រីរាជការចំនួន១រូប អនុប្រធានមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកែប ពីគ.៥ ទៅក៣.៤ ទៅក្រសួងមុខងារសាធារណៈ។

-បានធ្វើលិខិតស្តីពីការតម្លើងថ្នាក់មន្ត្រីរាជការ ដែលត្រូវឡើងតាមសញ្ញាបត្រ។

-បានធ្វើលិខិតស្តីពីការចាត់បញ្ជូនគ្រូឧទ្ទេសនាម ចំនួន២រូប ជំនាញច្បាប់ ការត្រួតពិនិត្យផលិតផលថ្នាំជក់ និងវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

-បានធ្វើលិខិតស្នើសុំនិយ័តឋានន្តរស័ក្តិ និងថ្នាក់ជូនមន្ត្រីរាជការចំនួន៤រូប។

-បានធ្វើលិខិតចាត់អ្នកនាំពាក្យក្រសួងចំនួន៥រូប ចូលរួមជាវាគ្មិនកិត្តិយសក្នុង សន្និសីទសារព័ត៌មានស្តីពីសមិទ្ធផលសម្រេចបានក្នុងរយៈពេល៥ឆ្នាំ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

-បានធ្វើសំណើស្នើសុំតម្លើងថ្នាក់ ឋានន្តរស័ក្តិ ជូនមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន៦០៨រូប សម្រាប់ឆ្នាំ២០២២។

-បានធ្វើលិខិតចាត់បញ្ជូនមន្ត្រីរាជការចំនួន២រូប ចូលរួមក្នុងកិច្ចប្រជុំពិភាក្សា លើរបាយការណ៍តម្រូវការបណ្តុះបណ្តាល។

-បានធ្វើលិខិតចាត់បញ្ជូនមន្ត្រីរាជការចំនួន៣រូប ចូលរួមកិច្ចសហការជាមួយក្រសួងមុខងារសាធារណៈលើការបោះពុម្ពអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ។

-បានធ្វើលិខិតចាត់បញ្ជូនមន្ត្រីរាជការ ចំនួន១រូប ចូលរួមកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តបញ្ចប់សេដ្ឋកិច្ចកម្ពុជា និងវៀតណាម។

-បានធ្វើលិខិតចាត់បញ្ជូនមន្ត្រីរាជការចំនួន១រូប បញ្ចូលជាសមាជិកគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

-បានធ្វើ និងបញ្ជូនលិខិតស្តីពីសំណើសុំពិនិត្យ និងផ្តល់ទិដ្ឋាការលើសំណុំឯកសារផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារ របស់មន្ត្រីរាជការស៊ីវិលនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ប្រចាំ ឆ្នាំ២០២២ ជូនទៅក្រសួងមុខងារសាធារណៈ និងនាយកដ្ឋានពាក់ព័ន្ធ។

-បានធ្វើ និងបញ្ជូនលិខិតស្តីពីការបើកប្រាក់បៀវត្សជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ប្រចាំ ឆ្នាំ២០២២ ជូនទៅធនាគារអេស៊ីលីដា និងនាយកដ្ឋានពាក់ព័ន្ធ។

-បានបញ្ជូនតារាងទូទាត់ប្រាក់បៀវត្ស និងអាណត្តិបើកប្រាក់បៀវត្សប្រចាំឆ្នាំ២០២២ ដែលមានហត្ថលេខាឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជូននាយកដ្ឋាន និងការិយាល័យពាក់ព័ន្ធ។

***ការងារបណ្តុះបណ្តាល**

-បានរៀបចំ និងចាត់បញ្ជូនមន្ត្រីរាជការចំនួន១៣៦រូបចូលរួមវគ្គបណ្តុះបណ្តាលជំនាញផ្សេងៗ នៅក្នុងប្រទេស ក្នុងនោះចំនួន២៤រូបតាមប្រព័ន្ធអនឡាញ និងក្រៅប្រទេសគ្មានរួមមាន៖

+បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចបឋមជំនាន់៤ វគ្គ១ វគ្គ២ វគ្គ៣ និងវគ្គ៤ ជូនមន្ត្រីរាជការ ចំនួន៩០រូប នៅទីស្តីការក្រសួង។(រៀបចំដោយវិទ្យាស្ថានជាតិអធិការកិច្ច)។

+បានចាត់បញ្ជូនមន្ត្រីរាជការ ចំនួន២រូបចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ និងរៀបចំកម្មវិធីវិនិយោគសាធារណៈ(ក.វ.ស) ៣ឆ្នាំរំកិលដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (២០១៩-២០២៣) នៅសណ្ឋាគារអង្គរប៉ារ៉ាឌីខេត្តសៀមរាប។

+បានចាត់បញ្ជូនមន្ត្រីរាជការចំនួន៦រូបចូលរួមវគ្គបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាលសម្រាប់ឆ្នាំ២០២២។

+បានចាត់បញ្ជូនមន្ត្រីរាជការចំនួន២រូបចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការផលិតព័ត៌មាន(សរសេរព័ត៌មានបឋម) នៅសាលប្រជុំធំសាលាខេត្តសៀមរាប។

+បានចាត់បញ្ជូនមន្ត្រីរាជការចំនួន១រូបចូលរួមវគ្គបណ្តុះបណ្តាលស្តីពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការខេត្តកំពង់ធំ នៅសណ្ឋាគារគ្លរៀ និងស្បា។

+បានចាត់បញ្ជូនមន្ត្រីរាជការចំនួន៣រូបចូលរួមវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ នៅក្រសួងមុខងារសាធារណៈ។

+បានចាត់បញ្ជូនមន្ត្រីរាជការចំនួន២រូបចូលរួមវគ្គបណ្តុះបណ្តាលវិក្រឹត្យការស្តីពីនីតិវិធីការអនុវត្តសវនកម្មផ្ទៃក្នុង នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

+បានចាត់បញ្ជូនមន្ត្រីរាជការ ចំនួន៣រូបចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីជំនាញឌីជីថលចាំបាច់ នៅមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តសៀមរាប។

+បានចាត់បញ្ជូនមន្ត្រីរាជការ ចំនួន៣រូបចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកែប។

+បានចាត់បញ្ជូនមន្ត្រីរាជការ ចំនួន១៤រូបចូលរួមវគ្គបណ្តុះបណ្តាលគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម តាមប្រព័ន្ធអនឡាញ(ZOOM)។

+បានចាត់បញ្ជូនមន្ត្រីរាជការចំនួន៤រូបចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីលទ្ធកម្មសាធារណៈ តាមប្រព័ន្ធអនឡាញ(ZOOM)។

+បានចាត់បញ្ជូនមន្ត្រីរាជការចំនួន៦រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជំនាញឌីជីថលចាំបាច់ រៀបចំដោយវិទ្យាស្ថានអភិបាលកិច្ចឌីជីថលនៃបណ្ឌិតសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា តាមប្រព័ន្ធអនឡាញ (Google Meet)។

## ១.៣.ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់

-បានចូលរួមពិនិត្យផ្តល់យោបល់ទាក់ទងចំណាយផ្ទៃក្នុងរបស់អង្គភាពក៏ដូចជាក្រសួងទាំងមូល។

-បានទូទាត់ឥណទានបើកសាច់ប្រាក់បេសកកម្មលើកទី៤ ឆ្នាំ២០២២។

-បានទូទាត់រង្វាន់ទេយ្យបុរេប្រទានជុំទី៤ ឆ្នាំ២០២២។

-បានទូទាត់ឥណទានបើកសាច់ប្រាក់មុនដំបូង វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងប្រជុំផ្សេងៗ ឆ្នាំ២០២២។

-បានទូទាត់ថ្លៃប្រើប្រាស់ទូរស័ព្ទ ( Mobitel )ត្រឹមខែធ្នូ ឆ្នាំ២០២២។

-បានទូទាត់ថ្លៃប្រើប្រាស់ទូរស័ព្ទ( IDD )ត្រឹមខែវិច្ឆិកា ឆ្នាំ២០២២។

-បានទូទាត់ថ្លៃប្រើប្រាស់អគ្គីសនីត្រឹមថ្ងៃទី២១ខែវិច្ឆិកា ឆ្នាំ២០២២។

-បានទូទាត់ថ្លៃប្រើប្រាស់ទឹកត្រឹមថ្ងៃទី២៣ខែមិថុនា ឆ្នាំ២០២២។

-បានទូទាត់ប្រាក់បៀវត្សជូនថ្នាក់ដឹកនាំមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យាប្រចាំខែមករា-ធ្នូ ឆ្នាំ ២០២២។

-បានទូទាត់ប្រាក់ឧបត្ថម្ភពិធីបុណ្យភ្ជុំបិណ្ឌជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា ឆ្នាំ២០២២។

-បានរៀបចំឯកសារស្នើសុំគោលការណ៍ធានាចំណាយទិញសម្ភារបរិក្ខាសុខភាព ឆ្នាំ២០២២។

-បានរៀបចំឯកសារប្រគល់-ទទួលសង្ហារិម និងសម្ភារប្រើប្រាស់ប្រចាំឆ្នាំ២០២២។

-បានរៀបចំឯកសារទូទាត់ប្រេងឥន្ធនៈប្រចាំឆ្នាំ២០២២។

-បានទូទាត់សង្ហារិម និងសម្ភារប្រើប្រាស់ប្រចាំឆ្នាំ២០២២។

-បានរៀបចំឯកសារទូទាត់សង្ហារិម និងបរិក្ខាបច្ចេកទេសមិនមែនព័ត៌មានវិទ្យាប្រចាំឆ្នាំ២០២២។

-បានរៀបចំឯកសារទូទាត់សង្ហារិម និងបរិក្ខាបច្ចេកទេសព័ត៌មានវិទ្យាប្រចាំឆ្នាំ២០២២។

-បានរៀបចំឯកសារទូទាត់ការទិញម៉ូតូ Honda Dream ប្រចាំឆ្នាំ២០២២។

-បានរៀបចំឯកសារកម្មវិធីចំណាយថវិកាទូទៅរបស់រដ្ឋប្រចាំត្រីមាសទី៤ ឆ្នាំ២០២២។

-បានរៀបចំរបាយការណ៍អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈប្រចាំត្រីមាសទី៤ ឆ្នាំ២០២២។

-បានរៀបចំឯកសារទូទាត់សម្ភារការិយាល័យប្រចាំឆ្នាំ២០២២។

-បានរៀបចំឯកសារទូទាត់បោះពុម្ពសៀវភៅច្បាប់ប្រចាំឆ្នាំ២០២២។

-បានរៀបចំឯកសារទូទាត់សម្ភារថែទាំអគារ និងសម្ភារថែទាំឧបករណ៍បច្ចេកទេស ប្រចាំឆ្នាំ ២០២២។

-បានរៀបចំឯកសារទូទាត់ការងារជួសជុលមធ្យោបាយដឹកជញ្ជូនប្រចាំឆ្នាំ២០២២។

-បានរៀបចំឯកសារទូទាត់មន្ត្រីមរណៈភាពប្រចាំឆ្នាំ២០២២។

-បានបែងចែកប្រេងឥន្ធនៈដោះស្រាយរាល់បេសកកម្ម សំណើផ្សេងៗជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ។

-បានបែងចែកសម្ភារការិយាល័យ សម្ភារបច្ចេកទេស និងដោះស្រាយរាល់បេសកកម្ម និងសំណើរផ្សេងៗ ជូនថ្នាក់ដឹកនាំនាយកដ្ឋានក្រោមឱវាទក្រសួង។

-បានបែងចែកទឹកបរិសុទ្ធសម្រាប់ប្រជុំជូនថ្នាក់ដឹកនាំ និងតាមបណ្តានាយកដ្ឋានក្រោមឱវាទក្រសួង។

-បានជួសជុលសម្ភារការិយាល័យ គ្រឿងយន្ត និងបរិក្ខាបច្ចេកទេស ក្នុងទីស្តីការក្រសួង។

-ត្រៀមចូលរួមផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមបណ្តាមន្ទីរ ទ.រព.អ រាជធានី-ខេត្ត។

## ១.៤.ការងារផែនការ និងស្ថិតិ

-បានរៀបចំកែសម្រួល និងបញ្ចូលសកម្មភាពថ្មីៗមួយចំនួនទៀតលើគម្រោងថវិការដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២(ចំណាយទូទៅរបស់រដ្ឋលម្អិតតាមមាតិកាថវិកា និងមាតិកាកម្មវិធី) របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដើម្បីឱ្យស្របតាមតម្រូវការបច្ចុប្បន្នរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-បានរៀបចំឯកសារសម្រាប់គម្រោងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស) ៣ឆ្នាំរំកិល ឆ្នាំ២០២៣-២០២៥ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានរៀបចំកែសម្រួលមុខងារចំណាយឆ្នាំ២០២២ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យស្របតាមបច្ចុប្បន្នភាពនៃមាតិកាថវិកា (ចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី)។

-បានរៀបចំកែសម្រួលសូចនាករមួយចំនួនសម្រាប់កញ្ចប់ថវិកាឆ្នាំ២០២២ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចឱ្យស្របតាមបច្ចុប្បន្នភាពនៃមាតិកាកម្មវិធី(សូចនាករ និងទិសដៅសូចនាករ)។

-បានរៀបចំកម្មវិធីវិនិយោគសាធារណៈ(ក.វ.ស)៣ឆ្នាំរំកិលឆ្នាំ(២០២៣-២០២៥) របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបានចងក្រងជាសៀវភៅ ដើម្បីជូនបណ្តាអង្គភាពពាក់ព័ន្ធ ជាពិសេសជូនក្រសួងផែនការ។

-បានរៀបចំឯកសារសម្រាប់ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ(២០២៣-២០២៥) របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបានព្រាងសូចនាករ និងទិសដៅសូចនាករ ស្របតាមបច្ចុប្បន្នភាព និងការវិវឌ្ឍជាក់ស្តែង។

-បានរៀបចំព្រាងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ(២០២៣-២០២៥) របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបានបញ្ចូលសូចនាករ និងទិសដៅសូចនាករថ្មីៗ ឱ្យស្របតាមវឌ្ឍនភាពនៃសេដ្ឋកិច្ចសង្គម។

-បានធ្វើសំណើសុំបង្កើតក្រុមការងារ និងរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ និងគម្រោងថវិការដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ(២០២៣-២០២៥) និងគម្រោងថវិការដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានរៀបចំរបាយការណ៍នៃការប្រជុំពិភាក្សា អំពីផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ (២០២៣-២០២៥)និងគម្រោងថវិការដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ របស់អគ្គនាយកដ្ឋានទាំង៣ នាយកដ្ឋានសវនកម្មផ្ទៃក្នុង វិទ្យាស្ថានជាតិអធិការកិច្ច និងបណ្តាមន្ទីររាជធានី-ខេត្តទាំង២៥ ជូនថ្នាក់ដឹកនាំជ្រាប។

-បានរៀបចំចងក្រងគម្រោងថវិការដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជាសៀវភៅ (ឯកភាពកម្រិតជំនាញ និងឯកភាពកម្រិតថ្នាក់ដឹកនាំ) ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបណ្តាអង្គភាពពាក់ព័ន្ធផ្សេងៗទៀត។

-បានរៀបចំកែសម្រួលទិន្នន័យនៃគម្រោងថវិការជ្ជសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បន្ទាប់ទទួលបានការឯកភាពពីថ្នាក់ដឹកនាំក្រសួង។

-បានរៀបចំរបាយការណ៍នៃការប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំ លើគម្រោងថវិការជ្ជសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ជូនបណ្ដាអង្គភាពចំណុះក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបណ្ដាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្តទាំង២៥ជ្រាប។

-បានព្រាងចំណុចថ្មីៗមួយចំនួន ដើម្បីស្នើសុំបញ្ចូលក្នុងគម្រោងថវិការជ្ជសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានរៀបចំរបាយការណ៍ ឆ្នាំ២០០២២ស្ដីពីការងារអប់រំផ្សព្វផ្សាយ ច្បាប់ផែនការសកម្មភាព ឆ្នាំ២០២២-២០២៤ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានកំពុងរៀបចំធាតុចូល ដើម្បីត្រៀមក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុ ជាឆ្នាំ២០២៣-២០៣០ ដើម្បីតាមដានការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្ដីពីប្រជាជន និងអភិវឌ្ឍ។

-បានរៀបចំ និងបញ្ជូន ស្ថិតិផ្លូវការដែលមានការចាត់តាំងតាមវិស័យប្រចាំ ឆ្នាំ២០២១ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជូនទៅវិទ្យានស្ថានជាតិស្ថិតិក្រសួងផែនការទីស្ដីការគណៈរដ្ឋមន្ត្រី និងចងក្រងជាសៀវភៅជូនអង្គភាពពាក់ព័ន្ធ។

-បានរៀបចំប្រមូលទិន្នន័យសម្រាប់ការចងក្រងស្ថិតិទូទៅ និងស្ថិតិផ្លូវការឆ្នាំ២០២២ ពីបណ្ដាអង្គភាពចំណុះក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ព្រមទាំងបណ្ដាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្តទាំង២៥។

-បានរៀបចំបូកសរុបរបាយការណ៍លទ្ធផល នៃការអនុវត្តថវិកាកម្មវិធីប្រចាំឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានទាំងបី នាយកដ្ឋានសវនកម្មផ្ទៃក្នុង វិទ្យាស្ថានជាតិអធិការកិច្ច និងបណ្ដាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-បានរៀបចំបញ្ចូលទិន្នន័យក្នុងតារាងរបាយការណ៍សមិទ្ធកម្ម ការអនុវត្តថវិកាកម្មវិធី សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ របស់អគ្គនាយកដ្ឋានទាំងបី នាយកដ្ឋានសវនកម្មផ្ទៃក្នុង វិទ្យាស្ថានជាតិអធិការកិច្ច និងបណ្ដាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-បានរៀបចំបូកសរុបរបាយការណ៍សមិទ្ធកម្ម (ការអនុវត្តថវិកាកម្មវិធី សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២) ប្រចាំឆមាសទី១ និងបន្តពីឆមាសទី១ របស់អគ្គនាយកដ្ឋានទាំងបី នាយកដ្ឋានសវនកម្មផ្ទៃក្នុង វិទ្យាស្ថានជាតិអធិការកិច្ច និងបណ្ដាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្តទាំង២៥។

-បានរៀបចំបូកសរុបរបាយការណ៍លទ្ធផលការអនុវត្តថវិកាកម្មវិធី ប្រចាំឆ្នាំ២០២២ របស់អគ្គនាយកដ្ឋានទាំងបី នាយកដ្ឋានសវនកម្មផ្ទៃក្នុង វិទ្យាស្ថានជាតិអធិការកិច្ច និងបណ្ដាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-បានចូលរួមជួបសម្ភាសន៍ជាមួយមន្ត្រីអង្គភាពស្រាវជ្រាវអំពីប្រជាជន និងគោលនយោបាយអភិវឌ្ឍរបស់អគ្គលេខាធិការដ្ឋានប្រជាជន និងការអភិវឌ្ឍនៃក្រសួងផែនការ ក្នុងគោលបំណងស្វែងយល់ អំពី (១) សមត្ថភាពរបស់មន្ត្រីរាជការផ្សារភ្ជាប់ទៅនឹងការងារផែនការ គោលនយោបាយជាតិ ឬស្ថាប័ន (២)

តម្រូវការបណ្តុះបណ្តាលមន្រ្តីជំនាញពាក់ព័ន្ធការរៀបចំផែនការ គោលនយោបាយ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តផែនការ នៅក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានរៀបចំប្រជុំ-ចូលរួមប្រជុំ សិក្ខាសាលា វេទិកាសាធារណៈ និងចូលរួមវគ្គបណ្តុះបណ្តាល ពាក់ព័ន្ធនឹងការងារជំនាញ និងការងារផ្សេងៗ នៅទីស្តីការក្រសួង និងក្រសួង-ស្ថាប័នផ្សេងចំនួន២៧លើក។

## ១.៥.ការងារសហប្រតិបត្តិការអន្តរជាតិ

-បានសម្របសម្រួលការជួបសវនាការការងារ រវាងថ្នាក់ដឹកនាំក្រសួងជាមួយលោកជំទាវឯកអគ្គរដ្ឋទូតសាធារណរដ្ឋឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា គណៈប្រតិភូសាធារណរដ្ឋសង្គមនិយមវៀតណាមដឹកនាំដោយឯកឧត្តម DINH TIEN DUNG សមាជិកការិយាល័យនយោបាយបក្សកុម្មុនីស្តវៀតណាម និងជាលេខាគណៈកម្មាធិការបក្សក្រុងហាណូយ និងគណៈប្រតិភូរណសិរ្សវៀតណាមដឹកនាំដោយឯកឧត្តម DO VAn CHIEN គណៈលេខាមជ្ឈិមបក្សកុម្មុនីស្តវៀតណាម និងជាប្រធានគណៈកម្មាធិការមជ្ឈិមបក្ស រណសិរ្សមាតុភូមិវៀតណាម នៅទីស្តីការក្រសួង។

-បានចូលរួម វេទិកា High-level Panel Discussion ស្តីពី Cambodia’s Role as ASEAN Chairmanship 2022 តាមប្រព័ន្ធ វីដេអូConference។

-បានចូលរួមពិធីបុណ្យខួបគម្រប់៧០ឆ្នាំនៃទំនាក់ទំនងការទូតរវាងអូស្ត្រាលី និងកម្ពុជា នៅគេហដ្ឋានឯកឧត្តមឯកអគ្គរដ្ឋទូតអូស្ត្រាលី។

-បានចូលរួមពិធីទទួល និងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ សាធារណរដ្ឋ ប្រជាធិបតេយ្យ ទីម័រខាងកើត ដឹកនាំដោយឯកឧត្តម DR JOSE RAMOS-HORIA ប្រធានាធិបតី និងគណៈប្រតិភូ ជាន់ខ្ពស់ព្រះរាជាណាចក្រប្រុយណេ ដឹកនាំដោយព្រះចៅស៊ុលតង់ HAJI HASSANAL BOLKIAH ព្រះមហាក្សត្រ និងជាព្រះប្រមុខរដ្ឋ នៅមុខព្រះបរមរាជវាំង។

-បានចូលរួមសិក្ខាសាលាស្តីពីការចែករំលែកព័ត៌មាន បទពិសោធន៍ និងនីតិវិធីគន្លឹះៗ ក្នុងការទទួលបានអាហារូបករណ៍ទៅប្រទេសអូស្ត្រាលី តាមប្រព័ន្ធអនឡាញ(ZOOM)។

-បានចូលរួមសន្និសីទគោលនយោបាយសាធារណៈអន្តរជាតិ ស្តីពីការពង្រឹង ភាពជាដៃគូ រវាងអាស៊ាន ដើម្បីកសាងអនាគតរួមគ្នា ក្នុងដំណាក់កាលក្រោយវិបត្តិកូវីដ-១៩ នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ។

-បានសម្របសម្រួលលិខិតស្តីពីដំណើរទស្សនកិច្ចផ្លូវការ របស់ថ្នាក់ដឹកនាំក្រសួង ទៅកាន់សាធារណរដ្ឋសង្គមនិយមវៀតណាម នាថ្ងៃទី២៣ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២។

-បានសម្របសម្រួលលិខិតឆ្លងដែនផ្លូវការជូនថ្នាក់ដឹកនាំក្រសួងចំនួន២៧ច្បាប់។

-បានបកប្រែលិខិតអញ្ជើញ និងឯកសារផ្សេងៗចំនួន១៧ច្បាប់។

-បានចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើការរៀបចំជំហររបស់កម្ពុជាសម្រាប់សន្និសីទកំពូលបណ្តាភាគីលើកទី២៧ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងវឌ្ឍនភាពការងារបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុ នៅក្រសួងបរិស្ថានចំនួន១លើក។

-បានចូលរួមកិច្ចប្រជុំមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងប្រជាជនវៀតណាម-កម្ពុជាលើកទី៥ និងបូកសរុបលទ្ធផល១០ឆ្នាំនៃកម្មវិធីបណ្ដុះពន្លកមិត្តភាព នៅខេត្តបិញហ្វឿក និងខេត្តដាក់ណុងចំនួន ១លើក។

-បានចូលរួមកិច្ចប្រជុំពិភាក្សាលើខ្លឹមសារអនុស្សរណៈយោគយល់គ្នា រវាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងអធិការកិច្ចរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅទីស្ដីការក្រសួងចំនួន១លើក។

# ២.សកម្មភាពការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

## ២.១.ការងារនីតិកម្ម

-បានចូលរួមប្រជុំអន្តរក្រសួង សិក្ខាសាលា និងកិច្ចប្រជុំនានាចំនួន៧លើក។

-បានចុះស្ទង់មតិស្ដីពីការយល់ដឹងរបស់ប្រជាពលរដ្ឋលើច្បាប់ចំនួន១៥លើក(អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភាចំនួន៦លើក និងមន្ទីររាជធានី-ខេត្តចំនួន៩លើក) គឺច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកចំនួន៩លើក(ខេត្តកំពតចំនួន៩លើក) និងច្បាប់ភូមិបាល ចំនួន ៦លើក (ខេត្តស្វាយរៀង ចំនួន២លើក កំពង់ចាមចំនួន២លើក និងខេត្តពោធិ៍សាត់ចំនួន២លើក) ដោយមានប្រជាពលរដ្ឋ ចូលរួមចំនួន១,៥២១នាក់(ស្ត្រីចំនួន៧១៥នាក់)។

-បានបញ្ចូលឯកសារច្បាប់ចំនួន៣៩ច្បាប់ទៅក្នុងបណ្ណាល័យអេឡិចត្រូនិច។

## ២.២.ការងារអប់រំផ្សព្វផ្សាយច្បាប់

-បានចុះផ្សព្វផ្សាយច្បាប់ចំនួន១៤៧លើក (អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភាចំនួន១០លើក និងមន្ទីររាជធានី-ខេត្តចំនួន១៣៧លើក) គឺច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកចំនួន៤៥លើក(ខេត្តស្ទឹងត្រែងចំនួន១០លើក កំពង់ធំចំនួន៩លើក កំពង់ចាមចំនួន៨លើក ក្រចេះចំនួន៧លើក ព្រះសីហនុចំនួន៣លើក បន្ទាយមានជ័យចំនួន ៣លើក កំពង់ស្ពឺចំនួន២លើក កំពត ចំនួន២លើក និងខេត្តសៀមរាបចំនួន១លើក) ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន៤០លើក(ខេត្តព្រះសីហនុចំនួន១០លើក ក្រចេះចំនួន៧លើក កំពង់ស្ពឺចំនួន៦លើក កំពង់ធំចំនួន៦លើក កំពង់ចាមចំនួន៥លើក តាកែវចំនួន៣លើក ត្បូងឃ្មុំចំនួន២លើក និងខេត្តកំពតចំនួន១លើក) ច្បាប់ភូមិបាលចំនួន៥លើក (ខេត្តក្រចេះចំនួន៤លើក និងខេត្តសៀមរាបចំនួន១លើក) ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះចំនួន៨លើក(ខេត្តក្រចេះចំនួន៥លើក កំពតចំនួន១លើក ព្រះសីហនុ ចំនួន ១លើក និងខេត្តសៀមរាបចំនួន១លើក) ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចំនួន១លើក (ខេត្តកំពតចំនួន១លើក) ច្បាប់ស្ដីពីផ្លូវថ្នល់ចំនួន២លើក(ខេត្តក្រចេះចំនួន២លើក) អនុក្រឹត្យស្ដីពីការគ្រប់គ្រងដីរដ្ឋចំនួន៤លើក (ខេត្តកំពង់ស្ពឺចំនួន២លើក និងខេត្តមណ្ឌលគិរីចំនួន ២លើក) អនុក្រឹត្យស្ដីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនចំនួន១លើក(ខេត្តក្រចេះចំនួន១លើក) ច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក និងវិធីការពារជំងឺកូវីដ-១៩ចំនួន១៥លើក(ខេត្តស្វាយរៀងចំនួន១២លើក និងខេត្តកែបចំនួន៣លើក) ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងវិធីការពារជំងឺកូវីដ-១៩ចំនួន

៩លើក (ខេត្តឧត្តរមានជ័យចំនួន៧លើក និងខេត្តកែបចំនួន២លើក) ច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ និងវិធីការពារជំងឺកូវីដ-១៩ ចំនួន២លើក(ខេត្តកែបចំនួន២លើក) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន អំពើល្មើសច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា និងវិធីការពារជំងឺកូវីដ-១៩ចំនួន១៤លើក(ខេត្តព្រៃវែងចំនួន១៤លើក) និងច្បាប់ភូមិបាល ច្បាប់ស្តីពីផលផល និងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងដីរដ្ឋចំនួន១លើក(ខេត្តត្បូងឃ្មុំចំនួន១លើក) ដោយមានអ្នកចូលរួមចំនួន ២០,៤២៩នាក់ (ស្ត្រី ចំនួន៨,៣៧៧នាក់) និងទទួលបានសំណួរចំនួន៣,៩៤១សំណួរ។

-បានផលិតវីដេអូផ្សព្វផ្សាយដើម្បីចាក់ផ្សាយតាមទូរទស្សន៍ និងបណ្តាញសង្គមចំនួន៩ ប្រធានបទរួមមាន៖

- ១.ច្បាប់ស្តីពីក្រមរដ្ឋប្បវេណី (ប្រធានបទ ការលែងលះ)
- ២.ច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ (ប្រធានបទ ផលប៉ះពាល់ និងវិធានការទប់ស្កាត់ចំពោះការប្រើប្រាស់ផលិតផលថ្នាំជក់)
- ៣.ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- ៤.ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- ៥.ច្បាប់ស្តីពីក្រមរដ្ឋប្បវេណី (ប្រធានបទ កុំជាប់ពាក្យ)
- ៦.ច្បាប់ស្តីពីក្រមរដ្ឋប្បវេណី (ប្រធានបទ អាពាហ៍ពិពាហ៍)
- ៧.ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ ជំងឺអេដស៍
- ៨.ច្បាប់ស្តីពីការរំលូតកូន (ប្រធានបទ បែបបទ និងលក្ខខណ្ឌ នៃការរំលូតកូន)
- ៩.អនុក្រឹត្យស្តីពីការគ្រប់គ្រង និងការប្រើប្រាស់អគារសហកម្មសិទ្ធិ (ប្រធានបទ សិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិ) ។

-បានតាមដានពីវឌ្ឍនភាពនៃការផ្សព្វផ្សាយវីដេអូឃ្លីបសំណួរ-ចម្លើយច្បាប់ ដែលនាយកដ្ឋានផលិតបានក្នុងបណ្តាញសង្គម តាមរយៈផេក (Facebook Page) ចំនួន៦វីដេអូឃ្លីបមានដូចខាងក្រោម៖

+ផេក(Facebook Page) របស់ក្រសួង បានផុសវីដេអូឃ្លីបសំណួរ-ចម្លើយច្បាប់ ចំនួនសរុប ៩ច្បាប់ និង អនុក្រឹត្យចំនួន១ (មាន៧វីដេអូឃ្លីប) ដោយទទួលបានអ្នកទស្សនាចំនួនសរុប២.៥៦៧នាក់ អ្នកចុចLike ចំនួនសរុប១.៣១១នាក់ អ្នកចែករំលែក(Share)ចំនួនសរុប១៤២នាក់។

+ផេក(Facebook Page) អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា បានផុសវីដេអូឃ្លីបសំណួរ-ចម្លើយច្បាប់ ចំនួនសរុប៦ច្បាប់ និងអនុក្រឹត្យចំនួន១ ដោយទទួលបានអ្នកទស្សនា ចំនួនសរុប១,៧៩៤នាក់ អ្នកចុចLike ចំនួនសរុប៨៨០នាក់ អ្នកចែករំលែក (Share) ចំនួនសរុប ១២៨ នាក់។

+ផេក(Facebook Page) នាយកដ្ឋានអប់រំផ្សព្វផ្សាយច្បាប់ បានផុសវីដេអូឃ្លីបសំណួរ-ចម្លើយច្បាប់ចំនួនសរុប៦ច្បាប់ និងអនុក្រឹត្យចំនួន១ ដោយទទួលបានអ្នកទស្សនាចំនួនសរុប៩៦១នាក់ អ្នកចុចLike ចំនួនសរុប៦៦៣ នាក់ អ្នកចែករំលែក(Share)ចំនួនសរុប៣៨នាក់។

+ផេក(Facebook Page) បណ្ណាល័យច្បាប់អេឡិចត្រូនិច បានផុសវីដេអូឃ្លីបសំណួរ-ចម្លើយច្បាប់ ចំនួន សរុប៦ច្បាប់ ដោយទទួលបានអ្នកទស្សនាចំនួនសរុប២០៧នាក់ អ្នកចុចLike ចំនួនសរុប៣១នាក់ អ្នកចែករំលែក (Share)ចំនួនសរុប១៣នាក់។

+ផេក(Facebook Page) ទូរទស្សន៍អប្សរា បានផុសវីដេអូឃ្លីបសំណួរ-ចម្លើយច្បាប់ សរុបចំនួន៦ច្បាប់ និងអនុក្រឹត្យចំនួន១ ដោយទទួលបានអ្នកទស្សនា ចំនួនសរុប១,៦៨៩នាក់ អ្នកចុច Like ចំនួនសរុប៧២នាក់ អ្នកចែករំលែក(Share)ចំនួនសរុប៣២នាក់។

-បានទំនាក់ទំនងផ្សព្វផ្សាយវិទ្យុ និងផេកមន្ទីរព័ត៌មានខេត្តកំពង់ចាម ពីលក្ខណៈសម្បត្តិភូមិ-ឃុំមានសុវត្ថិភាព ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន(អំពីទោសទណ្ឌនៃការប្រើប្រាស់ និងជួញដូរគ្រឿងញៀន) និងសេចក្តីជូនដំណឹងស្តីពីការប្រមូលពន្ធ លើមធ្យោបាយដឹកជញ្ជូន យានជំនិះ គ្រប់ប្រភេទចំនួន៤១៥លើក។

### ២.៣.ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា

-បានចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រីចំនួន៥៧លើក។

-បានចូលរួមស្តាប់សម័យប្រជុំពេញអង្គរបស់រដ្ឋសភាចំនួន២៦លើក។

-បានចូលរួមស្តាប់សម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភាចំនួន១៩លើក។

-បានរៀបចំវេទិកាសាធារណៈដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋចំនួន៦លើក គឺនៅខេត្តតាកែវចំនួន២លើក ពោធិ៍សាត់ ចំនួន២លើក និងខេត្តមណ្ឌលគិរី ចំនួន២លើក ដោយមានប្រជាពលរដ្ឋចូលរួមចំនួន៤៩៥នាក់ (ស្ត្រីចំនួន១៣៩នាក់) និងបានទទួលសំណូមពរពីប្រជាពលរដ្ឋចំនួន ៧២សំណូមពរ។

## ៣.សកម្មភាពការងារអធិការកិច្ច

### ៣.១.ការងារអធិការកិច្ច (វិស័យសេដ្ឋកិច្ច រដ្ឋបាល និងសង្គមកិច្ច)

-កំពុងចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ រដ្ឋាករទឹកស្វយ័តសៀមរាប និងនៅរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ សាលាដំបូងរាជធានី ខេត្ត ពន្ធនាគាររាជធានី ខេត្ត ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ មន្ទីរ-អង្គភាពជុំវិញរាជធានីខេត្ត នៅរាជធានីភ្នំពេញ ខេត្តពោធិ៍សាត់ និងខេត្តព្រះវិហារ។

-កំពុងឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំរដ្ឋបាលខេត្ត ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ និងរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក សាលាដំបូងខេត្ត ពន្ធនាគារខេត្ត ស្នងការដ្ឋាននគរបាល អធិការដ្ឋាននគរបាលក្រុង ស្រុក មន្ទីរ-អង្គភាពជុំវិញខេត្ត នៅខេត្តព្រះសីហនុ ខេត្តកែប ខេត្តប៉ៃលិន ខេត្តកណ្តាល និងខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តសៀមរាប ខេត្តមណ្ឌលគិរី ខេត្តស្វាយរៀង និងខេត្តកំពង់ធំ។

-កំពុងឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងសុខាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា ស្តីពីលទ្ធផលនៃចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ។

-បានបញ្ចប់ការចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅក្រសួងបរិស្ថាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងព័ត៌មាន អគ្គិសនីកម្ពុជា និងរដ្ឋបាលខេត្ត រដ្ឋបាលក្រុងស្រុក សាលាដំបូងខេត្ត ពន្ធនាគារខេត្ត ស្នងការដ្ឋាននគរបាលខេត្ត អធិការដ្ឋាននគរបាលក្រុងស្រុក មន្ទីរ-អង្គភាពជុំវិញខេត្ត នៅខេត្តបន្ទាយមានជ័យ ខេត្តរតនគិរី ខេត្តស្ទឹងត្រែង ខេត្តបាត់ដំបង ខេត្តតាកែវ ខេត្តបាត់ដំបង ខេត្តឧត្តរមានជ័យ ខេត្តក្រចេះ ខេត្តកោះកុង ខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ ខេត្តត្បូងឃ្មុំ និងខេត្តកំពត។

-បានចេញលិខិតជូនដំណឹងទៅក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងពាណិជ្ជកម្ម ដើម្បីជំរុញឱ្យធ្វើការកែលម្អចំណុចខ្វះខាត លើការអនុវត្តតួនាទីភារកិច្ច និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវបណ្តាវិធានការ របស់គណៈប្រតិភូអធិការកិច្ចក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ២០១៨។

-បានទទួលរបាយការណ៍ជូនជ្រាបតាមបណ្តាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន១៨ គឺមន្ទីរទរពអខេត្តកំពង់ចាមចំនួន១២លើក មន្ទីរទរពអខេត្តស្វាយរៀង ចំនួន១២លើក មន្ទីរទរពអខេត្តតាកែវចំនួន១២លើក មន្ទីរទរពអខេត្តត្បូងឃ្មុំចំនួន១២លើក មន្ទីរទរពអខេត្តកែបចំនួន១១លើក មន្ទីរទរពអខេត្តកំពត ចំនួន១១លើក មន្ទីរទរពអខេត្តកំពង់ស្ពឺចំនួន១១លើក មន្ទីរទរពអខេត្តក្រចេះចំនួន១០លើក មន្ទីរទរពអខេត្តកំពង់ធំចំនួន១០លើក មន្ទីរទរពអរាជធានី ភ្នំពេញចំនួន១០លើក មន្ទីរទរពអខេត្តពោធិ៍សាត់ចំនួន៩លើក មន្ទីរទរពអខេត្តកណ្តាលចំនួន៩លើក មន្ទីរទរពអខេត្តព្រះសីហនុ ចំនួន៩លើក មន្ទីរទរពអខេត្តបាត់ដំបង ចំនួន៨លើក មន្ទីរទរពអខេត្តកោះកុង ចំនួន៦លើក មន្ទីរទរពអខេត្តស្ទឹងត្រែង ចំនួន៤លើក មន្ទីរទរពអខេត្តកំពង់ឆ្នាំង ចំនួន២លើក និងមន្ទីរទរពអខេត្តព្រះវិហារ ចំនួន១លើក។

***លទ្ធផលការងារអធិការកិច្ច** (**វិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច**)

-បានចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ច ការគ្រប់គ្រងផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្ម សាធារណៈ តាមបណ្តាក្រសួងចំនួន១២ រដ្ឋបាលរាជធានី-ខេត្ត ស្នងការដ្ឋានរាជធានី-ខេត្ត អធិការដ្ឋានក្រុង-ស្រុក-ខណ្ឌ សាលាដំបូងរាជធានី-ខេត្ត ពន្ធនាគាររាជធានី-ខេត្ត មន្ទីរ-អង្គភាពជុំវិញរាជធានី-ខេត្ត ចំនួន២៥រាជធានី-ខេត្ត។

-បានធ្វើលិខិតជូនដំណឹងទៅក្រសួងពាណិជ្ជកម្ម ដើម្បីជំរុញឱ្យធ្វើការកែលម្អ ចំណុចខ្វះខាត លើការអនុវត្តតួនាទីភារកិច្ច ការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវបណ្តា

វិធានការរបស់គណៈប្រតិភូអធិការកិច្ច ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ២០១៨។

-បានធ្វើលិខិតជូនដំណឹងទៅក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្ត កងវិស្វកម្ម និងអង្គភាពពាក់ព័ន្ធ ដើម្បីជំរុញឱ្យធ្វើការកែលម្អចំណុចខ្វះខាតលើការអនុវត្តតួនាទីភារកិច្ចក្នុងការងារស្តារ សាងសង់ ជួសជុល ថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងការងារសាងសង់ ជួសជុល ថែទាំខួប ប្រចាំ និងបន្ទាន់ផ្លូវលំជនបទ ក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវបណ្តាវិធានការ របស់គណៈប្រតិភូអធិការកិច្ចក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ២០១៨។

-បានធ្វើលិខិតជូនដំណឹងទៅក្រសួងធនធានទឹក និងឧតុនិយម មន្ទីរធនធានទឹក និងឧតុនិយម រាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធ ដើម្បីជំរុញឱ្យធ្វើការកែលម្អចំណុចខ្វះខាត លើការអនុវត្តតួនាទីភារកិច្ចក្នុងការងារស្តារ សាងសង់ ជួសជុលថែទាំប្រព័ន្ធធារាសាស្ត្រ និងការប្រើប្រាស់ប្រេងអន្តរាគមន៍ ក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវបណ្តាវិធានការ របស់គណៈប្រតិភូអធិការកិច្ចក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ២០១៨។

-បានធ្វើលិខិតជូនដំណឹងទៅក្រសួងសាធារណការ និងដឹកជញ្ជូន មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត កងវិស្វកម្ម និងអង្គភាពពាក់ព័ន្ធ ដើម្បីជំរុញឱ្យធ្វើការកែលម្អ ចំណុចខ្វះខាតលើការអនុវត្តតួនាទីភារកិច្ចការផ្តល់ សេវាសាធារណៈ និងការងារសាងសង់ ជួសជុល ថែទាំខួប ប្រចាំ និងបន្ទាន់ ក្នុងការិយបរិច្ឆេទ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវបណ្តាវិធានការ របស់គណៈប្រតិភូអធិការកិច្ចក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ២០១៨។

**ក.ការអនុវត្តតួនាទីភារកិច្ច**

-នាយកដ្ឋានសុវត្ថិភាពចរាចរណ៍ផ្លូវគោកបានអប់រំផ្សព្វផ្សាយឈុតវីដេអូខ្លីៗ និងព័ត៌មាន ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ពុំទាន់ទូលំទូលាយនៅឡើយ ដោយបានផ្សព្វផ្សាយតាមរយៈបណ្តាញសង្គម Facebook តែប៉ុណ្ណោះ។

-នាយកដ្ឋានសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងក្រសួង ស្ថាប័នពាក់ព័ន្ធ ពុំទាន់បានកត់ត្រាទិន្នន័យគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកតាមប្រព័ន្ធព័ត៌មានវិទ្យានៅឡើយ។

-ការស្ថាបនា និងជួសជុលជលយានទន្លេ និងសមុទ្រមួយចំនួនពុំមានលិខិតអនុញ្ញាតពីនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក និងនាយកដ្ឋាននាវាជំនួញសមុទ្រ។

-កំពង់ផែមួយចំនួនបានធ្វើប្រតិបត្តិការកំពង់ផែ ដោយពុំមានលិខិតអនុញ្ញាត ធ្វើប្រតិបត្តិការកំពង់ផែ។

-មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តបាត់ដំបង ស្ទឹងត្រែង ត្បូងឃ្មុំ ក្រចេះ និងខេត្តព្រៃវែង ពុំបានប្រមូល និងចងក្រងស្ថិតិមធ្យោបាយដឹកជញ្ជូនតាមផ្លូវគោក ផ្លូវទន្លេ ឡូជីស្ទីកផ្លូវគោក ផ្លូវទន្លេ ការចុះបញ្ជីជលយានយន្ត ហាងលក់រថយន្ត ទិន្នន័យស្ថានីយ សេវាតាមដងផ្លូវ ស្ថានីយសម្រាក ទីតាំង សម្រាកលំហែ សួនច្បារនិងរុក្ខកម្ម ប្រព័ន្ធបំភ្លឺ បរិក្ខារសុវត្ថិភាពនៅក្នុងដែនដីខេត្តរបស់ខ្លួន។

-មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ស្ពឺពុំបានត្រួតពិនិត្យវាយតម្លៃបច្ចេកទេស សមត្ថភាព គុណភាពគ្រឿងចក្រ ចងក្រងព័ត៌មានទិន្នន័យ ការប្រើប្រាស់គ្រឿងចក្រ ដើម្បីធានាសុវត្ថិភាពការងារ ផលប៉ះពាល់សុខភាពអ្នកបើកបរ និងកម្មករពុំបានចុះត្រួតពិនិត្យការធ្វើសេវាកម្ម លាងយានយន្ត ទោចក្រយានយន្តពុំបានធ្វើសវនកម្មសុវត្ថិភាពចរាចរណ៍ផ្លូវគោក
និងសិក្សាវាយតម្លៃកម្រិតសុវត្ថិភាពផ្លូវថ្នល់។

-ការតភ្ជាប់បណ្តាញលូរបស់ប្រជាពលរដ្ឋមួយចំនួនមកបណ្តាញលូសាធារណៈរបស់រដ្ឋ ធ្វើឡើងដោយពុំមានការស្នើសុំមកមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តបាត់ដំបង។

-មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្ទឹងត្រែង និងខេត្តក្រចេះមានភាពយឺតយ៉ាវក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌផ្លូវជនបទក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងពុំបានរៀបចំបែបបទចងក្រងជាសមាគម ការគ្រប់គ្រង និងវិធានការដែលពាក់ព័ន្ធនឹងបញ្ជីការគណនេយ្យ របាយការណ៍ការពារមូលនិធិសន្សំប្រាក់។

-មន្ទីរផែនការខេត្តបាត់ដំបង ពុំបានបណ្តុះបណ្តាលនីតិវិធីនៃដំណើរការប្រមូលទិន្នន័យមូលដ្ឋានសម្របសម្រួលដំណើរការប្រមូលទិន្នន័យតាមភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ការពង្រឹងសមត្ថភាព ធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីការប្រើប្រាស់ឯកសារព័ត៌មានស្ថានភាព ឯកសារពិន្ទុវិស័យ ឯកសារអត្រាក្រីក្រ ឯកសារអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឯកសារផ្សេងៗទៀត សម្រាប់ជាឧបករណ៍នៃការរៀបចំផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគថ្នាក់ក្រោមជាតិ និងសម្រាប់គ្រប់គ្រង ការអភិវឌ្ឍមូលដ្ឋាន។

-មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបងពុំបានរៀបចំការប្រកួតកីឡាមហាជន និងកីឡាសិស្សការបង្កើត គណៈកម្មការទ្រទ្រង់សកម្មភាពកីឡា ការអនុវត្តកម្មវិធីសិក្សាផ្នែកអប់រំកាយ និងកីឡាសិស្សតាមគ្រឹះស្ថានសិក្សា។

-មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង និងខេត្តស្ទឹងត្រែង ពុំទាន់បានសិក្សាស្រាវជ្រាវអំពីវប្បធម៌ ប្រពៃណីទំនៀមទម្លាប់ជាតិ និងជនជាតិ ពុំទាន់បានចុះស្រង់ស្ថិតិទីតាំងអាជីវកម្មចម្លាក់ តម្បាញ ប៉ាក់ឌិន គំនូរ ការតែងលំអ សិល្បៈថតរូប អាជីវកម្មលក់ស៊ីឌី វីស៊ីឌី និងឌីវីឌី និងពុំទាន់បានធ្វើបច្ចុប្បន្នភាពស្ថិតិសេវាកម្មវប្បធម៌ និងវិចិត្រសិល្បៈគ្រប់ប្រភេទនៅក្នុងភូមិសាស្ត្រខេត្ត។

-មន្ទីរសុខាភិបាល មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មន្ទីរពាណិជ្ជកម្ម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី មន្ទីររ៉ែ និង ថាមពល មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ មន្ទីរទេសចរណ៍ មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ពុំទាន់បានជំរុញ និងមានវិធានការឱ្យម្ចាស់អាជីវកម្មសិប្បកម្ម សេវាកម្មដែលកំពុងប្រកបអាជីវកម្មក្នុងភូមិសាស្ត្រខេត្តរបស់ខ្លួនដោយពុំមានលិខិតអញ្ញាត។

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបាត់ដំបងពុំទាន់បានជំរុញ និងមានវិធានការឱ្យម្ចាស់គម្រោងអភិវឌ្ឍដីមួយចំនួនកំពុងប្រកបអាជីវកម្ម ក្នុងភូមិសាស្ត្រខេត្ត របស់ខ្លួនដោយពុំមានលិខិតអនុញ្ញាតអភិវឌ្ឍដី

-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបងពុំបានចុះធ្វើអធិការកិច្ច ដើម្បីត្រួតពិនិត្យការអនុវត្ត ច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតាមសហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង និងខេត្តស្ទឹងត្រែងពុំបានធ្វើបច្ចុប្បភាពស្ថិតិមុខរបរ និងស្ថិតិអ្នកគ្មានការងារធ្វើនៅក្នុងខេត្ត និងពុំបានផ្សព្វផ្សាយច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិពាក់ព័ន្ធ ឱ្យបានទូលំទូលាយនៅឡើយ។

-មន្ទីររ៉ែ និងថាមពលខេត្តបាត់ដំបងពុំទាន់បានប្រមូលចំណូលពីសួយសាររ៉ែនៃការប្រើប្រាស់អាចម៍ដី និងថ្លៃសំណង់ពីអ្នកធ្វើអាជីវកម្មលើគម្រោងសាងសង់ និងជួសជុលផ្លូវរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក មន្ទីរ អង្គភាពជំនាញ និងមូលនិធិឃុំ សង្កាត់។

-មន្ទីររ៉ែ និងថាមពលខេត្តបាត់ដំបង ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី និងខេត្តកំពង់ស្ពឺពុំទាន់មានវិធានការជំរុញ និងណែនាំដល់ម្ចាស់ស្ថានីយប្រេងឥន្ទនៈ ដែលពុំមានលិខិតអនុញ្ញាត ដំណើរការស្ថានីយប្រេងឥន្ទនៈ និងវិញ្ញាបនបត្របញ្ជាក់លក្ខណៈបច្ចេកទេសសុវត្ថិភាព ស្ថានីយប្រេងឥន្ទនៈ ពីក្រសួងរ៉ែ និងថាមពល។

-មន្ទីររ៉ែ និងថាមពលខេត្តរតនគិរីពុំមានបណ្ណាល័យសម្រាប់តាំងបង្ហាញ និងរក្សាទុកគំរូរ៉ែដែលមានក្នុងភូមិសាស្ត្ររបស់ខ្លួន។

-មន្ទីរបរិស្ថានខេត្តបាត់ដំបងពុំទាន់បានចុះបញ្ជីដីតំបន់ការពារធម្មជាតិ និងដីតំបន់ការពារបេតិកភណ្ឌដែលមានទំហំសរុប ចំនួន១០៧,៣១០ហិកតា។

-មន្ទីរបរិស្ថានខេត្តបាត់ដំបង និងខេត្តរតនគិរី ពុំទាន់បានស្តារ ដាំដុះព្រៃឈើ បោះបង្គោលព្រំប្រទល់កំណត់ដែនជម្រកសត្វព្រៃ និងពុំបានជំរុញម្ចាស់ក្រុមហ៊ុនអាជីវកម្ម និងសេវាកម្ម ដែលជាប្រភពបំពុលនៅក្នុងភូមិសាស្ត្រខេត្តរបស់ខ្លួន ឱ្យចូលរួមបង់វិភាគទានចូលមូលនិធិទាយជ្ជទានបរិស្ថានប្រចាំឆ្នាំតាមការស្ម័គ្រចិត្តសម្រាប់ការស្តារបរិស្ថានឡើងវិញ និងពុំទាន់បានអប់រំ និងផ្សព្វផ្សាយច្បាប់ស្តីពីបរិស្ថាន ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

-មន្ទីរធម្មការ និងសាសនាខេត្តស្ទឹងត្រែង ខេត្តបាត់ដំបង និងខេត្តរតនគិរី ពុំទាន់បានសិក្សាស្រាវជ្រាវ និងចងក្រងឯកសារស្តីពីជំនឿប្រពៃណីរបស់ជនជាតិដើមភាគតិចដែលរស់នៅក្នុងខេត្ត និងនៅមានការខ្វះខាតគ្រូបង្រៀនក្របខ័ណ្ឌគ្រប់កម្រិតនៅតាមសាលាពុទ្ធិកសិក្សា។

-មន្ទីរទេសចរណ៍ខេត្តស្ទឹងត្រែង ពុំបានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិទេសចរណ៍ ក្នុងភូមិសាស្ត្រខេត្តរបស់ខ្លួននាយកដ្ឋាន អង្គភាពសរុបចំនួន៧ នៃអគ្គិសនីកម្ពុជា និងមន្ទីរ អង្គភាពចំនួន១១ ក្នុងខេត្តតាកែវ បន្ទាយមានជ័យ ស្ទឹងត្រែង និងខេត្តសៀមរាប ពុំបានធ្វើរបាយការណ៍ បូកសរុបលទ្ធផលការងារប្រចាំឆ្នាំនៅឡើយ។

-គ្រូបង្រៀនតាមមុខវិជ្ជាជំនាញមួយចំនួននៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តរតនគិរី ពុំទាន់បានធ្វើកិច្ចតែងការបង្រៀនសម្រាប់ការបណ្តុះបណ្តាលដល់សិស្ស និស្សិត។

-ពាក្យសុំចូលរៀន និងប្រវត្តិរូបរបស់សិស្ស និស្សិតនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តរតនគិរីពុំមានការចុះហត្ថលេខារបស់សាមីខ្លួន រូបថត និងចុះហត្ថលេខារបស់នាយកមជ្ឈមណ្ឌល។

-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តរតនគិរី មានភាពយឺតយ៉ាវក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សាជូនសិក្ខាកាមដែលបានបញ្ចប់ការសិក្សា

-ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរ អង្គភាពសរុបចំនួន៩០ ក្នុងខេត្តបន្ទាយមានជ័យ តាកែវ ឧត្តរមានជ័យ ត្បូងឃ្មុំ កំពង់ស្ពឺ និងខេត្តសៀមរាប ពុំទាន់មានប្រធានការិយាល័យសម្រាប់ដឹកនាំ និងគ្រប់គ្រងនៅឡើយ។

-ស្នងការដ្ឋាននគរបាលខេត្តកោះកុង ពុំបានឃោសនា ផ្សព្វផ្សាយ អប់រំ ណែនាំប្រជាពលរដ្ឋឱ្យយល់ដឹង គោរព និងអនុវត្តបទដ្ឋានសុវត្ថិភាពចរាចរណ៍។

-មន្ទីរមុខងារសាធារណៈខេត្តរតនគិរីពុំទាន់បានរៀបចំផែនការក្នុងការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ។

-មន្ទីរពាណិជ្ជកម្មខេត្តរតនគិរី ពុំបានតាមដានទិន្នន័យស្តុកស្រូវ និងអង្ករតាមរោងម៉ាស៊ីន និងស្តុកឃ្លាំងក្នុងភូមិសាស្ត្រខេត្តរបស់ខ្លួន។

-មន្ទីរ អង្គភាពសរុបចំនួន៣៣ ក្នុងខេត្តរតនគិរី ឧត្តរមានជ័យ រតនគិរី បន្ទាយមានជ័យ និងខេត្តតាកែវ មានមន្ត្រីមួយចំនួនពុំបានមកបំពេញការងារឱ្យបានជាប់លាប់ និងមួយចំនួនឈប់សម្រាកដោយគ្មានលិខិតអនុញ្ញាតច្បាប់ត្រឹមត្រូវ។

-បទល្មើសព្រៃឈើមួយចំនួននៅតែបន្តកើតមានក្នុងដែនសមត្ថកិច្ចរបស់ខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តរតនគិរី (មានឈើគ្មានប្រភពច្បាស់លាស់ ត្រូវបានដឹកតាមម៉ូតូ និងឡាន ចូលរោងសិប្បកម្ម)។

-មន្ទីរធនធានទឹក និងឧតុនិយមរាជធានីភ្នំពេញ ខេត្តប៉ៃលិន សៀមរាប ត្បូងឃ្មុំ ព្រះសីហនុ កែប កំពង់ឆ្នាំង និងខេត្តកណ្តាល មានមន្ត្រីមួយចំនួនមានឈ្មោះចុះបេសកកម្ម ប៉ុន្តែមានហត្ថលេខាលើបញ្ជីវត្តមាននៅមន្ទីរ ក្នុងកាលបរិច្ឆេទដូចគ្នានឹងកាលបរិច្ឆេទចុះបេសកកម្ម។

-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តរតនគិរី ពុំទាន់បានជំរុញសហគមន៍កសិកម្មសរុបចំនួន១១សហគមន៍ឱ្យមកចុះបញ្ជីការនៅឡើយ។

-រដ្ឋបាលខេត្ត ក្រុង ស្រុកសរុបចំនួន១៥ ក្នុងខេត្តបាត់ដំបង មានភាពយឺតយ៉ាវ ក្នុងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយប្រចាំឆ្នាំ។

-ក្រុមប្រឹក្សានៃរដ្ឋបាលក្រុង ស្រុក សរុបចំនួន១៧ ក្នុងខេត្តបាត់ដំបង និងខេត្តមណ្ឌលគិរី ពុំទាន់បានដាក់ចេញនូវដីកាស្តីពីការកំណត់តម្លៃសេវារដ្ឋបាលជាក់ស្តែង សម្រាប់ប្រតិបត្តិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

-ការិយាល័យត្រួតពិនិត្យផ្ទៃក្នុងនៃរដ្ឋបាលក្រុងបាត់ដំបងពុំបានត្រួតពិនិត្យ លើការងាររដ្ឋបាល ការងារបុគ្គលិក ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលក្រុង។

-ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាននៃរដ្ឋបាលក្រុងបាត់ដំបង ពុំបានផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដល់មន្ត្រី បុគ្គលិក និងប្រជាពលរដ្ឋ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

-ស្នងការដ្ឋាននគរបាលខេត្តរតនគិរី ពុំបានបំពេញព័ត៌មានមួយចំនួន របស់អ្នកស្នើសុំប្រើប្រាស់អាវុធក្នុង សៀវភៅស្នើសុំប្រើប្រាស់អាវុធដូចជា រូបថត ប្រទេសផលិត លេខទូរស័ព្ទ ប័ណ្ណសម្គាល់ចាស់ ថ្ងៃខែឆ្នាំ ចេញប័ណ្ណ ថ្ងៃផុតកំណត់ និងពុំបានតាមដានការប្រើប្រាស់គ្រឿងផ្ទុះ នៅតាមទីតាំងការដ្ឋាននានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

-រដ្ឋបាលក្រុង ស្រុក សរុបចំនួន៣៩ក្នុងខេត្តរតនគិរី និងខេត្តបាត់ដំបងពុំទាន់បានបង្កើត ឬកែសម្រួលសមាសភាពក្រុមការងារដីរដ្ឋថ្នាក់ស្រុក និងមួយចំនួនទៀតបានកំពុងដំណើរការចុះបញ្ជីដីរដ្ឋ និងកសាងប្លង់គោលប្រើប្រាស់ដីធ្លីថ្នាក់ស្រុក តែពុំទាន់រួចរាល់នៅឡើយ។

-នាយកដ្ឋានបញ្ជូនអគ្គិសនីមានអនុស្ថានីយមួយចំនួន ពុំទាន់បានដាក់ដំណើរការប្រព័ន្ធតេឡេខម (Telecom) និងមានគ្រង់ស្វូនៅតាមបណ្ដាអនុស្ថានីយចំនួន១១ ដំណើការលើសបន្ទុក៩០% និងចំនួន ៣ ដំណើរការលើសបន្ទុក១០០%។

-គ្រឹះបង្គោលខ្សែបញ្ជូន១១៥KV ពីអនុស្ថានីយទី៧មកអនុស្ថានីយទី២ របស់នាយកដ្ឋានបញ្ជូនអគ្គិសនីត្រូវបានចាក់លុបដីជើងបង្គោលដោយសារការអភិវឌ្ឍនៅតំបន់ជុំវិញ។

-គម្រោងទី៥ របស់ក្រុមហ៊ុនអ៊ិនធើប៊ីភីសឺលូសិន ឧបភើរេសិន ដែលមានអាជ្ញាប័ណ្ណ លេខ២៥៩L ត្រូវបាននាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទវាយតម្លៃជាតំបន់ទី៣ ប៉ុន្តែទីតាំងជាក់ស្តែងដែលសេវាករស្នើសុំជាតំបន់ដែលមានប្រជាជនរស់នៅមធ្យម និងជាភូមិរបស់ប្រជាជន។

-នាយកដ្ឋានដឹកជញ្ជូនផ្លូវគោកនៃក្រសួងសាធារការ និងដឹកជញ្ជូនពុំទាន់បានជំរុញ ម្ចាស់អាជីវកម្មដឹកជញ្ជូនឱ្យមកសុំបន្តសុពលភាពលិខិតអនុញ្ញាតប្រកបអាជីវកម្មឱ្យអស់លទ្ធភាពនៅឡើយ។

-អធិការដ្ឋាននគរបាលក្រុង ស្រុកសរុបចំនួន៨ ក្នុងខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ស្ពឺ ពុំទាន់មាននាយផ្នែក និងនាយប៉ុស្តិ៍សម្រាប់ដឹកនាំ និងគ្រប់គ្រងនៅឡើយ។

-អគារ និងបន្ទប់ឃុំឃាំងសម្រាប់ជនជាប់ឃុំរបស់ពន្ធនាគារខេត្តរតនគិរី បន្ទាយមានជ័យ ព្រៃវែង កំពង់ស្ពឺ កំពង់ធំ មណ្ឌលគិរី និងខេត្តកំពង់ឆ្នាំង មានលក្ខណៈតូចចង្អៀតមិនសមាមាត្រទៅនឹងចំនួនជនជាប់ឃុំ។

-មានជនជាប់ឃុំចំនួន១២នាក់ក្នុងពន្ធនាគារខេត្តបន្ទាយមានជ័យ ពិរុទ្ធជន និងទណ្ឌិត ចំនួន៣នាក់ ក្នុងពន្ធនាគារខេត្តឧត្តរមានជ័យ បានទទួលមរណភាព ដោយពុំទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ធ្វើបុណ្យតាមប្រពៃណី។

-ការផ្តល់ថវិកាសម្រាប់របបជីវភាពជនជាប់ឃុំដល់ពន្ធនាគារខេត្តតាកែវ និងខេត្តឧត្តរមានជ័យ នៅមានភាពយឺតយ៉ាវ

-ពន្ធនាគារខេត្តរតនគិរី បាត់ដំបង ព្រៃវែង កោះកុង និងខេត្តតាកែវពុំបានរៀបចំហ្វឹកហាត់គម្រោងផែនការការពារ ធ្វើសមយុទ្ធ ប្រកាសអាសន្នសាកល្បង កម្មវិធីសម្រាប់អប់រំកែប្រែដល់ជនជាប់ឃុំអំពីច្បាប់ នីតិវិធី បទបញ្ជាផ្ទៃក្នុងពន្ធនាគារ ចំណេះដឹងទូទៅ សីលធម៌សង្គម ប្រពៃណី សិល្បៈ វប្បធម៌ សាសនា កីឡា កិច្ចការថែរក្សាសុខភាពអនាម័យ បង្ការជំងឺ និងការអប់រំណែ នាំដល់ទណ្ឌិតមុនពេលត្រូវដោះលែង។

-ការធ្វើសំណើសុំរបបឧបត្ថម្ភការដោះលែងគឺជាតួនាទី របស់ការិយាល័យអប់រំកែប្រែ និងស្តារនីតិសម្បទា ប៉ុន្តែពន្ធនាគារខេត្តរតនគិរី និងខេត្តបាត់ដំបងបានប្រគល់ឱ្យការិយាល័យ រដ្ឋបាលសរុបជាអ្នកអនុវត្ត។

-ការបើកប្រាក់របបឧបត្ថម្ភពិរុទ្ធជន និងទណ្ឌិតដែលត្រូវដោះលែងរបស់ពន្ធនាគារខេត្តរតនគិរី មានភាពពុំច្បាស់លាស់ដោយស្នាមមេដៃពិរុទ្ធជន និងទណ្ឌិតដែលដោះលែង ពុំដូចគ្នាជាមួយនឹងស្នាមមេដៃរបស់ពិរុទ្ធជន និងទណ្ឌិតនៅក្នុងសៀវភៅបញ្ជីឈ្មោះពិរុទ្ធជន និងទណ្ឌិត។

-ពន្ធនាគារខេត្តកោះកុង ពុំបានធ្វើជំរឿនស្ថិតិជនជាប់ឃុំ ញៀនថ្នាំ ដើម្បីទំនាក់ទំនងជាមួយមន្ទីរ-អង្គភាពពាក់ព័ន្ធ ក្នុងការគាំទ្រដល់ការព្យាបាលបន្សាបសារធាតុញៀន និងការអប់រំព្យាបាលសុខភាពនៅឡើយ។

-ពន្ធនាគារខេត្តរតនគិរី តាកែវ បន្ទាយមានជ័យ ព្រៃវែង កំពង់ធំ និងខេត្តមណ្ឌលគិរីមានភាពខ្វះចន្លោះក្នុងការកត់ត្រាក្នុងសៀវភៅបញ្ជីឈ្មោះពិរុទ្ធជន និងទណ្ឌិតមួយចំនួនដូចជាពុំបានបិទរូបថត និងផ្តិតមេដៃពិរុទ្ធជន។

-ស្នងការដ្ឋាននគរបាលខេត្ត អធិការដ្ឋាននគរបាលក្រុង ស្រុកសរុបចំនួន១១ ក្នុងខេត្តចំនួន៣ គឺខេត្តរតនគិរី បាត់ដំបង និងខេត្តកំពង់ស្ពឺ ពុំបានធ្វើសៀវភៅចុះលេខសំណុំរឿង សៀវភៅបញ្ជី នៃការឃាត់ខ្លួន និងសៀវភៅបញ្ជីបណ្តឹង។

-ស្នងការដ្ឋាននគរបាលខេត្តរតនគិរី និងខេត្តបាត់ដំបងពុំទាន់បានប្រមូលចំណូល ពីសហគ្រាសគ្រឹះស្ថានជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនផ្ទាល់ខ្លួនមួយចំនួនឱ្យអស់លទ្ធភាព និងពុំបានគ្រប់គ្រងទិន្នន័យ សំណុំបែបបទ បញ្ជីឈ្មោះភ្នាក់ងារសន្តិសុខឯកជនតាមប្រព័ន្ធព័ត៌មានវិទ្យា។

-ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ស្ទឹងត្រែង បាត់ដំបង និងខេត្តកោះកុងពុំបានកសាងផែនការបណ្តុះបណ្តាលមន្ត្រីនគរបាលជាតិ អំពីវិធានការ និងវិធីសាស្ត្រសុខាភិបាលសម្រាប់បម្រើដល់មន្ត្រីនគរបាលជាតិក្រោមឱវាទ។

-ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ពុំបានធ្វើបញ្ជីកំណត់មុខសញ្ញាប្រព្រឹត្តបទល្មើស គ្រឿងញៀនគ្រប់ប្រភេទ និងពុំបានចងក្រងបញ្ជីសម្រាប់គ្រប់គ្រងគោលដៅប្រឈមងាយរងគ្រោះ។

-ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបងពុំបានប្រមូល និងគ្រប់គ្រងទិន្នន័យជនបរទេស ដែលជាប់ពន្ធនាគារ និងជនបរទេសដែលជួបគ្រោះថ្នាក់ផ្សេងៗក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

-ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង បាត់ដំបង ត្បូងឃ្មុំ កោះកុង និងខេត្តសៀមរាប ពុំទាន់បានធ្វើបច្ចុប្បន្នភាពទិន្នន័យព័ត៌មានរបស់អាជីវកម្ម សេវាកម្ម និងផលិតកម្ម ដើម្បីបម្រើការងារជំនាញស្រាវជ្រាវស៊ើបអង្កេត និងគ្រប់គ្រង។

-អធិការដ្ឋាននគរបាលក្រុងបានលុង ស្រុកអូរជុំ ស្រុកអណ្តូងមាស ស្រុកអូរយ៉ាដាវ ស្រុកតាវែង ស្រុកវើនសៃ និងស្រុកលំផាត់ក្នុងខេត្តរតនគិរីនៅមានភាពខ្វះចន្លោះ ក្នុងការត្រួតពិនិត្យ សំណុំរឿងបទល្មើស ដូចជាពុំបានធ្វើសាវតាជាតិ ពុំមានស្នាមម្រាមដៃរបស់ជនសង្ស័យ និងហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌។

-អធិការដ្ឋាននគរបាលស្រុកសង្កែក្នុងខេត្តបាត់ដំបងពុំទាន់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀនក្នុងភូមិសាស្ត្រស្រុករបស់ខ្លួន។

-អធិការដ្ឋាននគរបាលក្រុង ស្រុក សរុបចំនួន១៨ ក្នុងខេត្តចំនួន៤ គឺខេត្តបន្ទាយមានជ័យ បាត់ដំបង រតនគិរី និងខេត្តកោះកុងពុំទាន់បានកត់ត្រាស្ថិតិអាជីវកម្ម សិប្បកម្ម គ្រឿងផ្ទុះ ជាតិងាយឆេះ ជាតិពុល អាស៊ីដខ្លាំង និងមុខរបរ ដែលងាយប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាពប្រជាពលរដ្ឋ។

-អធិការដ្ឋាននគរបាលក្រុង ស្រុក សរុបចំនួន៣០ ក្នុងខេត្តចំនួន៧ គឺខេត្តបន្ទាយមានជ័យ បាត់ដំបង រតនគិរី ព្រៃវែង ត្បូងឃ្មុំ និងខេត្តកំពង់ស្ពឺ ពុំទាន់មានកម្លាំងមន្ត្រីនគរបាលគ្រប់គ្រាន់ និងមាន

ការខ្វះខាតសម្ភារការិយាល័យ បរិក្ខារបច្ចេកទេស គ្រឿងសង្ហារិម និងមធ្យោបាយធ្វើដំណើរសម្រាប់ទ្រទ្រង់ដល់ការងារស្នូលរបស់អង្គភាព ដើម្បីឆ្លើយតបទៅនឹងទំហំការងារជាក់ស្តែង។

-អធិការដ្ឋាននគរបាលស្រុកវើនសៃ ស្រុកអណ្តូងមាស ស្រុកកូនមុំ និងស្រុកអូរយ៉ាដាវ ក្នុងខេត្តរតនគិរី បានកត់ត្រាស្នួននូវលេខសំណុំរឿងព្រហ្មទណ្ឌមួយចំនួន និងពុំបានធ្វើសៀវភៅចុះលេខសំណុំរឿងបទល្មើសគ្រឿងញៀន។ ចំណែកអធិការដ្ឋាននគរបាលស្រុកអណ្តូងមាស និងស្រុកអូរជុំក្នុងខេត្តរតនគិរី ពុំទាន់មានវិធានការចំពោះជនល្មើសច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដែលពុំទាន់បានបង់ប្រាក់ពិន័យ ក្រោយពីទទួលបានបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍។

-ក្រសួង មន្ទីរ អង្គភាពសរុបចំនួន៧៥ ពុំទាន់បានចុះបញ្ជីដីរដ្ឋនៅឡើយ។

## ខ. ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ

-ការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលស្រុកលំផាត់ខេត្តរតនគិរីពុំទាន់បានរៀបចំទីតាំង និងបំពាក់សម្ភារឱ្យបានត្រឹមត្រូវដូចជា ពុំមានបន្ទប់ទឹក ពុំមានបិទផ្លាកឈ្មោះទីកន្លែង និងផ្លាកឈ្មោះមុខតំណែងនានា ពុំមានរៀបចំឱ្យមានក្តារព័ត៌មាន និងពុំមានបិទតារាងតម្លៃសេវារដ្ឋបាលនៅឡើយ។

-មន្ទីរ អង្គភាព សរុបចំនួន១៦ និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុកសរុបចំនួន ១២ នៅក្នុងខេត្តចំនួន៦ គឺខេត្តរតនគិរី ព្រៃវែង ត្បូងឃ្មុំ កោះកុង ក្រចេះ និងខេត្តកណ្តាល បានផ្តល់សេវាផ្ទេរកម្មសិទ្ធិកាន់កាប់អចលនទ្រព្យចុះបញ្ជី និងមិនទាន់ចុះបញ្ជីដោយពុំមានឯកសារភ្ជាប់គ្រប់គ្រាន់ ដូចជា៖ (១) ចុះហត្ថលេខា ឬផ្តិតដោយគូភាគី និងសាក្សីជាមនុស្សតែម្នាក់ (២) ពុំមានស្នាមមេដៃ ពីអ្នកផ្ទេរសិទ្ធិ អ្នកទទួលសិទ្ធិ (៣) ពុំមានឯកសារយថាភូតបញ្ជាក់ពីកិរិយាកាន់កាប់ដីរបស់អ្នកលក់ (៤)ពុំមានឯកសារបង់ពន្ធប្រថាប់ត្រាពីសាខាពន្ធដារខេត្ត (៥) សលាកបត្រវាស់វែងមួយចំនួនពុំមានចុះកាលបរិច្ឆេទ និងពុំមានហត្ថលេខាប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក និងពុំមានស្នាមមេដៃអ្នកជាប់ព្រំនៅលើកំណត់ស្តីពីការចុះពិនិត្យវាស់វែង និងបានចុះកាលបរិច្ឆេទនៅលើសេចក្តីជូនដំណឹងស្តីពីការចុះវាស់វែងមុនកាលបរិច្ឆេទនៃពាក្យស្នើសុំ។

-ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និងស្រុកកំរៀង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ពុំបានរក្សាទុកសំណុំឯកសារផ្ទេរកម្មសិទ្ធិកាន់កាប់អចលនទ្រព្យឱ្យបានល្អនៅអង្គភាពសាមី។

-រដ្ឋបាលស្រុកបូទុមសាគរក្នុងខេត្តកោះកុង ពុំបានរៀបចំទម្រង់លិខិតផ្ទេរសិទ្ធកាន់កាប់អចលនទ្រព្យ មិនទាន់ចុះបញ្ជីឱ្យមានទម្រង់ឯកភាពតែមួយ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងប្រើប្រាស់។

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបាត់ដំបង និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងបាត់ដំបង ស្រុកឯកភ្នំ ស្រុករុក្ខគិរី ស្រុកមោងឫស្សី ស្រុកថ្មគោល ស្រុកបាណន់ ស្រុកបវេល ស្រុកសំពៅលូន ស្រុកភ្នំព្រឹក ស្រុកកំរៀង ស្រុករតនមណ្ឌល និងស្រុកសំឡូតក្នុងខេត្តបាត់ដំបងមានភាពយឺតយ៉ាវ ក្នុងការពិនិត្យផ្ទៀងផ្ទាត់សំណុំបែបបទ ស្នើសុំចុះបញ្ជីដី និងផ្ទេរកម្មសិទ្ធិ។

-ក្រសួងព័ត៌មាន និងមន្ទីរ អង្គភាព សរុបចំនួន១៧ ក្នុងខេត្តចំនួន៤ គឺខេត្តបន្ទាយមានជ័យ រតនគិរី កោះកុង និងខេត្តក្រចេះ មានភាពយឺតយ៉ាវផ្តល់សេវាសាធារណៈតាមកាលកំណត់។

-មន្ទីរ អង្គភាព សរុបចំនួន២៤ ក្នុងខេត្តសរុបចំនួន៦ គឺខេត្តរតនគិរី បាត់ដំបង ព្រៃវែង ត្បូងឃ្មុំ កំពង់ធំ និងខេត្តបន្ទាយមានជ័យ បានប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងបង្កាន់ដៃពិន័យអន្តរការណ៍ពុំបានត្រឹមត្រូវដូចជាៈ ពុំបានហែកបង្កាន់ដៃពិន័យអន្តរការណ៍ពណ៌ស សម្រាប់ភ្ជាប់សំណុំរឿង ពណ៌ផ្ទៃមេឃប្រគល់ជូនអតិថិជន សរសេរលុបលេខបង្កាន់ដៃ ពុំបានចុះហត្ថលេខាទទួលប្រាក់ បំពេញអត្ថន័យចំណូលមិនច្បាស់លាស់ ពុំបានរក្សាទុកបង្កាន់ដៃបង់ប្រាក់ផ្ទៃពណ៌សក្នុងសំណុំរឿង ពុំបានហែកបង្កាន់ដៃបង់ប្រាក់នៅផ្នែកខាងចុងជូនជនល្មើស ប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងបង្កាន់ដៃពិន័យអន្តរការណ៍បន្តពីឆ្នាំចាស់ក្នុងក្បាលតែមួយ។

-អធិការដ្ឋាននគរបាលក្រុង ស្រុកសរុបចំនួន១៦ ក្នុងខេត្តចំនួន៣ គឺខេត្តបាត់ដំបង ព្រៃវែង ត្បូងឃ្មុំ មានភាពយឺតយ៉ាវក្នុងការផ្តល់សៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋ។

-អធិការដ្ឋាននគរបាលក្រុង ស្រុកសរុបចំនួន៦ ក្នុងខេត្តចំនួន២ គឺខេត្តរតនគិរី និងខេត្តបាត់ដំបង បានចេញសៀវភៅគ្រួសារថ្មីដោយពុំមានភ្ជាប់សំបុត្រកំណើតលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ និងផ្តល់ទុតិយតាសៀវភៅគ្រួសារពុំមានភ្ជាប់ពាក្យបណ្តឹងពីប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ។

-អគាររដ្ឋបាលរបស់អធិការដ្ឋានស្រុកពាមជរខេត្តព្រៃវែង សាងសង់អំពីឈើចាស់ មានសភាពទ្រុឌទ្រោម ធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព និងគុណភាពក្នុងការអនុវត្ត តួនាទី ភារកិច្ចស្នូលផ្តល់សេវា រដ្ឋបាលជូនប្រជាពលរដ្ឋ និងអាចបណ្តាលឱ្យមានគ្រោះថ្នាក់ជាយថាហេតុ។

-រដ្ឋបាលក្រុង ស្រុកសរុបចំនួន២០ ក្នុងខេត្តចំនួន២ គឺខេត្តតាកែវ និងខេត្តបាត់ដំបង ពុំទាន់បានចុះស្រង់ទិន្នន័យអាជីវកម្ម សិប្បកម្ម សេវាកម្ម និងទិន្នន័យពាក់ព័ន្ធ ដើម្បីចងក្រងបញ្ជីសេវារដ្ឋបាល និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវារដ្ឋបាលគ្រប់វិស័យជារៀងរាល់ឆ្នាំ ។

-រដ្ឋបាលស្រុកព្រះស្តេច ក្នុងខេត្តព្រៃវែង បានចុះហត្ថលេខា លើកិច្ចសន្យា លក់ផ្តាច់ដី ដែលមានវិញ្ញាបនបត្រ សំគាល់ម្ចាស់អចលនវត្ថុ ដោយពុំបានប្រើប្រាស់យន្តការអង្គភាពច្រកចេញចូលតែមួយ និងពុំបានបង់ពន្ធប្រថាប់ត្រា។

-ឯកសារស្នើសុំសេវាសុរិយោដី និងភូមិសាស្ត្ររបស់អ្នកស្នើសុំមួយចំនួនបានចូលតាមរយៈអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្តរតនគិរី ប៉ុន្តែលទ្ធផលសម្រេចជាផ្លូវការរបស់អ្នកស្នើសុំ ពុំបានចេញតាមរយៈអង្គភាពច្រកចេញចូលតែមួយ។

-ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលស្រុកបកែវខេត្តរតនគិរី និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ពុំបានទុកដាក់ និងថែរក្សាសំណុំឯកសារសេវារដ្ឋបាលតាមផ្នែកនីមួយៗឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។

-ការិយាល័យបណ្ណបើកបរយានយន្តនៃនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ពុំទាន់បានធ្វើផ្ទាំងព័ត៌មានស្តីពីចរន្តការងារនៅទីតាំងផ្តល់សេវាសាធារណៈ ដើម្បីបង្កភាពងាយស្រួលដល់អតិថិជន។

-កាលបរិច្ឆេទនៃលិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ និងទំនិញមួយចំនួនរបស់នាយកដ្ឋានដឹកជញ្ជូនសាធារណៈក្រុង បានចេញមុនកាលបរិច្ឆេទនៃការស្នើសុំ។

-អគ្គិសនីសៀមរាបបានផ្តល់សេវាបន្តចរន្តអគ្គិសនីចាប់ពី 3phx63A ដល់ 3phx100A ជូនអតិថិជនដោយពុំភ្ជាប់ពីបណ្តាញសាធារណៈ។

-ការផ្តល់សេវាបន្តចរន្តអគ្គិសនីជូនអតិថិជនធុនធំ-មធ្យម នៅតាមបណ្តាអគ្គិសនីខេត្ត ពុំទាន់អនុវត្តតាមកម្មវិធីប្រតិបត្តិសេវាបន្តចរន្តស្តង់ដាររួម។

-ខណ្ឌត្រួតពិនិត្យអង្គភាពបណ្តាញនៃនាយកដ្ឋានអាជីវកម្មចែកចាយ ផ្នែកត្រួតពិនិត្យ នៃអគ្គិសនីព្រៃវែង និងអគ្គិសនីរតនគិរី មានភាពយឺតយ៉ាវ ក្នុងការចុះត្រួតពិនិត្យនាឡិកាស្ទង់ដំណើរការខុសប្រក្រតីមួយចំនួន។

-អគ្គិសនីសៀមរាប ពុំទាន់បានកែសម្រួលខ្សែបណ្តាញ LV ឱ្យមានរបៀបរៀបរយ និងសោភ័ណភាព។

-សាខាអគ្គិសនីវត្តភ្នំ និងអគ្គិសនីស្ទឹងត្រែងមានភាពយឺតយ៉ាវ ក្នុងការកសាងឯកសារស្នើសុំរំលឹកថាមពល។

-សាខាអគ្គិសនីអូរបែកក្អម សាខាអគ្គិសនីចាក់អង្រែក្រោម សាខាអគ្គិសនីវត្តភ្នំ អគ្គិសនីកំពង់ស្ពឺ អគ្គិសនីស្វាយរៀង អគ្គិសនីព្រៃវែង អគ្គិសនីកំពត អគ្គិសនីព្រះសីហនុ អគ្គិសនីតាកែវ អគ្គិសនីបន្ទាយមានជ័យ អគ្គិសនីបាត់ដំបង អគ្គិសនីក្រចេះ និងអគ្គិសនីរតនគិរីមានប្រអប់នាឡិកាស្ទង់ដែលបំពាក់តាមបង្គោលភ្លើងមួយចំនួន បែកកញ្ចក់ ចាស់ ស្រអាប់ គ្មានគម្រប និងងោក។

-ឯកសារស្នើសុំបន្តចរន្តអតិថិជនធុនធំនៅអគ្គិសនីស្វាយរៀង ត្រូវបានគ្រប់គ្រង និងថែរក្សាដោយផ្នែកបណ្តាញ-ចែកចាយ។

-អគ្គិសនីព្រះសីហនុ បានធ្វើបញ្ជីប៉ាន់តម្លៃសម្ភារ (Quotation) ជូនអតិថិជនធុនធំ និងមធ្យមមួយចំនួនពុំទាន់បានត្រឹមត្រូវតាមសេចក្តីណែនាំលេខ៦៦៩ នអជចច ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥។

-កំពង់ផែស្វយ័តភ្នំពេញ កំពង់ផែស្វយ័តក្រុងព្រះសីហនុ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកណ្តាល មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មន្ទីររ៉ែ និងថាមពលក្នុងខេត្តកំពង់ធំ អគ្គិសនី តាមបណ្តាខេត្ត រដ្ឋបាលជលផល ពុំទាន់មានវិធានការតឹងទារបំណុល ដែលអតិថិជនជំពាក់នៅឡើយ។

-រដ្ឋទេយ្យករចំណូលនៃទូរគមនាគមន៍កម្ពុជា និងមន្ទីរ អង្គភាពសរុបចំនួន១៤ ក្នុងខេត្តចំនួន៥ គឺខេត្តបាត់ដំបង បន្ទាយមានជ័យ រតនគិរី កំពង់ធំ និងខេត្តមណ្ឌលគិរីពុំបានធ្វើទិន្នានុប្បវត្តិទូទៅ-សៀវភៅធំ របាយការណ៍សន្និធិបង្កាន់ដៃបង់ប្រាក់ និងមានភាពយឺតយ៉ាវក្នុងការបង់ចំណូល ចូលថវិកាជាតិ។

-មន្ទីរ អង្គភាពសរុបចំនួន៤១ ក្នុងខេត្តចំនួន៤ គឺខេត្តបាត់ដំបង ស្ទឹងត្រែង និងខេត្តកំពង់ធំ ពុំបានបង្វែរត្រង់នូវប្រាក់រង្វាន់លើកទឹកចិត្តចូលគណនីប្រាក់បៀវត្សរបស់មន្ត្រីរាជការ។

-រដ្ឋទេយ្យករចំណូលនៃក្រសួងពាណិជ្ជកម្ម និងមន្ទីរ អង្គភាពសរុបចំនួន៧ ក្នុងខេត្តចំនួន៤ គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ កំពង់ធំ និងខេត្តមណ្ឌលគិរី បានរក្សាទុកសាច់ប្រាក់លើសការកំណត់នៅក្នុងបេឡារបស់ខ្លួន។

-រដ្ឋបាលក្រុង ស្រុកសរុបចំនួន១៣ក្នុងខេត្តបាត់ដំបង ពុំបានចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តលក្ខខណ្ឌនៃលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ។

## គ.ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ

-កំពង់ផែស្វយ័តភ្នំពេញបានបង្កើត គណៈកម្មាធិការលទ្ធកម្ម ដោយពុំមានឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកកំពង់ផែស្វយ័តភ្នំពេញជាប្រធានគណៈកម្មាធិការលទ្ធកម្ម និងបានតែងតាំងប្រធានអង្គភាពលទ្ធកម្មដែលពុំមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ទូរគមនាគមន៍កម្ពុជា ប្រៃសណីយ៍កម្ពុជា និងបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា និងមន្ទីរ អង្គភាព សរុបចំនួន៥៤ ក្នុងខេត្តចំនួន៨ គឺខេត្តបាត់ដំបង ឧត្តរមានជ័យ ត្បូងឃ្មុំ កោះកុង ក្រចេះ កំពង់ធំ សៀមរាប និងខេត្តមណ្ឌលគិរី ពុំបានធ្វើតារាងប្រៀបធៀបទីផ្សារនៃសមាសធាតុលទ្ធកម្មដែលជាមូលដ្ឋានសម្រាប់វាយតម្លៃជ្រើសរើសអ្នកផ្គត់ផ្គង់ឬផ្តល់សេវា និងប្រគល់កិច្ចសន្យា។

-មន្ទីរ អង្គភាពសរុបចំនួន១១ ក្នុងខេត្តកោះកុង បានសម្រេចប្រគល់កិច្ចសន្យាសំណង់ជូនក្រុមហ៊ុនដែលពុំមានវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីអ្នកទទួលការសាងសង់ ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងភ្ជាប់បណ្ណប៉ាតង់មិនសមស្របតាមកម្មវត្ថុនៃការដេញថ្លៃ។

-មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ចាម និងខេត្តកំពត បានចំណាយប្រើប្រាស់ប្រេងអន្តរាគមន៍ដោយពុំមានកំណត់ហេតុត្រួតពិនិត្យវាយតម្លៃស្តីពីផលប៉ះពាល់ ពុំមានស្នាមមេដៃស្នើសុំពីប្រជាពលរដ្ឋ និងពុំមានការបញ្ជាក់របស់អាជ្ញាធរមូលដ្ឋាន។

-មន្ទីរ អង្គភាពសរុបចំនួន៦៦ ក្នុងខេត្តចំនួន១០ គឺខេត្តស្ទឹងត្រែង រតនគីរី ព្រះវិហារ ព្រៃវែង តាកែវ បាត់ដំបង ឧត្តរមានជ័យ កោះកុង ក្រចេះ និងខេត្តកំពង់ស្ពឺ ពុំបានតែងតាំងគណៈកម្មការតាមដានការអនុវត្តគម្រោងកិច្ចលទ្ធកម្ម សំណង់។

-រដ្ឋបាលខេត្តតាកែវ រដ្ឋបាលខេត្តបាត់ដំបង និងមន្ទីរសុខាភិបាលខេត្តបាត់ដំបងពុំមានវិស្វករឬអ្នកបច្ចេកទេសសម្រាប់តាមដាន និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសសំណង់។

-រដ្ឋបាលខេត្តតាកែវបានអនុវត្តកិច្ចលទ្ធកម្មចំនួន៨គម្រោង ខុសវិធីសាស្ត្រដែលមានចែងក្នុងផែនការលទ្ធកម្មកែតម្រូវប្រចាំឆ្នាំ។

-និយ័តករទូរគមនាគន៍ ប្រៃសណីយ៍កម្ពុជា និងទូរគមនាគមន៍កម្ពុជា និងមន្ទីរ អង្គភាពសរុបចំនួន១៤១ ក្នុងខេត្តចំនួន១៦ គឺខេត្តកណ្តាល កែប តាកែវ បន្ទាយមានជ័យ បាត់ដំបង ស្ទឹងត្រែង រតនគិរី ព្រៃវែង ត្បូងឃ្មុំ កោះកុង ក្រចេះ កំពង់ស្ពឺ កំពង់ធំ សៀមរាប ស្វាយរៀង និងខេត្តមណ្ឌលគិរី មានភាពយឺតយ៉ាវក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈដែលអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-មន្ទីរ អង្គភាពសរុបចំនួន១២៩ ក្នុងខេត្តចំនួន៩ គឺខេត្តបន្ទាយមានជ័យ បាត់ដំបង ស្ទឹងត្រែង រតនគិរី ព្រៃវែង ត្បូងឃ្មុំ កំពង់ស្ពឺ មណ្ឌលគិរី និងខេត្តកំពង់ធំ ពុំទាន់បានធ្វើបច្ចុប្បន្នភាពក្រមសីលធម៌លទ្ធកម្មរបស់អ្នកដេញថ្លៃ និងក្រមសីលធម៌គណៈកម្មាធិការលទ្ធកម្ម ឬក្រុមលទ្ធកម្ម។

-មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ មន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ មន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ សាលាដំបូងខេត្តរតនគិរី រដ្ឋបាលស្រុកលំផាត់ខេត្តរតនគិរីបានប្រកាសក្រមសីលធម៌នៅពេលបើកសំណើឯកសារដេញថ្លៃ។

-រដ្ឋបាលស្រុកគងពិសី និងរដ្ឋបាលស្រុកភ្នំស្រួចពុំបានធ្វើសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មនៅពេលចូលរួមវាយតម្លៃសំណើដេញថ្លៃ។

-បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា និងមន្ទីរ អង្គភាពសរុបចំនួន៥១ ក្នុងខេត្តចំនួន៥ គឺខេត្តតាកែវ បាត់ដំបង ឧត្តរមានជ័យ កំពង់ធំ និងខេត្តមណ្ឌលគិរី មានភាពយឺតយ៉ាវក្នុងការធ្វើសំណើសុំគោលការណ៍ជានាចំណាយសម្រាប់កិច្ចលទ្ធកម្មសាធារណៈឆ្នាំ២០២១។

-ប្រៃសណីយ៍កម្ពុជា និងទូរគមនាគមន៍កម្ពុជាបានទូទាត់ជូនក្រុមហ៊ុនផ្គត់ផ្គង់ ឬអ្នកទទួលម៉ៅការដែលពុំទាន់បានបង់ពន្ធប្រថាប់ត្រា។

-ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងមន្ទីរ អង្គភាពសរុបចំនួន៤៦ ពុំបានចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ ជានាការដេញថ្លៃជូន ក្រុមហ៊ុនដែលបានចូលរួមដេញថ្លៃ។

-អង្គភាពលទ្ធកម្មនៃក្រសួងធនធានទឹក និងឧតុនិយមពុំបានចាត់មន្ត្រីឱ្យប្រចាំការរាល់ម៉ោងធ្វើការដើម្បីលក់ឯកសារដេញថ្លៃ។

-មន្ទីរ អង្គភាពសរុបចំនួន៣៥ ក្នុងខេត្តចំនួន៤ គឺខេត្តកោះកុង សៀមរាប ស្វាយរៀង និងខេត្តមណ្ឌលគិរី បានរៀបចំឯកសារដេញថ្លៃដោយពុំមានភ្ជាប់ប៉ាន់គំរូ កាតាឡុក។

-មន្ទីរពាណិជ្ជកម្ម រដ្ឋបាលស្រុកសំរោង រដ្ឋបាលស្រុកទ្រាំង រដ្ឋបាលស្រុកកោះអណ្តែត និងរដ្ឋបាលស្រុកអង្គរបូរីក្នុងខេត្តតាកែវបានវាយតម្លៃប្រគល់ កិច្ចសន្យាជូនក្រុមហ៊ុនដេញ ថ្លៃដោយក្រុមហ៊ុនពុំមាន ភ្ជាប់ឯកសារភស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាព ហិរញ្ញវត្ថុ បច្ចេកទេស បទពិសោធន៍។

-អគ្គិសនីកម្ពុជា បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា និងមន្ទីរ អង្គភាពសរុបចំនួន៣៦ បានចេញសេចក្តីជូនដំណឹង ស្តីពីការសម្រេចប្រគល់កិច្ចសន្យា ទៅឱ្យអ្នកដេញថ្លៃឈ្នះ ដោយពុំបានចម្លងទៅគ្រប់អ្នកដេញថ្លៃចាញ់ និងពុំបានទុក រយៈពេល១០ថ្ងៃ ដើម្បីឱ្យក្រុមហ៊ុនដេញថ្លៃចាញ់ប្តឹងជំទាស់តវ៉ាទៅនឹងលទ្ធផលនៃការដេញថ្លៃ។

-ក្រសួងធនធានទឹក និងឧតុនិយម និងមន្ទីរ អង្គភាព សរុបចំនួន៨ ពុំបានថែរក្សាទុកសំណុំឯកសារកិច្ចលទ្ធកម្មឱ្យបានគត់មត់។

-ក្រសួងពាណិជ្ជកម្ម និងមន្ទីរ អង្គភាព សរុបចំនួន៣១ ក្នុងខេត្តចំនួន៤ គឺខេត្តបន្ទាយមានជ័យ តាកែវ បាត់ដំបង និងខេត្តរតនគិរី ពុំទាន់បានចុះហត្ថលេខាលើពាក្យសុំដេញថ្លៃរបស់អ្នកផ្គត់ផ្គង់។

-អគ្គិសនីត្បូងឃ្មុំ បានប្រើប្រាស់គំរូស្តង់តម្លៃទំនិញមកអនុវត្តកិច្ចលទ្ធកម្មសំណង់។

-មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ធំពុំបានធ្វើសៀវភៅសម្រាប់គ្រប់គ្រងរថយន្ត គ្រឿងចក្រឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។

-រដ្ឋបាលស្រុកបរកែវ និងមន្ទីរផែនការខេត្តរតនគិរី បានប្រគល់-ទទួលទំនិញ សំណង់ ពុំស្របតាមទំហំការងារ លក្ខណៈបច្ចេកទេស និងគំនូសប្លង់សាងសង់ដែលមានចែងក្នុងកិច្ចសន្យា។

-រដ្ឋបាលស្រុកអណ្តូងមាស និងរដ្ឋបាលស្រុកតាវែងនៃរដ្ឋបាលខេត្តរតនគិរី បានវាយតម្លៃបញ្ចប់សុពលភាពជានាគុណភាពសំណង់ជាស្ថាពរ ដោយពុំមានកំណត់ហេតុបញ្ជាក់ពីគណៈកម្មាធិការប្រគល់-ទទួលសំណង់។

-មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តមណ្ឌលគិរី បានចំណាយលើការទិញសម្ភារ មួយចំនួនដែលមានតម្លៃខ្ពស់ ជាងទីផ្សារសម្រាប់ការងារសាងសង់ ថែទាំ ជួសជុល ខួប និងប្រចាំ។

-មន្ទីររ៉ែ និងថាមពលខេត្តរតនគិរីបានផ្លាស់ប្តូរសមាសភាពក្រុមលទ្ធកម្ម ប៉ុន្តែមិនទាន់បានស្នើសុំកែសម្រួល សមាសភាពក្រុមលទ្ធកម្មរបស់ខ្លួន។

-នាយកដ្ឋានគ្រឿងចក្រ និងស្ថាបនាផ្លូវនៅមានភាពយឺតយ៉ាវក្នុងការអនុវត្តការងារថែទាំផ្លូវថ្នល់ជាប្រចាំតាមប្រតិទិនការងារ។

-មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ ក្រចេះ កំពត រតនគីរី កោះកុង និងខេត្តកែប និងមន្ទីរអភិវឌ្ឍន៍ ជនបទខេត្តក្រចេះ ពុំមានគ្រឿងចក្រគ្រប់គ្រាន់សម្រាប់ទទួលអនុវត្តគម្រោងពីក្រសួង។

-នាយកដ្ឋានផ្លូវល្បឿនលឿន ស្ពានធំៗ និងវិនិយោគមានភាពយឺតយ៉ាវក្នុងការត្រួតពិនិត្យវាយតម្លៃលទ្ធផលការងារនៅដំណាក់កាលទី១ និងទី២។

-នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងនាយកដ្ឋានផ្លូវថ្នល់ដែលជាអ្នកត្រួតពិនិត្យគម្រោងនៃក្រសួងសាធារណការ និងដឹកជញ្ជូនពុំទាន់បានធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាព និងគុណភាពការងារសំណង់ជូនអង្គភាពលទ្ធកម្ម។

-មន្ទីរធនធានទឹក និងឧតុនិយមខេត្តក្រចេះ កំពង់ចាម រតនគីរី ស្វាយរៀង និងខេត្តកំពត ពុំបានធ្វើរបាយការណ៍ ចំណូល ចំណាយ សន្និធិប្រេងឥន្ធនៈសម្រាប់កត់ត្រា និងតាមដានការប្រើប្រាស់ ប្រេងអន្តរាគមន៍។

-មន្ទីរ អង្គភាព សរុបចំនួន២១ ក្នុងខេត្តចំនួន៤ គឺខេត្តតាកែវ បាត់ដំបង ស្ទឹងត្រែង និងខេត្តកំពង់ស្ពឺ ពុំទាន់បានចេញវិញ្ញាបនបត្របញ្ចប់ការងារ (ការទទួលយកជាបណ្តោះអាសន្ន) និងវិញ្ញាបនបត្រទទួលខុសត្រូវលើសុពលភាពសំណង់ (ការទទួលយកជាស្ថាពរ)។

-ការងារសាងសង់ ជួសជុល ថែទាំផ្លូវថ្នល់ដែលអនុវត្តដោយមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត មានចំណុចខ្វះខាតមួយចំនួនដូចជា៖ មានស្នាមឆ្នូត ផត ប៉ោង ស្រុត សំបុកមាន់ ឡើងកៅស៊ូ ស្នាមប្រេះស្រកានាគ មានស្មៅដុះនៅមាត់លូ ខូចខាតបង្គោលសុវត្ថិភាពចរាចរណ៍...។ល។

-នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងសំណង់កំពង់ផែបានលើកគម្រោង បញ្ជីឈ្មោះគ្រឿងចក្រសម្រាប់ការអនុវត្តការងារជីកស្តារប្រឡាយផ្លូវនាវាចរណ៍ ទន្លេវ៉ៃគោ ដោយពុំសមស្របទៅនឹងទំហំការងារ។

-មានកម្មករមួយចំនួននៅតាមការដ្ឋានរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ស្ពឺ និងខេត្តកំពត ពុំបានពាក់ឯកសណ្ឋានសុវត្ថិភាពឱ្យបានត្រឹមត្រូវ។

-ទូរគមនាគមន៍កម្ពុជា និងនិយ័តករទូរគមនាគមន៍ និងមន្ទីរ អង្គភាពសរុបចំនួន១០ ពុំបានបញ្ចូលព័ត៌មាន អំពីលេខគណនី ឈ្មោះ និងអាសយដ្ឋានធនាគារ លេខទូរស័ព្ទ និងអ៊ីម៉ែលរបស់អ្នកផ្គត់ផ្គង់ឬអ្នកទទួលការក្នុងកិច្ចសន្យាលទ្ធកម្ម។

-ទូរគមនាគមន៍កម្ពុជា និងនិយ័តករទូរគមនាគមន៍កម្ពុជា បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ខុសវិធីសាស្ត្រលទ្ធកម្មដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានអនុវត្តកិច្ចលទ្ធកម្ម ចំនួន១គម្រោង លើការងារផ្គត់ផ្គង់ទឹកសុទ្ធ ប្រើប្រាស់ ដោយពុំមានក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ។

-ទូរគមនាគមន៍កម្ពុជា អគ្គិសនីកម្ពុជា និងរដ្ឋបាលខេត្តកោះកុង បានអនុវត្តវិធីសាស្ត្រ លទ្ធកម្មដោយឡែក (ចចារថ្លៃ) ដោយពុំស្ថិតនៅក្នុងលក្ខខណ្ឌសមស្របតាមវិធាន បទប្បញ្ញត្តិ និងនីតិវិធីលទ្ធកម្មសាធារណៈ។

-នាយកដ្ឋានវិស្វកម្ម មន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់ ប៉ៃលិន បាត់ដំបង កំពង់ស្ពឺ តាកែវ ឧត្តរមានជ័យ កំពង់ចាម និងខេត្តស្វាយរៀងមានវិក្កយបត្រទូទាត់មួយចំនួនលើការងារស្តារ ជួសជុល ថែទាំប្រព័ន្ធធារាសាស្ត្រ និងសាងសង់សំណង់សិល្បការដោយ ពុំបានបញ្ជាក់យថាប្រភេទ ឈ្មោះម៉ាក ទំហំ និងខ្នាតឱ្យបានច្បាស់លាស់។

-នាយកដ្ឋានធារាសាស្ត្រកសិកម្មនៃក្រសួងធនធានទឹក និងឧតុនិយម បានប្រើប្រាស់កម្លាំងពលកម្មលើសពីទំហំការងារលើការងារឈូសឆាយ ជីកកាយកើបដីស្អុយដាក់ឡាន និងដឹកជញ្ជូនចេញ ក្រោយទ្វារទឹក ស្វ័យប្រវត្តិ និងការងារឈូសឆាយ ជ្រួយជីរូងនាគលើតួទំនប់ ឈូសឆាយ និងកិនបង្ហាប់កន្ទុយសំណង់ ក្រោយទ្វារទឹកស្វ័យប្រវត្តិ ការងារជួសជុលប្រព័ន្ធធារាសាស្ត្របន្ទាន់។

-ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា កំពង់ផែស្វយ័តក្រុងព្រះសីហនុ និងមន្ទីរ អង្គភាព សរុបចំនួន២៣០ ក្នុងខេត្តចំនួន១៨ គឺខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ព្រះវិហារ បន្ទាយមានជ័យ ឧត្តរមានជ័យ ក្រចេះ រតនគីរី កោះកុង បាត់ដំបង តាកែវ ព្រៃវែង ត្បូងឃ្មុំ កំពង់ស្ពឺ សៀមរាប ស្វាយរៀង និងខេត្តមណ្ឌលគិរី មានកិច្ចសន្យាលទ្ធកម្មពុំបានចុះហត្ថលេខាខ្លីលើគ្រប់សន្លឹក នៃកិច្ចសន្យាពីគ្រប់ភាគីពាក់ព័ន្ធ។

-មន្ទីរផែនការខេត្តកោះកុង និងរដ្ឋបាលខេត្តក្រចេះ ចុះកិច្ចសន្យាលទ្ធកម្ម ជាមួយក្រុមហ៊ុនផ្គត់ផ្គង់ទំនិញ ឬអ្នកទទួលការដោយពុំបានបញ្ជាក់ អំពីប្រភពនៃសម្ភារក្នុងតារាងឧបសម្ព័ន្ធភ្ជាប់កិច្ចសន្យាលទ្ធកម្ម។

-នាយកដ្ឋានធារាសាស្ត្រកសិកម្ម មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ទូរគមនាគមន៍កម្ពុជា រដ្ឋបាលក្រុងខេមរភូមិន្ទ និងរដ្ឋបាលក្រុងក្រចេះ បានចាប់ផ្តើមអនុវត្តការងារសាងសង់ ជួសជុល ថែទាំ មុនពេលចុះកិច្ចសន្យាលទ្ធកម្ម។

## ៣.២.ការខារតាមដានការអនុវត្តច្បាប់

-កំពុងដាក់ឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំខេត្តស្តីពីលទ្ធផល នៃការចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល អនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច កិច្ចសន្យាវិនិយោគធ្វើអាជីវកម្មយកភាស៊ី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តពោធិ៍សាត់ ស្ទឹងត្រែង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ។

-កំពុងដាក់ឆ្លងរបាយការណ៍ឆ្លងថ្នាក់ដឹកនាំក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ស្តីពីលទ្ធផលនៃការចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្ត កំពង់ចាម ព្រះវិហារ និងខេត្តមណ្ឌលគិរី។

-កំពុងធ្វើលិខិតជូនដំណឹងទៅក្រសួង-ស្ថាប័ន ដើម្បីឱ្យធ្វើការជំរុញទៅមន្ទីរ-អង្គភាព ម្ចាស់ក្រុមហ៊ុន ម្ចាស់សហគ្រាស និងម្ចាស់សិប្បកម្ម ឱ្យកែលម្អនូវចំណុចខ្វះខាតដែលបានរកឃើញក្នុងការចុះធ្វើការតាមដានត្រួតពិនិត្យច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ កិច្ចសន្យាវិនិយោគធ្វើអាជីវកម្មយកភាស៊ី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តក្រចេះ។

-បានចុះតាមដានការអនុវត្តច្បាប់(មន្ទីររាជធានីខេត្ត)៖ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីព្រៃឈើ ច្បាប់ភូមិបាលនៅខេត្តឧត្តរមានជ័យ ច្បាប់ស្តីពីព្រៃឈើ និងចូលរួមដាំដើមឈើ បោះបង្គោលកាត់ឆ្វៀលដីតំបន់៣នៅខេត្តកំពង់ធំ ច្បាប់លើវិស័យកសិកម្ម ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង ច្បាប់ស្តីពីបរិស្ថាននៅខេត្តស្វាយរៀង ចូលរួមចុះពិនិត្យ និងទប់ស្កាត់ការកាប់រានដីព្រៃខុសច្បាប់ ការប្រើប្រាស់គ្រឿងចក្រខុសច្បាប់ ការនេសាទខុសច្បាប់ ចូលរួមចុះពិនិត្យ និងវាស់វែងឈើជាក់ស្តែងដែលក្រុមការងារបានរឹបអូស ក្នុងរបៀងអភិរក្សជីវៈចម្រុះតំបន់ការពារធម្មជាតិ ស្ថិតនៅឃុំដាឡាត់ ស្រុកសេសាន និងចូលរួមជាមួយក្រុមការងារថ្នាក់ខេត្តដោះស្រាយវិវាទដីធ្លីទំហំ ៣៣៨.១៩ហិកតារបស់លោក កែ សួនសុភានៅខេត្តស្ទឹងត្រែង ច្បាប់ស្តីពីជលផលនៅខេត្តកំពត ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងការគ្រប់គ្រងថវិការបស់គ្រឹះស្ថានសិក្សារដ្ឋ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធនៅខេត្តតាកែវ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពនៅខេត្តកំពង់ចាម ការគ្រប់គ្រង និងការប្រមូលចំណូលភាស៊ីនៅតាមបណ្តាផ្សាររដ្ឋចំនួន២៥នៅរាជធានីភ្នំពេញ ការគ្រប់គ្រងរដ្ឋបាល-ហិរញ្ញវត្ថុរបស់គណៈគ្រប់គ្រងសាលាតាមបណ្តាសាលារៀនរដ្ឋចំនួន៤៩នៅខេត្តកំពង់ស្ពឺ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ច្បាប់ស្តីពីផ្លូវថ្នល់ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ អនុក្រឹត្យ លេខ ១៩៧ អនក្រ.បកស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិផ្លូវរថភ្លើង និងការកំណត់ដែនព្រៃលិចទឹកតំបន់៣ ការគ្រប់គ្រងរដ្ឋបាល-ថវិការដ្ឋ និងថវិកាផ្សេងៗតាមវិទ្យាល័យចំនួន១៦ ចូលរួមជាមួយប្រតិភូអន្តរក្រសួងពិនិត្យទីតាំងដីស្នើសុំកែសម្រួលព្រំប្រទល់តំបន់២ និងតំបន់៣ នៃបឹងទន្លេសាប ក្នុងភូមិសាស្ត្រស្រុកកំពង់លែង និងចូលរួមសហការជាមួយប្រតិភូក្រសួងបរិស្ថានចុះពិនិត្យជាក់ស្តែងលើករណីសំណើចូលរួមសហការលើកិច្ចការពារ និងអភិរក្សតំបន់ប្រើប្រាស់ច្រើនយ៉ាង (ភ្នំនាងកង្រី-ភ្នំទូកមាស) លើផ្ទៃដីទំហំប្រមាណ១,២៧២ហិកតាក្នុងភូមិសាស្ត្រឃុំពោធិ៍ និងឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។

*__លទ្ធផល__ស្តីពីការចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ អនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់ ប្រកាសលេខ០៨៧ ដនស.ប្រក/នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី កិច្ចសន្យាវិនិយោគធ្វើអាជីវកម្មចំនួន១១ខេត្ត៖

**១.ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ** នៅខេត្តកំពង់ឆ្នាំង ក្រចេះ កំពង់ស្ពឺ តាកែវ ព្រះវិហារ និងខេត្តកំពង់ចាម បានធ្វើការជាមួយមុខសញ្ញាសរុបចំនួន១០១៖

-ក្រុមហ៊ុន សហគ្រាស និងសិប្បកម្មធនធានរ៉ែ ចំនួន២៤ ស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង ក្រចេះ កំពង់ស្ពឺ តាកែវ កំពង់ចាម និងខេត្តឧត្តរមានជ័យ បានប្រើប្រាស់អាជ្ញាបណ្ណប្រកបអាជីវកម្មដែលផុតសុពលភាពរួមមាន៖ (១) ក្រុមហ៊ុន ហ្គោលដិនអេវើរីសអិុនជើណេសិនណលខូអិលធីឌី (២) ក្រុមហ៊ុនខេជីអេចអុីមផតអិចផត (៣) ក្រុមហ៊ុនសេងវណ្ណា អេនជីនារីងអេនខនស្ត្រាក់សិន (៤) ក្រុមហ៊ុនកៅសៀងអុិនវេសម៉ិនឯ.ក (៥) ក្រុមហ៊ុនអាយអេសខ្មែរ (៦) ក្រុមហ៊ុនខ្មែរ អេហ្គ្រីខូលប្រដាក់ឯ.ក (៧) ក្រុមហ៊ុនថៃវ៉ាន់ខាំហ្វាក្រាស៊្រីងអុិនធើណេស្សណល (៨) ក្រុមហ៊ុនសាជីវកម្មអន្តជាតិ ហិចសុន(កម្ពុជា) (៩) ក្រុមហ៊ុនហុងហ្វុងអិុនដាសស្ទ្រីឌបភើរេសិនអិលធីឌី (១០) ក្រុមហ៊ុនអុីស្តអូសិនម៉ាញនីង ខបភើរេសិន(ខេមបូឌា)ឯ.ក (១១) ក្រុមហ៊ុនវ៉ូឡុងសេងដាអុិនធើណេសិនណលអុិនវេសម៉ិនហូលឌីងគ្រុប (១២) ក្រុមហ៊ុនយន់ឃានមីនើរ៉ល(ខេមបូឌា) (១៣) ក្រុមហ៊ុនហានសេងខូលម៉ាញ (១៤) សហគ្រាសតាំងឆេងហ៊ាង (១៥) សហគ្រាសស្រ៊ុនតាយយាង (១៦) សហគ្រាសសុខសុខា (១៧) សហគ្រាសអានវេងស្រ៊ុន (១៨)សហគ្រាស វ៉ង់ស្រីនាថ (១៩) សហគ្រាសឌីនវ៉ាន់នឿន (២០) សហគ្រាសតៃហុងឆាយ (២១)សហគ្រាសហ៊ាងវិបុល (២២) សហគ្រាសហ៊ានចាន់ថា (២៣) សិប្បកម្មរឿងរិទ្ធី និង (២៤) សិប្បកម្មឈួរហាំងហួត។

-ក្រុមហ៊ុនសហគ្រាស និងសិប្បកម្មធនធានរ៉ែចំនួន១៥ ស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង ស្ទឹងត្រែង ពោធិ៍សាត់ និងខេត្តឧត្តរមានជ័យ បានដឹកជញ្ជូនផលិតផលធនធានរ៉ែ ដោយមិនបានគ្របតង់កៅស៊ូឱ្យបានជិត ហើយចងឱ្យបានជាប់គត់មត់ និងមិនទាន់បានស្រោចទឹកលើផ្លូវ ដែលបានប្រើប្រាស់ក្នុងការដឹកជញ្ជូនផលិតផលធនធានរ៉ែចេញពីការដ្ឋានរបស់ខ្លួនឱ្យបានជាប្រចាំនៅឡើយរួមមាន៖ (១) ក្រុមហ៊ុនជីឡូខនស្ត្រាក់សិន (២) ក្រុមហ៊ុនអុិតធីអី&ស៊ី ខូអិលធីឌី (៣) ក្រុមហ៊ុនដែងកិរម្យអុិមផតអិចផត (៤) ក្រុមហ៊ុនស៊ីវីអេនអេចខនស្ត្រាក់សិនឯ.ក (៥) ក្រុមហ៊ុន ហេងធាតខនស្ត្រាក់សិន (៦) ក្រុមហ៊ុន លឿតវឌ្ឍនៈ ខនស្ត្រាក់សិន (៧) សហគ្រាស ឡុច ចាន់ណារិទ្ធិ (៨) សហគ្រាស គីតុងប្រា (៩) សហគ្រាសគីមហេង (១០) សិប្បកម្មសំរិទ្ធប៊ុនធឿន (១១) សិប្បកម្មបូចនី (១២) សិប្បកម្មខាត់ថៃ (១៣) សិប្បកម្មភាវផាន់ណារ៉ុង (១៦) សហគ្រាស ជ័យសាម៉ាក់ (១៤) សិប្បកម្មស៊ិនកក្កដា និង (១៥) សិប្បកម្មបូចនី។

-ក្រុមហ៊ុន សហគ្រាស និងសិប្បកម្មធនធានរ៉ែចំនួន១៩ ស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង ស្ទឹងត្រែង តាកែវ និងខេត្តព្រះវិហារ ពុំទាន់បានរៀបចំកំណត់ត្រាលក់ប្រចាំថ្ងៃក្នុងបញ្ជីការ ឬសៀវភៅលក់នៅឡើយរួមមាន ៖ (១) ក្រុមហ៊ុនជីឡូ ខនស្ត្រាក់សិន (២) ក្រុមហ៊ុនអុិតធីអី&ស៊ីខូអិលធីឌី (៣) ក្រុមហ៊ុនជឺដាំងស៊ិនជូជីស៊ីមីងឡេគ័ងយីឯ.ក (៤) ក្រុមហ៊ុនយសសុវណ្ណសុគន្ធារស (៥) ក្រុមហ៊ុនហ៊ឹមសាវី (៦) ក្រុមហ៊ុនអុឹងយៀបឡាយ (៧) ក្រុមហ៊ុនកិនថ្មង៉ែតយាងពហុពាណិជ្ជ (៨) ក្រុមហ៊ុនប្រាឌើរអុីធើណេសិនណលគ្រុប (៩) ក្រុមហ៊ុនអុីនហ្សុងធាងឡូជីស្ទីកឯ.ក (១០) ក្រុមហ៊ុនសិលាអុិនដាសស្ទ្រី (១១) សហគ្រាសគង់ចាន់ចម្លាក់មរតកខ្មែរ (១២) សហគ្រាសពុំម៉ៅចម្លាក់កូនខ្មែរ (១៣) សហគ្រាសសេងវណ្ណាអេនជីនារីងអេនខនស្ត្រាក់សិន (១៤) សិប្បកម្មឡឹកសុកាន់ (១៥) សិប្បកម្មរុណចន្ទតារា

(១៦) សិប្បកម្មយៀបសុវណ្ណារ៉ា (១៧) សិប្បកម្មសំរិទ្ធប៊ុនធឿន (១៨) សិប្បកម្មម៉ៅសារឿន និង (១៩) សិប្បកម្មករិម្យសុវណ្ណតារា។

-មន្ទីររ៉ែ និងថាមពលខេត្តកំពង់ឆ្នាំង និងមន្ទីររ៉ែ និងថាមពលខេត្តឧត្តរមានជ័យ មានភាពខ្វះចន្លោះក្នុងការចងក្រង និងគ្រប់គ្រងទិន្នន័យពាក់ព័ន្ធក្នុងការធ្វើអាជីវកម្មធនធានរ៉ែក្នុងខេត្តរបស់ខ្លួន។

-ក្រុមហ៊ុន សហគ្រាស និងសិប្បកម្មធនធានរ៉ែចំនួន១១ ស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តព្រះវិហារ ពុំបានប្រើប្រាស់វិក្កយបត្រលក់ឆ្នាំ២០២២ ដែលមានការបោះត្រាទទួលស្គាល់ដោយមន្ទីររ៉ែ និងថាមពលខេត្ត ដែលខ្លួនកំពុងប្រកបអាជីវកម្មរួមមាន៖ (១) ក្រុមហ៊ុនអ៊ុតជីអឺ&ស៊ីខូអិលធីឌី (២) ក្រុមហ៊ុនអ៊ីនហ្សុងឆាងឡូជីស្ទីកឯ.ក (៣) ក្រុមហ៊ុនសិលាអ៊ិនដាសស្រ្ទី (៤) ក្រុមហ៊ុនសឺនហ័រអ៊ីមផត អិចផតខូអិលធីឌី (៥) ក្រុមហ៊ុនថៃវ៉ាន់ខាំហ្វាក្រាស៊្វីងអ៊ិនធើណេស្យូណល (៦) ក្រុមហ៊ុនជីបម៉ុងអ៊ិនដាស្ទ្រីស(ស៊ី អឹម អាយ)ឯ.ក (៧) ក្រុមហ៊ុនខេមបូឌាវើលដ៍ កាយហាស៊ូកូយូខនស្រ្តាក់សិន (៨) សហគ្រាសគង់ចាន់ចម្លាក់មរតកខ្មែរ (៩) សហគ្រាសពុំម៉ៅចម្លាក់កូនខ្មែរ (១០) សិប្បកម្មឡឹកសុកាន់ និង (១១) សិប្បកម្មយៀបសុវណ្ណារ៉ា។

-ក្រុមហ៊ុនយសសុវណ្ណសុគន្ធារស ស្ថិតនៅក្នុងខេត្តតាកែវ ចេញវិក្កយបត្រលក់មានភាពមិនត្រឹមត្រូវ ដោយមិនបានចុះបរិមាណ ចុះកាលបរិច្ឆេទ ចេញវិក្កយបត្រមិនបានតាមលេខរៀង និងប្រើប្រាស់វិក្កយបត្រច្រើនក្បាលក្នុងពេលតែមួយ។

-ក្រុមហ៊ុន និងសហគ្រាសធនធានរ៉ែចំនួន២ ស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង ពុំបានរៀបចំសេចក្តីប្រកាសផលិតកម្មប្រចាំខែជូនមន្ទីររ៉ែ និងថាមពលខេត្តនៅឡើយរួមមាន៖ (១) ក្រុមហ៊ុនអ៊ុតជីអឺ & ស៊ីខូអិលធីឌី និង (២) សហគ្រាសគី តុងប្រា។

-ក្រុមហ៊ុន និងសហគ្រាសចំនួន៧ ស្ថិតនៅក្នុងខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ ពុំបានធ្វើរបាយការណ៍ស្តីពីបរិមាណរ៉ែ ដែលបានជីកយកជូនក្រសួងរ៉ែ និងថាមពលនៅឡើយរួមមាន៖ (១) ក្រុមហ៊ុនអ៊ីនហ្សុងឆាងឡូជីស្ទីក ឯ.ក (២) ក្រុមហ៊ុនយន់យានមីនើរ៉ល(ខេមបូឌា) (៣) ក្រុមហ៊ុនហេងធាតខនស្រ្តាក់សិន (៤) ក្រុមហ៊ុនសិលាអ៊ិនដាសស្រ្ទី (៥) សហគ្រាសសេងវណ្ណាអេនជីនារីងអេនខនស្រ្តាក់សិន (៦) សហគ្រាសគង់ចាន់ចម្លាក់មរតកខ្មែរ និង (៧) សហគ្រាសពុំម៉ៅ ចម្លាក់កូនខ្មែរ ។

-ក្រុមហ៊ុនចំនួន២ ក្នុងខេត្តព្រះវិហារប្រើប្រាស់វិក្កយបត្រលក់ឆ្នាំ២០២២ ដែលមានការបោះត្រាទទួលស្គាល់ដោយមន្ទីររ៉ែ និងថាមពលខេត្តព្រះវិហារមិនទាន់បានទៀងទាត់នៅឡើយរួមមាន៖ ក្រុមហ៊ុនកិនថ្មង៉េតយាងពហុពាណិជ្ជ និងក្រុមហ៊ុនប្រាឌើរអ៊ីធើណេសិនណលគ្រុប។

-សហគ្រាសដាងភានថ្មកែវ ស្ថិតនៅក្នុងខេត្តពោធិ៍សាត់មិនបានផ្តល់ជូនក្រសួងរ៉ែ និងថាមពលពិនិត្យនូវរបាយការណ៍ស្តីពីការធ្វើអាជីវកម្មថ្មកែវ របាយការណ៍ស្តីពីបរិមាណថ្មកែវដែលជីកយកបាន និងរបាយការណ៍លក់ ឬបានប្រើប្រាស់ក្នុងត្រីមាសនីមួយៗរបស់ខ្លួនឱ្យបានទៀងទាត់នៅឡើយ។

-ក្រុមហ៊ុនចំនួន៣ ស្ថិតនៅក្នុងខេត្តតាកែវ មិនទាន់បានដាក់របាយការណ៍ស្តីពីការធ្វើអាជីវកម្មដីក្រហម(ឡាតេរីត) ដែលជីកបាន និងរបាយការណ៍លក់ក្នុងត្រីមាសនីមួយៗ ជូនក្រសួងរ៉ែ និងថាមពលនៅឡើយរួមមាន៖ (១) ក្រុមហ៊ុនយសសុវណ្ណសុគន្ធារស (២) ក្រុមហ៊ុនហ៊ឹមសារី និង (៣) ក្រុមហ៊ុនអ៊ឹងយៀបឡាយ។

-សហគ្រាសធនធានរ៉ែចំនួន៥ ស្ថិតនៅក្នុងខេត្តក្រចេះ បានខូចខាតពោងកំណត់ដែនអាជ្ញាបណ្ណ ដោយសារទឹកជំនន់ សាឡង់បរកាត់ ឬខូចខាតដោយសារប្រជានេសាទរួមមាន៖ (១) សហគ្រាស គ្រុយម៉េងលីហ៊ាង (២) សហគ្រាសស្រ៊ីហាប់ (៣) សហគ្រាសអិមរី (អេមផាយ) (៤) សហគ្រាសប៊ុន មយូ៉ាអេឃ្វីបមិ៉ន និង (៥) សហគ្រាស វាសនាចិន្តា។

-ក្រុមហ៊ុន សហគ្រាស និងសិប្បកម្មធនធានរ៉ែ ចំនួន១០ ស្ថិតនៅក្នុងខេត្តក្រចេះ និងខេត្ត ពោធិ៍សាត់ មិនទាន់បោះបង្គោលព្រំសម្គាល់កំណត់ដែនអាជ្ញាបណ្ណឱ្យបានពេញលេញ និងគ្រប់ចំនួន នៅឡើយរួមមាន៖ (១) ក្រុមហ៊ុន ស៊ីងយាន់យៃននីងយៀកខូអិលធីឌី (២) ក្រុមហ៊ុនឫទ្ធីក្រានីត (ខេមបូឌា) ខូអិលធីឌី (៣) ក្រុមហ៊ុនស៊ីនឡីដាឌី ម៉ាញនីងខូអិលធីឌី (៤) ក្រុមហ៊ុនហាវភីន (ខេមបូឌា) ខូអិលធីឌី (៥) ក្រុមហ៊ុនស៊ីវីអេនអេចខនស្ត្រាក់សិនឯ.ក (៦) ក្រុមហ៊ុនឌីឌីអិមអិល ខនស្ត្រាក់សិន (៧) សហគ្រាសភាវផាន់ណារ៉ុង (៨) សហគ្រាសជ័យសាម៉ាក់ (៩) សិប្បកម្មហួចចន្ទ តារា និង (១០) សិប្បកម្មងួនសុខបាន។

-ក្រុមហ៊ុន និងសហគ្រាសធនធានរ៉ែចំនួន១១ ស្ថិតនៅក្នុងខេត្តព្រះវិហារ កំពង់ស្ពឺ ស្ទឹងត្រែង និង ខេត្តកំពង់ចាម មានភាពយឺតយ៉ាវក្នុងការបង់សួយសារធនធានរ៉ែ រួមមាន៖ (១) ក្រុមហ៊ុនស៊ីងយាន់យៃន នីងយៀក ខូអិលធីឌី (២) ក្រុមហ៊ុនខេធីអេចអ៊ីមផតអិចផត (៣) ក្រុមហ៊ុនសឺហ័រអ៊ីមផតអិចផត ខូអីលធីឌី (៤) ក្រុមហ៊ុនទ្រី ភាពគ្រុប (៥) ក្រុមហ៊ុនសា៉ន់ធីប៊ីឌីវេឡុបមេន (៦) សហគ្រាសអាន សុគន្ធា (៧) សហគ្រាសពុំម៉ោចម្លាក់កូនខ្មែរ (៨) សហគ្រាសអេសខេវីអែវនរី (៩) សហគ្រាសស្រ៊ីហាប់ (១០) សហគ្រាសប៊ុនមយូ៉ាអែឃ្វីបមិ៉ន និង (១១) សហគ្រាសវាសនាចិន្តា។

-ក្រុមហ៊ុនធនធានរ៉ែ ចំនួន៨ ស្ថិតនៅក្នុងខេត្តស្ទឹងត្រែង ក្រចេះ កំពង់ស្ពឺ និងខេត្តឧត្តរមានជ័យ មិនទាន់បានរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយរួមមាន៖ (១) ក្រុមហ៊ុនលី នវតីឯ.ក (២) ក្រុមហ៊ុន ស៊ីងយាន់យៃននីងយៀកខូអិលធីឌី (៣) ក្រុមហ៊ុនហាវភីង(ខេមបូឌា) ខូអិលធីឌី (៤) ក្រុមហ៊ុនអេសភីខេអិម ស្គួនខនស្ត្រាក់សិនខូអិលធីឌី (៥) ក្រុមហ៊ុនសេងវណ្ណាអេនជី នារីងអេនខនស្ត្រាក់សិន (៦) ក្រុមហ៊ុនខ្មែរអេហ្វ្រីខូល ប្រដាក់ឯ.ក (៧) ក្រុមហ៊ុនស៊ីអេចអេចស៊ី អ៊ិន វេសមិ៉ន ឯ.ក និង (៨) ក្រុមហ៊ុន លឿត វឌ្ឍនៈខនស្ត្រាក់សិន។

-ក្រុមហ៊ុន និងសហគ្រាសធនធានរ៉ែចំនួន៨ ស្ថិតនៅក្នុងខេត្តក្រចេះ កំពង់ស្ពឺ ពោធិ៍សាត់ និង ខេត្តតាកែវ មិនទាន់បានតម្កល់ប្រាក់មូលនិធិស្តារការដ្ឋានរ៉ែឡើងវិញនៅឡើយ រួមមាន៖ (១) ក្រុមហ៊ុន អ៊ិតធីអ៊ី & ស៊ីខូអិលធីឌី (២) ក្រុមហ៊ុនប្លែកដាយមិនស្គួនអេសជេស៊ីខូអិលធីឌី (៣) ក្រុមហ៊ុនហុងហូ ស៊ុយីឯ.ក (៤) ក្រុមហ៊ុនរតនៈស្មោន ខេមបូឌាឌីវេឡុបមេន (៥) ក្រុមហ៊ុនសេងវណ្ណាអេនជីនារីងអេន ខនស្ត្រាក់សិន (៦) ក្រុមហ៊ុនហុងហ្វុងអ៊ិនដាសស្ទ្រី ខបភើរេសិនអិលធីឌី (៧) ក្រុមហ៊ុនវ៉ូឡុងសេងដា អ៊ិនធើណេសិនណលអ៊ិនវេសមិ៉នហូលឌីងគ្រុប និង (៨) សហគ្រាស ដាងភានថ្មកែវ។

-ក្រុមហ៊ុនសេងវណ្ណាអេនជិនារីងអេនខនស្ត្រាក់សិន ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ មិនទាន់បានបង់ ឈ្នួលដី សម្រាប់ឆ្នាំ២០២០ និងឆ្នាំ២០២១នៅឡើយ។

-ក្រុមហ៊ុនឫទ្ធីក្រានីត (ខេមបូឌា) ខូអិលធីឌី ស្ថិតនៅក្នុងខេត្តក្រចេះកំពុងមានទំនាស់ដីធ្លីជាមួយ ប្រជាពលរដ្ឋប្រហែលចំនួន២០គ្រួសារដែលបានចូលមកតាំងទីលំនៅ និងដាំដុះនៅក្នុងផ្ទៃដីអាជ្ញាបណ្ណ របស់ខ្លួន។

-ក្រុមហ៊ុនធនធានរ៉ែចំនួន២ ស្ថិតនៅក្នុងខេត្តក្រចេះ និងខេត្តព្រះវិហារ ពុំទាន់បានបំពាក់ជញ្ជីងនៅទីតាំងអាជីវកម្មនៅឡើយរួមមាន៖ (១) ក្រុមហ៊ុនអ៊ុតធីអ៊ី&ស៊ីខូអិលធីឌី និង (២) ក្រុមហ៊ុនអ៊ីនហ្សុងឆាងឡូជីស្ទីកឯ.ក។

-ក្រុមហ៊ុនធនធានរ៉ែចំនួន២ ស្ថិតនៅក្នុងខេត្តព្រះវិហារ ពុំទាន់បានប្រើប្រាស់ជញ្ជីងឱ្យបានទៀងទាត់នៅឡើយ (ដោយសារជញ្ជីងខូច) រួមមាន៖ (១) ក្រុមហ៊ុនកិនថ្មង៉ែតយាងពហុពាណិជ្ជ និង (២) ក្រុមហ៊ុនប្រាឌើរអ៊ិនធើណេសសិនណលគ្រុប។

-សហគ្រាសធនធានរ៉ែចំនួន៤ ស្ថិតនៅក្នុងខេត្តកំពង់ចាម បានដាក់ទីតាំងនៅជាប់នឹងច្រាំងទន្លេរួមមាន៖ (១) សហគ្រាសហ៊ានវិបុល (២) សហគ្រាសហ៊ានចាន់ថា (៣) សហគ្រាសជោតសុជា និង (៤) សហគ្រាសគ្រុយម៉េងលីហ៊ាង។

-ក្រុមហ៊ុនលីនវតីឯ.ក ក្នុងខេត្តស្ទឹងត្រែងទើបតែរៀបចំហេដ្ឋារចនាសម្ព័ន្ធនៅក្នុងការដ្ឋាន និងបកដីមុខលើ ហើយមានភាពយឺតយ៉ាវក្នុងការអនុវត្តផែនការអាជីវកម្ម ដោយសារការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។

-សិប្បកម្មធនធានរ៉ែចំនួន៤ ស្ថិតនៅក្នុងខេត្តពោធិ៍សាត់ ទទួលបានអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែដែលពុំមានភ្ជាប់សេចក្តីសម្រេចស្តីពីលក្ខខណ្ឌអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែរួមមាន៖ (១) សិប្បកម្មស៊ិនកក្កដា (២) សិប្បកម្ម ងួនសុខបាន (៣) សិប្បកម្មបូចន្ធី និង (៤) សិប្បកម្មខាត់ថៃ។

**២.ច្បាប់ស្តីពីព្រៃឈើ នៅខេត្តព្រះវិហារ និងខេត្តមណ្ឌលគិរី** (បានធ្វើការជាមួយមុខសញ្ញាសរុបចំនួន២៨)៖

-ផ្នែករដ្ឋបាលព្រៃឈើជាំក្សាន្ត និងផ្នែករដ្ឋបាលព្រៃឈើរវៀង មិនមានការគ្រប់គ្រងស្ថិតិរោងសិប្បកម្ម រោងសន្និធិ និងកន្លែងលក់គ្រឿងសង្ហារិមផល-អនុផលព្រៃឈើនៅឡើយ។

-ការបង្ក្រាបបទល្មើសព្រៃឈើរបស់ផ្នែករដ្ឋបាលព្រៃឈើជាំក្សាន្ត ផ្នែករដ្ឋបាលព្រៃឈើរវៀង ផ្នែករដ្ឋបាលព្រៃឈើត្បែងមានជ័យ និងផ្នែករដ្ឋបាលព្រៃឈើឆែប ពុំទាន់អស់លទ្ធភាពនៅឡើយ។

-រោងសិប្បកម្មកែច្នៃផល-អនុផលព្រៃឈើ និងរោងសន្និធិមួយចំនួនតូច នៅក្នុងដែនសមត្ថកិច្ចខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី មានសកម្មភាពដោយពុំទាន់មានលិខិតអនុញ្ញាតត្រឹមត្រូវនៅឡើយ។

-ខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី បានខិតខំព្យាយាមក្នុងការបង្ក្រាបបទល្មើសព្រៃឈើយ៉ាងខ្លាំងប៉ុន្តែបទល្មើសនៅតែបន្តកើតមានសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន (ឈើគ្មានប្រភពច្បាស់លាស់ត្រូវបានលួចដឹកចូលរោងសិប្បកម្ម)។

-ខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី នៅមានសំណុំរឿងបទល្មើសមួយចំនួនធំ ដែលមិនទាន់បានជម្រះរួចរាល់ ដែលនាំឱ្យមានការលំបាកក្នុងការថែរក្សាវត្ថុតាងបទល្មើស។

-ដីព្រៃក្នុងដែនសមត្ថកិច្ចរបស់ខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី ជាពិសេសក្នុងក្រុមហ៊ុនម៉ូហ៊ីបាម៉ាសូអូនកម្ពុជា ដេវីអិលធីឌី ក្រុមហ៊ុនផេស៊ីហ្វិកគ្លរីយ៉ាញស្តុក និងក្រុមហ៊ុនវ៉ាណាស៊ីខូអិលធីឌី នៅមានការចូលកាប់រុករានទន្ទ្រានដីព្រៃឈើ ដើម្បីយកដីធ្វើជាកម្មសិទ្ធិពីសំណាក់ប្រជាពលរដ្ឋ។

-មានរោងសនិធិ និងសិប្បកម្មកែច្នៃផល-អនុផលព្រៃឈើមួយចំនួន នៅខេត្តមណ្ឌលគិរី បានស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតរួចហើយ តែមិនទាន់បានទទួលលិខិតអនុញ្ញាតនៅឡើយ។

-ក្រុមហ៊ុនភីអិនធី ពុំទាន់ទទួលបានលិខិតអនុញ្ញាតឱ្យឈូសឆាយ និងមិនបានផ្តល់សិទ្ធឱ្យក្រុមហ៊ុនម៉ាយល ឡូជីស្ទិក(ខេមបូឌា) ក្នុងការសហការប្រមូលផល-អនុផលព្រៃឈើនៅឡើយ។

**៣.អនុក្រឹត្យលេខ១៤៦ អនក្រ. បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ចនៅខេត្តក្រចេះ ខេត្តព្រះវិហារ និងខេត្តមណ្ឌលគិរី** (បានធ្វើការជាមួយមុខសញ្ញាសរុបចំនួន៧២)៖

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន១៥ ស្ថិតនៅក្នុងខេត្តស្ទឹងត្រែង ក្រចេះ មណ្ឌលគិរី និងខេត្តពោធិ៍សាត់ មិនទាន់បានធ្វើអនុបយោគដីពីដីសាធារណៈ របស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ បានរួចរាល់នៅឡើយរួមមាន៖ (១) ក្រុមហ៊ុនភាពីមិច ក្រុមហ៊ុនកូម៉ាឌីអ៊ិនវេសមេនគ្រុប (២) ក្រុមហ៊ុនសលសុភាពាណិជ្ជ (៣) ក្រុមហ៊ុនសុកក្តិនីកា អ៊ីនវេសមេនអាហ្គ្រោអ៊ីនដាសស្ទ្រៀលផ្លេន (៤) ក្រុមហ៊ុនជីជីវើលគ្រុប (ខេមបូឌា) ឌីវេឡុបមេន (៥) ក្រុមហ៊ុនហ្គ្រេនលែនអេហ្គ្រីខលឈើរ៉ាលឌីវេឡុបមេន (ខេមបូឌា) លីមីតធីត (៦) ក្រុមហ៊ុនដុងណាយក្រចេះអភិវឌ្ឍន៍កៅស៊ូ (៧) ក្រុមហ៊ុនដុងភូក្រចេះអភិវឌ្ឍន៍កៅស៊ូ (៨) ក្រុមហ៊ុនមេហ្គាស្តារអ៊ិនវេសមេន&ហ្វរេសស្ទ្រីឌីវេឡុបមេន (៩) ក្រុមហ៊ុនមេហ្គាស្តារប្រូឌុសអែនអ៊ីមផតអិចផត (១០) ក្រុមហ៊ុនស៊ុនគុយទីអ៊ីមផតអិចផត (១១) ក្រុមហ៊ុនហ្គ្រីន អាយលែនអេហ្គ្រីខនឈើរ៉លឌីវេឡុបមេន(ខេមបូឌា)លីមីតធីត (១២) ក្រុមហ៊ុនស៊ីអេចភីប៊ីឌី វេឡុបមេន (១៣) ក្រុមហ៊ុនហេងហេងសម្បត្តិចំការកៅស៊ូ និង (១៤) ក្រុមហ៊ុនឌីជីស៊ីគ្រុបខូអិលធីឌី និង(១៥) ក្រុមហ៊ុនម៉ូហ៊ីបាម៉ាសូអូនកម្ពុជា ដេវីអិលធីឌី។

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន៧ ស្ថិតនៅក្នុងខេត្តពោធិ៍សាត់ ស្ទឹងត្រែង និងខេត្តមណ្ឌលគិរី មិនទាន់បានចុះបញ្ជីដីរដ្ឋរួចរាល់នៅឡើយរួមមាន៖ (១) ក្រុមហ៊ុនអិមឌីអេសអ៊ីមផតអិចផត (២) ក្រុមហ៊ុនសលសុភាពាណិជ្ជ (៣) ក្រុមហ៊ុនសុកក្តិនីកាអ៊ីនវេសមេនអាហ្គ្រោអ៊ីនដាសស្ទ្រៀលផ្លេន (៤) ក្រុមហ៊ុនជីជីវើលគ្រុប (ខេមបូឌា) ឌីវេឡុបមេន (៥) ក្រុមហ៊ុនវ៉ាណាស៊ីខូអិលធីឌី (៦) ក្រុមហ៊ុនសេដ្ឋីកុលាខូអិលធីឌី និង (៧) ក្រុមហ៊ុនខេភីសអ៊ិនវេសមេន(ខេមបូឌា) ខូអិលធីឌី ។

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន១៨ ស្ថិតនៅក្នុងខេត្តពោធិ៍សាត់ ក្រចេះ ស្ទឹងត្រែង និងខេត្តមណ្ឌលគិរី មិនទាន់បានធ្វើកិច្ចសន្យាកែសម្រួល ពីរយៈពេល៧០ឆ្នាំ មក៥០ឆ្នាំឱ្យ បានរួចរាល់នៅឡើយរួមមាន៖ (១) ក្រុមហ៊ុន អិមឌីអេសអ៊ីមផតអិចផត ក្នុងខេត្តពោធិ៍សាត់ (២) ក្រុមហ៊ុនស៊ុនគុយទីអ៊ីមផតអ៊ិចផត (៣) ក្រុមហ៊ុនខេមបូឌាយ៉ុង (៤) ក្រុមហ៊ុនដេភីអ៊ីខូអិលធីឌី (៥) ក្រុមហ៊ុនរតនៈស្ថានខេមបូឌាឌីវេឡុបមេនខូអិលធីឌី (៦) ក្រុមហ៊ុន ថេរវិនិយោ ខូអិលធីឌី (៧) ក្រុមហ៊ុនស៊ីអេចភីប៊ីឌីវេឡុបមេន (៨) ក្រុមហ៊ុនកូម៉ាឌីអ៊ិនវេសមេនគ្រុប (៩) ក្រុមហ៊ុនស៊ីវហ្គេច អ៊ិនវេសមេន (១០) ក្រុមហ៊ុនសលសុភាពាណិជ្ជ (១១) ក្រុមហ៊ុនសុកក្តិនីកាអ៊ីនវេសមេនអាហ្គ្រោអ៊ីនដាសស្ទ្រៀលផ្លេន (១២) ក្រុមហ៊ុនជីជីវើលគ្រុប(ខេមបូឌា)ឌីវេឡុបមេន (១៣) ក្រុមហ៊ុនវ៉ាណាស៊ីខូអិលធីឌី ក្រុមហ៊ុនសេដ្ឋីកុលា ខូអិលធីឌី (១៤) ក្រុមហ៊ុនកូវីផាម៉ាខូអិលធីឌី (១៥) ក្រុមហ៊ុនខេភី សអ៊ិនវេសមេន(ខេមបូឌា)ខូអិលធីឌី (១៦) ក្រុមហ៊ុនឌីជីស៊ីគ្រុបខូអិលធីឌី (១៧) ក្រុមហ៊ុនសៀងឡុងហ្គ្រីនលែនអ៊ិនវេសមេន (ខេមបូឌា) ម៉ូហ៊ីបាម៉ាសូអូនកម្ពុជា ដេវីអិលធីឌី និង (១៨) ក្រុមហ៊ុនអ៊ិនវេសមេនអេនឌីវ៉ឺឡុបមេនដាយថាន់ (ខេមបូឌា) ដេអេសស៊ីអិលធីឌី។

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន២២ ស្ថិតនៅក្នុងខេត្តពោធិ៍សាត់ ស្ទឹងត្រែង ក្រចេះ និងខេត្តមណ្ឌលគិរី មិនទាន់បានធ្វើផែនការមេកែសម្រួលរួចរាល់នៅឡើយរួមមាន៖ (១) ក្រុមហ៊ុនអភិវឌ្ឍន៍

តេនាវិសាល (២) ក្រុមហ៊ុន ផលិតម្សៅដំឡូងមីចំកាត់ (៣) ក្រុមហ៊ុនហ្វ្រេនលែនអេហ្គ្រីខលឈើរ័លឌីវេឡុបមេន(ខេមបូឌា)លីមីតធីត (៤) ក្រុមហ៊ុនដុងណាយក្រចេះអភិវឌ្ឍន៍កៅស៊ូ (៥) ក្រុមហ៊ុនដុងភូក្រចេះអភិវឌ្ឍន៍កៅស៊ូ (៦) ក្រុមហ៊ុនឈុនហុងរ៉ាប់ប៊ើរ បេតថឺរ (៧) ក្រុមហ៊ុនហ្វ្រីនអាយលែនអេហ្គ្រីខនឈើរ័លឌីវេឡុបមេន(ខេមបូឌា)លីមីតធីត (៨) ក្រុមហ៊ុនសុវណ្ណរាជសីហ៍ខូអិលធីឌី (៩) ក្រុមហ៊ុនអ៊ីអ៊ីនវេសម៉ិន (ខេមបូឌា) អិលធីឌី (១០) ក្រុមហ៊ុនស៊ី&រីគ្រុប (១១) ក្រុមហ៊ុន ឆាយណាដាយណាមិកអ៊ិនវេសមេន (១២) ក្រុមហ៊ុនភូរៀងក្រចេះអភិវឌ្ឍន៍កៅស៊ូខូអិលធីឌី (១៣) ក្រុមហ៊ុនដូរទីសាយហ្គន-ប៊ិញភឿក(អេសប៊ីខេ)ខូអិលធីឌី (១៤) ក្រុមហ៊ុនញូឡាយខេមភីធីរ៉ាយអិលធីឌី (១៥) ក្រុមហ៊ុនផេស៊ីហ្វិក វិថីវីយ៉ាញស្តុកខមផេនីលីមីតធីត (១៦) ក្រុមហ៊ុនផេស៊ីហ្វិកគ្លរីយ៉ាញស្តុកខមផេនីលីមីតធីត (១៧) ក្រុមហ៊ុនដាក់ឡាក់ មណ្ឌលគិរីអភិវឌ្ឍន៍កៅស៊ូ (១៨) ក្រុមហ៊ុនវីឡាឌីវឹឡុបមេន (១៩) ក្រុមហ៊ុនផេស៊ីហ្វិកឡូធើសយ៉ាញស្តុកខមភេនី លីមីធីត (២០) ក្រុមហ៊ុនផេស៊ីហ្វិកភើលយ៉ាញស្តុកខមភេនីលីមីធីត (២១) ក្រុមហ៊ុនផេស៊ីហ្វិកប្រាយដ៍យ៉ាញស្តុក ខមភេនីលីមីធីត និង (២២) ក្រុមហ៊ុនផេស៊ីហ្វិកហ្វ្រេនយ៉ាញស្តុកខមភេនីលីមីធីត ។

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ចំនួន៤១ ស្ថិតនៅក្នុងខេត្តពោធិ៍សាត់ ស្ទឹងត្រែង ក្រចេះ ព្រះវិហារ ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី មិនទាន់បានធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញរួចរាល់នៅឡើយរួមមានៈ (១) ក្រុមហ៊ុនអភិវឌ្ឍន៍តេនាវិសាល (២) ក្រុមហ៊ុនអិមឌីអេសអ៊ីមផតអិចផត (៣) ក្រុមហ៊ុន ស៊ីវហ្គេចអ៊ិនវេសមេនក្រុមហ៊ុនហ្វ្រីនស៊ីអេហ្គ្រីខលឈ័រ (៤) ក្រុមហ៊ុនជីជីវើលគ្រុប(ខេមបូឌា)ឌីវេឡុបមេន (៥) ក្រុមហ៊ុនភូម៉ាឌីអ៊ិនវេសមេន (៦) ក្រុមហ៊ុនសលសុភាពាណិជ្ជ (៧) ក្រុមហ៊ុនសំរោងរ៉ាប់ប៊ើរអ៊ិនដាសស្ទ្រីភីធីអ៊ី អិលធីឌី (៨) ក្រុមហ៊ុនមៀងលីហេងវិនិយោគ (៩) ក្រុមហ៊ុនមេហ្គាស្តារអ៊ិនវេសមេន&ហ្វរេសស្រ្ទីឌីវេឡុបមេន (១០) ក្រុមហ៊ុនមេហ្គាស្តារប្រូឌ្យូសអែនអ៊ីមផតអ៊ិចផត (១១) ក្រុមហ៊ុនឈុនហុងរ៉ាប់ប៊ើរបេតថឺរ (១២) ក្រុមហ៊ុនស៊ុនគុយទីអ៊ីមផតអ៊ិចផត (១៣) ក្រុមហ៊ុនហ្វ្រេតវ៉ៃឌើអេហ្គ្រីខនឈើរ័លឌីវេឡុបមេន (ខេមបូឌា) លីមីតធីត (១៤) ក្រុមហ៊ុនហ្វ្រីនអាយលែនអេហ្គ្រីខនឈើរ័លឌីវេឡុបមេន(ខេមបូឌា)លីមីតធីត (១៥) ក្រុមហ៊ុនសុវណ្ណរាជសីហ៍ ខូអិលធីឌី (១៦) ក្រុមហ៊ុនសាយឌុងកៅស៊ូឌុកឌុងខូអិលធីឌី (១៧) ក្រុមហ៊ុនប៊ីញហ្វឿកក្រចេះរ៉ាប់ប៊ើរខេមភេនីលីមីតធីត (១៨) ក្រុមហ៊ុនអ៊ីសជើនរ៉ាប់ប៊ើរ(ខេមបូឌា)ខូអិលធីឌី (១៩) ក្រុមហ៊ុនសុវណ្ណវុទ្ធីខូអិលធីឌី (២១) ក្រុមហ៊ុនចំការកៅស៊ូមេមត់ខូអិលធីឌី (២២) ក្រុមហ៊ុនអ៊ីអ៊ីនវេសម៉ិន(ខេមបូឌា)អិលធីឌី (២៣) ក្រុមហ៊ុនត្រាចញៀម ហ៊ូណានដូរទី-ហ្វាតទ្រៀនដាយណាមកម្ពុជា (២៤) ក្រុមហ៊ុនខេមបូឌាហាយ៉ុង (២៥) ក្រុមហ៊ុនដេភីអ៊ីខូអិលធីឌី (២៥) ក្រុមហ៊ុនថេវវិនិយោខូអិលធីឌី (២៦) ក្រុមហ៊ុនភូរៀងក្រចេះអភិវឌ្ឍន៍កៅស៊ូខូអិលធីឌី (២៧) ក្រុមហ៊ុន ញូឡាយខេមភីធីរ៉ាយអិលធីឌី (២៨) ក្រុមហ៊ុនស៊ីអេចភីប៊ីឌីវេឡុបមេន (២៩) ក្រុមហ៊ុនហេងហេងសម្បត្តិចំការកៅស៊ូ (៣០) ក្រុមហ៊ុនសីលាដាម៉ិច (៣១) ក្រុមហ៊ុនសុវណ្ណភូមិវិនិយោគកសិឧស្សាហកម្ម (៣២) ក្រុមហ៊ុនវ៉ារ៉ាណាស៊ី ខូអិលធីឌី (៣៣) ក្រុមហ៊ុនសេដ្ឋីកុលាខូអិលធីឌី (៣៤) ក្រុមហ៊ុនគូរីផាម៉ាខូអិលធីឌី (៣៥) ក្រុមហ៊ុនវីឡាឌីវឹឡុបមេន (៣៦) ក្រុមហ៊ុនឌីធីស៊ីគ្រុបខូអិលធីឌី (៣៧) ក្រុមហ៊ុនលែនអែនឌីវេលឡុបភីង (ខេមបូឌា) (៣៨) ក្រុមហ៊ុនសៀងឡុង ហ្វ្រីនលែនអ៊ិនវេសមេន(ខេមបូឌា) (៣៩) ក្រុមហ៊ុនផេស៊ីហ្វិកវិថីវីយ៉ាញស្តុកខមផេនីលីមីតធីត (៤០) ក្រុមហ៊ុន ផេស៊ីហ្វិកគ្លរីយ៉ាញស្តុកខម

ផេនីលីមីតធីត និង (៤១)ក្រុមហ៊ុនអ៊ិនវេសមេនអេនឌីវឡែបមេនដាយថាន់(ខេមបូឌា)ដេអេសស៊ី អិលធីឌី។

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ចំនួន៣៥ ស្ថិតនៅក្នុងខេត្តពោធិ៍សាត់ ស្ទឹងត្រែង ឧត្តរមានជ័យ ក្រចេះ និងខេត្តមណ្ឌលគិរី មានសល់ដីមួយចំនួនដែលបានឈូសឆាយរួចមិនទាន់បានដាំដុះ ឬដាំដុះដំណាំរួច តែងាប់ដំណាំអស់ ឬងាប់មួយចំនួនរួមមាន៖ (១) ក្រុមហ៊ុនអភិវឌ្ឍន៍រតនាវិសាល (២) ក្រុមហ៊ុនភូម៉ាឌីអ៊ិនវេសមេនគ្រុប (៣) ក្រុមហ៊ុនស៊ីវហ្គេច អ៊ិនវេសមេន (៤) ក្រុមហ៊ុនសុភក្តិនីកាអ៊ីនវេសមេនអាហ្គ្រោអ៊ីនដាសស្ទ្រៀលផ្លេន (៥) ក្រុមហ៊ុនហ្គ្រេនលែនអេហ្គ្រីខលឈើរ័លឌីវេឡុបមេន(ខេមបូឌា) លីមីតធីត (៦) ក្រុមហ៊ុនសំរោងរ៉ាប់ប៊ើរអ៊ិនដាសស្ទ្រីភីធីអ៊ីអិលធីឌី (៧) ក្រុមហ៊ុន តៃនីញសៀមរាបអភិវឌ្ឍន៍កៅស៊ូ (៨) ក្រុមហ៊ុនបេសរ៉ូយ៉ាល់(ខេ) ខូអិលធីឌី (៩) ក្រុមហ៊ុនដុងណាយក្រចេះអភិវឌ្ឍន៍កៅស៊ូ (១០) ក្រុមហ៊ុនដុងភូក្រចេះអភិវឌ្ឍន៍កៅស៊ូ (១១) ក្រុមហ៊ុនមេហ្គាស្តារអ៊ិនវេសមេន&ហ្វរេសស្ទ្រី ឌីវេឡុបមេន (១២) ក្រុមហ៊ុនមេហ្គាស្តារប្រូឌុសអែនអ៊ីមផតអ៊ិចផត (១៣) ក្រុមហ៊ុនឈុនហុងរ៉ាប់ប៊ើរបេតឋឺរ (១៤) ក្រុមហ៊ុនស៊ុនគុយទីអ៊ីមផតអ៊ិចផត (១៥) ក្រុមហ៊ុនអេស៊ារើលអេហ្គ្រីខនឈើរ័លឌីវេឡុបមេន(ខេមបូឌា) លីមីតធីត (១៦) ក្រុមហ៊ុនហ្គ្រេតវ៉ែនឌើអេហ្គ្រីខនឈើរ័លឌីវេឡុបមេន(ខេមបូឌា)លីមីតធីត (១៧) ក្រុមហ៊ុនហ្គ្រីន អាយលែនអេហ្គ្រីខនឈើរ័លឌីវេឡុបមេន(ខេមបូឌា) លីមីតធីត (១៨) ក្រុមហ៊ុនសុវណ្ណរាជសីហ៍ខូអិលធីឌី (១៩) ក្រុមហ៊ុនត្រាចញៀមហ៊ូណានដូវទីហ្វាតទ្រៀនដាយណាម-កម្ពុជា (២០) ក្រុមហ៊ុនដេភីអ៊ីខូអិលធីឌី (២១) ក្រុមហ៊ុន រតនៈស្ទោនខេមបូឌាឌីវេឡុបមេនខូអិលធីឌី (២២) ក្រុមហ៊ុនថេវនិយោខូអិលធីឌី (២៣) ក្រុមហ៊ុនភូរៀងក្រចេះ អភិវឌ្ឍន៍កៅស៊ូខូអិលធីឌី (២៤) ក្រុមហ៊ុនញូឡាយខេមភីធីវ៉ាយអិលធីឌី (២៥) ក្រុមហ៊ុនស៊ីអេចភីប៊ីឌីវេឡុបមេន (២៦) ក្រុមហ៊ុនវីឡាឌីវីឡុបមេនក្រុមហ៊ុនមេហ្គាហ្វីសឧបភើរេសិនប៊ឺហាដ (២៧) ក្រុមហ៊ុនលឹមរ៉ូយ៉ាល់ (២៨) ក្រុមហ៊ុន ផេស៊ីហ្វិកឡូជីសយ៉ញស្តុកខមភេនីលីមីធីត (២៩) ក្រុមហ៊ុនផេស៊ីហ្វិកភើលយ៉ញស្តុកខមភេនីលីមីធីត (៣០) ក្រុមហ៊ុនផេស៊ីហ្វិកប្រាយដ៍យ៉ញស្តុកខមភេនីលីមីធីត (៣១) ក្រុមហ៊ុនផេស៊ីហ្វិកហ្គ្រេនយ៉ញស្តុកខមភេនីលីមីធីត (៣២) ក្រុមហ៊ុនលែនអែនឌីវេលឡុបភីង(ខេមបូឌា) (៣៣) ក្រុមហ៊ុនសៀងឡុងហ្គ្រីនលែនអ៊ិនវេសមេន(ខេមបូឌា) (៣៤) ក្រុមហ៊ុនម៉ូហ៊ីបាម៉ាសូអូនកម្ពុជាដេវីអិលធីឌី និង (៣៥) ក្រុមហ៊ុនអ៊ិនវេសមេនអេនឌីវីឡុបមេនដាយថាន់ (ខេមបូឌា) ដេអេសស៊ីអិលធីឌី។

-ក្រុមហ៊ុនខេភីសអ៊ិនវេសមេន(ខេមបូឌា)ខូអិលធីឌី ក្នុងខេត្តមណ្ឌលគិរីមិនទាន់បានស្នើសុំផ្លាស់ប្តូរមុខដំណាំនៅឡើយ។

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន៣៨ ស្ថិតនៅក្នុងខេត្តពោធិ៍សាត់ ស្ទឹងត្រែង ក្រចេះ និងខេត្តឧត្តរមានជ័យ ក្រុមហ៊ុនខ្លះមានភាពយឺតយ៉ាវក្នុងការបង់ឈ្នួលសម្បទានដីសេដ្ឋកិច្ច ក្រុមហ៊ុនខ្លះមិនទាន់បានបង់ឈ្នួលសម្បទានដី សេដ្ឋកិច្ច ដោយគិតតាំងពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ និងក្រុមហ៊ុនខ្លះទៀតបង់បានបង់មិនបានបង់ទៀងទាត់រួមមាន៖ (១) ក្រុមហ៊ុនអភិវឌ្ឍន៍រតនាវិសាល (២) ក្រុមហ៊ុនអិមឌីអេសអ៊ីមផតអិចផត (៣) ក្រុមហ៊ុនម៉ាឌីអ៊ិនវេសមេនគ្រុប (៤) ក្រុមហ៊ុនស៊ីវហ្គេចអ៊ិនវេសមេន (៥) ក្រុមហ៊ុនសលសុភាពាណិជ្ជ (៦) ក្រុមហ៊ុនសុភក្តិនីកាអ៊ីនវេសមេន អាហ្គ្រោ អ៊ីនដាសស្ទ្រៀលផ្លេន (៧) ក្រុមហ៊ុនហ្គ្រីនស៊ីអេហ្គ្រីខលឈ័រ (៨) ក្រុមហ៊ុនផលិតម្សៅដំឡូងមីចំកាត់ (៩) ក្រុមហ៊ុន ជីជីវើល

គ្រុប (ខេមបូឌា) ឌីវេឡុបមេន (១០) ក្រុមហ៊ុនហ្វ្រេនលែនអេហ្គ្រីខលឈើរ៍លែឌីវេឡុបមេន (ខេមបូឌា) លីមីតធីត (១១) ក្រុមហ៊ុនដុងណាយក្រចេះអភិវឌ្ឍន៍កៅស៊ូ (១២) ក្រុមហ៊ុនដុងគូក្រចេះអភិវឌ្ឍន៍កៅស៊ូ (១៣) ក្រុមហ៊ុន មេហ្គាស្តារអ៊ិនវេសមេន&ហ្វរេសស្រ្ទីឌីវេឡុបមេន (១៤) ក្រុមហ៊ុនមេហ្គាស្តារប្រូឌុសអែនអ៊ីមផតអ៊ិចផត (១៥) ក្រុមហ៊ុនឈុនហុងរ៉ាប់ប៊ើរបេតថឺរ (១៦) ក្រុមហ៊ុនស៊ុនគុយទីអ៊ីមផតអ៊ិចផត (១៧) ក្រុមហ៊ុនអេស៊ាវើលអេហ្គ្រីខនឈើរ៍លែឌីវេឡុបមេន(ខេមបូឌា)លីមីតធីត (១៨) ក្រុមហ៊ុនហ្វ្រេតវ៉ែនឌើអេហ្គ្រីខនឈើរ៍លែឌីវេឡុបមេន(ខេមបូឌា)លីមីតធីត (១៩) ក្រុមហ៊ុនហ្វ្រីនអាយលែនអេហ្គ្រីខនឈើរ៍លែឌីវេឡុបមេន (ខេមបូឌា) លីមីតធីត (២០) ក្រុមហ៊ុន Vietnam (Kampuchea) Economy Trade And Industry Company Limited Co., Ltd (២១) ក្រុមហ៊ុនប៊ីញហ្វឿកក្រចេះរ៉ាប់ប៊ើរ២ខមភេនីលីមីតធីត (២២) ក្រុមហ៊ុនអ៊ីសជើនរ៉ាប់ប៊ើរ(ខេមបូឌា)ខូអិលធីឌី (២៣) ក្រុមហ៊ុនសុវណ្ណវុទ្ធីខូអិលធីឌី (២៤) ក្រុមហ៊ុនត្រាចញៀមហ៊ូណានដូវទី-ហ្វាតទ្រៀនដាយណាម-កម្ពុជា (២៥) ក្រុមហ៊ុនខេមបូឌាហាយ៉ុង (២៦) ក្រុមហ៊ុនដេភីអ៊ីខូអិលធីឌី (២៧) ក្រុមហ៊ុនរតនៈស្ទោនខេមបូឌាឌីវេឡុបមេន ខូអិលធីឌី (២៨) ក្រុមហ៊ុនថេវវិនិយោខូអិលធីឌី (២៩) ក្រុមហ៊ុនស៊ីអេចភីប៊ីឌីវេឡុបមេន (៣០) ក្រុមហ៊ុនហេងហេង សម្បត្តិចំការកៅស៊ូ (៣១) ក្រុមហ៊ុនមៀងលីហេងវិនិយោគ (៣២) ក្រុមហ៊ុនខេមបូឌាដោនផ្លេនថេសិនអិលធីឌី (៣៣) ក្រុមហ៊ុនស៊ីចាន់ថុនហ្វាមើឌីវីឡុបមេនអ៊ិនវេសមេន (៣៤) ក្រុមហ៊ុនហ្វ្រីនឌីវីឡុបមេនខូអិលធីឌី (៣៥) ក្រុមហ៊ុនកៅស៊ូមេគង្គខូអិលធីឌី (៣៦) ក្រុមហ៊ុនស៊ីអេឌីអាយខូអិលធីឌី (៣៧) ក្រុមហ៊ុនឆាយណាហ្វ្រេតខសអ៊ិនវេសមេន (ខេមបូឌា) (៣៨) ក្រុមហ៊ុនទ្រីភាពអ៊ីមផតអ៊ិចផត។

-ក្រុមហ៊ុន បូណាវីតា មិនដំណើរការ និងគ្មានសកម្មភាពអភិវឌ្ឍស្របតាមកិច្ចសន្យានៅឡើយ។

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន៣ ស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ មិនទាន់បានរៀបចំសាងសង់រោងចក្រកែច្នៃនៅឡើយរួមមាន៖ (១) ក្រុមហ៊ុនសំរោងរ៉ាប់ប៊ើអ៊ិនដាសស្ទ្រីភីធីអ៊ីអិលធីឌី (២) ក្រុមហ៊ុនតៃនីញសៀមរាបអភិវឌ្ឍន៍ កៅស៊ូ និង (៣) ក្រុមហ៊ុនបេសរ៉ូយ៉ាល់(ខេ)ខូអិលធីឌី។

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន២ ស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ ពុំទាន់បានរៀបចំស្លាកដាក់តាំងនៅជាប់ផ្លូវជាតិ ឬផ្លូវចូលទៅកាន់ទីតាំងស្នាក់ការរបស់សម្បទានដីសេដ្ឋកិច្ចនូវព័ត៌មានសំខាន់ៗរបស់ក្រុមហ៊ុននៅឡើយ រួមមាន៖ (១) ក្រុមហ៊ុនមៀងលីហេងវិនិយោគ (២) ក្រុមហ៊ុនបេសរ៉ូយ៉ាល់ (ខេ) ខូអិលធីឌី។

-ក្រុមហ៊ុនខេមបូឌាហាយ៉ុង ស្ថិតនៅក្នុងខេត្តក្រចេះ មិនទាន់បង់ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានៅឡើយ។

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ចំនួន១០ ស្ថិតនៅក្នុងខេត្តព្រះវិហារ និងខេត្តក្រចេះ កំពុងមានការទន្ទ្រានកាន់កាប់ដីក្រុមហ៊ុនពីសំណាក់ប្រជាពលរដ្ឋរួមមាន៖ (១) ក្រុមហ៊ុនរួយហ្វេង (ខេមបូឌា) អ៊ិនជើណេសិនណលខមភេនី លីមីតធីត (២) ក្រុមហ៊ុនហេងណុង (ខេមបូឌា) អ៊ិនជើណេសិនណលខមភេនីលីមីតធីត (៣) ក្រុមហ៊ុនហេងរួយ (ខេមបូឌា) អ៊ិនជើណេសិនណលខមភេនីលីមីតធីត (៤) ក្រុមហ៊ុនហេងយូ(ខេមបូឌា) អ៊ិនជើណេសិនណលខមភេនី លីមីតធីត (៥) ក្រុមហ៊ុនឡានហ្វេង (ខេមបូឌា) អ៊ិនជើណេសិនណលខមភេនីលីមីតធីត (៦) ក្រុមហ៊ុនមេហ្គាស្តារ អ៊ិនវេសមេន & ហ្វរេស

ស្រ្ទីឌីវេឡុបមេន (៧) ក្រុមហ៊ុនស៊ុនគុយទីអ៊ីមផតអ៊ិចផត (៨)ក្រុមហ៊ុនចំការកៅស៊ូមេមត់ ខូអិលធីឌី (៩) ក្រុមហ៊ុនខេមបូឌាហាយ៉ុង និង (១០) ក្រុមហ៊ុនស៊ីអេចកីប៊ីឌីវេឡុបមេន។

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន២ ស្ថិតនៅក្នុងខេត្តព្រះវិហាររួមមាន៖ ក្រុមហ៊ុនខេមបូឌាន ប្លូហេវិន លីមីតធីត នៅក្នុងខេត្តព្រះវិហារ បានដាក់ពាក្យស្នើសុំចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចរាល់ ប៉ុន្តែមិនទាន់ទទួលបានកិច្ចសន្យានៅឡើយ និងក្រុមហ៊ុន សុវណ្ណភូមិ វិនិយោគកសិ-ឧស្សាហកម្ម បានដាក់ពាក្យស្នើសុំទិន្នន័យដីដែលបានចុះបញ្ជី ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តព្រះវិហារ ដើម្បីយកទៅចុះកិច្ចសន្យាវិនិយោគសម្បទានដីសេដ្ឋកិច្ច ប៉ុន្តែនៅមិនទាន់បានទទួលនៅឡើយ។

-ក្រុមហ៊ុនស៊ីចាន់ថុនហ្វាមើឌីវ៉ឡុបមេនអ៊ិនវេសមេន ក្នុងខេត្តព្រះវិហារ បានឈូសឆាយដាក់ស្តែងសរុប ចំនួន១១៤ហិកតា និងក្រុមហ៊ុនហ្គ្រីនឌីវ៉ឡុបមេនខូអិលធីឌី បានឈូសឆាយដាក់ស្តែងសរុបចំនួន ១២៩ហិកតា ដែលលើសពីការអនុញ្ញាតរបស់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ។

-ក្រុមហ៊ុនរតនៈស្ទោនខេមបូឌាឌីវេឡុបមេនខូអិលធីឌី ក្នុងខេត្តក្រចេះ មិនទាន់បានធ្វើកិច្ចសន្យាការពារបរិស្ថានរួចរាល់នៅឡើយ។

-ក្នុងរោងម៉ាស៊ីនអារ កែច្នៃផល-អនុផលព្រៃ ក្នុងតំបន់វិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន Cambodia Dawn Plantation Ltd ក្នុងខេត្តព្រះវិហារ មានស្តុកឈើ ចំនួន១៣៥កំណាត់ ខុសច្បាប់ ដែលមានឈ្មោះ ជា សង្ឃធិតា ជាម្ចាស់បានប្រគល់សិទ្ធឱ្យឈ្មោះ ផាន់ ចាន់កុសល។

-ក្រុមហ៊ុនអេមិណិនអ៊ីលីត(ខេមបូឌា)ខូអិលធីឌី ស្ថិតនៅក្នុងខេត្តព្រះវិហារមិនទាន់បានចុះបោះបង្គោលកំណត់ព្រំប្រទល់សម្បទានដីសេដ្ឋកិច្ចរបស់ខ្លួននៅឡើយ។

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន៣ ស្ថិតនៅក្នុងខេត្តព្រះវិហារ មិនបានរក្សាឯកសារពាក់ព័ន្ធនានា នៅទីតាំងដីសម្បទានរួមមាន៖ (១) ក្រុមហ៊ុនអេមិណិនអ៊ីលីត(ខេមបូឌា)ខូអិលធីឌី (២) ក្រុមហ៊ុនហ្គ្រីនឈ័យ (ខេមបូឌា) ខូលីមីធីត និង (៣) ក្រុមហ៊ុនសីលាដាម៉ិច។

-ក្រុមហ៊ុនសីលាដាម៉ិច ស្ថិតនៅក្នុងខេត្តព្រះវិហារ មិនបានរៀបចំបុគ្គលិក កម្មករ និងសន្តិសុខដើម្បីការពារដីសម្បទាន ដែលរដ្ឋាភិបាលបានផ្តល់ជូននោះទេ។

-ក្រុមហ៊ុនសិលាដាម៉ិចស្ថិតនៅក្នុងខេត្តព្រះវិហារមានគ្រឿងចក្រជាច្រើនគ្រឿងក្នុងទីតាំងសម្បទានដីសេដ្ឋកិច្ចរបស់ខ្លួនដោយគ្មានលិខិតអនុញ្ញាត ឬគ្មានស្លាកសម្គាល់។

**៤.អនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់ និងប្រកាសលេខ០៨៧ ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី នៅខេត្តកំពង់ស្ពឺ តាកែវ និងខេត្តកំពង់ចាម** (បានធ្វើការជាមួយមុខសញ្ញាសរុបចំនួន២៨)៖

-ម្ចាស់សំណង់ ម្ចាស់គម្រោងអភិវឌ្ឍដី និងលំនៅដ្ឋានចំនួន៩ទីតាំង ស្ថិតនៅក្នុងខេត្តកំពង់ចាម និងខេត្តតាកែវ គ្មានលិខិតអនុញ្ញាតសាងសង់រួមមាន៖ (១) ម្ចាស់សំណង់សណ្ឋាគារផ្កាឈូកទិព្វ២ (២) ម្ចាស់សំណង់ផ្ទះល្វែងលោក កែវ សុខន (៣) គម្រោងដីឡូតិ៍ ក្រុមហ៊ុន ធ្មេល ផ្លាស គ្រាស់មីអ៊ិនវេសម៉ិន (៤) គម្រោងដីឡូតិ៍ក្រុមហ៊ុនខេស៊ី ៤ស្តារ (៥) គម្រោងដីឡូតិ៍ តាំងម៉ាប់ (៦) គម្រោងដីឡូតិ៍លោក យុន ខុន និងលោកស្រី យឿន ណារឿន (៧) គម្រោងលោក ជួន ជន និង លោកស្រី ខុន រ៉ាន់នី (៨)

គម្រោងលោក ជិន ប្រុស និងលោកស្រី ហ៊ុន ដាលីន និង (៩) គម្រោងលោក រ័ត្ន សុផាត និងលោក ផេង ចាន់ណារ៉ា។

-ម្ចាស់សំណង់ ចំនួន៤ទីតាំង ស្ថិតនៅក្នុងខេត្តតាកែវ និងខេត្តកំពង់ចាម កំពុងសាងសង់ដោយគ្មានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់រួមមាន៖ (១) ស្ថានីយប្រេងឥន្ធនៈប៉ាប៉ាភេត្រូលៀម របស់លោក ជូ សាត (២) ម្ចាស់សំណង់សណ្ឋាគារភ្នំប្រុស (៣) សំណង់ផ្ទះលែងលោក ផៃ ភារិន (៤) សំណង់ផ្ទះល្វែងលោក ប្រ៊ីក គឹមឈាន់។

-អ្នកអភិវឌ្ឍដីចំនួន២ទីតាំង ស្ថិតនៅក្នុងខេត្តកំពង់ចាម កំពុងធ្វើអាជីវកម្មអភិវឌ្ឍដី និងលំនៅដ្ឋានដោយគ្មានលិខិតអនុញ្ញាតអភិវឌ្ឍដីរួមមាន៖ (១) ក្រុមហ៊ុនធ្វេលផ្លាសត្រាស់មីអ៊ិនវេសម៉ិន និង (២) គម្រោងដីឡូត៍តាំងម៉ាប់។

-អ្នកអភិវឌ្ឍដី និងលំនៅដ្ឋាន ចំនួន៧ទីតាំង ស្ថិតនៅក្នុងខេត្តតាកែវ និងខេត្តកំពង់ចាម មិនទាន់បានរៀបចំអាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងប្រព័ន្ធទឹកពន្លត់អគ្គិភ័យនៅឡើយរួមមាន៖ (១) ក្រុមហ៊ុនធ្វេលផ្លាសត្រាស់មី អ៊ិនវេសម៉ិន (២) ក្រុមហ៊ុនខេស៊ី៤ស្តារឯ.ក (៣) គម្រោងដីឡូត៍តាំងម៉ាប់ (៤) គម្រោងដីឡូត៍លោក ឃុន ខុន (៥) គម្រោងលោក ជួន ជន និងលោកស្រី ខុន វ៉ាន្នី (៦) គម្រោងលោក ជិន ប្រុស និងលោកស្រី ហ៊ុន ដាលីន និង (៧) គម្រោងលោក រ័ត្ន សុផាត និងលោក ផេង ចាន់ណារ៉ា ។

**៥.កិច្ចសន្យាវិនិយោគធ្វើអាជីវកម្មយកកាស៊ី នៅខេត្តកំពង់ឆ្នាំង តាកែវ ព្រះវិហារ និងខេត្តកំពង់ចាម** (បានធ្វើការជាមួយមុខសញ្ញាសរុបចំនួន២២)៖

-ភ្នាក់ងារប្រមូលកាស៊ីចំនួន១៥ទីតាំង ស្ថិតនៅក្នុងខេត្តព្រះវិហារ តាកែវ កំពង់ឆ្នាំង និងខេត្តកំពង់ចាម មិនបានស្លៀកពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវ និងទៀងទាត់ក្នុងពេលបំពេញការងារតាមការកំណត់នៅក្នុងកិច្ចសន្យា និងសៀវភៅបន្ទុករួមមាន៖ (១) កំពង់ចម្លងជទទឹង (២) ផ្សារព្រៃខ្មែរ (៣) ផ្សារពង្រ (៤) ផ្សាររមាស (៥) ផ្សារពន្លៃ (៦) ផ្សារលើ (៧) ផ្សារព្រៃល្វា (១០) ចំណតជលយានអង្គរបូរី (១១) ចំណតជលយានកំពង់អំពិល (១២) ចំណតជលយានថ្មសរ (១៣) ផ្សារកំពង់ប្រណាក (១៤) សត្តឃាតដ្ឋានក្រុងកំពង់ចាម និង (១៥) សត្តឃាតដ្ឋានស្រុកកំពង់សៀម។

-អ្នកវិនិយោគធ្វើអាជីវកម្មកាស៊ី ចំនួន១១ទីតាំង ស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ ព្រះវិហារ តាកែវ និងខេត្តកំពង់ឆ្នាំង មិនទាន់បានរៀបចំសេចក្តីជូនដំណឹងថ្លៃកាស៊ីដែលត្រូវប្រមូល និងដាក់តាំងនៅច្រកផ្លូវចេញចូលសាធារណៈ ដើម្បីងាយស្រួលអតិថិជនបានឃើញនៅឡើយរួមមាន៖ (១) ផ្សារសំរោង (២) ផ្សារអន្លង់វែងថ្មី (៣) សត្តឃាតដ្ឋានក្រុងសំរោង (៤) ផ្សារកំពង់ប្រណាក (៥) សត្តឃាតដ្ឋានស្រុកកងមាស (៦) ផ្សារសែរ៉ា (៧) ផ្សារព្រៃខ្មែរ (៨) ផ្សារពង្រ (៩) ផ្សាររមាស (១០) ចំណតឡានក្រុងកំពង់ឆ្នាំង និង (១១) មណ្ឌលបែងចែកផលនេសាទ កសិផល និងថែទាំផែថ្ម។

-អ្នកវិនិយោគជលយានអង្គរបូរី ក្នុងខេត្តតាកែវបានរុះរើទីស្នាក់ការចាស់ដែលមានភាពទ្រុឌទ្រោម ហើយមិនទាន់បានសាងសង់ទីស្នាក់ការថ្មីឱ្យបានត្រឹមត្រូវឡើងវិញនៅឡើយ។

-អ្នកវិនិយោគធ្វើអាជីវកម្មយកកាស៊ីចំនួន៨ទីតាំង ក្នុងខេត្តតាកែវ កំពង់ឆ្នាំង និងខេត្តព្រះវិហារ មិនទាន់បានថែរក្សាអនាម័យឱ្យបានខ្ជាប់ខ្ជួន និងមិនទាន់រៀបចំសណ្តាប់ធ្នាប់ឱ្យមានរបៀបរៀបរយល្អនៅឡើយ ដោយនៅមានអាជីវករមួយចំនួនបានដាក់តាំងលក់ទំនិញនៅក្រៅបរិវេណតូប នៅលើផ្លូវដើរ មានត សំយ៉ាបចេញពីតូបផ្សារមកលើផ្លូវរួមមាន៖ (១) ផ្សារព្រៃល្វា (២) ផ្សារសែរ៉ា (៣)

ផ្សារកំពង់ប្រណាក (៤) ផ្សារព្រៃខ្មែរ (៥) ផ្សារពង្រ (៦) ផ្សាររមាស (៧) ផ្សារពន្លៃ និង (៨) ផ្សារលើ។

-អ្នកវិនិយោគធ្វើអាជីវកម្មយកភាស៊ីចំនួន៣ទីតាំង នៅក្នុងខេត្តឧត្តរមានជ័យ តាកែវ និង ខេត្តកំពង់ឆ្នាំង បានសាងសង់ពុំត្រឹមត្រូវតាមកិច្ចសន្យារួមមាន៖ (១) ចំណតរថយន្តក្រុងសំរោង (២) ផ្សារសែរ៉ា (៣) ផ្សារព្រៃខ្មែរ។

-អ្នកវិនិយោគធ្វើអាជីវកម្មយកភាស៊ីផ្សារតាកែវ ស្ថិតនៅក្នុងខេត្តតាកែវ មិនទាន់បានដាក់ពាក្យស្នើសុំធ្វើលិខិតប៉ះពាល់បរិស្ថាន ពីមន្ទីរបរិស្ថានខេត្តនៅឡើយ។

-ភ្នាក់ងារប្រមូលភាស៊ីចំនួន៧ទីតាំង ស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ ព្រះវិហារ តាកែវ និងខេត្តកំពង់ឆ្នាំង ពុំបានប្រើប្រាស់បណ្ណភាស៊ីដែលកំណត់ដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រមូលភាស៊ីប្រមូលភាស៊ីដោយមិនបានហែកបណ្ណប្រមូលភាស៊ីឱ្យទៅអតិថិជនរួមមាន៖ (១)ផ្សារសំរោង (២) ផ្សារកំពង់ប្រណាក (៣) ផ្សាររមាស (៤) មណ្ឌលបែងចែកផលនេសាទ កសិផល និងថែទាំផែថ្ម (៥) កំពង់ដទទឹង (៦) ចំណតជលយានអង្គរបូរី (៧) ចំណតជលយានថ្មសរ។

-អ្នកធ្វើអាជីវកម្មយកភាស៊ីចំនួន២ទីតាំង ស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ និងខេត្តតាកែវ មិនទាន់បានសម្អាតក្នុងទីសត្តឃាតដ្ឋានឱ្យបានល្អប្រសើរ និងមិនបានបាចកំបោរ ឬបាញ់ថ្នាំសម្លាប់មេរោគឱ្យបានជាប្រចាំនៅឡើយ រួមមាន៖ (១) សត្តឃាតដ្ឋានក្រុងសំរោង និង (២) សត្តឃាតដ្ឋានស្រុកកងមាស។

-អ្នកវិនិយោគធ្វើអាជីវកម្មយកភាស៊ីចំនួន២ទីតាំង ស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង មិនបានបង្កើតទីស្នាក់ការផ្សារនៅទីតាំងផ្សារនៅឡើយរួមមាន៖ (១) ផ្សារព្រៃខ្មែរ និង (២) ផ្សារពង្រ។

-អ្នកវិនិយោគធ្វើអាជីវកម្មយកភាស៊ីចំនួន២ទីតាំង ស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ និងខេត្តកំពង់ឆ្នាំង បានប្រមូលភាស៊ីនៅក្រៅទីតាំងបរិវេណផ្សាររួមមាន៖ (១) ផ្សារសំរោង (២) ផ្សារព្រៃខ្មែរ។

-អ្នកវិនិយោគធ្វើអាជីវកម្មយកភាស៊ីចំនួន២ទីតាំង ស្ថិតនៅក្នុងខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ បានយកថ្លៃភាស៊ីលើសពីការកំណត់នៅក្នុងសៀវភៅបន្ទុករួមមាន៖ (១) ផ្សារកំពង់ប្រណាក (២) ផ្សារសំរោង។

-អ្នកវិនិយោគធ្វើអាជីវកម្មភាស៊ីសត្តឃាតដ្ឋានក្រុងសំរោង ខេត្តឧត្តរមានជ័យ បានប្តូរទីតាំងសត្តឃាតដ្ឋានក្រុងសំរោង ដោយពុំមានការឯកភាពពីរដ្ឋបាលខេត្ត។

**៦.ច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ**

-ការបង្ក្រាបបទល្មើសជលផលរបស់ខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់ នៅមានកម្រិត និងមិនទាន់បានគ្រប់ជ្រុងជ្រោយ។

-ខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់ មិនទាន់បានគ្រប់គ្រងស្ថិតិឧបករណ៍នេសាទល្មើសច្បាប់នៅក្នុងមូលដ្ឋានរបស់ខ្លួនបានច្បាស់លាស់ និងត្រឹមត្រូវនៅឡើយ។

***លទ្ធផលការងារតាមដានការអនុវត្តច្បាប់របស់មន្ទីររាជធានី-ខេត្ត៖**

**១.ច្បាប់ស្តីពីព្រៃឈើ និងចូលរួមដាំដើមឈើ បោះបង្គោលកាត់ឆ្វៀលដីតំបន់៣ នៅខេត្តកំពង់ធំ៖**

-មានកិច្ចសហការពីរដ្ឋបាលស្រុក ខ័ណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើ។

-មានការបង្រ្កាបបទល្មើសព្រៃឈើ និងមានការសហការគ្នាបាល្អ ដោយបានឃាត់ខ្លួន និង បញ្ជូនវត្ថុតាងទៅតុលាការ។

-ម្ចាស់រោងសន្និធិមានលិខិតអនុញ្ញាតធ្វើអាជីវកម្មបានត្រឹមត្រូវតាមច្បាប់កំណត់។

-ជំនាញរដ្ឋបាលព្រៃឈើ បានធ្វើការអប់រំផ្សព្វផ្សាយពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ជូនដល់បងប្អូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

-ជំនាញរដ្ឋបាលព្រៃឈើ បានចុះអប់រំណែនាំដល់ម្ចាស់រោងសន្និធិទិញ-លក់ ចែកចាយផល-អនុផលព្រៃឈើ មិនឱ្យទិញឈើណាដែលមិនស្របច្បាប់ក្រៅពីក្រុមហ៊ុនឡើយ។

-ជំនាញរដ្ឋបាលព្រៃឈើ តែងតែចុះមកកាត់ស្តុកនៅតាមបណ្តារោងសន្និធិទិញ-លក់ ចែកចាយផល-អនុផលព្រៃឈើជាប្រចាំ។

-បានចូលរួមកិច្ចប្រជុំដើម្បីពិនិត្យផ្ទៀងផ្ទាត់ផែនទីស្នើសុំកាត់ឆ្វៀលដីពីតំបន់៣មកតំបន់២ ស្ថិតនៅក្នុងឃុំកំពង់គោ និងឃុំសាន់គ ស្រុកស្ទោង ខេត្តកំពង់ធំ ក្រោមអធិបតីភាពឯកឧត្តម ងួន រតនៈ អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ។

-បានចូលរួមជាមួយក្រុមការងាររបស់រដ្ឋបាលខេត្តកំពង់ធំ ដឹកនាំដោយឯកឧត្តម ទូច សុខា អភិបាលរងខេត្ត ស្ថិតនៅទីតាំងបឹងចំណា នៅឃុំញ្ញៅ និងឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

-បានចូលរួមជាមួយក្រុមការងាររបស់រដ្ឋបាលខេត្តកំពង់ធំ ដឹកនាំដោយឯកឧត្តម ព្រឹម រដ្ឋា អភិបាលរងខេត្ត ចុះលើកប៉ាណូ នៅតំបន់៣ ស្ថិតនៅភូមិត្រពាំងចេក ស្រុកស្ទោង ខេត្តកំពង់ធំ។

-បានសហការជាមួយរដ្ឋបាលក្រុងស្ទឹងសែន ចុះដាំគ្រាប់ត្នោត នៅតាមខ្សែក្រវ៉ាត់ដីព្រៃលិចទឹក (តំបន់៣) នៅតាមបន្ទាត់ស្ថិតក្នុងភូមិសាស្ត្រក្រុងស្ទឹងសែន ខេត្តកំពង់ធំ។

-បានចូលរួមជាមួយក្រុមការងាររបស់សាលាខេត្តកំពង់ធំ ចុះបោះបង្គោលឆ្វៀលដី(តំបន់៣) តាមអនុក្រឹត្យលេខ១០៥ និងសជណលេខ៣៩៣ កាត់ឆ្វៀលជូនប្រជាពលរដ្ឋ ដែលបានអាស្រ័យផលពិតប្រាកដកន្លងមក។

-បានចូលរួមជាមួយក្រុមការងាររបស់រដ្ឋបាលខេត្តកំពង់ធំ ដឹកនាំដោយឯកឧត្តម សុក ហៃ អភិបាលរងខេត្ត ចុះបោះបង្គោលឆ្វៀលដី(តំបន់៣) តាមអនុក្រឹត្យលេខ១០៥ និងសជណលេខ៣៩៣ នៅតំបន់អាង២០០០ និងវាលស្រង៉ែ ក្នុងឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

-បានចូលរួមជាមួយក្រុមការងាររបស់រដ្ឋបាលខេត្តកំពង់ធំ ដឹកនាំដោយឯកឧត្តម ងួន រតនៈ អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ចុះពិនិត្យជាក់ស្តែងដី(តំបន់៣) ដែលប្រជាពលរដ្ឋបានអាស្រ័យផលជាក់ស្តែង ក្នុងឃុំចំណាក្រោម ស្រុកស្ទោង ខេត្តកំពង់ធំ។

**២.ច្បាប់ស្តីពីជលផល នៅខេត្តកំពត៖**

-បានសហការណ៍ជាមួយជំនាញជលផល និងអាជ្ញាធរពាក់ព័ន្ធ បានចុះដល់សហគមន៍នេសាទទាំង១០ ស្ថិតនៅសង្កាត់ព្រែកត្នោត ឃុំបឹងទូក ក្រុងបូកគោ និងឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត។

-បានចុះអប់រំណែនាំដល់ប្រជានេសាទតាមសហគមន៍នីមួយៗ ឱ្យយល់ដឹងពីច្បាប់ស្តីពីជលផល យល់ពីឧបករណ៍ដែលហាមឃាត់ ឬមកប្រើប្រាស់ឧបករណ៍ស្របច្បាប់វិញ និងបានធ្វើលិខិតអញ្ជើញប៉ូលីសប៉ុស្តិ៍ឈរជើងត្រពាំងរពៅ មកធ្វើកំណត់ហេតុពាក់ព័ន្ធនឹងការងារការពារសុវត្ថិភាពដែនសមុទ្រ

និងឱ្យបញ្ឈប់ការទទួលយកប្រាក់ពីប្រជានេសាទ បើមាននរណាម្នាក់យកប្រាក់ពីប្រជានេសាទទៀតនោះ និងទទួលខុសត្រូវចំពោះមុខច្បាប់។

**៣.ច្បាប់ស្តីពីបរិស្ថាន នៅខេត្តស្វាយរៀង៖**

-នៅក្រុងបាវិត ក្រុងស្វាយរៀង និងស្រុករំដួល បានជួបផ្ទាល់ជាមួយម្ចាស់ និងតំណាងសហគ្រាសសិប្បកម្មទីតាំងអាជីវកម្មចំនួន៩នាក់ (ស្ត្រីចំនួន៤នាក់) ប្រកបអាជីកម្មផ្សេងៗរួមមាន៖

+ផ្នែកសិប្បកម្មផលិតទឹកកកដើម និងអនាម័យមាន៤នាក់ មានលិខិតអនុញ្ញាតនៅមានសុពលភាព ចំនួន៤នាក់។

+ផ្នែកលក់-ទិញអេតចាយមានចំនួន២នាក់ មានលិខិតអនុញ្ញាតនៅមានសុពលភាព ចំនួន២នាក់។

+ផ្នែកទីលានចាក់សម្រាមមានចំនួន៣នាក់ មានលិខិតអនុញ្ញាតនៅមានសុពលភាព ចំនួន៣នាក់។

**៤.ច្បាប់ស្តីពីជលផល នៅខេត្តបាត់ដំបង៖**

-បានចូលរួមសហការជាមួយគណៈបញ្ជាឯកភាពរដ្ឋបាលស្រុកសង្កែ និងស្រុកមោងឬស្សី នាយសង្កាត់រដ្ឋបាលជលផលទាំង២ស្រុក ព្រមទាំងកំលាំងមានសមត្ថកិច្ចទាំង៣ប្រភេទ សរុប៣០នាក់ បានចុះទៅបង្ក្រាបបទល្មើសនេសាទខុសច្បាប់ ក្នុងភូមិសាស្ត្រស្រុកទាំង២ ដោយបានកាប់បំផ្លាញឧបករណ៍ប្រព្រឹត្តល្មើសបានដូចជា សាច់មោងប្រវែង៨,៧៥០ម៉ែត្រ ឡុកចំនួន១៦ បង្គោលចំនួន ៣,០៥០ដើម បានព្រលែងកូនត្រីចំរុះចំនួន៤០០គីឡូក្រាម និងរាល់សម្ភារបទល្មើសត្រូវបានកាប់បំផ្លាញ ព្រមទាំងដុតកំទេចចោលនៅហ្នឹងកន្លែង។

-បានចូលរួមសហការជាមួយអាជ្ញាធររដ្ឋបាលស្រុកទាំងបួន គឺស្រុកសង្កែ ស្រុកឯកភ្នំ ស្រុកថ្មគោល និងស្រុកមោងឬស្សី ក្នុងខេត្តបាត់ដំបង ដើម្បីធ្វើការកាត់ឆ្វៀលដីក្នុងតំបន់បី ដែលប្រជាពលរដ្ឋបានអាស្រ័យផលយូរឆ្នាំមកហើយ មុនឆ្នាំ២០១១ តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ របស់ប្រមុខរដ្ឋាភិបាលជូនប្រជាពលរដ្ឋ។

**៥.ចូលរួមចុះពិនិត្យ និងទប់ស្កាត់ការកាប់រានដីព្រៃខុសច្បាប់ ការប្រើប្រាស់គ្រឿងចក្រខុសច្បាប់ ការនេសាទខុសច្បាប់ ចូលរួមចុះត្រួតពិនិត្យមើលការឈូសឆាយ និងកំណត់ព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនភូម៉ាឌី និងក្រុមហ៊ុនស៊ីវហ្គេកអិនវេសមេន ចូលរួមចុះពិនិត្យ និងវាស់វែងឈើជាក់ស្តែងដែលក្រុមការងារបានរឹបអូសក្នុងរបៀងអភិរក្សជីវៈចម្រុះតំបន់ការពារធម្មជាតិ នៅខេត្តស្ទឹងត្រែង៖**

-ក្រុមការងារបានពិនិត្យឃើញថាមានការកាប់ទន្ទ្រានដី យកមកធ្វើជាកម្មសិទ្ធិយ៉ាងអនាធិបតេយ្យនៅឃុំវាលដេញ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

-ក្រុមការងារបានពិនិត្យឃើញថាមានការកាប់ទន្ទ្រានដី យកមកធ្វើជាកម្មសិទ្ធិយ៉ាងអនាធិបតេយ្យនៅឃុំចំការលើ ស្រុកថាឡាបរិវ៉ាត់ ខេត្តតស្ទឹងត្រែង។

-ក្រុមការងារចុះបង្ក្រាបបទល្មើសការកាប់ទន្ទ្រានរំលោភយកដីព្រៃក្នុងសហគមន៍ការពារព្រៃឈើ (ឈើទាលប្រឹស) ដែលមានទំហំ៧៥ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រភូមិរំដេង ឃុំចំការលើ ស្រុកថាឡាបរិវ៉ាត់យកមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ដឹកនាំដោយលោក ដួង ពៅ អភិបាលរងខេត្តស្ទឹងត្រែង ដោយមានការចូលរួមសម្របសម្រួលដោយលោក ជា សុភ័ក្រ ព្រះរាជ្យារង និងមានការចូលរួមពីកម្លាំងកង

រាជអាវុធហត្ថខេត្ត កម្លាំងប៉ុស្តិ៍នគបាលឃុំអូររ៉េ មន្ត្រីបរិស្ថាន ខណ្ឌរដ្ឋបាលព្រៃឈើ មន្ត្រីរដ្ឋបាលស្រុក និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តបានប្រជុំផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើដល់ប្រជាការពារ និងប្រជាពលរដ្ឋ និងបានចុះពិនិត្យមើលការកាប់ទន្រ្ទានដីព្រៃសហគមន៍ ដោយបានចុះទៅយកនិយាមការដល់៖

+ទីតាំងទី១ចំណុចអូរចោណាប ត្រង់ចំណុចនិយាមការលេខ(575656-1488692,575487-1488448,575560-1488424,575626-1488366,575537-1488221,575466-1488174,575214-1488070,575210-1487881,5762771487818,576360-1488627,576092-1488905,575856-1488653 និង575718-1488628 មានទំហំដី៧៤,២៦ហិកតា។ តាមការស្រាវជ្រាវរបស់ក្រុមការងារបានរកឃើញមុខសញ្ញាជនប្រព្រឹត្តល្មើសពាក់ព័ន្ធក្នុងការកាប់រានដីព្រៃត្រង់ចំណុច ខាងលើនេះមាន ឈ្មោះ ស៊ុប ព្រីអារីន ឈ្មោះ ម៉ាត់ រ៉ន ឈ្មោះ ម៉ាត់ ស៊ីន ឈ្មោះ សេត និងឈ្មោះ អួន មានទីលំនៅចំណុចហុងស្រម៉ ភូមិរំដេង ឃុំចំការលើ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

+ទីតាំងទី២ចំណុចអូរជំទាត់ដៃ ត្រង់ចំណុះនិយាមការលេខ (576890-1489293, 576888 1489544,576711, 1489548,576691-1489711,576774-1489772,576840-1489764,576969-1489991,577310-1490000 និង577359-1489317 មានទំហំដី៣៤,៤៧ហិកតា។ តាមការស្រាវជ្រាវរបស់ក្រុមការងារបានរកឃើញមុខសញ្ញាជនប្រព្រឹត្តល្មើសពាក់ព័ន្ធ ក្នុងការកាប់រានដីព្រៃត្រង់ចំណុចខាងលើនេះមានឈ្មោះ ព្រំ សំអៀត ស្ថិតនៅភូមិរំដេង ឃុំចំការលើ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

+ទីតាំងទី៣ចំណុចក្បាលទូក ត្រង់ចំណុចនិយាមការ លេខ(577750-1487372,577906-1487421,577518-1487943និង577681-1487427 មានទំហំដី ៦,៣៥ហិកតា។ (មិនទាន់ស្គាល់អត្តសញ្ញាណ)។

+ទីតាំងទី៤ចំណុចក្បាលទូក ត្រង់ចំណុចនិយាមការលេខ577998-1487076,578113-1487290, 578011- 1487346,577958-1487362,577538-1487210 និង577646-1487023 មានទំហំដី ១២,០៨ហិចតា។ តាមការបញ្ជាក់ពីឈ្មោះ ស៊ូ ម៉ាលីន នៅភូមិកែស ជាម្ចាស់ដីមានទំហំ២ហិកតា ក្នុងទំហំដី១២,០៨ ហិកតាខាងលើគាត់បានប្រាប់ក្រុមការងារយើងថាគាត់បានទិញដីនេះពីឈ្មោះ ប៊ុន ចំរ៉ុង ស្ថិតនៅភូមិកាំងដែកឃុំកោះស្រឡាយ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។

+ត្រង់ចំណុចនិយាមការ លេខ 576473-1488903,576661-1488943,576742-1488872, 576900-1488601 និង576687-1488573 មានទំហំដី៨ហិកតា។(មិនទាន់ស្គាល់អត្តសញ្ញាណ)

+ត្រង់ចំណុចនិយាមការលេខ576113-1489097,576013-1489059,576108-1489949, 576256-1488946,576333-1488994,576477-1488901,576533-1488799 និង576433-1488649 មានទំហំដី១៣,១៤ហិកតា មានម្ចាស់ឈ្មោះ ហេង ផល្លា ភេទប្រុស ជនជាតិខ្មែរ អាយុ៦៥ឆ្នាំ ស្ថិតនៅភូមិរំដេង ឃុំចំការលើ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ទីតាំងនេះផ្នែករដ្ឋបាល ព្រៃឈើថាឡាបរិវ៉ាត់បានកសាងសំណុំរឿង និងបញ្ជូនទៅតុលាការរួចរាល់ហើយ។

-ក្រុមការងារបានពិនិត្យឃើញថា ការកាប់ទន្រ្ទានដីយកមកធ្វើជាកម្មសិទ្ធិនៅតែមានសកម្មភាពនៅភូមិវាលដេញ ឃុំអន្លង់ជ្រៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

-ក្រុមការងារបានទទួលរបាយការណ៍ពីមន្ត្រីជំនាញរដ្ឋបាលព្រៃឈើ ថាដីមានប្លង់កម្មសិទ្ធិកាន់កាប់ត្រឹមត្រូវនៅចំណុចត្រពាំងគគី ភូមិមន ឃុំអន្លង់ជ្រៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

-ក្រុមការងារបានចុះត្រួតពិនិត្យមើលការឈូសឆាយ និងកំណត់ព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនភូម៉ាឌី និងក្រុមហ៊ុនស៊ីវហ្គេកអិនវេសមេន ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង៖

+ទីតាំងទីមួយៈ ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនភូម៉ាឌី ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង បានជួបប្រជុំពិភាក្សាជាមួយប្រជាពលរដ្ឋនឹងបានស្នើសុំដី ចំនួន ៣០០ម៉ែត្រ ដល់ចំណុចអូរកែកពីប្រជាពលរដ្ឋជូនក្រុមហ៊ុនវិញ តែប្រជាពលរដ្ឋមិនយល់ព្រមលើសំណើរបស់ក្រុមការងារទេ។

+ទីតាំងទីពីរៈ ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនស៊ីវហ្គេកអិនវេសមេន ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង បានជួបប្រជុំពិភាក្សាជាមួយប្រជាពលរដ្ឋ និងបានស្នើសុំដីពីប្រជាពលរដ្ឋជូនក្រុមហ៊ុនវិញ តែប្រជាពលរដ្ឋបានស្នើសុំមកក្រុមការងារវិញតែដីចំនួន ៣,០០០ ហិកតា។

-ក្រុមការងារបានជួបប្រទះអិចស្កាវ៉ាទ័រមួយគ្រឿង ពណ៌ផ្ទៃមេឃកំពុងឈូសឆាយឈូសឆាយដីព្រៃរដ្ឋយកធ្វើជាកម្មសិទ្ធិ ដែលប្រព្រឹត្តដោយឈ្មោះ ប៉ាវ និងម្ចាស់ដីឈ្មោះ យុត ដែលមានទីលំនៅនៅភូមិចំការលើ ឃុំចំការលើស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។ បន្ទាប់ពីបានធ្វើការសាកសួរក្រុមការងារបានទាក់ទងទៅលោក វ៉ា សុខា នាយផ្នែករដ្ឋបាលព្រៃឈើថាឡាបរិវ៉ាត់ សៀមបូក ដើម្បីចុះមកពិនិត្យនិងវាយតម្លៃទៅលើស្ថានភាពព្រៃ និងទីតាំងដីជាក់ស្តែង តាមរយៈទូរសព្ទតែលោក វ៉ា សុខា ថាជាប់រវល់មិនអាចទៅបានទេ ចំណែកឯលោក មាស គឹមហេង នាយសង្កាត់ថាឡា ស្រុកសៀមបូក កំពុងមានជំងឺ។

-ក្រុមការងារបានពិនិត្យឃើញថាមានការកាប់រានដីព្រៃ តិចតួចដើម្បីបង្កបង្កើនផល ជាលក្ខណៈគ្រួសារ នៅឃុំចំការលើ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

-ក្រុមការងារបានពិនិត្យឃើញថានៅភូមិដាំធំ និងភូមិកំបោរ ឃុំកោះស្នែង ពុំមានការកាប់រានដីព្រៃដើម្បីដាំដំណាំអាស្រ័យផល និងមិនមានការនេសាទខុសច្បាប់នៅរដូវបិទនេសាទនោះទេ។

-ក្រុមការងារបានពិនិត្យឃើញថាមានការកាប់រានដីព្រៃតិចតួច ដើម្បីដាំដំណាំអាស្រ័យផល ជាលក្ខណៈគ្រួសារ នៅឃុំស្រែគរ ស្រុកសេសាន ខេត្តស្ទឹងត្រែង។

-ក្រុមការងារបានពិនិត្យឃើញថាមានការកាប់រានដីព្រៃតិចតួច ដើម្បីបង្កបង្កើនផលជាលក្ខណៈគ្រួសារ និង មិនមានការនេសាទខុសច្បាប់នៅរដូវបិទនេសាទនោះទេ នៅឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។

-ក្រុមការងារបានពិនិត្យឃើញថាមានការកាប់រានដីព្រៃតិចតួច ដើម្បីបង្កបង្កើនផល ជាលក្ខណៈគ្រួសារ និងមិនមានការនេសាទខុសច្បាប់នៅរដូវបិទនេសាទនោះទេ នៅឃុំភ្លុក ស្រុកសេសាន ខេត្តស្ទឹងត្រែង

-ក្រុមការងារបានធ្វើការវាស់វែងឈើ និងរាប់ជាក់ស្តែងឃើញថាឈើសរុបមានចំនួន២៨៣ដុំ ស្មើនឹង១១៨,២១ ម៉ែត្រគូប ដែលស្ថិតនៅក្នុងភូមិសាស្ត្រភូមិតាឡាត ឃុំតាឡាត ស្រុកសេសាន ខេត្តស្ទឹងត្រែង។

-ក្រុមការងារបានពិនិត្យឃើញថាមានការកាប់រានដីព្រៃតិចតួច ដើម្បីបង្ករបង្កើនផល ជាលក្ខណៈគ្រួសារ និងមិនមានការនេសាទខុសច្បាប់នៅរដូវបិទនេសាទនោះទេ នៅឃុំសេកុង ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។

-ដើម្បីទទួលបានព័ត៌មាន កាន់តែមានភាពច្បាស់លាស់ក្រុមការងារបានចុះជួបជាមួយក្រុមប្រឹក្សាឃុំ មេភូមិ និងប្រជាពលរដ្ឋនៅភូមិអូរឡង់។ ពួកគាត់បានបញ្ជាក់ថាករណីជញ្ជូនឈើខុសច្បាប់ ពិតជាមានមែនតែការដឹកជញ្ជូននោះមិនមានលក្ខណៈទ្រង់ទ្រាយធំទេ តែឈ្មួញដែលតែងតែប្រកបរបរនេះ គឺមានឈ្មោះ វុធ និងឈ្មោះ សែម ឈឹម នៅឃុំសៀមបូក ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។

-ក្រុមការងារបានពិនិត្យឃើញថា មានការកាប់រានដីព្រៃតិចតួចដើម្បីបង្ករបង្កើនផល ជាលក្ខណៈគ្រួសារ និងមិនមានការនេសាទខុសច្បាប់នោះទេ នៅឃុំកោះព្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។

-ក្រុមការងារបានពិនិត្យឃើញថា មិនមានការកាប់រានដីព្រៃយកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួននោះទេ។ ដោយឡែកក្រុមការងារបានចុះមកដល់ឃុំសំអាង ស្រុកថាឡាបរិវ៉ាត់ បានពិនិត្យឃើញថាមានការឈូសឆាយដីព្រៃដោយប្រើគ្រឿងចក្រ។ ពេលក្រុមការងារបានសួរនាំម្ចាស់ដី គាត់ប្រាប់ថាមានប្លង់រឹងតំកល់ទុកនៅសាលាស្រុកថាឡាបរិវ៉ាត់។ ប្រសិនបើចង់មើល អាចទៅមើលបាន នៅឃុំនួង់ជ្រៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

**៦.ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកកម្ម ច្បាប់ស្តីពីផ្លូវថ្នល់ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ អនុក្រឹត្យលេខ១៩៧ អនក្រ. បកស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិផ្លូវរថភ្លើង និងការកំណត់ដែនព្រៃលិចទឹកតំបន់៣ និងចូលរួមជាមួយប្រតិភូអន្តរក្រសួងពិនិត្យទីតាំងដីស្នើសុំកែសម្រួលព្រំប្រទល់តំបន់២ និងតំបន់៣នៃបឹងទន្លេសាប នៅខេត្តកំពង់ឆ្នាំង៖**

-មានការហ៊ុមសម្រាស នៅចំណុចកោះរកា ឃុំពោមឆ្កោក ស្រុកជលគីរី និងបានស្នើសុំឱ្យមន្ត្រីជំនាញ ជលផលចាត់វិធានការតាមផ្លូវច្បាប់ចំនួន១លើក។

-នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ មន្ត្រីជំនាញ និងអាជ្ញាធរពាក់ព័ន្ធ បានចុះបង្ក្រាបបទល្មើសជលផលចំនួន២ករណី នៅចំណុចកោះធំ ភូមិព្រៃគ្រីជើង ឃុំព្រៃគ្រី ស្រុកជលគីរី និងចំណុចឃុំពោធិ៍ ស្រុកកំពង់លែង គឺបានរុះរើរបាំងសាច់អួនចំនួន១៥កន្លែង ប្រវែង៩៥០ម៉ែត្រ និងលូស្បៃមុងចំនួន១៤មាត់ បង្គោលសរុបចំនួន៣០០ដើម និងចាក់លែងកូនត្រីចម្រុះ៧០គីឡូក្រាម ទៅក្នុងធម្មជាតិវិញ។

-នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២ មន្ត្រីជំនាញ និងអាជ្ញាធរពាក់ព័ន្ធ បានចុះបង្ក្រាបបទល្មើសជលផល ចំនួន ២ករណី នៅចំណុចស្វាស្លាប់ បឹងផុក ក្រោយភូមិអង្គជ្រុំ អន្លង់អក និងបឹងធកឫស្សី ស្ថិតនៅក្នុងឃុំកោះថ្កូវ និងឃុំជលសា ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង គឺបានរុះរើរបាំងស្បៃមុងចំនួន២៤កន្លែង ប្រវែង១,២០០ម៉ែត្រ លូស្បៃមុងចំនួន២៤មាត់ បង្គោលសរុប២៥០ដើម ចាក់លែងកូនត្រីចូលបឹងធម្មជាតិ ចំនួន១៥០គីឡូ និងសម្ភារៈត្រូវបានបំផ្លាញចោលនៅនឹងកន្លែង។

-បានចូលរួមក្រុមការងារគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តកំពង់ឆ្នាំង ចុះប្រតិបត្តិការបង្ក្រាបបទល្មើសជលផលក្នុងភូមិសាស្ត្រ ស្រុកកំពង់លែង ស្រុកជលគីរី ស្រុកបរិបូណ៌ និងក្រុងកំពង់ឆ្នាំងចំនួន៤លើកគឺ៖

+រុះរើរបាំងស្នៃមុងចំនួន៤កន្លែង ប្រវែង២០០ម៉ែត្រ បង្គោលចំនួន៨០ដើម លូស្នៃមុង ចំនួន៤មាត់។

+រុះរើរបាំងសាច់អួនចំនួន១៤កន្លែង ប្រវែង៨៥០ម៉ែត្រ បង្គោល ចំនួន៨០០ដើម លូសាច់អួនចំនួន១៧គ្រឿង។

+រុះរើសម្រាស់ចំនួន១៩កន្លែង ទំហំ៤,៣០០ម៉ែតការ៉េ បង្គោលចំនួន៤៥០ដើម សម្រាស់ចំនួន២,៨៥០មែក។

-មានករណីលេងល្បែងស៊ីសងជល់មាន់តាមទូរទស្សន៍អនឡាញ ដោយខុសច្បាប់ ជ្រកក្រោមស្លាកឆ្នោតឡូតូស្របច្បាប់ នៅចំណុចហាងកាហ្វេ នៅខាងក្រោយប៉ុស្តិ៍ប្អេរ ស្ថិតក្នុងសង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ទោះបីប៉ុស្តិ៍នគរបាល រដ្ឋបាលប្អេរ បានឱ្យម្ចាស់ធ្វើកិច្ចសន្យាច្រើនលើកច្រើនសារ ក៏នៅតែមិនរាងចាល។

-បច្ចុប្បន្នយោងតាមអនុសាសន៍ និងបទបញ្ជារបស់រាជរដ្ឋាភិបាល ទីតាំងល្បែងស៊ីសងទាំងអស់នៅក្នុងខេត្តកំពង់ឆ្នាំង ត្រូវបានបិទទាំងស្រុង។

-មានសំណង់ខុសច្បាប់ចំនួន៥កន្លែង ដែលមិនព្រមរុះរើចេញពីលើផ្លូវជាតិលេខ៥ ក្នុងភូមិសាស្ត្រផ្សារពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។

-នៅពេលដែលរដ្ឋពង្រីកផ្លូវជាតិលេខ៥ ម្ចាស់ផ្ទះចំនួន ៤កន្លែង បានទទួលសំណងផលប៉ះពាល់រួចហើយ តែមិនព្រមរុះរើ និង១កន្លែងទៀតមិនព្រមយកសំណង។

-នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ រដ្ឋបាលខេត្តកំពង់ឆ្នាំង បានចុះអនុវត្តវិធានការរុះរើផ្ទះ ដែលសង់លើដីចំណីផ្លូវជាតិលេខ៥ទាំងនោះ។

-ពាក់ព័ន្ធនឹងការជីកកាយយកដីនៅជាប់ចំណុចបឹងតំរែក ស្ថិតនៅភូមិដំបូកកោះ ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ពិនិត្យឃើញថា មានការជីកកាយធ្វើផ្លូវចូលទៅរណ្តៅដី ដើម្បីជីកយកអាចម៍ដី ប៉ុន្តែពុំមានច្បាប់អនុញ្ញាតទេ។

-ទោះបីមានការរឹតបន្តឹងការបង្ក្រាបការការពារព្រៃលិចទឹកក្នុងតំបន់៣ ជុំវិញបឹងទន្លេសាបយ៉ាងណា ក៏នៅមានជនល្មើសមួយក្រុម នៅតែបន្តឈូសឆាយទន្ទ្រានដីព្រៃលិចទឹក ក្នុងភូមិសាស្ត្រស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។

-កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ សមត្ថកិច្ច និងមន្ត្រីជំនាញ បានឃាត់ខ្លួនមនុស្សប្រុស-ស្រី ចំនួន ១៤នាក់ ដែលបានធ្វើសកម្មភាពកាប់ព្រៃក្នុងតំបន់៣ នៅចំណុចអ្នកតាទាំង ក្នុងភូមិឆ្នុកទ្រូ ឃុំឆ្នុកទ្រូ និងនៅចំណុចភូមិត្រពាំងចាន់ ឃុំត្រពាំងចាន់ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

-បានចូលរួមជាមួយប្រតិភូអន្តរក្រសួង ដឹកនាំដោយ ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះពិនិត្យដីនៅជុំវិញបឹងទន្លេសាប ក្នុងភូមិសាស្ត្រស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។

-បានចូលរួមជាមួយប្រតិភូអន្តរក្រសួង ដឹកនាំដោយឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងពិនិត្យទីតាំងដីស្នើសុំកែសម្រួលព្រំប្រទល់តំបន់២ និងតំបន់៣ នៃបឹងទន្លេសាប ក្នុងភូមិសាស្ត្រ ឃុំផ្លូវទូក ឃុំសំពោងសែន ស្រុកកំពង់លែង ដើម្បីផ្តល់ជូនប្រជាពលរដ្ឋរស់នៅអចិន្ត្រៃយ៍ និងអាស្រ័យផល។

-ក្រុមការងារមន្ទីរ បានចូលរួមជាមួយប្រតិភូអន្តរក្រសួង និងក្រុមការងាររបស់រដ្ឋបាលខេត្តកំពង់ឆ្នាំង ដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះពិនិត្យទីតាំងដែលរដ្ឋបាលខេត្ត ស្នើសុំកែសម្រួលព្រំប្រទល់តំបន់២ និងតំបន់៣ នៃតំបន់ទន្លេសាបក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង។

-បានចូលរួមជាមួយប្រតិភូក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រុមការងាររបស់រដ្ឋបាលខេត្ត កំពង់ឆ្នាំង ចុះពិនិត្យ និងស្រាវជ្រាវការទន្ទ្រានដីព្រៃលិចទឹកតំបន់ទន្លេសាប ក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំងចំនួន៥លើកតាមរយៈអនុក្រឹត្យលេខ១៩៧ អនក្រ.បក និងទិន្នន័យ ដែលទទួលបានពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ឆ្នាំង ព្រៃលិចទឹកតំបន់៣ ខេត្តកំពង់ឆ្នាំង មានផ្ទៃដីសរុបទំហំ៧៥,០២៨.១២ហិកតា គ្របដណ្តប់លើភូមិសាស្ត្រចំនួន៣ស្រុកគឺៈ ស្រុកកំពង់លែង មាន ផ្ទៃដី ទំហំ ៦២,០០៦.៣៦ហិកតា គ្របដណ្តប់លើ៧ឃុំ (២៧ភូមិ) ស្រុកបរិបូណ៌ មានផ្ទៃដីទំហំ ៨,៨៤៥.៧៧ ហិកតា គ្របដណ្តប់លើ៧ឃុំ (២០ភូមិ) និងស្រុកជលគិរី មានផ្ទៃដីទំហំ៤,១៧៦ហិកតា គ្របដណ្តប់លើ១ឃុំ (២ភូមិ)។

-ប្រជាពលរដ្ឋស្ម័គ្រចិត្តធ្វើលិខិតប្រគល់ដីជូនរដ្ឋសរុប ចំនួន៧,៥៣១គ្រួសារ លើផ្ទៃដីប្រកាសក្នុងលិខិតស្ម័គ្រចិត្ត សរុបទំហំ ៣០,៥៨៩.០០ហិកតា ក្នុងនោះ (បញ្ចប់ត្រឹមថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២) គឺស្រុកកំពង់លែងចំនួន ៥,០៨៥គ្រួសារ ផ្ទៃដីប្រកាសសរុបទំហំ២,៤០៩.៥៣២ហិកតា និងស្រុកបរិបូណ៌ចំនួន២,០៥៣គ្រួសារ ផ្ទៃដីប្រកាស សរុបទំហំ៤,៩៩៩.៩៤ហិកតា និងស្រុកជលគិរី ចំនួន៣៩៣គ្រួសារ ផ្ទៃដីប្រកាសសរុបទំហំ១,៤៩៣.៧៤ហិកតា។

-បានចុះវាស់វែងក្បាលដីតាមការចង្អុលបង្ហាញរបស់ប្រជាពលរដ្ឋស្ម័គ្រចិត្តប្រគល់ដីជូនរដ្ឋរួច ចំនួន ៥,០៤០គ្រួសារ ស្មើនឹង៥,៦០១ក្បាលដី លើផ្ទៃដីសរុបទំហំ១៥,២២៤.១៣ហិកតា គឺស្រុកកំពង់លែងចំនួន២,៩២២គ្រួសារ ស្មើនឹង៣,១១៩ក្បាល ដីសរុបទំហំ១០,៣៧៣.៣៦ហិកតា និងស្រុកបរិបូណ៌ចំនួន១,៨១៣គ្រួសារ ស្មើនឹង២,១៤៩ក្បាលដី សរុបទំហំ៣,៧៦៦.១៧ហិកតា និងស្រុកជលគិរី ចំនួន ៣០៥គ្រួសារ ស្មើនឹង៣៣៣ក្បាលដី សរុបទំហំ១,០៨៤.៥៨ហិកតា។

-បានរុះរើរោង និងដកបង្គោលកំណត់ព្រំដី នៅឃុំប្រឡូក ស្រុកកំពង់លែង គឺរុះរើរោងក្នុងដីព្រៃលិចទឹកតាម ផ្លូវលេខ៥០C ចំនួន៥៥រោង (បញ្ចប់១០០%) ដកបង្គោលព្រំដែលទន្ទ្រានកាន់កាប់ដីព្រៃចំនួន២២៣បង្គោល (បញ្ចប់ ១០០%) ដាក់ប៉ាណូកំណត់ព្រំប្រទល់តំបន់៣ បានចំនួន៤ទីតាំង ដាំកូនឈើក្នុងតំបន់ព្រៃលិចទឹកឡើងវិញ បានចំនួន ២៣,២៤៤ដើម និងដាំគ្រាប់ត្នោត នៅតាមព្រំដីព្រៃលិចទឹកតំបន់៣ សម្រេចបាន១៨,៥៧៤គ្រាប់ លើដីប្រវែង៧២.៥៦គីឡូម៉ែត្រ។

## ៣.៤.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

ក្រសួងបានទទួលពាក្យបណ្តឹងចំនួន៨១បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៣៨បណ្តឹង និង មន្ទីររាជធានី-ខេត្តចំនួន ៤៣ បណ្តឹង)៖

-ពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួង ចំនួន៩បណ្តឹង (ឆ្នាំ២០២២ ចំនួន៩បណ្តឹង)។

-ពាក្យបណ្តឹងដែលជាសមត្ថកិច្ចមន្ទីររាជធានី-ខេត្ត ចំនួន៣៧បណ្តឹង (ឆ្នាំ២០២២ ចំនួន៣៧ បណ្តឹង)។

-ពាក្យបណ្ដឹងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួង ចំនួន៥បណ្ដឹង (ឆ្នាំ២០២២ ចំនួន៥បណ្ដឹង)។

-ពាក្យបណ្ដឹងបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយ ចំនួន២១បណ្ដឹង (អគ្គនាយកដ្ឋានអធិការកិច្ច ចំនួន១៨បណ្ដឹង និងមន្ទីររាជធានី-ខេត្តចំនួន៣បណ្ដឹង ក្នុងនោះ ឆ្នាំ២០២១ ចំនួន៤បណ្ដឹង ឆ្នាំ២០២២ ចំនួន១៧បណ្ដឹង)។

-ពាក្យបណ្ដឹងដែលថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកមិនចាត់ការ ចំនួន៩បណ្ដឹង (ឆ្នាំ២០២០ ចំនួន១បណ្ដឹង ឆ្នាំ២០២១ ចំនួន១បណ្ដឹង ឆ្នាំ២០២២ ចំនួន៧បណ្ដឹង) ។

-ពាក្យបណ្ដឹងដែលម្ចាស់បណ្ដឹង សុំដកវិញចំនួន៥បណ្ដឹង (អគ្គនាយកដ្ឋានអធិការកិច្ច ចំនួន២បណ្ដឹង និងមន្ទីររាជធានី-ខេត្ត ចំនួន៣បណ្ដឹង ក្នុងនោះឆ្នាំ២០២១ ចំនួន២បណ្ដឹង ឆ្នាំ២០២២ ចំនួន៣បណ្ដឹង)។

-ពាក្យបណ្ដឹងដែលម្ចាស់បណ្ដឹងបានបោះបង់ចោល ចំនួន៣បណ្ដឹង (មន្ទីររាជធានី-ខេត្ត ឆ្នាំ២០២២ ចំនួន៣បណ្ដឹង)។

-ពាក្យបណ្ដឹងកំពុងសម្របសម្រួលថ្នាក់ក្រសួង ចំនួន៣បណ្ដឹង (ឆ្នាំ២០២១ ចំនួន២បណ្ដឹង ឆ្នាំ២០២២ ចំនួន១បណ្ដឹង)។

-ពាក្យបណ្ដឹងកំពុងចុះអង្កេតស្រាវជ្រាវ ចំនួន៤០បណ្ដឹង (អគ្គនាយកដ្ឋានអធិការកិច្ច ចំនួន១៦បណ្ដឹង និងមន្ទីរ រាជធានី-ខេត្តចំនួន២៤បណ្ដឹង ក្នុងនោះឆ្នាំ២០១៦ ចំនួន១បណ្ដឹង ឆ្នាំ២០១៩ ចំនួន២បណ្ដឹង ឆ្នាំ២០២០ ចំនួន២បណ្ដឹង ឆ្នាំ២០២១ ចំនួន៩បណ្ដឹង ឆ្នាំ២០២២ ចំនួន២៦បណ្ដឹង) ។

-ពាក្យបណ្ដឹងត្រៀមចុះអង្កេតស្រាវជ្រាវ ចំនួន១បណ្ដឹង (ឆ្នាំ២០២២ ចំនួន១បណ្ដឹង)។

-ពាក្យបណ្ដឹងបានទទួលការឆ្លើយតប ចំនួន១១បណ្ដឹង (ឆ្នាំ២០១៦ ចំនួន១បណ្ដឹង ឆ្នាំ២០២១ ចំនួន៦បណ្ដឹង ឆ្នាំ២០២២ ចំនួន៤បណ្ដឹង)។

-ពាក្យបណ្ដឹងដែលម្ចាស់បណ្ដឹងសុំជំរុញការដោះស្រាយ ចំនួន៣បណ្ដឹង (ឆ្នាំ២០១៦ ចំនួន១បណ្ដឹង ឆ្នាំ២០២១ ចំនួន២បណ្ដឹង)។

-ពាក្យបណ្ដឹងក្រសួងបានធ្វើលិខិតជំរុញការដោះស្រាយ ចំនួន១បណ្ដឹង (ឆ្នាំ២០២១ ចំនួន១បណ្ដឹង)។

-ពាក្យបណ្ដឹងបានធ្វើរបាយការណ៍ គោរពជូនឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត កំពង់ស្ពឺ ពិនិត្យសម្រេច ចំនួន១បណ្ដឹង (មន្ទីររាជធានី-ខេត្ត ឆ្នាំ២០២២ ចំនួន១បណ្ដឹង) ។

-ពាក្យបណ្ដឹងបានបញ្ចប់ការដោះស្រាយ ចំនួន៤៨បណ្ដឹង (អគ្គនាយកដ្ឋានអធិការកិច្ច ចំនួន៣១បណ្ដឹង និងមន្ទីររាជធានី-ខេត្តចំនួន១៧បណ្ដឹង ក្នុងនោះឆ្នាំ២០១៧ ចំនួន១បណ្ដឹង ឆ្នាំ២០១៩ ចំនួន៦បណ្ដឹង ឆ្នាំ២០២០ ចំនួន៤បណ្ដឹង ឆ្នាំ២០២១ ចំនួន១០បណ្ដឹង ឆ្នាំ២០២២ ចំនួន២៧បណ្ដឹង)គឺ៖

១.ឈ្មោះ ទ្រី គ្រឿន នៅភូមិកន្ទួត ឃុំសំឡូត ស្រុកសំឡូត ខេត្តបាត់ដំបង ប្ដឹងឈ្មោះ អ៊ុន សុផាត និងប្ដីឈ្មោះ ហួត ហាក់ បានរំលោភយកដីចម្ការរបស់គាត់ទំហំ៩,៣១០ម៉ែត្រការ៉េ ស្ថិតនៅភូមិកន្ទួត ឃុំសំឡូត ស្រុកសំឡូត ខេត្តបាត់ដំបង។ ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល។

២.ឈ្មោះ ពេជ្រ ភិរម្យ នៅភូមិ២ សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្ដឹងឈ្មោះ ទាវ ស៊ាងហ៊ាន់ និងឈ្មោះ អ៊ុំ បូរ៉ា បានឃុបឃិតគ្នាជាមួយឈ្មោះ ជុំ វ៉ន និងអាជ្ញាធរមានសមត្ថកិច្ច

រំលោភយកដីរបស់គាត់ទំហំ១៥,០០០ម៉ែត្រការ៉េ ស្ថិតនៅភូមិពូឡេះ ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី។ ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល។

៣.ឈ្មោះ កែវ សារ៉ាឌី ប្តឹងក្រុមហ៊ុនស៊ីង ស៊ីនួន ពុះដីឡូត៍លក់ និងមន្ត្រីមានអំណាចក្នុងខេត្តបន្ទាយមានជ័យបានឃុបឃិតគ្នាលួចយកដីរបស់លោក ខូវ ម៉េងហ៊ាន ទំហំ២០,០០០ម៉ែត្រការ៉េ យកទៅពុះឡូត៍លក់បន្តឱ្យឈ្មួញ។ ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងឱ្យតម្កល់ទុកលែងចាត់ការបន្ត។

៤.ឈ្មោះ ស៊ាន សុគន្ធមាលា ប្តឹងឈ្មោះ ផូ វុឌ្ឍី ជាមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងបក្ខពួកមកវាយកម្ទេចរបងរំលោភយកដីរបស់គាត់ ទំហំ៦,៨៩៥ម៉ែត្រការ៉េ ស្ថិតនៅភូមិឫទ្ធី១ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។ ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងឱ្យតម្កល់ទុកលែងចាត់ការបន្ត។

៥.ឈ្មោះ សុខ គឹមស្រេង និងឈ្មោះ ជី សុផាត នៅភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាលតំណាងប្រជាពលរដ្ឋចំនួន៤៥គ្រួសារ នៅភូមិ-ឃុំខាងលើ ប្តឹងឈ្មោះ នូវ ប៉េងច័ន្ទតារា អភិបាលរងខេត្តកណ្តាលបានរឹបអូសយកដីរបស់ពួកគាត់ទំហំ៨ហិកតា ស្ថិតនៅភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល។ ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងឱ្យតម្កល់ទុកលែងចាត់ការបន្ត។

៦. ឈ្មោះ ខូវ ស៊ាន់ និងឈ្មោះ ខូវ ហេង នៅផ្ទះលេខ១ ឃុំកំពេញ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ប្តឹងឈ្មោះ អ៊ឹម ប៉ូលីកា បានប្រើអំណាចឃុបឃិតជាមួយសមត្ថកិច្ចឈូសឆាយ បំផ្លាញដំណាំយកដីរបស់គាត់ ទំហំ១៦៨,៤៨៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិចំការកៅស៊ូ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងឱ្យតម្កល់ទុកលែងចាត់ការបន្ត។

៧.ឈ្មោះ ជា លាងជួង តំណាងឱ្យឈ្មោះ ជា វុត្ថា ឈ្មោះ តាំង វួចឡាយ ឈ្មោះ អ៊ឹង ឡាងអ៊ីម ឈ្មោះ អ៊ឹង សែ និងឈ្មោះ ឡៅ ឆេងណៃ ប្តឹងឈ្មោះ ថាច់ ថង ឈ្មោះ ខេង ង៉ូវ ឈ្មោះ ទួត លុច និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលបានឃុបឃិតគ្នា រំលោភយកដីគាត់ទំហំ១២០ហិកតា ស្ថិតនៅភូមិ៥ ឃុំប្រាសាទ ស្រុកស្អាង ខេត្តកណ្តាល។ ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងឱ្យតម្កល់ទុកលែងចាត់ការបន្ត។

៨.ប្រជាពលរដ្ឋចំនួន៥០គ្រួសារ ស្នើសុំជួយអន្តរាគមន៍ចុះធ្វើអធិការកិច្ច និងដោះស្រាយករណីដីទំនាស់ទំហំ៦៤ហិកតា ត្រូវបានឈ្មោះ ស៊ឹម ឈាន ឃុបឃិតគ្នាជាមួយអាជ្ញាធររំលោភយក ស្ថិតនៅភូមិតែងម៉ៅ ឃុំចន្រ្ទា ស្រុកចន្រ្ទា ខេត្តស្វាយរៀង។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺរដ្ឋបាលខេត្តស្វាយរៀង។

៩.ឈ្មោះ គឹម កញ្ញារ៉ា នៅភូមិដំណាក់ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ ស្នើសុំជួយអន្តរាគមន៍ដោះស្រាយវិវាទដីធ្លីទំហំ១២ហិកតា៣០អា ស្ថិតនៅចំណុចកូនភ្នំ ភូមិការកិច្ច សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ ករណីឯកឧត្តម ប្រាក់ សុវណ្ណ អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ បានប្រើប្រាស់គ្រឿងចក្រឈូសឆាយរបងផ្ទះ និងបំផ្លាញដំណាំស្វាយចន្ទីរបស់គាត់ និងរបស់ប្រជាពលរដ្ឋជាច្រើនគ្រួសារផ្សេងទៀត ដែលបានដាំរយៈពេល៧ឆ្នាំមកហើយ។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ គឺគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ។

១០.ឈ្មោះ ឡាយ ប៊ុនថូ ឈ្មោះ សាំង លី ឈ្មោះ ឈូ រិន ឈ្មោះ ហ៊ី សុភក្រ្តា ស្នើសុំជួយអន្តរាគមន៍ដោះស្រាយ និងផ្តល់សិទ្ធិកាន់កាប់ដីស្របច្បាប់ ដល់ពួកគាត់ទំហំ១៤ហិកតា នៅភូមិបឹងស្នោរ ឃុំស្លក្រាម ស្រុកស្វាយចេកខេត្ត បន្ទាយមានជ័យ។ ករណីនេះបានបញ្ចប់ ដោយបង្វែរទៅស្ថាប័ន ផ្សេងដោះស្រាយគឺសាលាដំបូងខេត្តបន្ទាយមានជ័យ។

១១.ឈ្មោះ ឡាយ ប៊ុនថូ ឈ្មោះ សាំង លី ឈ្មោះ ឈូ រិន ឈ្មោះ ហម លន់ និងឈ្មោះ សាំង ឌី ស្នើសុំជួយអន្តរាគមន៍ដោះស្រាយ និងផ្តល់សិទ្ធិកាន់កាប់ដីស្របច្បាប់ដល់ពួកគាត់ទំហំ២៩.៥ហិកតា នៅភូមិតំបន់១ ឃុំតាប៉ែនស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ ករណីនេះបានបញ្ចប់ ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺសាលាដំបូងខេត្តបន្ទាយមានជ័យ។

១២.ឈ្មោះ ឡាយ ប៊ុនថូ ឈ្មោះ សាំង លី និងឈ្មោះ សាំង ឌី ស្នើសុំជួយអន្តរាគមន៍ដោះស្រាយ និងផ្តល់សិទ្ធិកាន់កាប់ដីស្របច្បាប់ដល់ពួកគាត់ទំហំ៩ហិកតា នៅភូមិបឹងស្នោរ ឃុំស្លក្រាម ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ គឺសាលាដំបូងខេត្តបន្ទាយមានជ័យ។

១៣.ឈ្មោះ ច័ន្ទ សំអាន នៅរាជធានីភ្នំពេញ ស្នើសុំជួយអន្តរាគមន៍ករណីក្រសួងធនធានទឹក និងឧតុនិយម ដកហូតដីចម្ការរបស់គាត់ទំហំ១៥.៦១ហិកតា ស្ថិតនៅភូមិរនេស (បច្ចុប្បន្នហៅភូមិអន្ទង់ស) ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប យកទៅបញ្ចូលក្នុង ផ្ទៃរងអាងទឹកទំនប់រនេស។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ គឺរដ្ឋបាលខេត្តកែប។

១៤.ឈ្មោះ គឹម សោភ័ណ្ឌ នៅភូមិសុវណ្ណសាគរ សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត ប្តឹងឈ្មោះ សេង សិរីបុត្រ ជាអភិបាលរងខេត្តកំពត ឈ្មោះ នាក់ សុវណ្ណារី ជាអភិបាលស្រុកទឹកឈូ ខេត្តកំពត និងឈ្មោះ ចាន់ វណ្ណា ជាប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត ករណីអនុវត្តតួនាទីរំលោភបំពានមកលើដីកម្មសិទ្ធិឯកជនដែលមានប័ណ្ណរបស់ក្រុមគ្រួសារគាត់ ដោយកុហកភូតភរថ្នាក់ដឹកនាំ និងរំលោភលើអំណាចតុលាការ យកអំណាចមុខតំណែងតួនាទីខ្លួន ដើម្បីចោទប្រកាន់ទំលាក់កំហុសឱ្យគាត់ដែលជាម្ចាស់ដីមានប័ណ្ណរងទោសយ៉ាងអយុត្តិធម៌ជាទីបំផុតទៅវិញ។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺក្រសួងមហាផ្ទៃ។

១៥.ឈ្មោះ យ៉ន យុន នៅភូមិអន្លង់ស្លែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ស្នើសុំជួយអន្តរាគមន៍រកយុត្តិធម៌ ករណីវិវាទដីធ្លីជាមួយលោកឧកញ៉ា ជា សុខហេង និងលោកជំទាវ យុង ដាណេង ដែលបានបំពានយកដីរបស់គាត់ ទំហំ៣៩,៤៧៦ម៉ែត្រការ៉េ ស្ថិតនៅភូមិអន្លង់ស្លែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ គឺក្រសួងយុត្តិធម៌។

១៦.ឈ្មោះ ស្រី ម៉ាលីន នៅផ្ទះលេខ១៧១អឺ២ ផ្លូវកម្ពុជាក្រោម សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ស្នើសុំអន្តរាគមន៍ទៅក្រុមការងារចុះបញ្ជីដាលក្ខណៈប្រព័ន្ធ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តតាកែវ ដែលបានវាស់វែងកាត់ចំណីផ្លូវតែលើចំណែកដីរបស់គាត់ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ស្ថិតនៅភូមិស្នោ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ គឺក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

១៧.ឈ្មោះ នូ សាគពិសិដ្ឋ ជាមន្ត្រីចូលនិវត្តន៍ នៅភូមិសាក់សំពៅ សង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ស្នើសុំជួយអន្តរាគមន៍ករណីព្រះចៅអធិការវត្តសាក់សំពៅ ឈ្មោះ អឿន មាឃ និងតតិយជន (ព្រះសង្ឃ និងក្រុមកម្មករ) ដែលបានបិទបាំងផ្លូវលំជាប់របងវត្តប៉ែកខាងលិច នៃវត្តសាក់សំពៅ មិនឱ្យគាត់ធ្វើដំណើរចេញ-ចូល និងដកបង្គោលរបងព្រំដីរបស់គាត់ ដោយដាំបង្គោលថ្មរបស់ព្រះចៅអធិការវត្ត។ ករណីនេះបានបញ្ចប់ ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ គឺក្រសួងធម្មការ និងសាសនា។

១៨.ឈ្មោះ អ៊ុក ឃាន នៅភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ស្នើសុំជួយអន្តរាគមន៍ទៅមន្ទីរពេទ្យកាល់ម៉ែត្រ ដើម្បីធ្វើវិញ្ញាបនបត្រមរណភាពភរិយា របស់គាត់ឈ្មោះ ស្វាយ ចន្ទី ដែលបានទទួលមរណភាព ដោយគ្រោះថ្នាក់ចរាចរណ៍។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេង ដោះស្រាយគឺក្រសួងសុខាភិបាល។

១៩.ប្រជាពលរដ្ឋចំនួន៣គ្រួសារ មានឈ្មោះ សួរ ជុំ ឈ្មោះ ជា គាវ និងឈ្មោះ ញ៉ឹក ទី នៅភូមិចំពុះក្អែក១ សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្តឹងឈ្មោះ លីវ វណ្ណាថេង ជាចៅសង្កាត់ព្រែកថ្មី ដែលបានប្រើអំណាចបំពានយកដីរបស់ប្រជាពលរដ្ឋពង្រីកផ្លូវ សម្រាប់ចេញចូលទីតាំងដី របស់ខ្លួន ធ្វើឱ្យប៉ះពាល់ដល់ដីផ្ទះរដ្ឋនតារបស់ប្រជាពលរដ្ឋ និងមិនព្រមចុះហត្ថលេខា លើលិខិតស្នាមជូនប្រជាពលរដ្ឋ ដើម្បីធ្វើប្លង់កម្មសិទ្ធិជាប្រព័ន្ធ ព្រមទាំងបំពានសាលក្រមរបស់តុលាការទៀតផង។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ គឺមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានីភ្នំពេញ។

២០.ឈ្មោះ ឡុច សុខហេង នៅផ្ទះលេខ១២៤ ផ្លូវមហាវិថីឈ្នះឈ្នះ ភូមិកប់ស្រូវធំ សង្កាត់គោករការ ខណ្ឌ ព្រែកព្នៅ រាជធានីភ្នំពេញ ស្នើសុំជួយអន្តរាគមន៍ទៅអាជ្ញាធរមូលដ្ឋាន ដើម្បីបានកាន់កាប់ជាកម្មសិទ្ធិស្របច្បាប់លើដី របស់គាត់ ទំហំ១០០ម៉ែត្រx១៣៦ម៉ែត្រ ស្ថិតនៅផ្លូវមហាវិថី ឈ្នះឈ្នះ ភូមិកប់ស្រូវធំ សង្កាត់គោករការ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺរដ្ឋបាលរាជធានីភ្នំពេញ។

២១.ឈ្មោះ ឡូញ ចាន់ណា និងឈ្មោះ ឡូញ លាងឃី តំណាងឱ្យឈ្មោះ លី ឌៀន (ម្តាយ) នៅភូមិផ្ទះវាល ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ស្នើសុំកិច្ចសម្របសម្រួលដល់លោក សុខ លីគាង អនុប្រធាននាយកដ្ឋានអធិការកិច្ចនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលបានប្តឹងសុំផ្អាកផ្តល់កម្មសិទ្ធិ និងចេញវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ស្ថិតនៅភូមិផ្ទះវាល ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ គឺរដ្ឋបាលខេត្តកំពង់ចាម។

២២.ឈ្មោះ ភោគ ចុល ឈ្មោះ ឆាន ហាន ឈ្មោះ ហន ហៃ និងឈ្មោះ ប៊ូ សារ៉េត តំណាងប្រជាពលរដ្ឋចំនួន២២៦គ្រួសារ នៅភូមិបុស្សតាអឹម ភូមិសំពៅលូន ភូមិជំនុំពល ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ស្នើសុំជួយអន្តរាគមន៍ទៅអាជ្ញាធរខេត្តត្បូងឃ្មុំ ដើម្បីឱ្យពួកគាត់បានប្រកបអាជីវកម្មជីករករ៉ែលោហៈមាស ជាលក្ខណៈគ្រួសារឡើងវិញ ស្ថិតនៅតំបន់រ៉ែមាសសំពៅលូន។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺរដ្ឋបាលខេត្តត្បូងឃ្មុំ។

២៣.ឯកឧត្តម តាក វណ្ណថា ជាតំណាងរាស្ត្រ នៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ស្នើសុំជួយអន្តរាគមន៍ដើម្បីបានកាន់កាប់ជាកម្មសិទ្ធិ ស្របច្បាប់លើដីរបស់គាត់ ទំហំ ៣៩,៤៧៦ម៉ែត្រការ៉ េស្ថិតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺរដ្ឋបាលខេត្តព្រះសីហនុ។

២៤.ប្រជាពលរដ្ឋចំនួន៨គ្រួសារ មានឈ្មោះ ប៊ូ រីរ៉ា ឈ្មោះ ស៊ិន សុវណ្ណារី ឈ្មោះ ស៊ិន សុវណ្ណអន ឈ្មោះ ស៊ិន សុខគឿន ឈ្មោះ ងួន សុម៉ាលី ឈ្មោះ គ្រី ស្រីលក្ខ ឈ្មោះ អ៊ឹង លីតាំង និងឈ្មោះ អ៊ឹង ប៊ុនតុង នៅរាជធានីភ្នំពេញ ស្នើសុំជួយអន្តរាគមន៍ករណីក្រុមហ៊ុនហ្វូហាយអ៊ីនវេសមិន បានឈូសឆាយរបង ផ្ទះ ដំណាំ លើដីរបស់ពួកគាត់សរុបទំហំ២៨,៥១៩ម៉ែត្រការ៉េ ស្ថិតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺរដ្ឋបាលខេត្តព្រះសីហនុ។

២៥.ឈ្មោះ ព្រំ សុម៉ាលី ឈ្មោះ ឈុន សុគន្ធារី និងឈ្មោះ អ៊ុក សារ៉ែន តំណាងប្រជាពលរដ្ឋ ចំនួន ១០គ្រួសារ នៅភូមិ៣ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ស្នើសុំជួយអន្តរាគមន៍យកដីទំហំ៤៦ម៉ែត្រការ៉េ មកដាក់ជាដីសាធារណៈរបស់រដ្ឋដូចដើមឡើងវិញ ដែលកន្លងមកឈ្មោះ ទៀង សុផាត និងប្រពន្ធឈ្មោះ សុខ គីមលាង នៅភូមិ៣ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ បានឃុបឃិតគ្នាធ្វើប័ណ្ណយកជាកម្មសិទ្ធិផ្ទាល់ខ្លួន។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺរដ្ឋបាលខេត្តព្រះសីហនុ។

២៦.ឈ្មោះ ធីម ថារី ជាប្រពន្ធឈ្មោះ ឡេង ប៊ុនធឿន (ស្លាប់) ឈ្មោះ ហង្ស ម៉ាលី និងប្រជាពលរដ្ឋរងគ្រោះចំនួន១៤គ្រួសារ នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្តឹងឈ្មោះ ឌី ជុំ ឈ្មោះ កែវ ចាន់ ឈ្មោះ ប៉ុក ឌុក ឈ្មោះ សុខ ឡី ឈ្មោះ ហាវ ស្រី ឈ្មោះ ឈុន ថាន់ ឈ្មោះ សំ សេង ឈ្មោះ ថន វណ្ណៈ ឈ្មោះ សុន សិទ្ធិរ៉ា ឈ្មោះ កែវ ស្រីម៉ាច និងឈ្មោះ តល លន ជាម្ចាស់ក្រុមហ៊ុនលនស៊ីធី ដែលបានឃុបឃិតគ្នារំលោភយកដីរបស់ពួកគាត់ ទំហំ៣០,០០០ម៉ែត្រការ៉េ ស្ថិតនៅភូមិចំណោតរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺរដ្ឋបាលខេត្តព្រះសីហនុ។

២៧.ឈ្មោះ អ៊ូ ក្រូច នៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ស្នើសុំជួយអន្តរាគមន៍ដោះស្រាយបញ្ចប់ទំនាស់ដីធ្លីរបស់គាត់ ជាមួយឈ្មោះ សៅ ប៊ុនរ៉េត ដែលមានទំហំ ១១ម៉ែត្រ គុណនឹង ២២ម៉ែត្រ ស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ករណីនេះបានបញ្ចប់ ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ គឺរដ្ឋបាលខេត្តបន្ទាយមានជ័យ។

២៨.ឈ្មោះ អឿង សារី ឈ្មោះ កៅ កុសល ឈ្មោះ សួង ពៅ ឈ្មោះ ទូន វណ្ណៈ ឈ្មោះ ណៃ ភន ឈ្មោះ ជួន សុខលី ឈ្មោះ បូ លាប ឈ្មោះ ឃឹម ម៉ាលី និងឈ្មោះ សេង ឡេង (៩គ្រួសារ) តំណាងឱ្យប្រជាពលរដ្ឋចំនួន ១២១គ្រួសារ នៅឃុំបឹងខ្យាង និងឃុំព្រែកស្តែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ស្នើសុំជួយអន្តរាគមន៍សម្របសម្រួល ដល់ក្រុមហ៊ុនOCIC និងក្រុមហ៊ុនCAIC ជាក្រុមហ៊ុនសាងសង់ព្រលានយន្តហោះភ្នំពេញថ្មី ឱ្យទិញដីកម្មសិទ្ធិរបស់ប្រជាពលរដ្ឋតាមតម្លៃទីផ្សារ មុនឈូសឆាយដី របស់ប្រជាពលរដ្ឋ។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺរដ្ឋបាលខេត្តកណ្តាល។

២៩.ឈ្មោះ អ៊ឹម តារ៉ា ឈ្មោះ គង់ យន ឈ្មោះ ឆន ចាន់ថុល ឈ្មោះ ខាត់ លៀន ឈ្មោះ ប៉ាង សំបូរ ឈ្មោះ ម៉ាក់ ម៉ៅ ឈ្មោះ មុយ ប៉េងឡៃ ឈ្មោះ សេង ផេង និងឈ្មោះ ផាត សុខ តំណាងប្រជាពលរដ្ឋចំនួន ៣០៨គ្រួសារ នៅឃុំព្រែកស្ដែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល និងឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ ស្នើសុំជួយអន្តរាគមន៍ដោះស្រាយដីរបស់ប្រជាពលរដ្ឋទំហំ១២៧ហិកតា ដែលកំពុងមានវិវាទជាមួយក្រុមហ៊ុនOCIC ជាក្រុមហ៊ុនម៉ៅការសាងសង់ព្រលានយន្តហោះភ្នំពេញថ្មី។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺរដ្ឋបាលខេត្តកណ្ដាល និងខេត្តតាកែវ។

៣០.ឈ្មោះ ហ៊ឹម ប៊ុនហេង ឈ្មោះ គង់ ចាន់ និងឈ្មោះ ង៉ាន សុគុន នៅភូមិតានួន ឃុំពោធិ៍ម្រាល ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ស្នើសុំជួយអន្តរាគមន៍ដើម្បីរក្សាផ្ទៃបឹងតានួន និងបឹងតាដែង ស្ថិតនៅភូមិតានួន ភូមិតាដែងថ្មី ភូមិតាដែងចាស់ ឃុំពោធិ៍ម្រាល ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺរដ្ឋបាលខេត្តកំពង់ស្ពឺ។

៣១.ឈ្មោះ កឹម ចន្ថា នៅផ្ទះលេខ១០៩-១១១E1 មហាវិថីព្រះសីហនុ កែងផ្លូវសុកហុក សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ ស្នើសុំជួយអន្តរាគមន៍ទៅរដ្ឋបាលខេត្តសៀមរាប ឱ្យអភិវឌ្ឍន៍ផ្លូវតាមប្លង់ចាស់ ករណីលោកជំទាវ អ៊ឹង កន្ថាផាវី សង់ផ្ទះកណ្ដាលផ្លូវ ហើយធ្វើបេងបិទផ្លូវ ដើម្បីភ្ជាប់ដីឡូតិ៍ខាងផ្លូវមាត់ស្ទឹង និងដីឡូតិ៍ខាងក្រោយផ្ទះរបស់គាត់ឱ្យបានធំ។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺរដ្ឋបាលខេត្តសៀមរាប។

៣២.ឈ្មោះ សៅ ធិន នៅភូមិក្បាលដំរី ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ប្ដឹងឈ្មោះ ខេន បូផា នៅភូមិក្បាលដំរី ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ បានរំលោភយកព្រំដីរបស់គាត់ ក្បាលទំហំ៦ម៉ែត្រ x ១៣០ម៉ែត្រ ដែលមានលេខក្បាលដី២៨ ស្ថិតនៅភូមិក្បាលដំរី ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ ករណីនេះបានបញ្ចប់ ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ គឺសាលាដំបូងខេត្តកំពង់ស្ពឺ។

៣៣.រដ្ឋបាលសង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ស្នើសុំជួយអន្តរាគមន៍ដោះស្រាយបញ្ហាទំនាស់ដីធ្លីរបស់ឈ្មោះ សុង សាម៉ុញ និងឈ្មោះ ស៊ីន វ៉ាន់សាយ ដែលឈ្មោះ ដួង ស្រេង បានរំលោយយកទៅលក់ ស្ថិតនៅភូមិលើ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺគណៈកម្មាធិការគ្រប់គ្រង និងដោះស្រាយទំនាស់ដីធ្លីខេត្តស្ទឹងត្រែង។

៣៤.ឈ្មោះ មុំ ប៊ុនសេង ឈ្មោះ សូ សាខែម និងឈ្មោះ ម៉ា ប៊ុនសឿន ស្នើសុំជួយអន្តរាគមន៍ និងធ្វើការដោះស្រាយករណីឈ្មោះ ទូច រដ្ឋា ហៅ(ធី) នៅខេត្តរតនគិរី បានប្ដឹងទៅសាលាដំបូងខេត្តស្ទឹងត្រែង ដោយចោទប្រកាន់ពួកគាត់ថាបានរំលោភកាន់កាប់ដីរបស់ឈ្មោះ ទូច រដ្ឋា ហៅ(ធី) ដោយខុសច្បាប់ ស្ថិតនៅភូមិបាចុង សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។ ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយគឺគណៈកម្មាធិការគ្រប់គ្រង និងដោះស្រាយទំនាស់ដីធ្លីខេត្តស្ទឹងត្រែង។

៣៥.ឈ្មោះ យឹម ផល្លា នៅផ្ទះលេខ៧០ ផ្លូវលេខ១៩៩០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ស្នើសុំជួយអន្តរាគមន៍ដោះស្រាយលើដីមួយកន្លែង ស្ថិតនៅភូមិត្រពាំងស្នោរ ឃុំម្កាក់

ស្រុកអង្គស្នួល ខេត្តកណ្តាល ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវតាមច្បាប់ លើទំហំដីដែលស្របតាមគំនូសប្លង់ដី លេខ៤៦២/០៨ បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៨។ ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល។

៣៦.ឈ្មោះ ឆាយ ខេង នៅភូមិព្រៃស្លឹក សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ កាំង ច័ន្ទសុវណ្ណ នៅភូមិក្បាលទំនប់ សង្កាត់បឹងទំពន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ បានរំលោភយក ដីលំនៅដ្ឋានរបស់គាត់ និងលួចធ្វើប័ណ្ណកម្មសិទ្ធិដែលមានផ្ទៃដីទំហំ៥ម៉ែត្រx១៥ម៉ែត្រ ស្ថិតនៅភូមិ កំណប់ ឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល។

៣៧.ឈ្មោះប៉ាវ សុផល នៅភូមិតានី ឃុំក្រាំងចេក ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ងីន គីមសេង នៅភូមិក្រាំងចេក ឃុំក្រាំងចេក ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ បានរំលោភយកដីចំណីផ្លូវ សាធារណៈជាប់ពីមុខដីស្រែរបស់គាត់ទំហំប្រហែល១០ម៉ែត្រx២៥ម៉ែត្រ ស្ថិតនៅភូមិក្រាំងចេក ឃុំក្រាំង ចេក ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។ ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល។

៣៨.ឈ្មោះ ម៉េង ណារី នៅភូមិត្រពាំងទ្រា សង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិ៍សែនជ័យ រាជធានី ភ្នំពេញ ប្តឹងឈ្មោះ គូ ចាន់ នៅភូមិឆ្លេន ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ មិនព្រមប្រគល់ដី ឱ្យគាត់តាមកិច្ចសន្យាលក់-ទិញ ដែលមានទំហំ១០ម៉ែត្រx២០ម៉ែត្រ ស្ថិតនៅភូមិអំពិលទឹក ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល។

៣៩.ឈ្មោះ រ៉ែន កូឡាប នៅភូមិតានៃ ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ គុះ ស៊ីង ជាមេភូមិតានៃ ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ មិនព្រមចុះហត្ថលេខាលើលិខិតទិញ-លក់ដី ជាកម្មសិទ្ធិរបស់គាត់ដែលមានទំហំ២,១០០ម៉ែត្រការ៉េ ស្ថិតនៅភូមិតានៃ ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល។

៤០.ឈ្មោះ ទេស សារីន ប្រពន្ធឈ្មោះខៀវ ពុធលី និងឈ្មោះ ខៀវ ស្រពៅ ប្តីឈ្មោះ លឹម នឿន (ស្លាប់) នៅភូមិព្រៃរពេង ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ឡុច ចាន់រ៉ា និងឈ្មោះ ឆោម ច័ន្ទវិចិត្រ អគ្គនាយកក្រុមហ៊ុនD.H Master Land ស្ថិតនៅភូមិស្រុកធំ ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មិនព្រមប្រគល់ប្រាក់ថ្លៃទិញ-លក់ដី ឱ្យពួកគាត់ទាំងពីរគ្រួសារតាមកិច្ចសន្យា ដែលមាន ទំហំ១០,៣២៧ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃរពេង ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ករណីនេះបាន បញ្ចប់ដោយការសម្របសម្រួល។

៤១.ឈ្មោះ សុខ ឡាង នៅផ្ទះ២២៦អឺ០ ផ្លូវលេខ២១៧ ភូមិ៥ សង្កាត់អូរឫស្សីទី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ ប្តឹងឈ្មោះ ហេង ឡាយជា នៅភូមិតាងៅ ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បាន រៀបដីលក់ឱ្យគាត់ទំហំប្រហែល ២ហិកតា ស្ថិតនៅភូមិត្រាវ ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ក៏ប៉ុន្តែមិនមានដីប្រគល់ឱ្យគាត់ និងមិនព្រមប្រគល់ប្រាក់បានកក់ទ្រនាប់ដៃឱ្យគាត់វិញ។ ករណីនេះ បានបញ្ចប់ដោយការសម្របសម្រួល។

៤២.ឈ្មោះ ស៊ីង រស្មី នៅភូមិថ្មី ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ជ័យ ហឹម មេឃុំចំបក់ ឈ្មោះ ម៉ម សំអាត អនុប្រធានភូមិថ្មី ឈ្មោះ ប៉ាង ស៊ុន ជំទប់ទី២ឃុំចំបក់ ឈ្មោះ ឃិន យ៉េត មេភូមិបន្ទាយរកា ឃុំក្រាំងដីវ៉ាយ ឈ្មោះ វល្លិ៍ ខាំ អតីតមេឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ បាន ឃុបឃិតគ្នារំលោភយកដីរបស់គាត់ទំហំ ប្រហែល៤៥ហិកតា យកទៅលក់ ស្ថិតនៅភូមិថ្មី ឃុំចំបក់ និង

ភូមិបន្ទាយរកា ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ករណីនេះបានបញ្ចប់ដោយការសម្រុះសម្រួល។

៤៣.ឈ្មោះ យួន សុន ឈ្មោះ សាយ រិទ្ធ ឈ្មោះ គង់ គីម និងប្រពន្ធឈ្មោះ យួន សុខា និងឈ្មោះ ឈា សំណាង និងប្រពន្ធឈ្មោះ យួន ចាន់ណា ទាំងបួនគ្រួសារនៅភូមិកប់ចិន ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ សុខ ចន្ទី និងប្រពន្ធឈ្មោះ លី លឹម នៅភូមិ-ឃុំខាងលើ បានរំលោភយកដីរបស់ពួកគាត់ទាំងបួនគ្រួសារ ដោយមិនព្រមប្រគល់នូវប្រាក់បង្គ្រប់ថ្លៃលក់-ទិញដី ដែលមានទំហំសរុប ១៧,១៩៨ម៉ែត្រការ៉េ ស្ថិតនៅភូមិកប់ចិន និងភូមិត្រពាំងកន្ទួត ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ ករណីនេះបានបញ្ចប់ដោយការសម្រុះសម្រួល។

៤៤.ប្រជាពលរដ្ឋចំនួន៥នាក់ តំណាងឱ្យប្រជាពលរដ្ឋចំនួន៧៥គ្រួសារ ប្តឹងឈ្មោះ យ៉ន់ ហួន មេភូមិធ្និកជ្រុំ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប បានជំរិតទារប្រាក់ជាថ្នូរនឹងការចុះហត្ថលេខាបញ្ជាក់លើលិខិតស្នាមលក់-ទិញដី និងជាថ្នូរផ្សេងៗ។ ករណីនេះក្រុមការងារបានសង្កេតឃើញថា ដីដែលមានក្នុងបណ្តឹងខាងលើនេះ ស្ថិតនៅក្នុងដែនជំរកសត្វព្រៃគូលែនព្រហ្មទេព គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដីទាំងអស់មិនទាន់ស្របច្បាប់ ខាងជំនាញបរិស្ថានរក្សាទុក រង់ចាំការសម្រេច ពីរាជរដ្ឋាភិបាល តែបច្ចុប្បន្នចាត់ទុកជាទ្រព្យសម្បត្តិរដ្ឋ លើកលែងតែមានបទបញ្ជាលេខ០១។ ជាចុងបញ្ចប់តំណាងប្រជាពលរដ្ឋចំនួន៥គ្រួសារ បានឯកភាពគ្នាបញ្ចប់បណ្តឹងខាងលើដោយបានព្រមព្រៀង និងសុខចិត្តយកតាមការបកស្រាយខាងលើរបស់ក្រុមការងារ។

៤៥.ឈ្មោះ សាន្ត ម៉ារ៉ែន ឈ្មោះ គួន វណ្ណា និងឈ្មោះ អេវ ពៅ តំណាងប្រជាពលរដ្ឋនៅភូមិព្រៃផ្ការ ឃុំនាម ស្រុកទ្រាំង ខេត្តតាកែវ ប្តឹងឈ្មោះ យិន ផន នៅភូមិ-ឃុំជាមួយគ្នា បានលួចធ្វើរបងព័ទ្ធយកស្រះទឹករួមភូមិ ទៅធ្វើជារបស់បុគ្គលឯកជនផ្ទាល់ខ្លួន។ ករណីនេះភាគីទាំងពីរបានឯកភាពគ្នា ទទួលយកលទ្ធផលនៃការចុះវាស់វែងជាក់ស្តែងពីមន្ត្រីជំនាញ ដើម្បីបញ្ចប់ទំនាស់។

៤៦.ឈ្មោះ គៀត មុំ នៅភូមិប្រុំ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ តំណាងឱ្យបងប្អូនបង្កើតឈ្មោះ គៀត ហឿន ឈ្មោះ គៀត សុភាព និងឈ្មោះ គៀត ឈាវ ស្នើសុំជួយអន្តរាគមន៍ករណីឈ្មោះ គៀត ជឿន និងឈ្មោះ គៀត វុត (ត្រូវជាបងប្អូនបង្កើត) និងឈ្មោះ ជុំ ពៅ (ជាអ្នកទិញ) បានឃុបឃិតគ្នាធ្វើការទិញ-លក់ដីកេរ្តិ៍ឪពុកម្តាយ និងលួចធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនទ្រព្យ ដោយគ្មានការយល់ព្រមពីបងប្អូនទាំងអស់គ្នា។ ករណីនេះការទិញ-លក់បានដំណើរការតាមការព្រមព្រៀងស្របតាមនីតិវិធីច្បាប់ ដោយមានការឯកភាពពីភាគីអ្នកទិញ-អ្នកលក់ មានការដឹងឮទទួលស្គាល់ពីអាជ្ញាធរភូមិ-ឃុំ និងជំនាញភូមិបាលស្រុកផង។

៤៧.ឈ្មោះ ផាត់ ម៉ុន នៅភូមិប្រច័ក្ស ឃុំព្រៃមូល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ប្តឹងឈ្មោះ យួន ទ្រី នៅខេត្តតាកែវ បានគំរាមកំហែងឱ្យគាត់ប្រគល់ដីដែលគាត់ បានកាន់កាប់តាំងពីឆ្នាំ១៩៩៨ រហូតដល់បច្ចុប្បន្ន និងមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៤០៦០៩០៥-០១៥៥ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៧ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង ស្ថិតនៅភូមិត្រពាំងតាសុខ ឃុំព្រៃមូល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ ករណីនេះភាគីទាំងពីរបានព្រមព្រៀងគ្នាបញ្ចប់ទំនាស់ ដោយបំបែកក្បាលដីជាពីរ ចែកគ្នាពាក់កណ្តាលម្នាក់ ចំពោះការចំណាយទាំងអស់ឈ្មោះ យួន ទ្រី ជាអ្នកចេញចំណាយ។

៤៨-ឈ្មោះ ទាំ សារី និងប្រពន្ធឈ្មោះ រូន ម៉ារី នៅភូមិក្រសះថ្មី ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ស្នើសុំជួយដោះស្រាយទំនាស់ដីធ្លីជាមួយក្រុមហ៊ុនសុខ ម៉ៅ ចំនួន៤កន្លែង ស្ថិតនៅភូមិក្រសះថ្មី ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ ករណីនេះភាគីទាំងពីរបានព្រមព្រៀងគ្នាបញ្ចប់ទំនាស់ ដោយភាគីក្រុមហ៊ុន សុខ ម៉ៅ ដោះស្រាយគោលនយោបាយជូនភាគី ឈ្មោះ ទាំ សារី និងប្រពន្ធឈ្មោះ រូន ម៉ារី ចំនួន៥០,០០០ដុល្លារអាមេរិក។ ចំណែក ភាគីឈ្មោះ ទាំ សារី និងប្រពន្ធឈ្មោះ រូន ម៉ារី យល់ព្រមដកពាក្យបណ្តឹងពីគ្រប់ស្ថាប័នទាំងអស់។

## ៤.សកម្មភាពការងារសវនកម្មផ្ទៃក្នុង

-បានចុះធ្វើសវនកម្មលើការដឹកនាំ និងការគ្រប់គ្រងធនធានមនុស្ស ទ្រព្យសម្បត្តិរដ្ឋ ការប្រើប្រាស់ចំណូល-ចំណាយថវិការដ្ឋ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាផ្នាំពាក់ព័ន្ធ នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពត ព្រះសីហនុ កំពង់ឆ្នាំង ពោធិ៍សាត់ ត្បូងឃ្មុំ ក្រចេះ កំពង់ធំ សៀមរាប បាត់ដំបង ប៉ៃលិន និងខេត្តឧត្តរមានជ័យ។

-បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការណែនាំធ្វើសវនកម្មសាកល្បង លើបច្ចេកវិទ្យាព័ត៌មាន តាមប្រព័ន្ធអនឡាញ(ZOOM)។

-បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីនៃការអនុវត្តការងារសវនកម្មផ្ទៃក្នុង តាមប្រព័ន្ធអនឡាញ(ZOOM)។

-បានចូលរួមសិក្ខាសាលា ស្តីពីការពង្រឹងគណនេយ្យភាពសវនកម្មផ្ទៃក្រៅ និងផ្ទៃក្នុង នៃព្រះរាជាណាចក្រកម្ពុជា តាមប្រព័ន្ធអនឡាញ(ZOOM)។

-បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយការអនុវត្តកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគោលការណ៍ណែនាំសវនកម្មលើបច្ចេកវិទ្យាព័ត៌មាន នៅសណ្ឋាគារសុខាភ្នំពេញ។

-បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មានដោយផ្ទាល់ នៅសណ្ឋាគារភ្នំពេញ និងចូលរួមតាមប្រព័ន្ធអនឡាញ(ZOOM)។

## ៥.សកម្មភាពការងារវិទ្យាស្ថានជាតិអធិការកិច្ច

-បានពង្រឹងការគ្រប់គ្រងរដ្ឋបាល និងចរន្តការងារទូទៅ របស់វិទ្យាស្ថាន។

-បានស្រាវជ្រាវ និងរៀបចំចងក្រងជាសៀវភៅស្តីពីរបៀបប្រើប្រាស់កម្មវិធីZoom និងGoogle Meet។

-បានស្រាវជ្រាវ និងចងក្រងអនុសាសន៍សម្តេចតេជោសរុបចំនួន១៤០ច្បាប់ និងស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តនានាសរុបចំនួន៩១៣ច្បាប់។

-បានបង្កើតក្រុមគ្រូបង្គោលជំនាញវិជ្ជាជីវៈអធិការកិច្ចចំនួន៩រូប សម្រាប់វិទ្យាស្ថាន។

-បានធ្វើរបាយការណ៍សម្រង់ទិន្នន័យមន្ត្រីអធិការកិច្ចបានទទួល និងមិនទាន់បានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចគោរពជូនរដ្ឋមន្ត្រី។

-បានចុះស្ទង់មតិអំពីការគ្រប់គ្រង និងការអភិវឌ្ឍការងារអធិការកិច្ច នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន៥ខេត្ត។

-បានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចបឋមជំនាន់៤ បានចំនួន៥វគ្គ ដល់មន្ត្រីរាជការចំនួន១៥០ រូប ដែលមកពីក្រសួងទរពអ និងក្រសួង-ស្ថាប័នផ្សេងៗចំនួន១៦។

-បានធ្វើសម្រង់ស្ទង់មតិយោបល់សិក្ខាកាមចំនួន២លើក អំពីការវាយតម្លៃវគ្គបណ្តុះបណ្តាល និងគ្រូឧទ្ទេសនាម។

-បានទទួលសៀវភៅអានចម្រុះចំនួន៥១៥ក្បាល និងបោះពុម្ពសៀវភៅចំនួន ៣២ក្បាលបន្ថែមដាក់ក្នុងបណ្ណាល័យវិទ្យាស្ថាន។

-បានចុះស្រាវជ្រាវស្ទង់មតិស្តីពីវឌ្ឍនភាពការងារមន្ត្រីរាជការ ដែលបានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ច នៅតាមមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅតាមបណ្តាខេត្តចំនួន៦ខេត្ត។

-បានចូលរួមផ្សព្វផ្សាយបន្តក្នុងផេករបស់វិទ្យាស្ថានជាប្រចាំ នូវសកម្មភាពការងារថ្នាក់ដឹកនាំក្រសួងការងាររបស់វិទ្យាស្ថាន និងសេចក្តីណែនាំ វិធានការ លិខិតបទដ្ឋានផ្សេងៗ របស់ក្រសួងសុខាភិបាលពាក់ព័ន្ធនឹងការការពារ និងបង្ការការចម្លងជំងឺកូវីដ-១៩ ព្រមទាំងវិធានការ ៣ការពារ និង៣កុំ របស់រាជរដ្ឋាភិបាល ក្នុងអំឡុងបុណ្យកាន់បិណ្ឌ។

-បានផ្តល់ព័ត៌មាន ណែនាំ និងក្រើនរំលឹកមន្ត្រីរាជការនៃវិទ្យាស្ថាន ក្នុងការការពារសុខភាព រួមទាំងការការពារការចម្លងវីរុសកូវីដ-១៩ និងជំងឺអុតស្វាជាប្រចាំ។

# ៦.សកម្មភាពការងារផ្សេងៗ

## ៦.១.សកម្មភាពការងារយេនឌ័រ

-ក្រោយបរិបទកូវីដ-១៩ ថ្នាក់ដឹកនាំជាស្ត្រីត្រូវបានតែងតាំង ជារដ្ឋលេខាធិកាចំនួន១រូប អនុរដ្ឋលេខាធិការចំនួន១រូប និងជាប្រធាននាយកដ្ឋានចំនួន១រូប។

-សមាសភាពស្ត្រីក្នុងមុខតំណែងរួមមាន៖ នៅថ្នាក់កណ្តាល ស្ត្រីជារដ្ឋលេខាធិការ ចំនួន៦រូប ទីប្រឹក្សាក្រសួង ចំនួន២៧រូប អនុប្រធាននាយកដ្ឋានចំនួន២១រូប ប្រធានការិយាល័យចំនួន១០រូប អនុប្រធានការិយាល័យ ចំនួន៦៣រូប និងថ្នាក់រាជធានី-ខេត្ត ស្ត្រីជាប្រធានមន្ទីរចំនួន២រូប អនុប្រធានមន្ទីរចំនួន៣រូប ប្រធានការិយាល័យចំនួន៩រូប អនុប្រធានការិយាល័យចំនួន១៤រូប។ បើគិតជាភាគរយ នៅទីស្តីការក្រសួង និងមន្ទីររាជធានី-ខេត្ត មន្ត្រីរាជការជាស្ត្រី ក្នុងមុខតំណែងធៀបទៅនឹងឆ្នាំ២០២១ គឺមានការកើនឡើង៣៣%។

-លោកជំទាវប្រធានក្រុមការងារបច្ចេកទេសយេឌ័របានសួរសុខទុក្ខផ្ទាល់ និងចាត់ប្រតិភូចុះសួរសុខទុក្ខមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រី បានសម្រាលមាតុភាពចំនួន៦រូប និងឧបត្ថម្ភថវិកា

សរុបចំនួន៤,២០០,០០០រៀល ក្នុងនោះថវិកាផ្ទាល់របស់លោកជំទាវកិត្តិសង្គហបណ្ឌិតឧបនាយករដ្ឋមន្ត្រី ឧបត្ថម្ភ ក្នុង១នាក់ចំនួន៥០ម៉ឺនរៀល ស្មើនឹងថវិកាសរុប ចំនួន៣,០០០,០០០រៀល និងថវិការបស់ក្រុមការងារយេនឌ័រប្រចាំក្រសួងឧបត្ថម្ភក្នុងម្នាក់ចំនួន២០ម៉ឺនរៀល សរុបថវិកា ចំនួន ១,២០០,០០០រៀល បន្ថែមលើថវិកាឧបត្ថម្ភតាមរបបមាតុភាព។

-បានឧបត្ថម្ភថវិកាចំនួន២០០,០០០រៀល ជូនគ្រួសារមន្ត្រីជាប់កិច្ចសន្យាទទួលមរណៈភាព ចំនួន១រូប។

-ដោយការរីករាលដាលជំងឺកូវីដ-១៩ ក្រុមការងារបច្ចេកទេសយេនឌ័រ ពុំបានប្រារព្ធខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២២ ក្រោមប្រធានបទ «សមភាពយេនឌ័រថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត» ប៉ុន្តែលោកជំទាវកិត្តិសង្គហបណ្ឌិតឧបនាយករដ្ឋមន្ត្រី និងក្រុមការងារបច្ចេកទេសយេនឌ័រ បានយកចិត្តទុកដាក់ ឧបត្ថម្ភថវិកាចំនួន៥ម៉ឺនរៀល និងវត្ថុអនុស្សាវរីយ៍ ជូនថ្នាក់ដឹកនាំ ទីប្រឹក្សា មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យាជាស្ត្រីទាំងអស់។ លោកជំទាវកិត្តិសង្គហបណ្ឌិតឧបនាយករដ្ឋមន្ត្រី មានទឹកចិត្តដ៏ថ្លៃថ្លា បានឧបត្ថម្ភថវិកាចំនួន៥ម៉ឺនរៀល ជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាជាបុរសក្នុងម្នាក់ៗ។

-បានចូលរួមអមដំណើរជាមួយលោកជំទាវកិត្តិសង្គហបណ្ឌិតឧបនាយករដ្ឋមន្ត្រីទៅធ្វើទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម។

-បានចូលរួមប្រជុំនៅក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ក្រុមការងារបច្ចេកទេសយេនឌ័រអន្តរក្រសួង។

-បានចូលរួមវគ្គបណ្តុះបណ្តាល «ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍» វគ្គការលើកកម្ពស់ភាពជាអ្នកដឹកនាំជាស្ត្រី សិល្បៈនៃការប្រាស្រ័យទាក់ទង ប្រកបដោយឥទ្ធិពល និងវគ្គបណ្តុះបណ្តាលភាសាចិនតាមអនឡាញ។

## ៦.២.សកម្មភាពការងារចងសម្ព័ន្ធមេត្រីភាព

ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងតំណាងក្រុមហ៊ុនម៉ុង ឫទ្ធីគ្រុប បានចុះសួរសុខទុក្ខ និងនាំយកនូវអំណោយជាថវិកា សម្ភារ និងគ្រឿងឧបភោគបរិភោគ ជូនកងកម្លាំងជួរមុខវរសេនាតូចនគរបាលការពារព្រំដែនទឹកលេខ២៦៩ និងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨២៧ នៃគណៈបញ្ជាការនគរបាលជាតិប្រចាំទិសភូមិភាគ៣ រួមមាន៖ អង្ករចំនួន២០តោន ត្រីខកំប៉ុងចំនួន៥០កេស មីជាតិចំនួន៤០០កេស ផ្លែប៉ូវចំនួន ៤០០ គីឡូក្រាម សៀវភៅផ្អែមចំនួន៤០០ដប ទឹកត្រីចំនួន៤០០កេស ទឹកស៊ីអ៊ីវចំនួន២០០យួរ ទឹកបរិសុទ្ធចំនួន៤០០យួរ ម៉ាសចំនួន១២កេសធំ អាល់កុលចំនួន៥០០ដប ក្រម៉ាចំនួន៣៥០ក្រម៉ា និងថវិកាចំនួន ៥០,២៨០,០០០រៀល គឺសរុបការឧបត្ថម្ភទាំងអស់គិត ជាទឹកប្រាក់មានចំនួន ៨០,២៨០,០០០រៀល និងចំនួន១១,០០០ដុល្លារអាមេរិក។

## ៦.៣. សមាគមសង្គហមិត្តភាព

-ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២២ សមាជិក សមាជិកា សមាគមសង្គហមិត្តភាពមានចំនួន ៤៣៧នាក់ ថ្នាក់កណ្តាលមានចំនួន១៤នាយកដ្ឋាន វិទ្យាស្ថានជាតិអធិការកិច្ច សមាជិកផ្សេងៗ និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន២៥រាជធានី-ខេត្ត មានចំនួន២៥១នាក់។

-សមាគមសង្គហមិត្តភាពក៏បានឧបត្ថម្ភប្រាក់ជូនដល់មន្ត្រីរាជការ ដែរទទួលមរណភាពចំនួន២ នាក់ គឺលោក ឃូ វិចិត្រ អនុប្រធានការិយាល័យសវនកម្មទី១ នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងលោក ម៉ៅ ស៊ិនណាក់ អនុប្រធាន នាយកដ្ឋានផែនការ និងស្ថិតិ។

## ៦.៤.សកម្មភាពការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង

បានស្នើសុំគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនក្រសួងចំនួន១៥៩នាក់។

## ៦.៥.សកម្មភាពការងារក្រុមការងារសម្រង់ព័ត៌មាន និងខ្លឹមសារអនុសាសន៍របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី និងឥស្សរជនជាន់ខ្ពស់

-ក្រុមការងារបានដកស្រង់ និងចងក្រងអនុសាសន៍សម្តេចតេជោនាយករដ្ឋមន្ត្រី បានដាក់ចេញជាបន្តបន្ទាប់តាមរយៈការថ្លែងសុន្ទរកថានៅក្នុងពិធីផ្សេងៗ សរុបចំនួន១០០លើក រួមមាន៖ ខែមករាចំនួន៤លើក ខែកុម្ភៈ ចំនួន១១លើក ខែមីនាចំនួន៦លើក ខែមេសាចំនួន១០លើក ខែឧសភា ចំនួន៨លើក ខែមិថុនាចំនួន៤លើក ខែកក្កដា ចំនួន៥លើក ខែសីហាចំនួន៧លើក ខែកញ្ញាចំនួន៦លើក ខែតុលាចំនួន១៨លើក ខែវិច្ឆិកាចំនួន១១លើក និងខែធ្នូ ចំនួន១០លើក។

-ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសរុបចំនួន៨ រួមមាន៖ (១) ខែមករាចំនួន១ គឺសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ ស្តីពីការកំណត់យកទិវានយោបាយឈ្នះ ឈ្នះ ថ្ងៃទី២៩ ខែធ្នូ ទៅក្នុងប្រតិទិនប្រចាំឆ្នាំ ដោយមិនឈប់សម្រាក (២) ខែមេសាចំនួន១ គឺសេចក្តីប្រកាសព័ត៌មាន លេខ០២ ប្រកព របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីថ្ងៃសុក្រ ១៥រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ (៣) ខែមិថុនាចំនួន១ គឺអនុក្រឹត្យលេខ១២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត (៤) ខែកក្កដា ចំនួន១ គឺគណៈរដ្ឋមន្ត្រីអនុម័តទាំងស្រុងលើ សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ (៥) ខែសីហាចំនួន១ គឺព្រះរាជក្រមលេខ នស/រកម/០៨២២/០០៧ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២ ប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ ថ្មី (មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី(មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញ (៦) ខែកញ្ញា ចំនួន១ គឺសេចក្តីសម្រេចលេខ២៦២ សសរ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមការងារបង្ក្រាបការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ (៧) ខែតុលាចំនួន១គឺសេចក្តីសម្រេចលេខ២៦៧ សសរ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០២២ស្តីពីអន្តរាគមន៍គាំពារសង្គមដើម្បីឆ្លើយតបនឹងសម្ពាធអតិផរណា (៨) ខែ

វិច្ឆិកា ចំនួន១ គឺ ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

-អនុសាសន៍របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ធ្វើឡើងនៅរសៀលថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ក្នុងឱកាសអញ្ជើញបិទសន្និបាតបូកសរុបការងារឆ្នាំចាស់ និងលើកទិសដៅការងារឆ្នាំថ្មីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់រួមមាន៖

+សូមបន្តអនុវត្តផែនការចុះបញ្ជីដី រួមទាំងការចុះបញ្ជីដីរដ្ឋ ដីសាធារណរបស់រដ្ឋ ដីសម្បទានសេដ្ឋកិច្ច និងដីសហគមន៍ជនជាតិដើមភាគតិច ដើម្បីធានានូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ដែលជាទុនផ្តល់ដោយរាជរដ្ឋាភិបាលជូនប្រជាពលរដ្ឋសម្រាប់រស់នៅ ដាំដុះ និងវិនិយោគ ដើម្បីបង្កើតមុខរបរ និងបង្កើនប្រាក់ចំណូល។

+ត្រូវបន្តលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅមូលដ្ឋាន ជាពិសេសវិវាទដីធ្លីដើម្បីពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដី បង្កើតភាពសុខដុមរមនា-សង្គម បង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅតាមមូលដ្ឋាន និងឈានទៅ បង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

+ត្រូវបន្តពង្រីកវិសាលភាពនៃការអនុវត្តគម្រោងសាងសង់ស្ថានីយវាស់វែងអចិន្ត្រៃយ៍ ដោយផ្កាយរណបសម្រាប់ការគ្រប់គ្រងដី និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ឱ្យបានទូទាំងប្រទេស។

+ត្រូវពង្រឹងការអនុវត្តច្បាប់សំណង់ ទាំងលើការងារសាងសង់ និងការត្រួតពិនិត្យសំណង់ ដើម្បីធានាបង្កើនគុណភាព សុវត្ថិភាព និងសុខមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន។ ទន្ទឹមនោះ ត្រូវបន្តការយកចិត្តទុកដាក់ការពារសំណង់អគារបេតិកភណ្ឌ និងជំរុញការចុះបញ្ជីទីតាំងតំបន់ការពារបុរាណដ្ឋានជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

+សូមបន្តលើកទឹកចិត្ត និងគាំទ្រគម្រោងសាងសង់លំនៅឋានតម្លៃសមរម្យ សំដៅលើកកម្ពស់សិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលបានលំនៅឋានសមរម្យ។ បន្តអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ដើម្បីចែកដីជូនប្រជាពលរដ្ឋក្រីក្រដែលខ្វះដី និងបន្តអនុវត្តចែកដី និងផ្ទះជូនកងកម្លាំងប្រដាប់អាវុធកំពុងឈរជើងនៅតាមព្រំដែន។

+ត្រូវជំរុញការអភិរក្សនៅតំបន់រមណីយដ្ឋានអង្គរ ស្របគ្នានឹងការអភិវឌ្ឍនៅតំបន់អភិវឌ្ឍ រុនតាឯក និងតំបន់ពាក់ស្នែកជូនបងប្អូនប្រជាពលរដ្ឋ ដែលស្ម័គ្រចិត្តចាកចេញពីតំបន់រមណីយដ្ឋានអង្គរទៅតាំងទីលំនៅថ្មីនៅតំបន់នោះ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលនយោបាយគាំទ្រផ្នែកសង្គមកិច្ច និងផ្នែកហេដ្ឋារចនសម្ព័ន្ធ ដែលរាជរដ្ឋាភិបាល បានដាក់ចេញ។

+ត្រូវបន្តដោះស្រាយបញ្ហាជូនប្រជាជនដែលរស់នៅជាភូមិករនៅជុំវិញបឹងទន្លេសាប ដោយធ្វើបច្ចុប្បន្នភាពផែនទីតាមខេត្តនីមួយៗ កែសម្រួលព្រំប្រទល់តំបន់៣ ព្រំប្រទល់តំបន់២ និងកាត់ឆ្វៀលទីតាំងដី ដែលប្រជាជនរស់នៅពីយូរលង់មកហើយក្នុងតំបន់៣ និងតំបន់២ ឱ្យចប់នៅខែឧសភា ឆ្នាំ២០២៣។

+គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា និងគណៈកម្មាធិការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រខេត្តទាំង៤ ត្រូវជំរុញរៀបចំផែនការអភិរក្ស ការពារ និងអភិវឌ្ឍតំបន់ឆ្នេរដើម្បីគាំទ្រដល់ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ប្រកបដោយប្រសិទ្ធភាព

ចីរភាព និងសមធម៌ ឱ្យស័ក្តិសមជាឆ្នេរសមុទ្រដែលស្អាតបំផុតលើសាកលលោក និងជាតារារះនៅទិសនិរតី។

+សូមរួមគ្នាបន្តពង្រឹង និងកែលម្អការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ ដោយជំរុញអនុវត្តឱ្យបានតាមទិសស្លោក «ធ្វើឱ្យបាន ធ្វើឱ្យលឿន និងមានតម្លាភាព» ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងយកចិត្តទុកដាក់ដោះស្រាយរាល់សំណូមពរ និងខិតខំកាត់បន្ថយការថ្នាំងថ្នាក់របស់ប្រជាជន។

## ៦.៦.សកម្មភាពការងារគេហទំព័រ MONASRI.GOV.KH និង MONASRI App

-ក្រុមកាងារឌីជីថលបានចូលរួមសិក្ខាសាលាស្តីពីកម្មវិធីព័ត៌វិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅអង្គភាព- ការិយាល័យច្រកចេញចូលតែមួយ។

-ក្រុមការងារឌីជីថលបានចូលរួមសិក្ខាសាលាផ្សព្វផ្សាយគោលយោបាយរដ្ឋាភិបាលឌីជីថល។

-បានចូលប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីសេវាប្រៃសណីយ៍ តាមប្រព័ន្ធអនឡាញ។

-ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីតម្លាភាព នៃការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធ និងសារនយោបាយ និងការបោះឆ្នោតតាមប្រព័ន្ធទំនាក់ទំនងសង្គម នៅសណ្ឋាគារហៃយ៉ាត់រីជេនស៊ីភ្នំពេញ។

-ចូលរួមកិច្ចប្រជុំពិភាក្សាអំពីការរៀបចំការងារពាក់ព័ន្ធ និងបរិវត្តកម្មរដ្ឋាភិបាលឌីជីថល និងផែនការសកម្មភាពសម្រាប់ការងារបរិវត្តកម្មឌីជីក្នុងឆ្នាំ២០២៣-២០២៥ នៅទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

-ចូលរួមកម្មវិធីបណ្តុះបណ្តាលស្តីពី Cyber Essential-Be Digitally Ready to Reduce Your Risks រៀបចំ និងប្រព្រឹត្តទៅដោយក្រសួងឧស្សាហ៍កម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

-បានស្រាវជ្រាវឯកសារពាក់ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍។

-បានបញ្ចូលព័ត៌មាន សេចក្តីជូនដំណឹង និងឯកសារផ្សេងៗ ក្នុង វេបសាយ និងផេក។

-បានរៀបចំប្រព័ន្ធទទួលពាក្យបណ្តឹងតាមអនឡាញ។

-បានធ្វើការចុះផ្សាយព័ត៌មាន និងសកម្មភាពការងាររបស់ថ្នាក់នាំ និងស្ថាប័នក្រោមចំណុះឱ្យក្រសួងសរុបចំនួន៦១២ គឺលោកជំទាវឧបនាយករដ្ឋមន្ត្រីចំនួន២៦៩ ថ្នាក់ដឹកនាំក្រសួងចំនួន៨៤ វិទ្យាស្ថានជាតិអធិការកិច្ចចំនួន៤៥ មន្ទីរទេពអ រាជធានី-ខេត្តចំនួន១៦៤ និងលិខិតផ្សេងៗចំនួន៤៩។

-បានដឹកនាំក្រុមការងាររដ្ឋាភិបាលឌីជីថល ទៅចូលរួមពិភាក្សា អំពីការរៀបចំការងារពាក់ព័ន្ធនឹងបរិវត្តកម្ម រដ្ឋាភិបាលឌីជីថល និងផែនការសកម្មភាពការងារបរិវត្តកម្មឌីជីថលក្នុងឆ្នាំ២០២៣-២០២៥ ដឹកនាំដោយ ឯកឧត្តម ជា វ៉ាន់ដេត រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងនោះមានរបៀបវារៈចំនួន៦ រួមមាន៖ (១)ការបង្កើតអង្គភាពបរិវត្តកម្មឌីជីថល (២) តម្រូវការឧបករណ៍ និងកម្មវិធីឌីជីថល (កុំព្យូទ័រ Window Office ប្រព័ន្ធអ៊ីម៉ែល និង សុសវែរ) (៣) ការរៀបចំបណ្តាញតភ្ជាប់ឌីជីថល (៤) តម្រូវការមជ្ឈមណ្ឌលទិន្នន័យ (៥) ការបណ្តុះបណ្តាលសម្រាប់រដ្ឋាភិបាលឌីជីថល (៦) ការរៀបចំផែនការសកម្មភាពរបស់បណ្តាក្រសួង-ស្ថាប័ន សម្រាប់ការងារបរិវត្តកម្មឌីជីថល ក្នុងឆ្នាំ២០២៣-២០២៥។

-ដោយសារសម័យបច្ចុប្បន្នវិស័យបច្ចេកវិទ្យាមានការរីកចំរើនខ្លាំង ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងធនធានមនុស្ស និងដំណើរចរន្តការងារ ក្នុងអង្គភាពមានភាពងាយស្រួល និងរហ័សនោះ និងឱ្យស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថល របស់រដ្ឋាភិបាល ឯកឧត្តមរដ្ឋមន្ត្រី តម្រូវឱ្យក្រសួងស្ថានប័ននីមួយៗ គួរបង្កើតឱ្យមានអង្គភាពបរិវត្តកម្មឌីជីថលមួយដាច់ដោយឡែក ពីព្រោះថាអង្គភាពនេះ សម្រាប់តែអនុវត្តការងារឌីជីថល សម្រាប់ក្រសួង-ស្ថាប័ន។ គួរមានរៀបចំឱ្យមានជារចនាសម្ព័ន្ធចាត់តាំងការទទួលខុសត្រូវ តាមឋានានុក្រមមួយឱ្យបានត្រឹមត្រូវ។

## ៦.៧. ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ FMIS

ក្រុមការងារការកែទម្រង់ក្រសួង ក្នុងនោះ នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ និងមន្ត្រីបង្គោល បានរៀបចំរបាយការណ៍ប្រៀបធៀបផែនការ ចំណាយតាមកម្មវិធីប្រចាំ ត្រីមាសនីមួយៗ និងការអនុវត្តជាក់ស្តែង ដោយឆ្លុះបញ្ចាំងគោលដៅចំណាយក្នុងត្រីមាស រួមមានៈ

-ផែនការសាច់ប្រាក់របស់ក្រសួងប្រចាំត្រីមាសនីមួយៗ ត្រូវបានបញ្ចូលក្នុងប្រព័ន្ធCMS។

-ផែនការលទ្ធកម្មឆ្នាំ២០២៣ត្រូវបានរៀបចំ និងអនុម័តមុនថ្ងៃទី៣១ ខែធ្នូ២០២២។

-សេចក្តីជូនដំណឹងស្តីពីការចូលរួមដេញថ្លៃប្រកួតប្រជែងរបស់អង្គភាពលទ្ធកម្ម ឆមាសទី១-ទី២ ត្រូវបានផ្សព្វផ្សាយ។

-អង្គភាពលទ្ធកម្ម បានរៀបចំរបាយការណ៍កិច្ចលទ្ធកម្មក្រោមសិទ្ធិឆមាសទី១-ទី២ បញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ផែនការរដ្ឋទេយ្យបុរេប្រទានឆ្នាំ២០២៣ត្រូវបានអនុម័ត យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២២។

-បានទូទាត់ថវិការដ្ឋទេយ្យបុរេប្រទានប្រចាំត្រីមាស(ជុំទី១-៤) ឱ្យទាន់ពេលវេលា។

-នីតិវិធីចំណាយកម្រិត១ និងកម្រិត២ ត្រូវបានអនុវត្តតាមប្រព័ន្ធFMIS។

-កិច្ចការលទ្ធកម្មពេញលេញក្នុងឆមាសទី១-ទី២ ត្រូវបានក្រុមការងារFMIS បញ្ចូលក្នុងប្រព័ន្ធ។

-បានចូលរួមបណ្តុះបណ្តាលជាមួយក្រុមការងារFMIS ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-របាយការណ៍អនុវត្តថវិកាប្រចាំខែត្រីមាសនីមួយៗត្រូវបានផលិតចេញពីប្រព័ន្ធFMIS និងធ្វើដោយដៃ (Manual Ms Excel) ។

-បានរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋកើន ថយ ប្រចាំឆ្នាំ២០២២។

-ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងត្រូវបានអនុវត្ត តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-បានបញ្ចូលទិន្នន័យបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋក្នុង ប្រព័ន្ធប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (SARMIS)។

-បានពិនិត្យ និងរៀបចំរបាយការណ៍ចំនួនមន្ទីរ ដែលមិនទាន់មានប័ណ្ណកម្មសិទ្ធ។

-បានរៀបចំប្រកាសស្តីពីការកំណត់សមាសភាពទទួលខុសត្រូវលើកម្មវិធី និងអនុកម្មវិធី។

-របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធីប្រចាំត្រីមាសនីមួយៗត្រូវបានរៀបចំ និងបានផ្ញើជូនអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាកម្មវិធី លក្ខណៈសម្បត្តិរបស់អង្គភាពថវិកា និងបញ្ហាប្រឈម។

-ផែនការយុទ្ធសាស្ត្រអធិការកិច្ច ៣ឆ្នាំរំកិល ២០២៣-២០២៥ ត្រូវបានបញ្ចប់ និងអនុម័ត។

-ផែនការអធិការកិច្ចប្រចាំឆ្នាំ២០២៣ ត្រូវបានបញ្ចប់ និងអនុម័ត។

-ឯកសារក្របខណ្ឌគតិយុត្តិសម្រាប់អនុវត្តសវនកម្មសមិទ្ធកម្មត្រូវបានធ្វើបច្ចុប្បន្នភាព។

-របាយការណ៍សវនកម្មផ្ទៃក្នុងចំនួន៣សវនដ្ឋានត្រូវបានរំលេចនូវសូចនាករសមិទ្ធកម្ម។

បានរៀបចំសិក្ខាសាលាស្តីពីសវនកម្មលើបច្ចេកវិទ្យាព័ត៌មាន។

-នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងបានធ្វើរបាយការណ៍សវនកម្មផ្ទៃក្នុង ជូនអាជ្ញាធរសវនកម្មជាតិ។

-បានចុះធ្វើសវនកម្មផ្ទៃក្នុងនៅអង្គភាពជាតិ និងថ្នាក់ក្រោមជាតិ ទៅតាមផែនការ។

-បានចុះពិនិត្យតាមដាន អនុសាសន៍លើសវនដ្ឋាន។

-ផែនការយុទ្ធស្រ្តសវនកម្ម៣ឆ្នាំរំកិល ២០២៣-២០២៥ ត្រូវបានបញ្ចប់និងអនុម័ត។

-ផែនការសវកម្មផ្ទៃក្នុងឆ្នាំ២០២៣ត្រូវបានរៀបចំ និងអនុម័ត។

-បានរៀបចំតារាងសូចនាករសមិទ្ធកម្មគន្លឹះ (KPI) និងតារាងតម្រូវការថវិកាសម្រាប់ការអនុវត្តឆ្នាំ ២០២៣ និងបានផ្ញើជូនអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យទាន់ពេលវេលា។

# ជំពូក ៣
# ការប្រឈម



# ជំពូក ៣. បញ្ហាប្រឈម

ទន្ទឹមនឹងលទ្ធផលទទួលបានខាងលើ ក្រសួងនៅជួបបញ្ហាប្រឈមមួយចំនួនដូចជាៈ

## ១. កង្វះលិខិតបទដ្ឋានគតិយុត្ត

សេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចត្រូវបានអូសបន្លាយ ជាច្រើនឆ្នាំ ដោយសារមានបញ្ហាសំខាន់ខ្លះដែលតម្រូវសម្របសម្រួលជាមួយស្ថាប័នមួយចំនួន ដែលមានភារកិច្ចស្រដៀងគ្នា។ ដូច្នេះ លិខិតបទដ្ឋានគតិយុត្តិផ្សេងទៀត ត្រូវបានរាំងស្ទះ ដោយសារការរង់ចាំច្បាប់ស្តីពីអធិការកិច្ច។

## ២. កង្វះមធ្យោបាយ សម្ភារៈ

ដោយសារមានការរិតត្បិតចំណាយ ក្នុងថវិការដ្ឋ ជាពិសេសក្នុងសម័យវិបត្តិកូវីដ១៩ក្រសួងនៅមានការខ្វះខាត យានយន្ត សម្រាប់ចុះទៅបំពេញភារកិច្ច ដូចជាការធ្វើអធិការកិច្ច ការតាមដានការអនុវត្តច្បាប់ ការអង្កេត ស្រាវជ្រាវ ដោះស្រាយពាក្យបណ្តឹង និងការផ្សព្វផ្សាយច្បាប់ តាមខេត្ត និងតំបន់ដាច់ស្រយាល។

ម្យ៉ាងទៀត ក្រសួងក៏នៅខ្វះខាត ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន សម្ភារការិយាល័យ និងសម្ភារបរិក្ខាបច្ចេកទេសផ្សេងទៀត សម្រាប់ប្រើប្រាស់ និងសម្រួលដល់ប្រសិទ្ធភាពក្នុងការបំពេញការងារប្រចាំថ្ងៃ។

## ៣. ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅមិនទាន់សម្រេចបានពេញលេញ

ទោះជាការកែទម្រង់របស់ក្រសួងបានអនុវត្តទៅ ដោយរលូនយ៉ាងណាក្តី ក៏ផ្នែកខ្លះនៅមិនទាន់អនុវត្តបាន ដូចជាៈ

១. ការផ្តល់ប្រាក់បេកសកកម្ម និងលាភការផ្សេងៗ ចូលត្រង់ទៅគណនេយ្យបុគ្គល នៅមិនទាន់អនុវត្ត។

២. អង្គភាពថវិកាអង្គភាពថវិកាអាណាបកផ្ទេរសិទ្ធពេញលេញ នៅទីស្តីការក្រសួងចំពោះអង្គភាពថវិកាទាំងបី នៅមិនទាន់អនុវត្ត។

## ៤.ក្រមសីលធម៌មន្ត្រីអធិការកិច្ចនៅមានកំរិត

គណៈប្រតិភូ និងមន្ត្រីអធិការកិច្ច មួយចំនួនតូច នៅពេលចុះបំពេញភារកិច្ច តាមក្រសួង ស្ថាប័ន អង្គភាពនានា នៅមានការយោគយល់ និងមិនទាន់គោរពក្រមសីលធម៌ស្អាតស្អំ ពោលគឺត្រូវធ្វើការប្រកប ដោយឯករាជ្យភាព និងមិនលំអៀងបានល្អពេញលេញនៅឡើយ។

## ៥.ភាពស្មុគ្រស្មាញ និងឧបសគ្គមួយចំនួនដែលរារាំងការងារ

-កិច្ចសហការរបស់ក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធមួយចំនួនលើការងារ អធិការកិច្ច ការងារតាមដានការអនុវត្តច្បាប់ និងការងារអង្កេតស្រាវជ្រាវបណ្តឹងនៅមានកម្រិត។

-របាយការណ៍អធិការកិច្ចមិនទាន់ឯករាជ្យ ដោយតម្រូវឱ្យប្រធានស្ថាប័ន ឬប្រធានអង្គភាពរង អធិការកិច្ច ចុះហត្ថលេខាលើលទ្ធផលអធិការកិច្ច។

-ការទទួល អង្កេត និងដោះស្រាយពាក្យបណ្តឹងនៅមានភាពអូសបន្លាយ ដោយសារទិដ្ឋភាពច្បាប់ និងភាពស្មុគ្រស្មាញខ្លះទៀត។

-ពុំទាន់មានដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិជួយគាំទ្រលើវិស័យអធិការកិច្ចឱ្យបានទូលំទូលាយ។

-អនុក្រឹត្យលេខ ១៦៨ បានបង្កភាពស្រពិចស្រពិលនៅឡើយ ចំពោះភារកិច្ចស្នូលខ្លះរបស់ក្រសួង ជាពិសេសអ្វីដែលទាក់ទងនឹងកិច្ចការហិរញ្ញវត្ថុ

# ជំពូក ៤
# ទិសដៅការងារ ឆ្នាំ ២០២៣



# ជំពូក ៥. ទិសដៅការងារឆ្នាំ ២០២៣

ដើម្បីចូលរួមគាំទ្រ និងអនុវត្តតាមយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមានទិសដៅ គោលនយោបាយ និងយុទ្ធសាស្ត្រច្បាស់លាស់អនុវត្តតាមបេសកកម្មតួនាទី ភារកិច្ចការទទួលខុសត្រូវរបស់ខ្លួនស្របតាមសភាពការជាក់ស្តែង ប្រកបដោយប្រសិទ្ធភាព ដោយត្រូវផ្តោតលើសកម្មភាពអាទិភាព ដូចខាងក្រោម៖

## ១. រដ្ឋបាលកិច្ចការទូទៅ

### ១-១-ការងាររដ្ឋបាល

-បន្តទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងការចូលរួមពិធីបុណ្យជាតិ អន្តរជាតិ និងពិធីបុណ្យផ្សេងៗទៀត។

-បន្តអនុវត្តចរន្តការងាររដ្ឋបាលឱ្យកាន់តែប្រសើរ។

-បន្តទំនាក់ទំនងកិច្ចសហការជាមួយរដ្ឋបាលថ្នាក់កណ្តាល គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសជាមួយរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី។

-បន្តគ្រប់គ្រងកិច្ចការរដ្ឋបាលក្រសួងឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងបន្តកែលម្អ ដោយធ្វើការសម្របសម្រួលគ្រប់បណ្តាអង្គភាព និងមន្ទីររាជធានី-ខេត្ត ជាពិសេសបន្តចូលរួមគ្រប់កំណែទម្រង់រដ្ឋបាលសាធារណៈ ឱ្យស្របតាមតួនាទីភារកិច្ចរបស់ក្រសួង និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ១-២-ការងារបុគ្គលិក និងធនធានមនុស្ស

-បន្តទំនាក់ទំនង និងសម្របសម្រួលជាមួយក្រសួងមុខងារសាធារណៈលើការងារបុគ្គលិក និងធនធានមនុស្ស។

-បន្តអនុវត្តនូវរាល់ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ លិខិតបទដ្ឋានគតិយុត្តផ្សេងៗរបស់រាជរដ្ឋាភិបាល។

-បន្តធ្វើទំនាក់ទំនងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងការដាក់មន្ត្រី រាជការឱ្យចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ ឬបាត់បង់សមត្ថភាពការងារ។

-ពង្រឹងការងារពិនិត្យផ្តល់ទិដ្ឋាការលើរបាយការណ៍ស្តីពីស្ថានភាពរដ្ឋបាល និងស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការថ្នាក់រាជធានី-ខេត្តឱ្យបានទាន់ពេលវេលា។

### ១-៣-ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់

-ត្រៀមទូទាត់លើការប្រើប្រាស់អគ្គិសនី ទឹក ទូរស័ព្ទ តាមវិក័យបត្រជាក់ស្តែង ដែលផ្តល់ឡើងដោយអ្នកផ្គត់ផ្គង់។

-ត្រៀមទូទាត់ថ្លៃប្រើប្រាស់ទឹក អគ្គិសនី ទូរស័ព្ទ(Mobitel) ទូរស័ព្ទទូរស័ព្ទ(IDD) ប្រចាំខែ ឆ្នាំ ២០២៣។

-ត្រៀមទូទាត់រង្វាន់ទេយ្យបុរេប្រទានតាមជុំ ប្រចាំឆ្នាំ ឆ្នាំ២០២៣។

-ត្រៀមទូទាត់បេសកកម្មឆ្នាំ២០២២ ឆ្នាំ២០២៣។

-បន្តពិនិត្យ និងចូលរួមយោបល់ទាក់ទងតម្រូវការចំណាយផ្សេងៗក្នុងក្រសួង។

-ត្រៀមរៀបចំទូទាត់ប្រាក់បៀវត្សជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា ប្រចាំខែ ឆ្នាំ ២០២៣។

-ត្រៀមរៀបចំឯកសារស្នើសុំធានាចំណាយសម្ភារប្រើប្រាស់ប្រចាំឆ្នាំ២០២៣។

-រៀបចំឯកសារចំណាយថវិកាទូទៅរបស់ក្រសួងចំនួន៤ត្រីមាសប្រចាំឆ្នាំ២០២៣។

-ត្រៀមបែងចែកប្រេងឥន្ធនៈ ដោះស្រាយរាល់សំណើផ្សេងៗជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការ។

-ត្រៀមរៀបចំបែងចែកសម្ភារការិយាល័យ សម្ភារបច្ចេកទេស និងដោះស្រាយរាល់សំណើផ្សេងៗ ជូនថ្នាក់ ដឹកនាំគ្រប់នាយកដ្ឋាន។

-ត្រៀមបែងចែកសម្ភារអនាម័យតាមបណ្តានាយកដ្ឋាន។

-ត្រៀមចូលរួមផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមបណ្តាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-ត្រៀមរៀបចំបែងចែកទឹកបរិសុទ្ធសម្រាប់ប្រជុំជូនថ្នាក់ដឹកនាំ និងតាមនាយកដ្ឋាន។

-ត្រៀមរៀបចំការងារជួសជុលសម្ភារការិយាល័យ ជួសជុលអគារការិយាល័យ គ្រឿងយន្ត និងបរិក្ខាបច្ចេកទេស។

## ១-៤-ការងារផែនការ និងស្ថិតិ

-ពិនិត្យតាមដាន និងវាយតម្លៃលើប្រតិទិនការងារសម្រាប់ការិយាល័យដើម្បីអនុវត្តឆ្នាំ២០២៣។

-ត្រៀមបំពេញការងារស្នូលរបស់នាយកដ្ឋានក្នុងឆ្នាំ២០២៣ ឱ្យកាន់តែប្រសើរឡើង និងតាមការកំណត់។

-ត្រៀមចូលរួមវគ្គបណ្តុះបណ្តាលលើការងារកសាងផែនការ និងគម្រោងផ្សេងៗ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យកាន់តែមានប្រសិទ្ធភាព។

-រៀបចំបូកសរុបរបាយការណ៍លទ្ធផល នៃការអនុវត្តថវិកាកម្មវិធី ប្រចាំឆ្នាំ២០២២ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី-ខេត្តទាំង២៥នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

## ១-៥-ការងារសហប្រតិបត្តិការអន្តរជាតិ

-បន្តទំនាក់ទំនង និងសហប្រតិបត្តិការជាមួយស្ថានទូតចិន និងគណៈកម្មាធិការត្រួតពិនិត្យ នៃសាធារណរដ្ឋប្រជាមានិតចិន។

-បន្តទំនាក់ទំនង ជាមួយអធិការកិច្ចរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីត្រៀមជំរុញអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងស្ថាប័នទាំងពីរ។

-បន្តទំនាក់ទំនងពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ។

-បន្តទំនាក់ទំនងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-បន្តការសិក្សាស្រាវជ្រាវបណ្តាប្រទេសជាសមាជិកអាស៊ាន និងអង្គការអន្តរជាតិ។

-ត្រៀមចូលរួមអនុវត្តការងារដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ២-ការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា

### ២.១.ការងារនីតិកម្ម

-បន្តពិនិត្យ និងពិភាក្សាបន្ថែមលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច ដើម្បីផ្ញើទៅក្រសួងពាក់ព័ន្ធ។

-បន្តចូលរួមពិនិត្យ និងប្រមូលឯកសារទាក់ទងនឹងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច និងច្បាប់នានា។

-ត្រៀមរៀបចំឯកសារកម្រងសំណួរ ដើម្បីចុះទៅស្ទង់មតិច្បាប់ នៅតាមបណ្តាឃុំ ស្រុក នៃខេត្តគោលដៅសម្រាប់ឆ្នាំ២០២៣។

-បន្តទំនាក់ទំនងរៀបចំការប្រជុំការតាក់តែងសេចក្តីព្រាងច្បាប់ សេចក្តីព្រាងអនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ឱ្យ។

-បន្តទទួលអនុវត្តសកម្មភាពការងារផ្សេងៗទៀត របស់ថ្នាក់ដឹកនាំក្រសួងប្រគល់ឱ្យ។

### ២.២.ការងារអប់រំផ្សព្វផ្សាយច្បាប់

-សិក្សាស្រាវជ្រាវទៅលើអនុក្រឹត្យស្តីពីការកែសម្រួល និងឯកសារពាក់ព័ន្ធ និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដើម្បីពង្រឹងនូវសមត្ថភាពបន្ថែមរបស់មន្រ្តីក្នុងការិយាល័យ។

-បោះពុម្ពឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់ផ្តត់ផ្គង់ការផ្សព្វផ្សាយច្បាប់ ស្របតាមផែនការ ឆ្នាំ២០២៣។

-សិក្សាស្រាវជ្រាវទៅលើច្បាប់ អនុក្រឹត្យស្តីពីការកែសម្រួល និងឯកសារពាក់ព័ន្ធ ដើម្បីចុះធ្វើការស្ទាបស្ទង់ការយល់ដឹងរបស់ប្រជាពលរដ្ឋ តាមផែនការដែលបានកំណត់។

-សិក្សាឯកសារច្បាប់ សិក្សាពីកម្រងសំណួរ។

### ២.៣.ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា-ព្រឹទ្ធសភា

-ចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី។

-ចូលរួមស្តាប់សម័យប្រជុំនៅរដ្ឋសភា-ព្រឹទ្ធសភា
និងបន្តសកម្មភាពចុះអមដំណើរជាមួយតំណាងរាស្ត្រ និង

គណៈកម្មការនានានៃរដ្ឋសភាជាតិ និងអមដំណើរជាមួយគណៈកម្មការនានា ក្រុមសមាជិកព្រឹទ្ធសភាតាមភូមិភាគ និងក្រុមសមាជិក សមាជិកានៃព្រឹទ្ធសភា។

-បន្តធ្វើការទំនាក់ទំនងជាមួយមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច តាមបណ្តាខេត្ត ដើម្បីរៀបចំធ្វើវេទិកាសាធារណៈតាមផែនការឆ្នាំ២០២៣។

## ៣.ការងារអធិការកិច្ច

### ៣.១.ការងារអធិការកិច្ច(លើវិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច)

-បន្តចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងរដ្ឋាករទឹកស្វយ័ត សៀមរាប និងរដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលក្រុង-ស្រុក-ខណ្ឌ សាលាដំបូងរាជធានី-ខេត្ត ពន្ធដានាគាររាជធានី-ខេត្ត ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត អធិការដ្ឋាននគរបាលក្រុង-ស្រុក-ខណ្ឌ មន្ទីរ-អង្គភាពជុំវិញរាជធានី-ខេត្ត អង្គភាពក្រោមឱវាទ និងអង្គភាពពាក់ព័ន្ធ នៅរាជធានីភ្នំពេញ ខេត្តពោធិ៍សាត់ និងខេត្តព្រះវិហារ។

-ត្រៀមឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំខេត្ត ស្តីពីលទ្ធផលចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង-ស្រុក សាលាដំបូងខេត្ត ពន្ធនាគារខេត្ត ស្នងការដ្ឋាននគរបាលខេត្ត អធិការដ្ឋាននគរបាលក្រុង-ស្រុក មន្ទីរ-អង្គភាពជុំវិញខេត្ត អង្គភាពក្រោមឱវាទ និងអង្គភាពពាក់ព័ន្ធ នៅខេត្តព្រះសីហនុ កែប ប៉ៃលិន កណ្តាល កំពង់ចាម កំពង់ឆ្នាំង សៀមរាប មណ្ឌលគិរី ស្វាយរៀង និងខេត្តកំពង់ធំ។

-ត្រៀមឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងវប្បធម៌វិចិត្រសិល្បៈ ក្រសួងសុខាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា ស្តីពីលទ្ធផលចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ច ការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវបណ្តាវិធានការរបស់គណៈប្រតិភូអធិការកិច្ចក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងការិយបរិច្ឆេទ២០១៨។

-ត្រៀមធ្វើលិខិតជូនដំណឹងទៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង-ស្រុក សាលាដំបូងខេត្ត ពន្ធនាគារខេត្ត ស្នងការដ្ឋាននគរបាលខេត្ត អធិការដ្ឋាននគរបាលក្រុង-ស្រុក មន្ទីរ-អង្គភាពជុំវិញខេត្ត អង្គភាពក្រោមឱវាទ និងអង្គភាពពាក់ព័ន្ធ ដើម្បីជំរុញឱ្យការកែលម្អចំណុចខ្វះខាតលើការអនុវត្តតួនាទីភារកិច្ច ការផ្តល់សេវាសាធារណៈ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង-ស្រុក សាលាដំបូងខេត្ត ពន្ធនាគារខេត្ត ស្នងការដ្ឋាននគរបាលខេត្ត អធិការដ្ឋាននគរបាលក្រុង-ស្រុក មន្ទីរ-អង្គភាពជុំវិញខេត្ត អង្គភាពក្រោមឱវាទ និងអង្គភាពពាក់ព័ន្ធ នៅខេត្តស្ទឹងត្រែង ឧត្តរមានជ័យ បន្ទាយមានជ័យ រតនគិរី បាត់ដំបង ខេត្តតាកែវ ក្រចេះ ខេត្តកោះកុង ព្រៃវែង កំពង់ស្ពឺ ត្បូងឃ្មុំ និងខេត្តកំពត។

-ត្រៀមធ្វើលិខិតជូនដំណឹងទៅអគ្គិសនីកម្ពុជា ក្រសួងបរិស្ថាន និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឱ្យជំរុញការកែលម្អចំណុចខ្វះខាតលើការអនុវត្តតួនាទីភារកិច្ច ការផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ។

-ត្រៀមចុះធ្វើអធិការកិច្ចតាមផែនការសកម្មភាពឆ្នាំ២០២៣។

-ត្រៀមមន្ត្រីដើម្បីចូលរួមវិភាគ ដោះស្រាយបញ្ហាអធិការកិច្ច អង្កេតស្រាវជ្រាវ និងបញ្ហាផ្សេងៗទៀត។

-បន្តទទួល និងបូកសរុបរបាយការណ៍ស្តីពីលទ្ធផលអធិការកិច្ចថ្នាក់ក្រោមជាតិ និងធ្វើអធិការកិច្ចឡើងវិញ ក្នុងករណីយល់ឃើញថាមិនទាន់ត្រឹមត្រូវ ឬមានការតវ៉ា។

-ត្រៀមធ្វើអធិការកិច្ចតាមហានិភ័យ និងរបាយការណ៍លទ្ធផលអធិការកិច្ច ក្នុងការិយបរិច្ឆេទ២០២២។

-ត្រៀមអនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង។

## ៣.២.ការងារតាមដានការអនុវត្តច្បាប់

-ត្រៀមឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំខេត្តស្តីពីលទ្ធផល នៃការចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល អនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច កិច្ចសន្យាវិនិយោគធ្វើអាជីវកម្មយកភាស៊ី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តពោធិ៍សាត់ ស្ទឹងត្រែង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ។

-ត្រៀមឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ស្តីពីលទ្ធផលនៃការចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តតាកែវ កំពង់ចាម ព្រះវិហារ និងខេត្តមណ្ឌលគិរី។

-ត្រៀមធ្វើលិខិតជូនដំណឹងទៅក្រសួង-ស្ថាប័ន ដើម្បីឱ្យធ្វើការជំរុញទៅមន្ទីរ-អង្គភាព ម្ចាស់ក្រុមហ៊ុន ម្ចាស់សហគ្រាស និងម្ចាស់សិប្បកម្ម ឱ្យកែលម្អនូវចំណុចខ្វះខាតដែលបានរកឃើញក្នុងការចុះធ្វើការតាមដានត្រួតពិនិត្យច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ កិច្ចសន្យាវិនិយោគធ្វើអាជីវកម្មយកភាស៊ី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តក្រចេះ។

-បន្តស្រាវជ្រាវ និងចងក្រងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងអនុសាសន៍របស់នាយករដ្ឋមន្ត្រី។

-ត្រៀមអនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២៣ និងភារកិច្ចផ្សេងៗទៀត តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង។

### ៣.៣.ការងារទទួលពាក្យបណ្ដឹង និងអង្កេតស្រាវជ្រាវ

-បន្តរង់ចាំទទួលពាក្យបណ្ដឹងពីគ្រប់មជ្ឈដ្ឋាននានា រួមទាំងពាក្យបណ្ដឹងក្នុងសារព័ត៌មានផងដែរ។

-បន្ត និងត្រៀមចុះអង្កេតស្រាវជ្រាវពាក្យបណ្ដឹង ដែលជាសមត្ថកិច្ចក្រសួង និងពាក្យបណ្ដឹង ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

-ត្រៀមអនុវត្តការកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង។

## ៤.ការងារសវនកម្មផ្ទៃក្នុង

-បន្តអនុវត្តការងាររបស់ខ្លួនស្របតាមអនុក្រឹត្យលើលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាល ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ និងប្រកាសលេខ០៧៣ ទរពអ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ការិយាល័យ ចំណុះនាយកដ្ឋាននៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

## ៥.ការងារវិទ្យាស្ថានជាតិអធិការកិច្ច

### ៥.១.ការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

#### ៥.១.១. អភិវឌ្ឍ និងពង្រឹងសមត្ថភាពស្ថាប័ន

-បន្តបណ្ដុះបណ្ដាល និងពង្រឹងសមត្ថភាពមន្ត្រីវិទ្យាស្ថានបន្ថែមលើជំនាញអធិការកិច្ច និងជំនាញសំខាន់ៗរួមផ្សំបន្ថែមទៀត ដើម្បីបំពេញការងារជូនស្ថាប័នកាន់តែមានប្រសិទ្ធភាព។

-បន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការងារជាប្រចាំ។

-ស្នើសុំមធ្យោបាយធ្វើដំណើរ ក្របខណ្ឌមន្ត្រីរាជការបន្ថែម មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្ដែតសម្រាប់ វិទ្យាស្ថាន។

-ស្នើសុំផ្ដល់ការបណ្ដុះបណ្ដាលដល់ក្រុមគ្រូបង្គោលវិជ្ជាជីវៈអធិការកិច្ចបន្ថែម។

-កែលម្អរចនាសម្ព័ន្ធគ្រប់គ្រង។

#### ៥.១.២. ពង្រឹងការគ្រប់គ្រងរដ្ឋបាល បុគ្គលិក និង ហិរញ្ញវត្ថុ

-ស្នើសុំបង្កើតអង្គភាពថវិកាវិទ្យាស្ថានជាតិអធិការកិច្ចដើម្បីសម្រួល
និងពន្លឿនចរន្តការងារឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព។

-ពង្រឹងការគ្រប់គ្រងចំណូល ចំណាយ ផ្គត់ផ្គង់សម្ភារ បរិក្ខារ និងសារពើភ័ណ្ឌរបស់វិទ្យាស្ថាន។

-ពង្រឹងការគ្រប់គ្រងបុគ្គលិក ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភរបស់សាស្ត្រាចារ្យ និងគ្រូ។

-ពង្រឹងការគ្រប់គ្រងសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ និងអនាម័យរបស់វិទ្យាស្ថាន។

### ៥.២. ការងារផែនការ និងស្រាវជ្រាវ

#### ៥.២.១. ពង្រឹងការគ្រប់គ្រងផែនការ

-ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថាន។

-រៀបចំផែនការសកម្មភាពរបស់វិទ្យាស្ថាន និងការអភិវឌ្ឍវិទ្យាស្ថានជាតិអធិការកិច្ច។

-បកប្រែឯកសារសំខាន់ៗពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។

**៥.២.២. ពង្រឹងការគ្រប់គ្រងការសិក្សាស្រាវជ្រាវ**

-បន្តស្រាវជ្រាវ និងចងក្រងអនុសាសន៍សម្តេចតេជោ នាយករដ្ឋមន្ត្រី។

-បន្តស្រាវជ្រាវរក និងប្រមូលផ្តុំឯកសារ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងឯកសារពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។

-តាមដានអំពីវឌ្ឍនភាព និងប្រសិទ្ធភាពការងារមន្ត្រីរាជការដែលទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ច។

-រៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថាន។

-សិក្សាស្រាវជ្រាវអំពីការដោះស្រាយបណ្តឹងតវ៉ា បណ្តឹងបរិហារ រួមទាំងស្រាវជ្រាវ អំពីទស្សនៈទូទៅពាក់ព័ន្ធនឹងការងារអធិការកិច្ច ការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា។

## ៥.៣. ការងារបណ្តុះបណ្តាល

**៥.៣.១. ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ចរយៈពេលខ្លី**

-រៀបចំកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ច ។

-ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ចកម្រិតបឋម កម្រិតមធ្យម កម្រិតជាន់ខ្ពស់ ដល់មន្ត្រីរាជការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីជំនាញវិជ្ជាជីវៈអធិការកិច្ចដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**៥.៣.២. ផ្តល់សេវាអប់រំវិស័យអធិការកិច្ច និងវិស័យពាក់ព័ន្ធ**

-ផ្តល់ការបណ្តុះបណ្តាលផ្នែកច្បាប់ ផ្នែកសេដ្ឋកិច្ច ផ្នែកគ្រប់គ្រង ផ្នែកគណនេយ្យ ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងនិស្សិតកម្រិតបរិញ្ញាបត្រ និងអនុបណ្ឌិត។

## ៥.៤. ការងារទំនាក់ទំនងសាធារណៈ

**៥.៤.១. ពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ**

-បន្តពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាស្ថានទូតនានា អង្គការជាតិ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍ និងគ្រឹះស្ថានសិក្សា។

**៥.៤.២. ពង្រឹងការគ្រប់គ្រងព័ត៌មានវិទ្យា និងបណ្ណាល័យ**

-បង្កើត និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យារបស់វិទ្យាស្ថាន។

-រៀបចំ និងបង្កើនប្រសិទ្ធភាពគ្រប់គ្រងបណ្ណាល័យ។

-រៀបចំបង្កើតរោងពុម្ព និងបោះពុម្ពឯកសារ។

**៥.៤.៣. កិច្ចការផ្សេងៗទៀត**

-អនុវត្តការងារផ្សេងៗ តាមការណែនាំ និងចង្អុលបង្ហាញពីថ្នាក់ដឹកនាំក្រសួង។

-បន្តផ្តល់ព័ត៌មាន ណែនាំ និងក្រើនរំលឹកមន្ត្រីរាជការនៃវិទ្យាស្ថានជាតិអធិការកិច្ច ដើម្បីចូលរួមទប់ស្កាត់ និងការពារការឆ្លងជំងឺកូវីដ-១៩។

-បន្តផ្សព្វផ្សាយព័ត៌មាន និងសារក្រើនរំលឹកដល់សាធារណៈជន ដើម្បីចូលរួមទប់ស្កាត់ និងការពារការឆ្លងជំងឺកូវីដ-១៩។

# ៦.ការងារផ្សេងៗ

## ៦.១.ការងារយេនឌ័រ

-បន្តផ្សព្វផ្សាយ ជំរុញ និងតាមដានការអនុវត្តអនុសញ្ញាស៊ីដ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ១១ ចំណុចរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី នៅថ្នាក់កណ្តាល និងមន្ទីររាជធានី-ខេត្ត។

-ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ២០២២-២០២៥ ក្នុងវិស័យទំនាក់ទំនងជាមួយរដ្ឋសភា- ព្រឹទ្ធសភា និងអធិការកិច្ច។

-ជំរុញការបង្កើនបរិមាណ និងសមត្ថភាពស្ត្រីក្នុងការធ្វើសេចក្តីសម្រេច និងភាពជាអ្នកដឹកនាំ។

-រៀបចំវេទិកាសាធារណៈ ស្តីពីតម្រូវការ និងបញ្ហាប្រឈមរបស់មន្ត្រីរាជការជាស្ត្រី។

-អនុវត្តផែនការបញ្ជ្រាបយេនឌ័រឆ្នាំ២០២៣។

## ៦.២.ការងារចងសម្ព័ន្ធមេត្រីភាព

ក្រសួងនឹងចូលរួមយ៉ាងសកម្មថែមទៀត ក្នុងការពង្រឹងសម្ព័ន្ធមេត្រីភាពជាមួយកងវរសេនាតូចនគរបាលព្រំដែន ទាំងពីរអង្គភាព ឱ្យកាន់តែជិតស្និទ្ធ ក្នុងន័យផ្តល់កម្លាំងចិត្ត និងសម្ភារ ដើម្បីបង្កើនជីវភាពរស់នៅ របស់គាត់ឱ្យកាន់តែមានភាពប្រសើរឡើង និងដើម្បីរួមចំណែកថែរក្សាការពារទឹកដីរបស់យើងឱ្យមានសុខសន្តិភាពយូរអង្វែងតរៀងទៅ។

## ៦.៣.ការងារសមាគមសង្គហមិត្តភាព

-បន្តសម្របសម្រួល និងទទួលសមាជិក សមាជិកាថ្មីចូលក្នុងសមាគមសង្គហមិត្តភាព ក្រសួងបន្ថែមទៀត។

-បន្តប្រមូលយក និងគៀងគរថវិកាពីសមាជិក សមាជិកា ដែលមិនទាន់បានបង់ថវិកា។

## ៦.៤.ការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង

បន្តស្នើសុំគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនក្រសួង ក្នុងឆ្នាំ២០២៣។

## ៦.៥.ការងារគេហទំព័រ MONASRI.GOV.KH និង MONASRI App

-ធ្វើការ Backup ទិន្នន័យនៅក្នុង Website ជាប្រចាំ ដើម្បីរក្សាទុករាល់ទិន្នន័យដែលមានកន្លងមកឱ្យមានសុវត្ថិភាព។

-បាន និងកំពុងរៀបចំទម្រង់វេបសាយ របស់ក្រសួងមួយទៀតជាភាសាអង់គ្លេស។

-បន្តចូលរួមពិធីផ្សេងៗ តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង។

-បន្តតាមដានយ៉ាងម៉ត់ចត់តាមរយៈវេបសាយរបស់ក្រសួង-ស្ថាប័ននានា និងរាជរដ្ឋាភិបាលអំពីសារាចរណែនាំ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីដាក់ជូនថ្នាក់ដឹកនាំជ្រាប។

## ៦.៦. ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈនិងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS

-ត្រៀមអនុវត្តផែនការរួមដំណាក់កាលទី៤ ឆ្នាំ២០២៣ ដើម្បីឈានឆ្ពោះទៅសម្រេចគោលដៅ ដែលបានអនុម័តដោយរាជរដ្ឋាភិបាលរួចហើយ។

# ជំពូក ៥
# សេចក្តីសន្និដ្ឋាន



# ជំពូក ៥. សេចក្តីសន្និដ្ឋាន

នៅឆ្នាំ ២០២២ ក្រសួងបានបំពេញភារកិច្ច ប្រកបដោយទទួលខុសត្រូវ និងប្រសិទ្ធភាពខ្ពស់ និងទទួលបានសមិទ្ធផលគួរជាទីពេញចិត្ត។ ក្រសួងបានធ្វើការកែទម្រង់ ទៅតាមទិសដៅ ដែលរាជរដ្ឋាភិបាលបានកំណត់ ដោយបានអភិវឌ្ឍស្ថាប័ន ទាំងថ្នាក់កណ្តាល និងមន្ទីរ គ្រប់រាជធានី ខេត្ត របស់ក្រសួងផ្ទាល់ និងបានពង្រឹងសមត្ថភាព ជំនាញ គ្រប់ផ្នែក និងបានតម្រង់ទិស និងណែនាំឱ្យក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋដែលរងអធិការកិច្ចនានាអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត បង្កើនការប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ ក្នុងសកម្មភាពការងាររបស់ខ្លួន ស្របតាមការកែទម្រង់ ស៊ីជម្រៅ ការពង្រឹងនីតិរដ្ឋ និងអភិបាលកិច្ចល្អ។ លើសពីនេះទៀត ក្រសួងបានផ្សព្វផ្សាយច្បាប់ដើម្បីពង្រឹងការយល់ដឹងរបស់ប្រជាពលរដ្ឋ ឱ្យយល់ពីច្បាប់ និងគោរពច្បាប់ដើម្បីរួមគ្នាការពារ និងកសាងជាតិ ជាពិសេស ការទប់ស្កាត់ភាពអសកម្មនានា ក្នុងសង្គម និងបានបណ្តុះបណ្តាលជំនាញអធិការកិច្ច ដល់មន្ត្រីរាជការក្រសួង និងស្ថាប័ន អង្គភាពរដ្ឋជាច្រើនទៀតផង។

ដូច្នេះការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ពិតជាមានសារៈសំខាន់មិនអាចខ្វះបាន ដើម្បីបម្រើឱ្យផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋយើង ក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជា ទទួលបានសន្តិភាពយ៉ាងពិតប្រាកដ និងការអភិវឌ្ឍន៍លើគ្រប់វិស័យ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ។

ជាការពិត ក្រសួងនៅមានការប្រឈមខ្លះ ដូចជានៅមានបុគ្គល និងស្ថាប័នមួយចំនួនមិនយកចិត្តទុកដាក់ ឬមានចេតនាមិនផ្តល់កិច្ចសហការពេញលេញដល់ក្រុមការងារក្រសួង ជាពិសេសគណៈប្រតិភូអធិការកិច្ច ដែលត្រូវចុះទៅបំពេញបេសកកម្ម នៅតាមស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយសារ បញ្ហាប៉ះពាល់ដល់ផលប្រយោជន៍បុគ្គល។ ទន្ទឹមនឹងនេះ ក្រសួងនៅមានការប្រឈមជាច្រើន ដូចជានៅតាមស្ថាប័នរដ្ឋមួយចំនួន យល់ថាក្រសួងមានភារកិច្ចស្រដៀងគ្នា ឬជាន់គ្នាជាមួយស្ថាប័នមួយចំនួន។ ម្យ៉ាងទៀតការអនុវត្តក្រមសីលធម៌របស់ក្រុមការងារចុះធ្វើបេសកកម្មអធិការកិច្ចមួយចំនួនតូចនៅមានការខ្វះខាត ដោយសារការចង់បានលាភសក្ការៈខ្លះ និងមានការឃោគយល់។

ទោះជាយ៉ាងនេះក្តី ក៏ក្រសួងបានជម្នះ និងបំពេញតួនាទីទៅតាមច្បាប់អនុញ្ញាត ហើយយើងបានឃើញច្បាស់ថា ការងាររបស់យើង ពិតជាជួយធានាការពង្រឹងប្រសិទ្ធភាពការងារស្ថាប័ន អង្គភាពរដ្ឋ ធានាសុវត្ថិភាព និងសិទ្ធិសេរីភាព ជូនប្រជាពលរដ្ឋ និងនាំមកនូវតម្លាភាព កាត់បន្ថយបាននូវបាតុភាពអសកម្មនានា ដូចជាតម្រូវឱ្យអនុវត្តកិច្ចសន្យា រវាងក្រុមហ៊ុននានា ជាមួយរដ្ឋបានល្អ ជួយកាត់បន្ថយ និងលុបបំបាត់ ការកឹបកេង និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋខុសទិសដៅជាដើម។

លទ្ធផលដែលសម្រេចបានកន្លងមកនេះបានបង្ហាញពីតួនាទីភារកិច្ចការទទួលខុសត្រូវ របស់ក្រសួងពិតជាមានសារៈសំខាន់មិនអាចខ្វះបាន ដែលរួមចំណែកដល់ការជំរុញអភិបាលកិច្ចល្អ និងទប់ស្កាត់ កាត់បន្ថយអំពើពុករលួយ។ កត្តាជាគន្លឹះដែលនាំឱ្យសម្រេចបាននូវលទ្ធផលខាងលើ គឺដោយសារមានការដឹកនាំប្រកបដោយបញ្ញាញាណដ៏ត្រឹមត្រូវ និងភ្លឺស្វាង របស់ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ដែលតែងតែនៅជិតស្និទ្ធ ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង និងការខិតខំបំពេញ

ភារកិច្ច ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្រមសីលធម៌វិជ្ជាជីវៈ និងជំនាញ របស់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ទាំងថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ និងកិច្ចសហការ និងគាំទ្រពីសំណាក់ ស្ថាប័ន អង្គភាពរដ្ឋដទៃទៀត ដែលតែងតែគោរព ឱ្យតម្លៃ និងយល់ច្បាស់ពីគុណប្រយោជន៍ និងភារកិច្ចដ៏ ថ្លៃថ្លារបស់ក្រសួង។

ក្នុងឆ្នាំ២០២៣ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គ្រប់លំដាប់ថ្នាក់ នឹងកាន់តែជម្រុញការខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីដោះស្រាយ និងកាត់បន្ថយឱ្យបានជាអតិបរមា នូវចំណុចខ្វះខាតរបស់ក្រសួង ក៏ដូចជារួមចំណែកលុបបំបាត់ និង កាត់បន្ថយបាតុភាពអសកម្មនានា ការរំលោភដោយអំណាចខុសច្បាប់ និងប្រយុទ្ធប្រឆាំងនឹងអំពើ ពុករលួយក្នុងសង្គម។

# ជំពូក ៦.
# ឧបសម្ព័ន្ធ



# ជំពូក ៦. ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ទី១. កម្មវិធីសន្និបាត

**កម្មវិធី**

**សន្និបាតបូកសរុបការងារឆ្នាំ២០២២ និង ទិសដៅ ឆ្នាំ២០២៣**
**របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**
ថ្ងៃអង្គារ ២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹង ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣
សណ្ឋាគារសុខា វិថីកែវ ចិន្តា ភូមិ១ សង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ

| **ម៉ោង** | **កម្មវិធី** | **គណៈអធិបតី** |
|---|---|---|
| **ពេលព្រឹក** | | |
| ៧.៣០ - ៨.០០ | សមាជិក សមាជិកា សន្និបាតចុះឈ្មោះ | |
| ៨.០០ - ៨.២០ | គណៈអធិបតីអញ្ជើញដល់ | |
| ៨.៣០ | ឯកឧត្តម **ឆេង សារឿន** រដ្ឋលេខាធិការប្រចាំការ អញ្ជើញដល់ | |
| | **ពិធីបើកសន្និបាត** | |
| ៨.៣០ - ៩.៣០ | - ប្រកាសហេតុ<br>- គោរពភ្លេងជាតិ នៃព្រះរាជាណាចក្រកម្ពុជា<br>- សុន្ទរកថាបើកសន្និបាតដោយ ឯកឧត្តម **ឆេង សារឿន** រដ្ឋលេខាធិការប្រចាំការ តំណាង **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន**<br>- របាយការណ៍សង្ខេបស្ដីពីលទ្ធផលការងារឆ្នាំ២០២២ និងទិសដៅ ឆ្នាំ២០២៣ ដោយ**ឯកឧត្តម ម៉ែន ច័ន្ទសុខរិន** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក រដ្ឋបាលកិច្ចការទូទៅ | -ឯកឧត្តម **ឆេង សារឿន** រដ្ឋលេខាធិការប្រចាំការ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ៩.៣០ - ៩.៤៥ | សម្រាក ពិសាភេសជ្ជៈ និងអាហារសម្រន់ | |
| | **ដំណើរការសន្និបាតដឹកនាំដោយឯកឧត្តម ឆេង សារឿន រដ្ឋលេខាធិការប្រចាំការ** | |
| ៩.៤៥ - ១១.០០ | -បទអន្តរាគមន៍ របស់មន្ទីរទេពអ ខេត្តបាត់ដំបង<br>-បទអន្តរាគមន៍ របស់មន្ទីរទេពអ ខេត្តមណ្ឌលគីរី<br>-បទអន្តរាគមន៍ របស់មន្ទីរទេពអ ខេត្តកោះកុង<br>-បទអន្តរាគមន៍ របស់មន្ទីរទេពអ រាជធានីភ្នំពេញ<br>-បទអន្តរាគមន៍ របស់មន្ទីរទេពអ ខេត្តកំពង់ចាម<br>-បទអន្តរាគមន៍ របស់អង្គភាព ឬមន្ទីរ ផ្សេងទៀត | -ឯកឧត្តម **ឆេង សារឿន**<br>-រដ្ឋលេខាធិការ |

| | | |
|---|---|---|
| ១១.០០- ១១.១៥ | -បទអន្តរាគមន៍ របស់អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា (សមិទ្ធផល ការប្រឈម និងទិសដៅ) | -ឯកឧត្តម **ឆេង សារឿន**<br>-រដ្ឋលេខាធិការ |
| ១១.១៥-១១.៤៥ | ពិភាក្សាលើចំណាប់អារម្មណ៍ និងរបាយការណ៍ | -ឯកឧត្តម **ឆេង សារឿន**<br>-រដ្ឋលេខាធិការ |
| ១១.៤៥- ១៣.៣០ | សម្រាកអាហារថ្ងៃត្រង់ Buffet នៅសណ្ឋាគារសុខាភ្នំពេញ | អង្គសន្និបាត |
| **ម៉ោង** | **កម្មវិធី** | **គណៈអធិបតី/ថ្នាក់ដឹកនាំ** |
| **ពេលរសៀល** | | |
| ១៤.០០- ១៤.១៥ | -បទអន្តរាគមន៍ របស់អគ្គនាយកដ្ឋានអធិការកិច្ច (សមិទ្ធផល ការប្រឈម និងទិសដៅ) | -ឯកឧត្តម **ឆេង សារឿន**<br>-រដ្ឋលេខាធិការ |
| ១៤.១៥-១៤.៣០ | -បទអន្តរាគមន៍ របស់អគ្គនាយកដ្ឋានរដ្ឋបាល កិច្ចការទូទៅ (សមិទ្ធផល ការប្រឈម និងទិសដៅ) | -ឯកឧត្តម **ឆេង សារឿន**<br>-រដ្ឋលេខាធិការ |
| ១៤.៣០-១៤.៤០ | -បទអន្តរាគមន៍ របស់វិទ្យាស្ថានជាតិអធិកិច្ច (សមិទ្ធផល ការប្រឈម និងទិសដៅ) | -ឯកឧត្តម **ឆេង សារឿន**<br>-រដ្ឋលេខាធិការ |
| ១៤.៤០-១៥.៣០ | ការពិភាក្សាលើចំណាប់អារម្មណ៍ និងលើរបាយការណ៍ | -ឯកឧត្តម **ឆេង សារឿន**<br>-រដ្ឋលេខាធិការ |
| ១៥.៣០ - ១៦.០០ | សម្រាកពិសាភេសជ្ជៈ និងអាហារសម្រន់ | អង្គសន្និបាត |
| **ពិធីបិទសន្និបាត** | | |
| ១៦.០០ | លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ អញ្ជើញដល់ | |
| ១៦.០០-១៦.១៥ | - របាយការណ៍បូកសរុបលទ្ធផលសន្និបាតដោយ ឯកឧត្តមបណ្ឌិត **ចាប សុថារិទ្ធ** រដ្ឋលេខាធិការ | -លោកជំទាវកិត្តិសង្គហបណ្ឌិត<br>-រដ្ឋលេខាធិការ |
| ១៦.១៥- ១៦.៣០ | -សុន្ទរកថាបិទសន្និបាត និងមតិផ្តាំផ្ញើ ដោយ លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ | -លោកជំទាវកិត្តិសង្គហបណ្ឌិត<br>-រដ្ឋលេខាធិការ |
| ១៦.៣០-១៧.០០ | -ពិធីបំពាក់មេដាយ-គ្រឿងឥស្សរិយយស | -លោកជំទាវកិត្តិសង្គហបណ្ឌិត |
| ១៧.០០ | -គោរពភ្លេងជាតិបិទកម្មវិធី។ | អង្គសន្និបាត |
| ១៧.០០-១៧.១០ | ការថតរូបអនុស្សាវរីយ | អង្គសន្និបាត |
| ១៨.៣០-២១.៣០ | អាហារសាមគ្គី នៅភោជនីយដ្ឋានកាជូ ផ្លូវជាតិលេខ៦ ចម្ងាយពីស្ពានជ្រោយចង្វា ២គ.ម សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ ភ្នំពេញ (ដោយថវិកា ថ្នាក់ដឹកនាំមន្ត្រីរាជការ តាមការស្ម័គ្រចិត្ត) | សមាជិក សមាជិកាសន្និបាតទាំងអស់ |

***កំណត់សំគាល់៖***

១) គណៈកម្មាធិការរៀបចំសន្និបាតសូមរក្សាសិទ្ធិកែប្រែកម្មវិធីក្នុងករណីចាំបាច់។
២) សម្លៀកបំពាក់៖ បុរស៖ អាវធំ ក្រវ៉ាត់ក នារី៖ ប្រពៃណី។
៣) បើសមាជិក សមាជិកាអង្គសន្និបាតមិនចូលរួមក្នុងពិធីជប់លៀង ល្ងាចថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០២៣ សូមមេត្តាជម្រាប លោក ស្រ៊ុន សារ៉ន ដើម្បីកំណត់ចំនួនពិតប្រាកដ និងងាយស្រួលក្នុងការរៀបចំ។
៤) សូមទាក់ទងទូរស័ព្ទ ឯកឧត្តម គឹម សុខជា៖ ០១៧៤៦៩៦៩៩ និង លោក ស្រ៊ុន សារ៉ន៖ ០៨៩៧២៩២៩២

# ឧបសម្ព័ន្ធ ទី២. របាយការណ៍សង្ខេប

**របាយការណ៍សង្ខេប**
**ស្តីពី**
**ការបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣**
**របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**
អានដោយឯកឧត្តម **ម៉ែន ច័ន្ទសុខរិន**
ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក រដ្ឋបាលកិច្ចការទូទៅ

## ក-សេចក្តីផ្តើម

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ក្នុងការងារចម្បង គឺការទំនាក់ទំនង សម្របសម្រួល រវាងរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ការចូលរួមតាក់តែង សេចក្តីព្រាងច្បាប់ ការអប់រំផ្សព្វផ្សាយច្បាប់ ការទទួល និងដោះស្រាយ ពាក្យបណ្តឹង របស់ប្រជាពលរដ្ឋ ការតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋាន គតិយុត្តនានា និងធ្វើអធិការកិច្ច លើគ្រប់វិស័យ សំដៅ បង្ការ ទប់ស្កាត់ កែលម្អ និងមានវិធានការ ដើម្បីរួមចំណែកប្រឆាំងនឹងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា ដើម្បីពង្រឹងអភិបាលកិច្ចល្អ ការពារសិទ្ធិ របស់ប្រជាពលរដ្ឋ និងការពារសុវត្ថិភាពសាធារណៈ និងរួមចំណែកដល់ការអភិវឌ្ឍន៍ សេដ្ឋកិច្ច សង្គម។

ដើម្បីសម្រេចបានភារកិច្ចខាងលើ ក្រសួងមានគោលបំណងគោលនយោបាយ៖ ការលើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈការអប់រំ បង្ការ ទប់ស្កាត់បាតុភាពអសកម្ម បង្កើនគណនេយ្យភាព ប្រសិទ្ធភាពការងារ និងពង្រឹងនីតិរដ្ឋ។ ក្នុងការអនុវត្តថវិកា ក្រសួងមានកម្មវិធីមួយគឺ ៖ បង្កើន និងពង្រឹងប្រសិទ្ធភាព វិស័យទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និង អនុកម្មវិធី ៤ គឺ៖ អនុកម្មវិធីទី១៖ «ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអប់រំផ្សព្វផ្សាយច្បាប់» អនុកម្មវិធីទី២៖ ការងារអធិការកិច្ច អនុកម្មវិធីទី៣ ៖ សេវាគាំទ្រទូទៅ និង អនុកម្មវិធីទី៤ ៖ ការងារទំនាក់ ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ថ្នាក់រាជធានី-ខេត្ត។

ក្នុងឆ្នាំ២០២២ នេះ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានសម្រេចនូវសមិទ្ធផលនានា ដែលមានជាសង្ខេបដូចខាងក្រោម៖

## ខ-សមិទ្ធផលការងារ

### ១-សកម្មភាពការងាររដ្ឋបាលកិច្ចការទូទៅ

១-១-ការងាររដ្ឋបាល

-បានទទួលលិខិតចូលពីក្រសួង-ស្ថាប័ននានាចំនួន១,៤៦១ច្បាប់ និងបញ្ជូនលិខិតចេញ ចំនួន១,៣២៦ច្បាប់។

-បានរៀបចំ និងបញ្ជូនសារលិខិតថ្វាយ និងជូនពរ ចំពោះព្រះមហាក្សត្រ សម្តេចព្រះមហាក្សត្រី និង ថ្នាក់ដឹកនាំកំពូលរបស់ជាតិ ក្នុងពីធីបុណ្យជាតិ-អន្តរជាតិ និងពិធីខួបកំណើត។

-បានគ្រប់គ្រងសរសេរខ្លឹមសារ និងថតសកម្មភាពការងារថ្នាក់ដឹកនាំ និងមន្ត្រីរាជការបញ្ចូលក្នុងគេហទំព័រផ្លូវការរបស់ក្រសួង។

-បានតាមដានរាល់សកម្មភាពព័ត៌មានដែលចេញតាមវេបសាយក្រសួង និងតាមប្រព័ន្ធ Facebook page។

-បានចូលរួមប្រជុំ និងពិធីបុណ្យជាតិនានា និងទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេសមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។

**១.២.ការងារបុគ្គលិក និងធនធានមនុស្ស**

-បានធ្វើសេចក្តីសម្រេច ចំនួន ២ ច្បាប់

-បានធ្វើសេចក្តីជូនដំណឹង ប្រកាសស្តីពីការតែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការ ការទទួលយកក្របខ័ណ្ឌមន្ត្រីរាជការមកពីក្រសួង-ស្ថាប័នផ្សេង ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការទៅក្រសួង-ស្ថាប័នផ្សេង

-បានធ្វើផែនការទិន្នន័យស្ថិតិបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីរាជការ ដែលទើបប្រឡងជាប់ថ្មី សម្រាប់ឆ្នាំ២០២២-២០២៣។

-បានធ្វើលិខិតណែនាំស្តីពីវិសមតភាពក្នុងការបំពេញមុខងារសាធារណៈ និងការប្រកបវិជ្ជាជីវៈជាមេធាវី របស់មន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានធ្វើលិខិតស្តីពីការតម្លើងថ្នាក់មន្ត្រីរាជការ ដែលត្រូវឡើងតាមសញ្ញាបត្រ។

-បានធ្វើលិខិតស្តីពីការចាត់បញ្ជូនគ្រូឧទ្ទេសនាមចំនួន២រូប ជំនាញច្បាប់ ការត្រួតពិនិត្យផលិតផលថ្នាំជក់ និងវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

-បានធ្វើលិខិតស្នើសុំនិយ័តឋានន្តរស័ក្តិ និងថ្នាក់ជូនមន្ត្រីរាជការចំនួន៤រូប។

-បានធ្វើសំណើស្នើសុំតម្លើងថ្នាក់ ឋានន្តរស័ក្តិ ជូនមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន៦០៨រូប សម្រាប់ឆ្នាំ២០២២។

-ការងារផ្សេងទៀត

***ការងារបណ្តុះបណ្តាល**

-បានរៀបចំ និងចាត់បញ្ជូនមន្ត្រីរាជការចំនួន១៣៦រូបចូលរួមវគ្គបណ្តុះបណ្តាលជំនាញផ្សេងៗនៅក្នុងប្រទេស ក្នុងនោះចំនួន២៤រូបតាមប្រព័ន្ធអនឡាញ និងក្រៅប្រទេសគ្មានរួមមាន៖

**១.៣.ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់**

-បានទូទាត់ឥណទានបើកសាច់ប្រាក់បេសកកម្មលើកទី៤ ឆ្នាំ២០២២។

-បានទូទាត់រង្វាន់ទេយ្យបុរេប្រទានជុំទី៤ ឆ្នាំ២០២២។

-បានទូទាត់ឥណទានបើកសាច់ប្រាក់មុនដំបូង វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងប្រជុំផ្សេងៗឆ្នាំ២០២២។

-បានទូទាត់ថ្លៃប្រើប្រាស់សេវានានា

-បានទូទាត់ប្រាក់បៀវត្សជូនថ្នាក់ដឹកនាំមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យាប្រចាំខែមករា-ធ្នូ ឆ្នាំ ២០២២។

-បានរៀបចំឯកសារប្រគល់-ទទួលសង្ហារិម និងសម្ភារប្រើប្រាស់ប្រចាំឆ្នាំ២០២២។

-បានរៀបចំឯកសារទូទាត់ប្រេងឥន្ធនៈប្រចាំឆ្នាំ២០២២។

-បានទូទាត់សង្ហារិម និងសម្ភារប្រើប្រាស់ប្រចាំឆ្នាំ២០២២។

-បានរៀបចំឯកសារទូទាត់សង្ហារិម និងបរិក្ខាបច្ចេកទេសមិនមែនព័ត៌មានវិទ្យា និងបរិក្ខាបច្ចេកទេសព័ត៌មានវិទ្យាប្រចាំឆ្នាំ២០២២។

-បានបែងចែកប្រេងឥន្ធនៈដោះស្រាយរាល់បេសកកម្ម សំណើផ្សេងៗជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ។

-បានបែងចែកសម្ភារការិយាល័យ សម្ភារបច្ចេកទេស និងដោះស្រាយរាល់បេសកកម្ម និងសំណើរផ្សេងៗ ជូនថ្នាក់ដឹកនាំនាយកដ្ឋានក្រោមឱវាទក្រសួង។

-ការងារផ្សេងទៀត

**១.៤.ការងារផែនការ និងស្ថិតិ**

-បានរៀបចំកែសម្រួល និងបញ្ចូលសកម្មភាពថ្មីៗមួយចំនួនទៀតលើគម្រោងថវិការជួសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។

-បានរៀបចំឯកសារកម្មវិធីវិនិយោគសាធារណៈ(ក.វ.ស)៣ឆ្នាំរំកិលឆ្នាំ២០២៣-២០២៥ ។

-បានរៀបចំកែសម្រួលមុខងារចំណាយឆ្នាំ២០២២ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យស្របតាមបច្ចុប្បន្នភាពនៃមាតិកាថវិកា(ចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី)។

-បានរៀបចំកែសម្រួលសូចនាករមួយចំនួនសម្រាប់កញ្ចប់ថវិកាឆ្នាំ២០២២ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យស្របតាមបច្ចុប្បន្នភាពនៃមាតិកាកម្មវិធី(សូចនាករ និងទិសដៅសូចនាករ)។

-បានរៀបចំឯកសារសម្រាប់ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ(២០២៣-២០២៥)។

-បានរៀបចំចងក្រងគម្រោងថវិការជួសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

-បានរៀបចំធាតុចូលក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជាឆ្នាំ ២០២៣-២០៣០ ដើម្បីតាមដានការអនុវត្តកម្មវិធីសកម្មភាព នៃសន្និសីទអន្តរជាតិស្តីពីប្រជាជន និងអភិវឌ្ឍ។

-ការងារផ្សេងទៀត

**១.៥.ការងារសហប្រតិបត្តិការអន្តរជាតិ**

-បានសម្របសម្រួលការជួបសវនាការការងារ រវាងថ្នាក់ដឹកនាំក្រសួងជាមួយលោកជំទាវឯកអគ្គរដ្ឋទូតសាធារណរដ្ឋឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា គណៈប្រតិភូសាធារណរដ្ឋសង្គមនិយមវៀតណាម ដឹកនាំដោយឯកឧត្តម DINH TIEN DUNG លេខា គណៈកម្មាធិការបក្សក្រុងហាណូយ និងគណៈប្រតិភូរណសិរ្សវៀតណាមដឹកនាំដោយឯកឧត្តម DO VAN CHIEN ប្រធានគណៈកម្មាធិការមជ្ឈិមរណសិរ្សមាតុភូមិវៀតណាម នៅទីស្តីការក្រសួង។

-បានសម្របសម្រួលលិខិតឆ្លងដែនផ្លូវការជូនថ្នាក់ដឹកនាំក្រសួងចំនួន២៧ច្បាប់។

-បានបកប្រែលិខិតអញ្ជើញ និងឯកសារផ្សេងៗចំនួន១៧ច្បាប់។

-បានចូលរួមកិច្ចប្រជុំ អន្តរក្រសួង ជាច្រើនលើក។

-បានពិភាក្សាលើខ្លឹមសារអនុស្សរណៈយោគយល់គ្នា រវាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងអធិការកិច្ចរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

-ការងារផ្សេងទៀត

## ២.សកម្មភាពការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

### ២.១.ការងារនីតិកម្ម

-បានចូលរួមប្រជុំអន្តរក្រសួង សិក្ខាសាលា និងកិច្ចប្រជុំនានាចំនួន៧លើក។

-បានចុះស្ទង់មតិស្តីពីការយល់ដឹង របស់ប្រជាពលរដ្ឋលើច្បាប់ចំនួន១៥លើក ដោយមានប្រជាពលរដ្ឋចូលរួមចំនួន១,៥២១នាក់(ស្ត្រីចំនួន៧១៥នាក់)។

-បានបញ្ចូលឯកសារច្បាប់ចំនួន៣៩ច្បាប់ទៅក្នុងបណ្ណាល័យអេឡិចត្រូនិច។

-ការងារផ្សេងទៀត

### ២.២.ការងារអប់រំផ្សព្វផ្សាយច្បាប់

-បានចុះផ្សព្វផ្សាយច្បាប់ចំនួន១៤៧លើក ដោយមានអ្នកចូលរួមចំនួន២០,៤២៩នាក់ (ស្ត្រីចំនួន៨,៣៧៧នាក់) និងទទួលបានសំណួរចំនួន៣,៩៤១សំណួរ។

-បានផលិតវីដេអូផ្សព្វផ្សាយដើម្បីចាក់ផ្សាយតាមទូរទស្សន៍ និងបណ្តាញសង្គម ចំនួន៩ប្រធានបទ រួមមាន៖

១. ច្បាប់ស្តីពីក្រមរដ្ឋប្បវេណី ២. ច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ៣. ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ៤. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ៥. ច្បាប់ស្តីពីក្រមរដ្ឋប្បវេណី ៦. ក្រមរដ្ឋប្បវេណី ៧. ច្បាប់ស្តីពីបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ៨. ច្បាប់ស្តីពីការរំលូតកូន ៩. អនុក្រឹត្យស្តីពីការគ្រប់គ្រង និងការប្រើប្រាស់អគារសហកម្មសិទ្ធិ។

-បានតាមដានពីវឌ្ឍនភាពនៃការផ្សព្វផ្សាយវីដេអូឃ្លីបសំណួរ-ចម្លើយច្បាប់ ដែលនាយកដ្ឋានផលិតបានក្នុងបណ្តាញសង្គម តាមរយៈផេក (Facebook Page) ចំនួន ៦ វីដេអូឃ្លីប។

-ការងារផ្សេងទៀត

### ២.៣.ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា

-បានចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រីចំនួន៥៧លើក។

-បានចូលរួមស្តាប់សម័យប្រជុំពេញអង្គរបស់រដ្ឋសភាចំនួន២៦លើក។

-បានចូលរួមស្តាប់សម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភាចំនួន១៩លើក។

-បានរៀបចំវេទិកាសាធារណៈដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋចំនួន៦លើក ដោយមានប្រជាពលរដ្ឋចូលរួមចំនួន៤៩៥នាក់ (១៣៩នាក់) និងបានទទួលសំណូមពរពីប្រជាពលរដ្ឋចំនួន៧២សំណូមពរ។

### ៣.សកម្មភាពការងារអធិការកិច្ច

#### ៣.១.ការងារអធិការកិច្ច (វិស័យសេដ្ឋកិច្ច រដ្ឋបាល និងសង្គមកិច្ច)

-ចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅអង្គភាពមួយចំនួន។

-ឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំរដ្ឋបាលខេត្ត ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅអង្គភាពមួយចំនួន។

-បានបញ្ចប់ការចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅស្ថាប័ន អង្គភាព មួយចំនួន។

-បានចេញលិខិតជូនដំណឹងទៅក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងពាណិជ្ជកម្ម ដើម្បីជំរុញឱ្យធ្វើការកែលម្អចំណុចខ្វះខាតលើការអនុវត្តតួនាទីភារកិច្ច និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងត្រួតពិនិត្យនូវបណ្តាវិធានការរបស់គណៈប្រតិភូអធិការកិច្ចក្រសួង។

-បានទទួលរបាយការណ៍ជូនជ្រាប ពីបណ្តាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន១៨ ។

***លទ្ធផលការងារអធិការកិច្ច (វិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច)**

-បានចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ច ការគ្រប់គ្រងផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្ម សាធារណៈ តាមបណ្តាក្រសួងចំនួន១២ អង្គភាព ជុំវិញរាជធានី-ខេត្ត ចំនួន២៥រាជធានី-ខេត្ត។

-បានធ្វើលិខិតជូនដំណឹងទៅក្រសួងពាណិជ្ជកម្ម ក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត កងវិស្វកម្ម និងអង្គភាពពាក់ព័ន្ធ ក្រសួងធនធានទឹក និងឧតុនិយម មន្ទីរធនធានទឹក និងឧតុនិយមរាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធ និងក្រសួងសាធារណការ និងដឹកជញ្ជូន មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត កងវិស្វកម្ម និងអង្គភាពពាក់ព័ន្ធ ដើម្បីជំរុញឱ្យធ្វើការកែលម្អចំណុចខ្វះខាតលើការអនុវត្តតួនាទីភារកិច្ច។

#### ៣.៤.ការងារតាមដានការអនុវត្តច្បាប់

-បានឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំខេត្តស្តីពីលទ្ធផល នៃការចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល អនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច កិច្ចសន្យាវិនិយោគធ្វើអាជីវកម្មយកភាស៊ី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តពោធិ៍សាត់ ស្ទឹងត្រែង បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ចាម ព្រះវិហារ និងមណ្ឌលគិរី។

-បានផ្ញើលិខិតជូនដំណឹងទៅក្រសួង-ស្ថាប័ន ដើម្បីឱ្យធ្វើការជំរុញទៅមន្ទីរ-អង្គភាព ម្ចាស់ក្រុមហ៊ុន ម្ចាស់សហគ្រាស និងម្ចាស់សិប្បកម្ម ឱ្យកែលម្អនូវចំណុចខ្វះខាតដែលបានរកឃើញនៅខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តក្រចេះ។

-បានចុះតាមដានការអនុវត្តច្បាប់(មន្ទីររាជធានីខេត្ត)៖ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីព្រៃឈើ ច្បាប់ភូមិបាលនៅខេត្តឧត្តរមានជ័យ ច្បាប់ស្តីពីព្រៃឈើ ច្បាប់លើវិស័យកសិកម្ម ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង ច្បាប់ស្តីពីបរិស្ថាន នៅខេត្តស្វាយរៀង ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកកម្ម ច្បាប់ស្តីពីផ្លូវថ្នល់ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ អនុក្រឹត្យលេខ១៩៧ អនក្រ.បកស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិផ្លូវថេភ្លើង និងការកំណត់ដែនព្រៃលិចទឹកតំបន់៣ ការគ្រប់គ្រងរដ្ឋបាល-ថវិការដ្ឋ និងថវិកាផ្សេងៗតាមវិទ្យាល័យចំនួន១៦។

-ចុះតាមដាន ការអនុវត្តន៍គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពនៅខេត្តកំពង់ចាម

-ចុះត្រួតពិនិត្យការគ្រប់គ្រង និងការប្រមូលចំណូលភាស៊ីនៅតាមបណ្តាផ្សាររដ្ឋចំនួន២៥ នៅរាជធានីភ្នំពេញ ការគ្រប់គ្រងរដ្ឋបាល-ហិរញ្ញវត្ថុរបស់គណៈគ្រប់គ្រងសាលាតាមបណ្តាសាលារៀនរដ្ឋចំនួន៤៩ នៅខេត្តកំពង់ស្ពឺ

-ចូលរួមចុះពិនិត្យ និងទប់ស្កាត់ការកាប់រានដីព្រៃខុសច្បាប់ ការប្រើប្រាស់គ្រឿងចក្រខុសច្បាប់ ការនេសាទខុសច្បាប់ ចូលរួមចុះពិនិត្យ និងវាស់វែងឈើជាក់ស្តែងដែលក្រុមការងារបានរឹបអូសក្នុងរបៀងអភិរក្សជីវៈចម្រុះតំបន់ការពារធម្មជាតិស្ថិតនៅឃុំដាឡាត់ ស្រុកសេសាន ។

-ចូលរួមជាមួយប្រតិភូអន្តរក្រសួងពិនិត្យទីតាំងដីស្នើសុំកែសម្រួលព្រំប្រទល់តំបន់២ និងតំបន់៣ នៃបឹង ទន្លេសាប ក្នុងភូមិសាស្ត្រស្រុកកំពង់លែង

-ចូលរួមសហការជាមួយប្រតិភូក្រសួងបរិស្ថានចុះពិនិត្យជាក់ស្តែង លើករណីសំណើចូលរួមសហការលើកិច្ចការពារ និងអភិរក្សតំបន់ប្រើប្រាស់ច្រើនយ៉ាង (ភ្នំនាងកង្រី-ភ្នំទូកមាស) លើផ្ទៃដីទំហំប្រមាណ ១,២៧២ហិកតាក្នុងភូមិសាស្ត្រឃុំពោធិ៍ និងឃុំប្រណូក ស្រុកកំពង់លែងខេត្តកំពង់ឆ្នាំង។

**៣.៥.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ**

ក្រសួងបានទទួលពាក្យបណ្តឹងចំនួន៨១ បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៣៨បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៤៣ បណ្តឹង)៖

-ពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួងចំនួន៩បណ្តឹង(ឆ្នាំ២០២២ ចំនួន៩បណ្តឹង)។

-ពាក្យបណ្តឹងដែលជាសមត្ថកិច្ចមន្ទីររាជធានី-ខេត្តចំនួន៣៧បណ្តឹង(ឆ្នាំ២០២២ ចំនួន៣៧បណ្តឹង)។

-ពាក្យបណ្តឹងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួងចំនួន៥បណ្តឹង(ឆ្នាំ២០២២ ចំនួន៥បណ្តឹង)។

-ពាក្យបណ្តឹងបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយ ចំនួន២១បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន១៨បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៣បណ្តឹង ក្នុងនោះ ឆ្នាំ២០២១ ចំនួន៤បណ្តឹង ឆ្នាំ២០២២ ចំនួន១៧បណ្តឹង)។

-ពាក្យបណ្តឹងដែលថ្នាក់ដឹកនាំក្រសួងសម្រេច តម្កល់ទុកមិនចាត់ការ ចំនួន ៩បណ្តឹង (ឆ្នាំ២០២០ ចំនួន១ បណ្តឹង ឆ្នាំ២០២១ ចំនួន១បណ្តឹង ឆ្នាំ២០២២ ចំនួន៧បណ្តឹង) ។

-ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងសុំដកវិញ ចំនួន៥បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន ២បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៣បណ្តឹង ក្នុងនោះឆ្នាំ២០២១ ចំនួន២បណ្តឹង ឆ្នាំ២០២២ ចំនួន ៣បណ្តឹង)។

-ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងបានបោះបង់ចោលចំនួន៣បណ្តឹង(មន្ទីររាជធានី-ខេត្ត ឆ្នាំ២០២២ ចំនួន៣បណ្តឹង)។

-ពាក្យបណ្តឹងកំពុងសម្របសម្រួលថ្នាក់ក្រសួងចំនួន៣បណ្តឹង(ឆ្នាំ២០២១ ចំនួន២បណ្តឹង ឆ្នាំ២០២២ ចំនួន១បណ្តឹង)។

-ពាក្យបណ្តឹងកំពុងចុះអង្កេតស្រាវជ្រាវចំនួន៤០បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ច ចំនួន១៦ បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន២៤បណ្តឹង ក្នុងនោះឆ្នាំ២០១៦ ចំនួន១បណ្តឹង ឆ្នាំ២០១៩ ចំនួន២បណ្តឹង ឆ្នាំ២០២០ ចំនួន២បណ្តឹង ឆ្នាំ២០២១ ចំនួន៩បណ្តឹង ឆ្នាំ២០២២ ចំនួន២៦បណ្តឹង)។

-ពាក្យបណ្តឹងត្រៀមចុះអង្កេតស្រាវជ្រាវចំនួន១បណ្តឹង(ឆ្នាំ២០២២ ចំនួន១បណ្តឹង)។

-ពាក្យបណ្តឹងបានទទួលការឆ្លើយតបចំនួន១១បណ្តឹង(ឆ្នាំ២០១៦ ចំនួន១បណ្តឹង ឆ្នាំ២០២១ ចំនួន៦បណ្តឹង ឆ្នាំ២០២២ ចំនួន៤បណ្តឹង)។

-ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងសុំជំរុញការដោះស្រាយចំនួន៣បណ្តឹង (ឆ្នាំ២០១៦ ចំនួន១ បណ្តឹង ឆ្នាំ២០២១ ចំនួន២បណ្តឹង)។

-ពាក្យបណ្តឹងក្រសួងបានធ្វើលិខិតជំរុញការដោះស្រាយចំនួន១បណ្តឹង (ឆ្នាំ២០២១ ចំនួន១ បណ្តឹង)។

-ពាក្យបណ្តឹងបានធ្វើរបាយការណ៍គោរពជូនឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ ពិនិត្យសម្រេចចំនួន១បណ្តឹង (មន្ទីររាជធានី-ខេត្ត ឆ្នាំ២០២២ ចំនួន១ បណ្តឹង) ។

-ពាក្យបណ្តឹងបានបញ្ចប់ការដោះស្រាយ ចំនួន៤៨បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ច ចំនួន៣១បណ្តឹងនិងមន្ទីររាជធានី-ខេត្តចំនួន១៧បណ្តឹង ក្នុងនោះឆ្នាំ២០១៧ ចំនួន១បណ្តឹង ឆ្នាំ ២០១៩ ចំនួន៦បណ្តឹង ឆ្នាំ២០២០ ចំនួន៤បណ្តឹង ឆ្នាំ២០២១ ចំនួន១០បណ្តឹង ឆ្នាំ២០២២ ចំនួន ២៧បណ្តឹង)។

៤.សកម្មភាពការងារសវនកម្មផ្ទៃក្នុង

-បានចុះធ្វើសវនកម្មលើការដឹកនាំ និងការគ្រប់គ្រងធនធានមនុស្ស ទ្រព្យសម្បត្តិរដ្ឋ ការប្រើប្រាស់ចំណូល-ចំណាយថវិការដ្ឋ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពត ព្រះសីហនុ កំពង់ឆ្នាំង ពោធិ៍សាត់ ត្បូងឃ្មុំ ក្រចេះ កំពង់ធំ សៀមរាប បាត់ដំបង ប៉ៃលិន និងខេត្តឧត្តរមានជ័យ។

-បានចូលរួមវគ្គបណ្តុះបណ្តាល ទាក់ទងនឹង ជំនាញសវនកម្ម ចំនួន ២លើក

-បានចូលរួមសិក្ខាសាលាទាក់ទងនឹងជំនាញសវនកម្មផ្ទៃក្នុង ចំនួន ៣លើក។

## ៥.សកម្មភាពការងារវិទ្យាស្ថានជាតិអធិការកិច្ច

-បានស្រាវជ្រាវ និងរៀបចំចងក្រងជាសៀវភៅស្តីពីរបៀបប្រើប្រាស់កម្មវិធី Zoom និងGoogle Meet។

-បានស្រាវជ្រាវ និងចងក្រងអនុសាសន៍សម្តេចតេជោសរុបចំនួន១៤០ច្បាប់ និងស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តនានាសរុបចំនួន៩១៣ច្បាប់។

-បានបង្កើតក្រុមគ្រូបង្គោលជំនាញវិជ្ជាជីវៈអធិការកិច្ចចំនួន៩រូប សម្រាប់វិទ្យាស្ថាន។

-បានធ្វើរបាយការណ៍សម្រង់ទិន្នន័យមន្ត្រីអធិការកិច្ចបានទទួល និងមិនទាន់បានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចគោរពជូនរដ្ឋមន្ត្រី។

-បានចុះស្ទង់មតិអំពីការគ្រប់គ្រង និងការអភិវឌ្ឍការងារអធិការកិច្ចនៅមន្ទីរ ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន ៦ ខេត្ត។

-បានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចបឋមជំនាន់៤ បានចំនួន៤វគ្គ ដល់មន្ត្រីរាជការចំនួន៩០រូប ដែលមកពីក្រសួង-ស្ថាប័នផ្សេងៗចំនួន១០។

-បានធ្វើសម្រង់ស្ទង់មតិយោបល់សិក្ខាកាមចំនួន២លើក អំពីការវាយតម្លៃវគ្គបណ្តុះបណ្តាល និងគ្រូឧទ្ទេសនាម។

-បានទទួលសៀវភៅអានចម្រុះចំនួន៥១៥ក្បាល និងបោះពុម្ពសៀវភៅ ចំនួន៣២ក្បាលបន្ថែមដាក់ក្នុងបណ្ណាល័យវិទ្យាស្ថាន។

-សកម្មភាពផ្សេងទៀត

# ៦.សកម្មភាពការងារផ្សេងៗ

## ៦.១.សកម្មភាពការងារយេនឌ័រ

-សមាសភាពស្ត្រីក្នុងមុខតំណែងរួមមាន៖ នៅថ្នាក់កណ្តាល ស្ត្រីជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ១ រូប ជារដ្ឋលេខាធិការចំនួន ៧រូប អនុរដ្ឋលេខាធិការ ១រូប ទីប្រឹក្សាក្រសួងចំនួន ២៧រូប អនុប្រធាននាយកដ្ឋានចំនួន ២១ រូប ប្រធានការិយាល័យចំនួន១០រូប អនុប្រធានការិយាល័យចំនួន៦៣រូប និងថ្នាក់រាជធានី-ខេត្ត ស្ត្រីជាប្រធានមន្ទីរចំនួន ២រូប អនុប្រធានមន្ទីរចំនួន៣រូប ប្រធានការិយាល័យចំនួន៩រូប អនុប្រធានការិយាល័យ ចំនួន ១៤រូប។ បើគិតជាភាគរយនៅទីស្តីការក្រសួង និងមន្ទីររាជធានី-ខេត្ត មន្ត្រីរាជការជាស្ត្រី ក្នុងមុខតំណែងធៀបទៅនឹងឆ្នាំ២០២១ គឺមានការកើនឡើង៣៣%។

-ក្រុមការងារបច្ចេកទេសយេឌ័របានសួរសុខទុក្ខផ្ទាល់ និងចាត់ប្រតិភូចុះសួរសុខទុក្ខមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ច សន្យាជាស្ត្រីបានសម្រាលមាតុភាពចំនួន៦រូប និងឧបត្ថម្ភថវិកាសរុបចំនួន ៤.២០០.០០០រៀល ក្នុងនោះ ថវិកាផ្ទាល់លោកជំទាវកិត្តិសង្គហបណ្ឌិឧបនាយករដ្ឋមន្ត្រី ឧបត្ថម្ភក្នុង១នាក់ ចំនួន៥០ម៉ឺនរៀល។

-បានឧបត្ថម្ភថវិកា ចំនួន២០០,០០០រៀល ជូនគ្រួសារមន្ត្រីជាប់កិច្ចសន្យា ទទួលមរណៈភាពចំនួន១រូប។

-ក្នុងឱកាសខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២២ លោកជំទាវកិត្តិសង្គហបណ្ឌិតឧបនាយករដ្ឋមន្ត្រី និងក្រុមការងារបច្ចេកទេសយេនឌ័រ បានយកចិត្តទុកដាក់ ឧបត្ថម្ភ

ថវិកាចំនួន៥ម៉ឺនរៀល និងវត្ថុអនុស្សាវរីយ៍ ជូនថ្នាក់ដឹកនាំ ទីប្រឹក្សា មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យាជាស្ត្រីទាំងអស់ ព្រមទាំង បានឧបត្ថម្ភថវិកាចំនួន៥ម៉ឺនរៀល ជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាជាបុរសក្នុងម្នាក់ៗ។

**៦.២.សកម្មភាពការងារចងសម្ព័ន្ធមេត្រីភាព**

តំណាងក្រសួង និងតំណាងក្រុមហ៊ុនម៉ុង ឫទ្ធីគ្រុបបានចុះសួរសុខទុក្ខ និងនាំយកនូវអំណោយជាថវិកា សម្ភារ និងគ្រឿងឧបភោគបរិភោគ ជូនវរសេនាតូចនគរបាលការពារព្រំដែនទឹកលេខ ២៦៩ និងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨២៧ សរុបការឧបត្ថម្ភទាំងអស់ គិតជាទឹកប្រាក់មានចំនួន ៨០,២៨០,០០០ រៀល និងចំនួន១១,០០០ដុល្លារអាមេរិក។

**៦.៣. សមាគមសង្គហមិត្តភាព**

-ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២២ សមាជិក សមាជិកា សមាគមសង្គហមិត្តភាពមានចំនួន៤៣៧នាក់ នៅថ្នាក់កណ្តាល ចំនួន២៥១នាក់ នៅមន្ទីរ។

-សមាគមសង្គហមិត្តភាពក៏បានឧបត្ថម្ភប្រាក់ជូនដល់មន្ត្រីរាជការ ដែរទទួលមរណភាព ចំនួន២នាក់ ។

**៦.៤.សកម្មភាពការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង**

បានស្នើសុំគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនក្រសួងចំនួន១៥៩នាក់។

**៦.៥.សកម្មភាពការងារក្រុមការងារសង្រង់ព័ត៌មាន និងខ្លឹមសារអនុសាសន៍ របស់សម្តេចតេជោនាយរដ្ឋមន្ត្រី និងឥស្សរជនជាន់ខ្ពស់**

-ក្រុមការងារបានដកស្រង់ និងចងក្រងអនុសាសន៍សម្តេចតេជោនាយករដ្ឋមន្ត្រី បានដាក់ចេញជាបន្តបន្ទាប់តាមរយៈការថ្លែងសុន្ទរកថានៅក្នុងពិធីផ្សេងៗ សរុបចំនួន១០០លើក រួមមាន៖ ខែមករាចំនួន៤លើក ខែកុម្ភៈចំនួន១១លើក ខែមីនាចំនួន៦លើក ខែមេសាចំនួន១០លើក ខែឧសភាចំនួន៨លើក ខែមិថុនាចំនួន៤លើក ខែកក្កដា ចំនួន៥លើក ខែសីហាចំនួន៧លើក ខែកញ្ញាចំនួន៦លើក ខែតុលា ចំនួន១៨លើក ខែវិច្ឆិកាចំនួន១១លើក និងខែធ្នូ ចំនួន១០លើក។

**៦.៦.សកម្មភាពការងារគេហទំព័រ MONASRI.GOV.KH និង MONASRI App**

-ក្រុមកាងារឌីជីថលបានចូលរួមសិក្ខាសាលាស្តីពីកម្មវិធីព័ត៌វិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅអង្គភាព- ការិយាល័យច្រកចេញចូលតែមួយ។

-ក្រុមការងារឌីជីថលបានចូលរួមសិក្ខាសាលា និងចូលប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់និង ការងារទាក់ទងនឹង រដ្ឋាភិបាលឌីជីថល

-ចូលរួមវគ្គបណ្តុះបណ្តាល

-បានស្រាវជ្រាវឯកសារពាក់ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍។

-បានបញ្ចូលព័ត៌មាន សេចក្តីជូនដំណឹង និងឯកសារផ្សេងៗ ក្នុង វេបសាយ និងផេក។

-បានរៀបចំប្រព័ន្ធទទួលពាក្យបណ្តឹងតាមអនឡាញ។

-បានធ្វើការចុះផ្សាយព័ត៌មាន និងសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងស្ថាប័នក្រោម ចំណុះក្រសួងសរុបចំនួន៦១២ គឺលោកជំទាវឧបនាយករដ្ឋមន្ត្រីចំនួន២៦៩ ថ្នាក់ដឹកនាំក្រសួងចំនួន៨៤ វិទ្យាស្ថានជាតិអធិការកិច្ចចំនួន៤៥ មន្ទីរទរពអ រាជធានី-ខេត្តចំនួន១៦៤ និងលិខិតផ្សេងៗចំនួន៤៩។

**៦.៧. ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS ៖**

-ក្រុមការងារកែទម្រង់ ដែលក្នុងនោះ នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ និងមន្ត្រីបង្គោល បានរៀបចំរបាយការណ៍ប្រៀបធៀបផែនការ ចំណាយតាមកម្មវិធីប្រចាំ ត្រីមាសនីមួយៗ

-ផែនការសាច់ប្រាក់របស់ក្រសួងប្រចាំត្រីមាសនីមួយៗ ត្រូវបានបញ្ចូលក្នុងប្រព័ន្ធCMS។

-ផែនការលទ្ធកម្មឆ្នាំ២០២៣ត្រូវបានរៀបចំ និងអនុម័តមុនថ្ងៃទី៣១ ខែធ្នូ២០២២។

-សេចក្តីជូនដំណឹងស្តីពីការចូលរួមដេញថ្លៃប្រកួតប្រជែងរបស់អង្គភាពលទ្ធកម្ម ឆមាសទី១-ទី២ ត្រូវបានផ្សព្វផ្សាយ។

-អង្គភាពលទ្ធកម្ម បានរៀបចំរបាយការណ៍កិច្ចលទ្ធកម្មក្រោមសិទ្ធិឆមាសទី១-ទី២ បញ្ជូន ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ផែនការរដ្ឋទេយ្យបុរេប្រទានឆ្នាំ២០២៣ ត្រូវបានអនុម័ត យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

-បានទូទាត់ថវិការដ្ឋទេយ្យបុរេប្រទានប្រចាំត្រីមាស(ជុំទី១-៤) ឱ្យទាន់ពេលវេលា។

-នីតិវិធីចំណាយកម្រិត១ និងកម្រិត២ ត្រូវបានអនុវត្តតាមប្រព័ន្ធFMIS។

-កិច្ចការលទ្ធកម្មពេញលេញក្នុងឆមាសទី១-ទី២ ត្រូវបានក្រុមការងារFMIS បញ្ចូលក្នុងប្រព័ន្ធ។

-បានចូលរួមប្រជុំ និងវគ្គបណ្តុះបណ្តាលជាមួយក្រុមការងារFMIS ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-របាយការណ៍អនុវត្តថវិកាប្រចាំខែត្រីមាសនីមួយៗត្រូវបានផលិតចេញពីប្រព័ន្ធFMIS និងធ្វើដោយដៃ (Manual Ms Excel) ។

-បានរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋកើន ថយ ប្រចាំឆ្នាំ២០២២។

-បានបញ្ចូលទិន្នន័យបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ក្នុងប្រព័ន្ធប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (SARMIS)។

-បានរៀបចំសិក្ខាសាលាស្តីពីសវនកម្មលើបច្ចេកវិទ្យាព័ត៌មាន។

-បានរៀបចំតារាងសូចនាករសមិទ្ធកម្មគន្លឹះ (KPI) និងតារាងតម្រូវការថវិកាសម្រាប់ការអនុវត្តឆ្នាំ២០២៣ និងបានផ្ញើជូនអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យទាន់ពេលវេលា។

## គ-បញ្ហាប្រឈម

ទន្ទឹមនឹងលទ្ធផលទទួលបានខាងលើ ក្រសួងនៅជួបបញ្ហាប្រឈមមួយចំនួនដូចជា៖

-កង្វះច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។

-កង្វះថវិកាបុរេប្រទាន មធ្យោបាយធ្វើដំណើររបស់រដ្ឋ និងសម្ភារបច្ចេកវិទ្យាគ្រប់គ្រាន់សម្រាប់ចុះបំពេញបេសកកម្ម។

-មិនទាន់បានអនុវត្តអង្គភាពថវិកាអង្គភាពថវិកាអាណាបកផ្ទេរសិទ្ធពេញលេញ។

-ពុំទាន់មានដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិជួយគាំទ្រលើវិស័យអធិការកិច្ចឱ្យបានទូលំទូលាយ។

-កិច្ចសហការរបស់ក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធមួយចំនួនលើការងារអធិការកិច្ច ការងារតាមដានការអនុវត្តច្បាប់ និងការងារអង្កេតស្រាវជ្រាវបណ្ដឹងនៅមានកម្រិត។

-របាយការណ៍អធិការកិច្ចមិនទាន់ឯករាជ្យ ដោយតម្រូវឱ្យប្រធានស្ថាប័ន ឬប្រធានអង្គភាពរងអធិការកិច្ច ចុះហត្ថលេខាលើលទ្ធផលអធិការកិច្ច។

-ពុំទាន់មានសម្ភារការិយាល័យ និងសម្ភារបរិក្ខាបច្ចេកទេសគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ និងសម្រួលដល់ប្រសិទ្ធភាពក្នុងការបំពេញការងារប្រចាំថ្ងៃរបស់វិទ្យាស្ថានជាតិអធិការកិច្ច។

## ឃ.ទិសដៅការងារបន្ត

ដើម្បីចូលរួមគាំទ្រ និងអនុវត្តតាមយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួង មានទិសដៅ គោលនយោបាយ និងយុទ្ធសាស្ត្រច្បាស់លាស់អនុវត្តតាមបេសកកម្មតួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ខ្លួនស្របតាមសភាពការជាក់ស្តែង ប្រកបដោយប្រសិទ្ធភាព ដោយត្រូវផ្តោតលើសកម្មភាពអាទិភាព ដូចខាងក្រោម៖

### ១. រដ្ឋបាលកិច្ចការទូទៅ

#### ១-១-ការងាររដ្ឋបាល

-បន្តទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងការចូលរួមពិធីបុណ្យជាតិ អន្តរជាតិ និងពិធីបុណ្យផ្សេងៗទៀត។

-បន្តអនុវត្តចរន្តការងាររដ្ឋបាលឱ្យកាន់តែប្រសើរ។

-បន្តទំនាក់ទំនងកិច្ចសហការជាមួយរដ្ឋបាលថ្នាក់កណ្តាល គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសជាមួយរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី។

-បន្តគ្រប់គ្រងកិច្ចការរដ្ឋបាលក្រសួងឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងបន្តកែលម្អ ដោយធ្វើការសម្របសម្រួលគ្រប់បណ្តាអង្គភាព និងមន្ទីររាជធានី-ខេត្ត ជាពិសេសបន្តចូលរួមគ្រប់កំណែទម្រង់រដ្ឋបាលសាធារណៈ ឱ្យស្របតាមតួនាទីភារកិច្ចរបស់ក្រសួង និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

#### ១-២-ការងារបុគ្គលិក និងធនធានមនុស្ស

-បន្តទំនាក់ទំនង និងសម្របសម្រួលជាមួយក្រសួងមុខងារសាធារណៈលើការងារបុគ្គលិក និងធនធានមនុស្ស។

-បន្តអនុវត្តនូវរាល់ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ របស់រាជរដ្ឋាភិបាល។

-បន្តធ្វើទំនាក់ទំនងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងការដាក់មន្ត្រី រាជការឱ្យចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ ឬបាត់បង់សមត្ថភាពការងារ។

-ពង្រឹងការងារពិនិត្យផ្តល់ទិដ្ឋាការលើរបាយការណ៍ស្តីពីស្ថានភាពរដ្ឋបាល និងស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការថ្នាក់រាជធានី-ខេត្តឱ្យបានទាន់ពេលវេលា។

**១-៣-ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់**

-ត្រៀមទូទាត់លើការប្រើប្រាស់អគ្គិសនី ទឹក ទូរស័ព្ទ តាមវិក័យបត្រជាក់ស្តែង ដែលផ្តល់ឡើងដោយអ្នកផ្គត់ផ្គង់។

-ត្រៀមទូទាត់ថ្លៃប្រើប្រាស់ទឹក អគ្គិសនី ទូរស័ព្ទ(Mobitel) ទូរស័ព្ទទូរស័ព្ទ (IDD) ប្រចាំខែ នៅឆ្នាំ២០២៣។

-ត្រៀមទូទាត់រង្វាន់ទេយ្យបុរេប្រទានតាមជុំ ប្រចាំឆ្នាំ ឆ្នាំ២០២៣។

-ត្រៀមទូទាត់បេសកកម្មឆ្នាំ២០២២ ឆ្នាំ២០២៣។

-ត្រៀមរៀបចំឯកសារស្នើសុំជានាចំណាយសម្ភារប្រើប្រាស់ប្រចាំឆ្នាំ២០២៣។

-រៀបចំឯកសារចំណាយថវិកាទូទៅរបស់ក្រសួងចំនួន៤ត្រីមាសប្រចាំឆ្នាំ២០២៣។

-ត្រៀមបែងចែកប្រេងឥន្ធនៈ ដោះស្រាយរាល់សំណើផ្សេងៗជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការ។

-ត្រៀមរៀបចំបែងចែកសម្ភារការិយាល័យ សម្ភារបច្ចេកទេស និងដោះស្រាយរាល់សំណើផ្សេងៗជូនថ្នាក់ ដឹកនាំគ្រប់នាយកដ្ឋាន។

-ត្រៀមចូលរួមផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមបណ្តាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

១-៤-ការងារផែនការ និងស្ថិតិ

-ពិនិត្យតាមដាន និងវាយតម្លៃលើប្រតិទិនការងារសម្រាប់ការិយាល័យដើម្បីអនុវត្តឆ្នាំ២០២៣។

-ត្រៀមបំពេញការងារស្នូលរបស់នាយកដ្ឋានក្នុងឆ្នាំ២០២៣ ឱ្យកាន់តែប្រសើរឡើង និងតាមការកំណត់។

-ត្រៀមចូលរួមវគ្គបណ្តុះបណ្តាលលើការងារកសាងផែនការ និងគម្រោងផ្សេងៗ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យកាន់តែមានប្រសិទ្ធភាព។

-រៀបចំបូកសរុបរបាយការណ៍លទ្ធផលការអនុវត្តថវិកាកម្មវិធី ប្រចាំឆ្នាំ២០២២ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី-ខេត្តទាំង២៥នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

**១-៥-ការងារសហប្រតិបត្តិការអន្តរជាតិ**

-បន្តទំនាក់ទំនង និងសហប្រតិបត្តិការជាមួយស្ថានទូតចិន និងក្រសួងត្រួតពិនិត្យនៃសាធារណរដ្ឋប្រជាមានិតចិន និងអធិការកិច្ចរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីត្រៀមជំរុញអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងស្ថាប័នទាំងពីរ។

-បន្តទំនាក់ទំនងពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ។

-បន្តទំនាក់ទំនងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-បន្តការសិក្សាស្រាវជ្រាវបណ្ដាប្រទេសជាសមាជិកអាស៊ាន និងអង្គការអន្តរជាតិ។

-ត្រៀមចូលរួមអនុវត្តការងារដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ២-ការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា

### ២.១.ការងារនីតិកម្ម

-បន្តពិនិត្យ និងពិភាក្សាបន្ថែមលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច ដើម្បីផ្ញើទៅក្រសួងពាក់ព័ន្ធ។

-បន្តចូលរួមពិនិត្យ និងប្រមូលឯកសារទាក់ទងនឹងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច និងច្បាប់នានា។

-ត្រៀមរៀបចំឯកសារកម្រងសំណួរ ដើម្បីចុះទៅស្ទង់មតិច្បាប់ នៅតាមបណ្តាឃុំ ស្រុក នៃខេត្តគោលដៅសម្រាប់ឆ្នាំ២០២៣។

-បន្តទំនាក់ទំនងរៀបចំការប្រជុំការតាក់តែងសេចក្តីព្រាងច្បាប់ សេចក្តីព្រាងអនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ឱ្យ។

-បន្តទទួលអនុវត្តសកម្មភាពការងារផ្សេងៗទៀត របស់ថ្នាក់ដឹកនាំក្រសួងប្រគល់ឱ្យ។

### ២.២.ការងារអប់រំផ្សព្វផ្សាយច្បាប់

-សិក្សាស្រាវជ្រាវទៅលើអនុក្រឹត្យស្តីពីការកែសម្រួល និងឯកសារពាក់ព័ន្ធ និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដើម្បីពង្រឹងនូវសមត្ថភាពបន្ថែមរបស់មន្ត្រីក្នុងការិយាល័យ។

-បោះពុម្ពឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់ផ្តត់ផ្គង់ការផ្សព្វផ្សាយច្បាប់ស្របតាមផែនការឆ្នាំ២០២៣។

-សិក្សាស្រាវជ្រាវទៅលើច្បាប់ អនុក្រឹត្យស្តីពីការកែសម្រួល និងឯកសារពាក់ព័ន្ធ ដើម្បីចុះធ្វើការស្ទាបស្ទង់ការយល់ដឹងរបស់ប្រជាពលរដ្ឋ តាមផែនការដែលបានកំណត់។

-សិក្សាឯកសារច្បាប់ សិក្សាពីកម្រងសំណួរ។

### ២.៣.ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា-ព្រឹទ្ធសភា

-ចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី។

-ចូលរួមស្តាប់សម័យប្រជុំនៅរដ្ឋសភា-ព្រឹទ្ធសភា
និងបន្តសកម្មភាពចុះអមដំណើរជាមួយតំណាងរាស្ត្រ និង
គណៈកម្មការនានានៃរដ្ឋសភាជាតិ និងអមដំណើរជាមួយគណៈកម្មការនានា ក្រុមសមាជិកព្រឹទ្ធសភាតាមភូមិភាគ និងក្រុមសមាជិក សមាជិកានៃព្រឹទ្ធសភា។

-បន្តធ្វើការទំនាក់ទំនងជាមួយមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចតាមបណ្តាខេត្ត ដើម្បីរៀបចំធ្វើវេទិកាសាធារណៈតាមផែនការឆ្នាំ២០២៣។

## ៣.ការងារអធិការកិច្ច

### ៣.១.ការងារអធិការកិច្ច(លើវិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច)

-បន្តចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅអង្គភាព រដ្ឋាករ

ទឹកស្វយ័តក្រុងភ្នំពេញ និងរដ្ឋាករទឹកស្វយ័ត សៀមរាប និងរដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលក្រុង-ស្រុក-ខណ្ឌ សាលាដំបូងរាជធានី-ខេត្ត ពន្ធជានាគាររាជធានី-ខេត្ត ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត អធិការដ្ឋាននគរបាលក្រុង-ស្រុក-ខណ្ឌ មន្ទីរ-អង្គភាពជុំវិញរាជធានី-ខេត្ត អង្គភាពក្រោមឱវាទ និងអង្គភាពពាក់ព័ន្ធ នៅរាជធានីភ្នំពេញ ខេត្តពោធិ៍សាត់ និងខេត្តព្រះវិហារ។

-ត្រៀមឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំខេត្តស្តីពីលទ្ធផលចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ច ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង-ស្រុក សាលាដំបូងខេត្ត ពន្ធនាគារខេត្ត ស្នងការដ្ឋាននគរបាលខេត្ត អធិការដ្ឋាននគរបាលក្រុង-ស្រុក មន្ទីរ-អង្គភាពជុំវិញខេត្ត អង្គភាពក្រោមឱវាទ និងអង្គភាពពាក់ព័ន្ធ នៅខេត្តព្រះសីហនុ កែប ប៉ៃលិន កណ្តាល កំពង់ចាម កំពង់ឆ្នាំង សៀមរាប មណ្ឌលគិរី ស្វាយរៀង និងខេត្តកំពង់ធំ។

-ត្រៀមឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងវប្បធម៌ វិចិត្រសិល្បៈ ក្រសួងសុខាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា ស្តីពីលទ្ធផលចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ច ការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

-ត្រៀមធ្វើលិខិតជូនដំណឹងទៅអង្គភាពមួយចំនួន ដើម្បីជំរុញឱ្យការកែលម្អចំណុចខ្វះខាតលើការអនុវត្តតួនាទីភារកិច្ច ការផ្តល់សេវាសាធារណៈ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ។

-ត្រៀមធ្វើលិខិតជូនដំណឹងទៅអគ្គិសនីកម្ពុជា ក្រសួងបរិស្ថាន និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឱ្យជំរុញការកែលម្អចំណុចខ្វះខាតលើការអនុវត្តតួនាទីភារកិច្ច ការផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធ។

-ត្រៀមចុះធ្វើអធិការកិច្ចតាមផែនការសកម្មភាពឆ្នាំ២០២៣។

-ត្រៀមមន្ត្រីដើម្បីចូលរួមវិភាគ ដោះស្រាយបញ្ហាអធិការកិច្ច អង្កេតស្រាវជ្រាវ និងបញ្ហាផ្សេងៗទៀត។

-បន្តទទួល និងបូកសរុបរបាយការណ៍ស្តីពីលទ្ធផលអធិការកិច្ចថ្នាក់ក្រោមជាតិ និងធ្វើអធិការកិច្ចឡើងវិញ ក្នុងករណីយល់ឃើញថាមិនទាន់ត្រឹមត្រូវ ឬមានការតវ៉ា។

-ត្រៀមធ្វើអធិការកិច្ចតាមហានិភ័យ និងរបាយការណ៍លទ្ធផលអធិការកិច្ច ក្នុងការិយបរិច្ឆេទ ២០២២។

-ត្រៀមអនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង។

**៣.២.ការងារតាមដានការអនុវត្តច្បាប់**

-ត្រៀមឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំខេត្ត ស្តីពីលទ្ធផលនៃការចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ នៅខេត្តពោធិ៍សាត់ ស្ទឹងត្រែង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ។

-ត្រៀមឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចស្តីពីលទ្ធផលនៃការចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ នៅខេត្តតាកែវ កំពង់ចាម ព្រះវិហារ និងខេត្តមណ្ឌលគិរី។

-ត្រៀមធ្វើលិខិតជូនដំណឹងទៅក្រសួង-ស្ថាប័ន ដើម្បីឱ្យធ្វើការជំរុញទៅមន្ទីរ-អង្គភាព ម្ចាស់ក្រុមហ៊ុន ម្ចាស់សហគ្រាស និងម្ចាស់សិប្បកម្ម ឱ្យកែលម្អនូវចំណុចខ្វះខាតដែលបានរកឃើញក្នុងការចុះធ្វើការតាមដានត្រួតពិនិត្យច្បាប់ នៅខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តក្រចេះ។

**៣.៣.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ**

-បន្តរង់ចាំទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋាននានា រួមទាំងពាក្យបណ្តឹងក្នុងសារព័ត៌មានផងដែរ។

-បន្ត និងត្រៀមចុះអង្កេតស្រាវជ្រាវពាក្យបណ្តឹង ដែលជាសមត្ថកិច្ចក្រសួង និងពាក្យបណ្តឹងដែលរាជរដ្ឋាភិបាលប្រគល់ជូន។

-ត្រៀមអនុវត្តការកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង។

## ៤.ការងារសវនកម្មផ្ទៃក្នុង

-បន្តអនុវត្តការងាររបស់ខ្លួនស្របតាមអនុក្រឹត្យលើលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ និងប្រកាសលេខ០៧៣ ទរពអ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ការិយាល័យ ចំណុះនាយកដ្ឋាននៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

## ៥.ការងារវិទ្យាស្ថានជាតិអធិការកិច្ច

-បន្តអភិវឌ្ឍ និងពង្រឹងសមត្ថភាពស្ថាប័ន

-បន្តពង្រឹងការគ្រប់គ្រងរដ្ឋបាល បុគ្គលិក និង ហិរញ្ញវត្ថុ

-បន្តការងារផែនការ និងស្រាវជ្រាវ

-រៀបចំកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ច ។

-ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ចកម្រិតបឋម កម្រិតមធ្យម កម្រិតជាន់ខ្ពស់ ដល់មន្ត្រីរាជការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងក្រសួងស្ថាប័នផ្សេងទៀត។

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីជំនាញវិជ្ជាជីវៈអធិការកិច្ចដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

-បន្តពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាស្ថានទូតនានា អង្គការជាតិ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍ និងគ្រឹះស្ថានសិក្សា។

-បង្កើត និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យារបស់វិទ្យាស្ថាន។

-រៀបចំ និងបង្កើនប្រសិទ្ធភាពគ្រប់គ្រងបណ្ណាល័យ។

-រៀបចំបង្កើតរោងពុម្ព និងបោះពុម្ពឯកសារ។

## ៦.ការងារផ្សេងៗ

**៦.១.ការងារយេនឌ័រ**

-បន្តផ្សព្វផ្សាយ ជំរុញ និងតាមដានការអនុវត្តអនុសញ្ញាស៊ី-ដ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ១១ចំណុចរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី នៅថ្នាក់កណ្តាល និងមន្ទីរាជធានី-ខេត្ត។

-ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ២០២២-២០២៥ ក្នុងវិស័យទំនាក់ទំនងជាមួយរដ្ឋសភា- ព្រឹទ្ធសភា និងអធិការកិច្ច។

-ជំរុញការបង្កើនបរិមាណ និងសមត្ថភាពស្ត្រីក្នុងការធ្វើសេចក្តីសម្រេច និងភាពជាអ្នកដឹកនាំ។

-រៀបចំវេទិកាសាធារណៈ ស្តីពីតម្រូវការ និងបញ្ហាប្រឈមរបស់មន្ត្រីរាជការជាស្ត្រី។

-អនុវត្តផែនការបញ្ជ្រាបយេនឌ័រឆ្នាំ២០២៣។

**៦.២.ការងារចងសម្ព័ន្ធមេត្រីភាព**

ក្រសួងនឹងចូលរួមយ៉ាងសកម្មថែមទៀត ក្នុងការពង្រឹងសម្ព័ន្ធមេត្រីភាពជាមួយកងវរសេនាតូចនគរបាលព្រំដែន ទាំងពីរអង្គភាព ឱ្យកាន់តែជិតស្និទ្ធ ក្នុងន័យផ្តល់កម្លាំងចិត្ត និងសម្ភារ ដើម្បីបង្កើនជីវភាពរស់នៅ របស់គាត់ឱ្យកាន់តែមានភាពប្រសើរឡើង និងដើម្បីរួមចំណែកថែរក្សាការពារទឹកដីរបស់យើងឱ្យមានសុខសន្តិភាពយូរអង្វែងតរៀងទៅ។

**៦.៣.ការងារសមាគមសង្គហមិត្តភាព**

-បន្តសម្របសម្រួល និងទទួលសមាជិក សមាជិកាថ្មីចូល ក្នុងសមាគមសង្គហមិត្តភាពក្រសួងបន្ថែមទៀត។

-បន្តប្រមូលយក និងគៀងគរថវិកាពីសមាជិក សមាជិកា ដែលមិនទាន់បានបង់ថវិកា។

**៦.៤.ការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង**

បន្តស្នើសុំគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនក្រសួង ក្នុងឆ្នាំ២០២៣។

**៦.៥.ការងារគេហទំព័រ MONASRI.GOV.KH និង MONASRI App**

-ធ្វើការ Backup ទិន្នន័យនៅក្នុង Website ជាប្រចាំ ដើម្បីរក្សាទុករាល់ទិន្នន័យដែលមានកន្លងមកឱ្យមានសុវត្ថិភាព។

-បាន និងកំពុងរៀបចំទម្រង់វេបសាយ របស់ក្រសួងមួយទៀតជាភាសាអង់គ្លេស។

-បន្តចូលរួមពិធីផ្សេងៗ តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង។

-បន្តតាមដានយ៉ាងម៉ត់ចត់តាមរយៈវេបសាយរបស់ក្រសួង-ស្ថាប័ននានា និងរាជរដ្ឋាភិបាល អំពីសារាចរណែនាំ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីដាក់ជូនថ្នាក់ដឹកនាំជ្រាប។

**៦.៦. ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS**

-ត្រៀមអនុវត្តផែនការរួមដំណាក់កាលទី៤ ឆ្នាំ២០២៣ ដើម្បីឈានឆ្ពោះទៅសម្រេចគោលដៅដែលបានអនុម័ត ដោយរាជរដ្ឋាភិបាល។

## ខ-សេចក្តីសន្និដ្ឋាន

នៅឆ្នាំ ២០២២ ក្រសួងបានបំពេញភារកិច្ច ប្រកបដោយទទួលខុសត្រូវ និងប្រសិទ្ធភាពខ្ពស់ និងទទួលបានសមិទ្ធផលគួរជាទីពេញចិត្ត។ ក្រសួងបានធ្វើការកែទម្រង់ ទៅតាមទិសដៅដែលរាជរដ្ឋាភិបាលបានកំណត់ ដោយបានអភិវឌ្ឍស្ថាប័ន ទាំងថ្នាក់កណ្តាល និងមន្ទីរ គ្រប់រាជធានី ខេត្ត របស់ក្រសួងផ្ទាល់ និងបានពង្រឹងសមត្ថភាព ជំនាញ គ្រប់ផ្នែក និងបានតម្រង់ទិស និងណែនាំឱ្យក្រសួង

ស្ថាប័ន និងអង្គភាពរដ្ឋដែលរងអធិការកិច្ចនានាអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត បង្កើនការប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ ក្នុងសកម្មភាពការងាររបស់ខ្លួន ស្របតាមការកែទម្រង់ ស៊ីជម្រៅ ការពង្រឹងនីតិរដ្ឋ និងអភិបាលកិច្ចល្អ។ លើសពីនេះទៀត ក្រសួងបានផ្សព្វផ្សាយច្បាប់ដើម្បីពង្រឹងការយល់ដឹងរបស់ប្រជាពលរដ្ឋ ឱ្យយល់ពីច្បាប់ និងគោរពច្បាប់ដើម្បីរួមគ្នាការពារ និងកសាងជាតិ ជាពិសេស ការទប់ស្កាត់ភាពអសកម្មនានា ក្នុងសង្គម និងបានបណ្តុះបណ្តាលជំនាញអធិការកិច្ចដល់មន្ត្រីរាជការក្រសួង និងស្ថាប័ន អង្គភាពរដ្ឋជាច្រើនទៀតផង។

ដូច្នេះការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ពិតជាមានសារៈសំខាន់មិនអាចខ្វះបាន ដើម្បីបម្រើឱ្យផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋយើង ក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជា ទទួលបានសន្តិភាពយ៉ាងពិតប្រាកដ និងការអភិវឌ្ឍន៍លើគ្រប់វិស័យ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន ជាប្រមុខ។

លទ្ធផលដែលសម្រេចបានកន្លងមកនេះបានបង្ហាញពីតួនាទីភារកិច្ចការទទួលខុសត្រូវ របស់ក្រសួងពិតជាមានសារៈសំខាន់មិនអាចខ្វះបាន ដែលរួមចំណែកដល់ការជំរុញអភិបាលកិច្ចល្អ និងទប់ស្កាត់ កាត់បន្ថយអំពើពុករលួយ។ កត្តាជាគន្លឹះដែលនាំឱ្យសម្រេចបាននូវលទ្ធផលខាងលើ គឺដោយសារមានការដឹកនាំប្រកបដោយបញ្ញាញាណដ៏ត្រឹមត្រូវ និងភ្លឺស្វាង របស់ **លោកជំទាវកិត្តិសង្គហបណ្ឌិត** ម៉ែន សំអន ដែលតែងតែនៅជិតស្និទ្ធ ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង និងការខិតខំបំពេញភារកិច្ច ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្រមសីលធម៌វិជ្ជាជីវៈ និងជំនាញ របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ទាំងថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ និងកិច្ចសហការ និងគាំទ្រពីសំណាក់ស្ថាប័ន អង្គភាពរដ្ឋដទៃទៀត ដែលតែងតែគោរព ឱ្យតម្លៃ និងយល់ច្បាស់ពីគុណប្រយោជន៍ និងភារកិច្ចដ៏ថ្លៃថ្លារបស់ក្រសួង។

ក្នុងឆ្នាំ២០២៣ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គ្រប់លំដាប់ថ្នាក់ នឹងកាន់តែជម្រុញការខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីដោះស្រាយ និងកាត់បន្ថយឱ្យបានជាអតិបរមា នូវចំណុចខ្វះខាតរបស់ក្រសួង ក៏ដូចជារួមចំណែកលុបបំបាត់ និងកាត់បន្ថយបាតុភាពអសកម្មនានា ការរំលោភដោយអំណាចខុសច្បាប់ និងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក្នុងសង្គម។

សូមអរគុណ!

## ឧបសម្ព័ន្ធ ទី៣. របាយការណ៍បូកសរុបលទ្ធផលសន្និបាត

**របាយការណ៍បូកសរុបលទ្ធផលសន្និបាត ឆ្នាំ ២០២២-២០២៣**
**របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**
ដោយ **ឯកឧត្តម ចាប សុថារិទ្ធ** រដ្ឋលេខាធិការ

*សូមគោរព*

លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់
ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ
ឯកឧត្តមអគ្គនាយក
ឯកឧត្តម នាយកខុទ្ទកាល័យ
ឯកឧត្តម លោកជំទាវ លោក លោកស្រី
អង្គសន្និបាតទាំងមូល ជាទីមេត្រី

សន្និបាត ដែលមានរយៈពេលពេញមួយថ្ងៃនេះមានគោលបំណង ត្រួត ពិនិត្យ វាយតម្លៃ និង បូកសរុបលទ្ធផលការងារ ដែលក្រសួងសម្រេចបាន ក្នុងឆ្នាំ២០២២កន្លងមក ដោយលើកឡើងពីសមិទ្ធផលគ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន វិទ្យាស្ថានជាតិអធិការកិច្ច និងមន្ទីរនៅរាជធានី ខេត្ត ដោយរំលេចពីការប្រឈម និងវិធានការណ៍ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះសម្រាប់អនុវត្តបន្តក្នុងឆ្នាំ ២០២៣។

សន្និបាតយើងធ្វើឡើងក្រោយពេលដែលប្រទេសយើងបានបើកសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច និង សេវាកម្មឡើងវិញ បន្ទាប់ពីយើងអាចគ្រប់គ្រងបាននូវការរាលដាល នៃជំងឺកូវីដ ឱ្យ១៩ និង ដោយអនុវត្ត ***ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣***។

ដោយសារ ឆ្នាំ ២០២៣ នេះជាឆ្នាំពិសេស ព្រោះជាឆ្នាំចុងអណត្តិ នៃរាជរដ្ឋាភិបាល អណត្តិទី ៦ (២០១៨-២០២៣) នៃរដ្ឋសភា ទើបក្រសួងរៀបចំសន្និបាត ក្នុងទ្រង់ទ្រាយធំជាងឆ្នាំមុន និងមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួង ទាំងនៅថ្នាក់កណ្តាល ទាំងថ្នាក់រាជធានី ខេត្ត ក្នុងក្រសួងរួមទាំងតំណាងក្រសួង ស្ថាប័ន និងរាជធានី ខេត្តផងដែរ។

នៅថ្នាក់ក្រសួង អ្នកចូលរួមចាប់ពីថ្នាក់ អនុប្រធានការិយាល័យ ឡើងទៅ នៅថ្នាក់កណ្តាល និង តំណាង ៣នាក់ ពីមន្ទីរ រាជធានី ខេត្ត។ ភ្ញៀវកិត្តិយស រួមមាន តំណាងអគ្គាធិការគ្រប់ក្រសួង ស្ថាប័ន និងតំណាងអភិបាល នៃគណៈអភិបាលខេត្ត គ្រប់រាជធានី ខេត្ត។ ដូច្នេះអ្នកចូលរួមសរុបមានចំនួន ៤១១ នាក់ (ស្ត្រី ១៣៨) នាក់ បានប្រព្រឹត្តទៅយ៉ាងរលូនតាមកម្មវិធីដែលបានគ្រោងទុក។

នៅពេលបើកសន្និបាត ឯកឧត្តម **ឆេង សារឿន** រដ្ឋលេខាធិការប្រចាំការ តំណាងលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី បានថ្លែងសុន្ទរកថាបើកសន្និបាត ដោយបានបញ្ជាក់ថា ឆ្នាំ២០២២ កន្លងទៅ ជាឆ្នាំពិសេស និងដ៏មមាញឹក មានអត្ថន័យជាប្រវត្តិសាស្ត្រ សម្រាប់ព្រះរាជាណាចក្រកម្ពុជា។ កម្ពុជាបានសម្រេចភារកិច្ចដ៏មមាញឹក និងមានអត្ថន័យយ៉ាងជ្រាលជ្រៅ ក្នុង

តួនាទីជាម្ចាស់ផ្ទះ និងជាប្រធានប្តូរវេននៃ **កិច្ចប្រជុំកំពូលអាស៊ានលើក ទី ៤០-៤១** ព្រមទាំង កិច្ចប្រជុំកំពូលពាក់ព័ន្ធ និង**មហាសន្និបាតអន្តរសភាអាស៊ាន (អាយប៉ា AIPA) លើកទី ៤៣** ដែលមហាព្រឹត្តិការណ៍ទាំងពីរបានប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ ដ៏ត្រចះត្រចង់ជូនជាតិមាតុភូមិ។ ជោគជ័យខាងលើបានមកក៏ដោយសារកត្តាសន្តិភាព សន្តិសុខ និងការជានាគ្រប់គ្រងបាននូវការរាលដាល នៃជំងឺកូវីដ១៩ផងដែរ។

ឯកឧត្តម ក៏បានរំលឹកពីតួនាទី និងភារកិច្ចស្នូលចំបងៗរបស់ក្រសួង និងបានសម្តែងនូវមោទនភាព កោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបណ្តាក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានខិតខំរួមចំណែក ក្នុងកិច្ចសហការជាមួយក្រសួង ដើម្បីបំពេញការងារជូនរាជរដ្ឋាភិបាល និងបំរើប្រជាជន។

ឯកឧត្តម រដ្ឋលេខាធិការប្រចាំការ បានរំលឹកថា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចមានទស្សនៈវិស័យគឺ៖ *«អភិវឌ្ឍស្ថាប័ន ឱ្យក្លាយជារដ្ឋបាលទំនើបមួយ ប្រកបដោយសមត្ថភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីធ្វើជាភ្នែក ជាត្រចៀករបស់រាជរដ្ឋាភិបាល បំរើប្រជាពលរដ្ឋ ការពារសុវត្ថិភាពសាធារណៈ ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ស្ថាប័ន និងប្រជាពលរដ្ឋ ពង្រឹងតម្លាភាព អភិបាលកិច្ចល្អ និងនីតិរដ្ឋ»* ។

ដើម្បីប្រែក្លាយទស្សនវិស័យខាងលើឱ្យទៅជាការពិត ក្រសួងមានបេសកកម្ម គឺ៖ *«បំពេញការងារដោយយកច្បាប់ជាគោល ក្នុងការផ្សព្វផ្សាយច្បាប់ជូនប្រជាពលរដ្ឋ ធ្វើអធិការកិច្ច តាមដានការអនុវត្តច្បាប់ និងដោះស្រាយបណ្តឹង ដើម្បីសម្រេចលទ្ធផលដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួង ក្នុងគោលដៅទប់ស្កាត់បាតុភាពអសកម្ម អំពើពុករលួយ និងការរំលោភដោយអំណាច ដើម្បីបំរើប្រជាពលរដ្ឋ និងបង្កើនជំនឿជឿជាក់មកលើរាជរដ្ឋាភិបាល»*។

ឯកឧត្តមក៏បានផ្តល់ការណែនាំ ដល់អង្គសន្និបាត បញ្ចេញយោបល់ តាមរយៈធ្វើបទអន្តរាគមន៍ ឬចោទជាសំណួរដើម្បីពិភាក្សា លើរបាយការណ៍បូកសរុបការងារ ឆ្នាំ ២០២២ និងទិសដៅ ឆ្នាំ ២០២៣ របស់ក្រសួង ដែលបានចែកជូន អង្គសន្និបាត។

ឯកឧត្តម **ម៉ែន ច័ន្ទសុខរិន** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅបានអានរបាយការណ៍សង្ខេប ស្តីពីលទ្ធផលការងារ ឆ្នាំ ២០២២ និងទិសដៅឆ្នាំ ២០២៣។ តាមរយៈរបាយការណ៍ ក្រសួងបានបំពេញការងារយ៉ាងសកម្ម នៅគ្រប់មុខសញ្ញា ដោយបានចុះបំពេញបេសកកម្មជាច្រើន ជាពិសេសការចុះធ្វើអធិការកិច្ច ការតាមដានការអនុវត្តច្បាប់ ការទទួល និងដោះស្រាយបណ្តឹង ការផ្សព្វផ្សាយច្បាប់ និងការបណ្តុះបណ្តាលជំនាញអធិការកិច្ច ដោយវិទ្យាស្ថានជាតិអធិការកិច្ច។

បន្ទាប់ពីសម្រាកស្រស់ស្រូបអាហារសម្រន់មក ឯកឧត្តម **ឆេង សារឿន** បានដឹកនាំការពិភាក្សាលើរបាយការណ៍បូកសរុបលទ្ធផលការងារ ឆ្នាំ២០២២ និងទិសដៅឆ្នាំ ២០២៣ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច។

អង្គសន្និបាតបានស្តាប់ដោយយកចិត្តទុកដាក់នូវ បទអន្តរាគមន៍ របស់មន្ទីរទរពអ ខេត្តបាត់ដំបង ខេត្តមណ្ឌលគីរី ខេត្តកោះកុង រាជធានីភ្នំពេញ និង ខេត្តកំពង់ចាម។

ជាកិច្ចបន្ទាប់ អង្គសន្និបាតបានស្តាប់បទអន្តរាគមន៍ របស់អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា បទអន្តរាគមន៍ របស់អគ្គនាយកដ្ឋានអធិការកិច្ច បទអន្តរាគមន៍ របស់អគ្គនាយកដ្ឋានរដ្ឋបាល កិច្ចការទូទៅ និងបទអន្តរាគមន៍ របស់វិទ្យាស្ថានជាតិអធិកិច្ច។

ជាការឆ្លើយតប គណៈអធិបតី បានកត់ត្រាទុកជាធាតុចូល និងបានឆ្លើយតប ពន្យល់ និងបកស្រាយជូនអង្គសន្និបាតទៅតាម វិស័យទទួលខុសត្រូវរៀងៗខ្លួនបានយ៉ាងច្បាស់លាស់ និងក្បោះក្បាយ។

ជារួម អង្គសន្និបាតបានឯកភាពទាំងស្រុងនឹងខ្លឹមសារ របាយការណ៍ ស្តីពី លទ្ធផលការងារ ឆ្នាំ ២០២២ និងទិសដៅការងារ ឆ្នាំ ២០២៣ របស់ក្រសួង និងបានលើកពីសំណូមពរមួយចំនួន ដើម្បីកែលម្អខ្លឹមសាររបាយការណ៍ឆ្នាំក្រោយៗទៀត ដោយត្រូវរំលេចសូចនាករណ៍ដែលអាចវាស់វែងបានដោយប្រៀបធៀប ទៅនឹងសូចនាករណ៍ឆ្នាំមុន ដើម្បីបញ្ជាក់ឃើញច្បាស់ពីវឌ្ឍនភាព និងសមិទ្ធផលសំខាន់ៗ របស់ក្រសួង។

នាយកដ្ឋានផែនការ និងស្ថិតិ ត្រូវរៀបចំទម្រង់ផែនការរួមមួយ សម្រាប់ប្រើប្រាស់ក្នុងក្រសួង និងជូនទៅមន្ទីរទរពអ រាជធានី ខេត្ត អនុវត្ត។

អង្គសន្និបាតបានលើកឡើងនូវចំណុចខ្វះខាតខ្លះ នៃរបាយការណ៍ក្រសួង ដែលត្រូវកែសម្រួលជាអត្ថបទបោះពុម្ព ដើម្បីដាក់ជូនលោកជំទាវឧបនាយករដ្ឋមន្ត្រីចុះហត្ថលេខាលើអារម្ភកថា និងផុសក្នុងវិបសាយផ្លូវការរបស់ក្រសួង។

ជារួម អង្គសន្និបាតបានរកឃើញការប្រឈមមួយចំនួន គឺទី១) សមិទ្ធផលរបស់ក្រសួងភាគច្រើនគឺមិនអាចវាស់វែងបាន (អរូបីយ) ដូចជា ការពង្រឹងអភិបាលកិច្ចល្អ ការចូលរួមចំណែកប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការធ្វើឲ្យប្រសើរឡើងនូវការយល់ដឹងរបស់ប្រជាពលរដ្ឋលើច្បាប់ និងគោលនយោបាយនានា ។ល។ ដែលនាំឱ្យមានការលំបាកក្នុងការរៀបចំ និងការការពារថវិកាប្រចាំឆ្នាំ ទី២) កង្វះច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងវិស័យដែលក្រសួងកំពុងគ្រប់គ្រង ជាពិសេសវិស័យអធិការកិច្ច ដែលទាមទាការខិតខំទ្វេរដងដើម្បីដោះស្រាយការប្រឈមនោះ ទី៣) កង្វះថវិកា ធនធានមនុស្ស និងមធ្យោបាយធ្វើដំណើរបេសកកម្ម។

តំណាងអគ្គាធិការដ្ឋាន ក្រសួងមុខងារសាធារណៈ បានលើកឡើងនូវសំណូមពរ ១) ស្នើវិទ្យាស្ថានជាតិអធិការកិច្ចបន្តបណ្តុះបណ្តាលមុខជំនាញអធិការកិច្ចដល់ អគ្គាធិការដ្ឋានក្រសួងស្ថាប័ន ដើម្បីអគ្គាធិការដ្ឋានអាចបណ្តុះបណ្តាលបន្ត ២) ស្នើក្រសួងទរពអ ផ្តល់គម្រូរបាយការណ៍អធិការកិច្ច ដើម្បីក្រសួងផ្សេងៗអនុវត្តតាម ៣) ស្នើវិទ្យាស្ថានជាតិអធិការកិច្ច បន្តើនសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានា ជាពិសេសក្នុងអាស៊ាន ដើម្បីដកបទពិសោធន៍ក្នុងជំនាញអធិការកិច្ច បង្កើនចំណេះដឹងឱ្យកាន់តែទូលំទូលាយថែមទៀត និង ៤) ក្នុងការចុះធ្វើអធិការកិច្ច ជាពិសេសការតាមដានការអនុវត្តច្បាប់ សូមស្នើអញ្ជើញតំណាងអគ្គាធិការដ្ឋាន ក្រសួងសាមីចូលរួមផង ដើម្បីសហការការងារ និងបង្កើនប្រសិទ្ធភាព នៃការងារអធិការកិច្ច។

ទន្ទឹមនិងនោះដែរ អង្គសន្និបាតបានស្នើឱ្យអគ្គនាយកដ្ឋានទាំងបីចំណុះក្រសួង ជាពិសេសអគ្គនាយកដ្ឋានអធិការកិច្ច និងគ្រប់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រាជធានី-ខេត្ត ទាំងអស់ត្រូវយកចិត្តទុកដាក់បន្ថែមទៀត មិនត្រូវរង់ចាំច្បាប់អធិការកិច្ចនោះទេ ព្រោះយើងមានអនុក្រឹត្យ ០៣ ដែលបានកំណត់នូវបេសកកម្មរបស់ក្រសួងយើង ជាក់ស្តែងក្នុងអនុក្រឹត្យនេះ

ត្រង់មាត្រា៤ បានចែងច្បាស់លាស់រួចហើយ គឺ «ធ្វើការងារអធិការកិច្ច លើគ្រប់វិស័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅបង្ការ ទប់ស្កាត់ កែលម្អ និងមានវិធានការ ដើម្បីប្រឆាំងនឹងអំពើពុករលួយ ការរំលោភ ដោយអំណាច និងបាតុភាពអសកម្មនានា»។ ម្យ៉ាងទៀត ការយើងអាចដោះស្រាយករណីបណ្ដឹងក្រៅប្រព័ន្ធតុលាការ ដោយឈរលើភាពយុត្តិធម៌ សមធម៌ សីលធម៌វិជ្ជាជីវៈ ជាពិសេសយើងត្រូវឈរលើគោលការណ៍ឈ្នះឈ្នះ ដែលជាយុទ្ធសាស្ត្រ បានដាក់ចេញដោយប្រមុខរាជរដ្ឋាភិបាល។ ដោយឡែកគ្រប់អង្គភាព និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រាជធានី-ខេត្ត ត្រូវមាន របបប្រជុំបីខែម្តងក្នុងអង្គភាពរបស់ខ្លួន។

ចំពោះការលើកឡើងនូវសំណូមពរ របស់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច រាជធានី-ខេត្ត ក៏ដូចនិងអគ្គនាយកដ្ឋានទាំងបីផងដែរ ដែលជួបនូវកង្វះខាតក្របខណ្ឌ ធនធានមនុស្ស មធ្យោបាយធ្វើដំណើរ និងថវិកា បញ្ហានេះក្រសួងក៏កំពុងខិតខំព្យាយាមដោះស្រាយ ជាបណ្តើរៗផងដែរ។

អំពីបញ្ហាទម្រង់របាយការណ៍ ស្តីពីលទ្ធផលអធិការកិច្ច ក្រសួងនឹងរៀបចំជាទម្រង់របាយការណ៍ ស្តង់ដាររួម ដើម្បីឱ្យអគ្គាធិការដ្ឋាន ឬអធិការដ្ឋានតាមបណ្តាក្រសួង ស្ថាប័នងាយស្រួលយកទៅអនុវត្ត។

ជាការសន្និដ្ឋាន ក្រោយពីការងារក្រសួងត្រូវបានប៉ះពាល់ ដោយវិបត្តិនៃជំងឺកូវីដ ១៩ នៅឆ្នាំ ២០២២ ក្រសួងបានដំណើរការវិញយ៉ាងល្អប្រសើរ។ អង្គសន្និបាតបានវាយតម្លៃខ្ពស់ ចំពោះជោគជ័យ នៃឆ្នាំ ២០២២ ដោយថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ របស់ក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខិតខំពុះពាររាល់ការលំបាក ប្រឹងប្រែងអនុវត្តការងារប្រកបដោយ ប្រសិទ្ធភាព សមត្ថភាពជំនាញ មនសិការទទួលខុសត្រូវខ្ពស់ និងដោយសារមានការគាំទ្រ និងកិច្ច សហការល្អពីគ្រប់មជ្ឈដ្ឋាន ទាំងស្ថាប័នរដ្ឋ ស្ថាប័នឯកជន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពល រដ្ឋផងដែរ។

ជាទិសដៅ ក្នុងឆ្នាំ ២០២៣ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គ្រប់លំដាប់ថ្នាក់ ប្តេជ្ញាខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីដោះស្រាយ និងកាត់ បន្ថយឱ្យបានជាអតិបរមា នូវចំណុចខ្វះខាតរបស់ក្រសួង ក៏ដូចជាបាតុភាពអសកម្មនានាដែលកើតមាន ក្នុងសង្គម។

អង្គសន្និបាត សង្ឃឹមថា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័ននានា រដ្ឋបាលដែនដីគ្រប់ លំដាប់ថ្នាក់ ក្រុមហ៊ុន សហគមន៍ និងប្រជាពលរដ្ឋ នឹងបន្តចូលរួមសហការ ឱ្យកាន់តែល្អប្រសើរថែម ទៀត ដើម្បីធ្វើឱ្យក្រសួងសម្រេចបានជោគជ័យ និងសមិទ្ធផលថ្មីៗ បន្ថែមទៀត ជូនជាតិមាតុភូមិ នៃ យើង។

ជាទីបញ្ចប់នេះ ក្នុងនាម អង្គសន្និបាត ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ ខ្ញុំបាទមានកិត្តិយស សូមគោរពអញ្ជើញ លោកជំទាវកិត្តិសង្គហបណ្ឌិតឧបនាយករដ្ឋមន្ត្រី មេត្តាឡើងថ្លែងសន្ទរកថាបិទ សន្និបាត និងមានមតិណែនាំ ដ៏ខ្ពង់ខ្ពស់។

សូមគោរពអញ្ជើញ។

## ឧបសម្ព័ន្ធ ទី៤. សុន្ទរកថាបើកសន្និបាត

**សុន្ទរកថា**

ឯកឧត្តម **ឆេង សារឿន** រដ្ឋលេខាធិការប្រចាំការ

តំណាងដ៏ខ្ពង់ខ្ពស់ របស់លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

ក្នុងពិធីបើកសន្និបាតបូកសរុបការងារឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣

របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

សណ្ឋាគារ សុខា វិថីកែវចិន្តា ភូមិ១ សង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ

ថ្ងៃ អង្គារ ២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹង ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣

**ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី!**

ខ្ញុំមានសេចក្តីរីករាយ និងសូមស្វាគមន៍ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ក្រសួង ព្រមទាំងឯកឧត្តម លោកជំទាវ ដែលជាភ្ញៀវកិត្តិយសមកពីក្រសួង ស្ថាប័ន និង រាជធានីខេត្ត ទាំងអស់ដែលបានចូលរួមក្នុងពិធីបើកសន្និបាតប្រចាំឆ្នាំរបស់ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចនាពេលនេះ។

សន្និបាត ដែលមានរយៈពេលពេញមួយថ្ងៃនេះមានគោលបំណងត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបលទ្ធផលការងារ ដែលក្រសួងសម្រេចបាន ក្នុងឆ្នាំ២០២២កន្លងមក ដោយលើកឡើងពីសមិទ្ធផលគ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន វិទ្យាស្ថានជាតិអធិការកិច្ច និងមន្ទីរនៅរាជធានី ខេត្ត ដោយរំលេចពីការប្រឈម និងវិធានការណ៍ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ សម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២៣ ដើម្បីសម្រេចបានលទ្ធផលទៅតាម ផែនការ និងយុទ្ធសាស្ត្រដូចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន។

សន្និបាតយើងធ្វើឡើងចំពេលដែលប្រទេសយើងបានបើកសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច និងសេវាកម្មឡើងវិញ បន្ទាប់ពីយើងអាចគ្រប់គ្រងបាននូវការរាលដាល នៃជំងឺកូវីដ ១៩។ នេះគឺដោយសារការខិតខំរបស់រាជរដ្ឋាភិបាល ដែលមានការបញ្ជាពីសម្តេចតេជោផ្ទាល់បានចាត់វិធានការណ៍អន្តរាគមន៍យ៉ាងទាន់ពេល និងមានប្រសិទ្ធភាព ដូចជាការចាក់វ៉ាក់សាំង ស្រោច និងអនុវត្ត *ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣*។

ម៉្យាងទៀត ដោយសារឆ្នាំនេះជាឆ្នាំពិសេស ព្រោះជាឆ្នាំចុងអណត្តិ នៃរាជរដ្ឋាភិបាល អណត្តិទី ៦ (២០១៨-២០២៣) នៃរដ្ឋសភា ទើបសន្និបាតឆ្នាំនេះត្រូវបានរៀបចំឡើងដោយទ្រង់ទ្រាយធំជាងឆ្នាំមុន និងមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួង ទាំងនៅថ្នាក់កណ្តាល ទាំងថ្នាក់រាជធានីខេត្ត ក្នុងក្រសួងរួមទាំងតំណាងក្រសួង ស្ថាប័ន និងរាជធានី ខេត្តផងដែរ។

ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះថ្លែងអំណរគុណ ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ដែលមានបានចូលរួមក្នុងពិធីនេះ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !*

ខ្ញុំសូមរំលឹកឡើងវិញបន្តិចថា ឆ្នាំ២០២២ កន្លងទៅនេះ ជាឆ្នាំពិសេស និងដ៏មមាញឹក មានអត្ថន័យជាប្រវត្តិសាស្ត្រ សម្រាប់ព្រះរាជាណាចក្រកម្ពុជា។ កម្ពុជាបានសម្រេចភារកិច្ចដ៏មមានញឹក និងមានអត្ថន័យយ៉ាងជ្រាលជ្រៅ ក្នុងតួនាទីជាម្ចាស់ផ្ទះ និងជាប្រធានប្តូរវេននៃ **កិច្ចប្រជុំកំពូលអាស៊ានលើក ទី ៤០-៤១** ព្រមទាំង កិច្ចប្រជុំ កំពូលពាក់ព័ន្ធ និង**មហាសន្និបាតអន្តរសភាអាស៊ាន (អាយប៉ា AIPA) លើកទី ៤៣** ដែលមហាព្រឹត្តិការណ៍ទាំងពីរបានប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ ដ៏ត្រចះត្រចង់ជូនជាតិមាតុភូមិ។ ថ្នាក់ដឹកនាំកំពូលៗ នៃប្រទេសមហាអំណាច និងប្រទេសជាមិត្តនៅក្នុង តំបន់ និងសកលលោកបានចូលរួមព្រឹត្តិការណ៍ខាងលើ និងកោតសរសើរកម្ពុជាចំពោះការទទួលបដិសណ្ឋារកិច្ច និងការរៀបចំដែលទទួលបានលទ្ធផលល្អប្រសើរ។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ បាននាំមកនូវកេរ្តិ៍ឈ្មោះដ៏ឧត្តុង្គឧត្តម មហាកិត្តិយសមោទនភាពជាតិ កិត្យានុភាពជាតិដ៏ថ្លៃថ្លា និងភាពល្បីរន្ទឺក្នុងតំបន់ និងអន្តរជាតិ សម្រាប់ប្រជាជនកម្ពុជាទាំងមូល ព្រមទាំងរួមចំណែកដល់ការផ្សព្វផ្សាយ អំពីកម្ពុជា នៅលើឆាកអន្តរជាតិ ជាពិសេសមនុញ្ញផលនេះ នឹងផ្តល់នូវសក្តានុពលយ៉ាងសំខាន់ ដល់ព្រះរាជាណាចក្រកម្ពុជានាពេលខាងមុខ។ ជោគជ័យខាងលើបានមកក៏ដោយសារកត្តាសន្តិភាព សន្តិសុខ និងការធានាគ្រប់គ្រងបាននូវការរាលដាលនៃជំងឺកូវីដ១៩ផងដែរ។

ជាមួយគ្នានេះ យើងទាំងអស់គ្នា សូមឆ្លៀតឱកាសដ៏ថ្លៃថ្លានេះ សម្តែងនូវមនោសញ្ចេតនាអបអរសាទរ ចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឋានៈជាប្រធានអាស៊ាន ដែលមានបទពិសោធន៍ចាស់ទុំ មានទេពកោសល្យខ្ពស់ក្នុងការដឹកនាំកិច្ចប្រជុំកំពូលអាស៊ាន លើកទី ៤០ និង៤១ និងកិច្ចប្រជុំពាក់ព័ន្ធ កាលពីថ្ងៃទី១០-១៣ ខែវិច្ឆិកា ដែលបានដំណើរការទៅយ៉ាងរលូន និងទទួលបានលទ្ធផលផ្លែផ្កាជាប្រវត្តិសាស្ត្រគួរជាទីមោទនៈ ធានាបានទាំងទម្រង់ចាត់តាំង និងទាំងខ្លឹមសារ ដោយរក្សាបាននូវសន្តិសុខ សុវត្ថិភាព របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម និងកិច្ចសហ-ប្រតិបត្តិការល្អ ហើយត្រូវបានមតិជាតិ និងអន្តរជាតិ កោតសរសើរ និងវាយតម្លៃថាជាកិច្ចប្រជុំកំពូលខាងលើពិតជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏អស្ចារ្យមួយនៅកម្ពុជា នាចុងឆ្នាំ២០២២នេះ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !*

ក្រសួងមានភារកិច្ច ដឹកនាំគ្រប់គ្រង សម្របសម្រួលការងារ តាមរយៈទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងធ្វើអធិការកិច្ច លើគ្រប់វិស័យក្នុងព្រះរាជាណាចក្រកម្ពុជា។

ដូច្នេះ ការងារទី ១ របស់ក្រសួងគឺ **ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា** ដែលរួមមានការសម្របសម្រួល ធ្វើទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា និងចូលរួមតាក់តែងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល លើកកម្ពស់ការយល់ដឹងពីច្បាប់ និងការអនុវត្តន៍ច្បាប់ ដោយធ្វើការផ្សព្វផ្សាយច្បាប់យ៉ាងទូលំទូលាយ ជូនដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេសឱ្យបានយល់។ ក្រៅពីការងារខាងលើ ក្រុមការងារក្រសួងបានចុះទៅដល់គ្រប់ខេត្ត ក្រុង ស្រុក ទីប្រជុំជន ជនបទ

ដាច់ស្រយាល និងសហគមន៍នានា ដើម្បីបើកវេទិកាសាធារណៈ អប់រំ ផ្សព្វផ្សាយច្បាប់ ធ្វើការស្ទាបស្ទង់មតិ ដើម្បីស្វែងយល់ពីទុក្ខលំបាករបស់ប្រជាពលរដ្ឋ ផ្សព្វផ្សាយរាល់អនុសាសន៍ ដ៏ថ្លៃថ្លារបស់ថ្នាក់ដឹកនាំពិសេសកម្មវិធីនយោបាយ ផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជូនដល់ប្រជាពលរដ្ឋ ហើយពាំនាំនូវសំណូមពររបស់ប្រជាពលរដ្ឋ ជូនរាជរដ្ឋាភិបាលដើម្បីដោះស្រាយ។

ចំណែកការងារទី២គឺ **ការងារអធិការកិច្ច** ដែលត្រូវអនុវត្តតាមស្ថាប័ន និងអង្គភាពនានាជាប្រចាំ ដែលនេះជាភារកិច្ច ដ៏សំខាន់ទាក់ទងនឹងការពង្រឹងការអនុវត្តន៍ច្បាប់ សំដៅជានាប្រឆាំងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា នៅក្នុងជួររដ្ឋបាលសាធារណៈ ក៏ដូចជាផ្នែកឯកជន ដើម្បីធានាការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៃថវិកា និងទ្រព្យសម្បត្តិរដ្ឋ ការពារសុវត្ថិភាពសាធារណៈ និងការពារសិទ្ធរបស់ប្រជាជន។

ក្រៅពីការងារខាងលើ ក្រសួងនៅមានភារកិច្ចច្រើនទៀត ដូចជាការតាមដានការអនុវត្តច្បាប់ ការទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ដោះស្រាយពាក្យបណ្តឹង បណ្តុះបណ្តាលជំនាញអធិការកិច្ច តាមរយៈវិទ្យាស្ថានជាតិអធិការកិច្ច និងរដ្ឋបាលកិច្ចការទូទៅដើម្បីទ្រទ្រង់ដំណើរការ និងពង្រឹងប្រសិទ្ធភាពការងារក្រសួង។

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចមានទស្សនៈវិស័យគឺ៖ *«អភិវឌ្ឍស្ថាប័ន ឱ្យក្លាយជារដ្ឋបាលទំនើបមួយ ប្រកបដោយសមត្ថភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីធ្វើជាផ្នែក ជាត្រចៀករបស់រាជរដ្ឋាភិបាល បំរើប្រជាពលរដ្ឋ ការពារសុវត្ថិភាពសាធារណៈ ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ស្ថាប័ន និងប្រជាពលរដ្ឋ ពង្រឹងតម្លាភាព អភិបាលកិច្ចល្អ និងនីតិរដ្ឋ»* ។

ដើម្បីប្រែក្លាយទស្សនវិស័យខាងលើឱ្យទៅជាការពិត ក្រសួងមានបេសកកម្ម គឺ៖ *«បំពេញការងារដោយយកច្បាប់ជាគោល ក្នុងការផ្សព្វផ្សាយច្បាប់ជូនប្រជាពលរដ្ឋ ធ្វើអធិការកិច្ច តាមដានការអនុវត្តច្បាប់ និងដោះស្រាយបណ្តឹង ដើម្បីសម្រេចលទ្ធផលដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួង ក្នុងគោលដៅទប់ស្កាត់បាតុភាពអសកម្ម អំពើពុករលួយ និងការរំលោភដោយអំណាច ដើម្បីបំរើប្រជាពលរដ្ឋ និងបង្កើនជំនឿជឿជាក់មកលើរាជរដ្ឋាភិបាល»*។

### *អង្គសន្និបាតទាំងមូលជាទីមេត្រី*

ការទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ និងការជម្រុញអភិបាលកិច្ចល្អទាមទាឱ្យមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន អង្គភាព ទាំងវិស័យរដ្ឋ និងឯកជន។ ដោយសារការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើពុករលួយ ត្រូវផ្តោតទៅលើអភិក្រមជាសារវន្តចំនួន ៣ គឺ៖ ការអប់រំបង្ការទប់ស្កាត់ជាមុន ការអនុវត្តច្បាប់ និងការចូលរួមគាំទ្រពីមហាជន។ ដូច្នេះការងារអធិការកិច្ច និងការពង្រឹងការអនុវត្តច្បាប់ មិនអាចផ្តាច់ចេញពីការអប់រំផ្សព្វផ្សាយច្បាប់ជូនដល់មហាជន និងការចូលរួមរបស់ប្រជាជនបានឡើយ។ ដូច្នេះ ការងារស្នូលដ៏សំខាន់របស់ក្រសួង គឺជានាការដឹកនាំគ្រប់គ្រងរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងនីតិរដ្ឋ ដើម្បីពង្រឹងអភិបាលកិច្ចល្អ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។

ចាប់តាំងពីការបង្កើតស្ថាប័ននេះមក ក្រសួងសម្រេចបានលទ្ធផលជាច្រើន ជាពិសេសក្នុងការងារស្នូលដូចជា អធិការកិច្ច ការទទួល និងដោះស្រាយពាក្យបណ្តឹង (បណ្តឹងតវ៉ា និងបណ្តឹងបរិហារ) ការចុះស៊ើបអង្កេតករណីបណ្តឹងពាក់ព័ន្ធទំនាស់ដីធ្លី ការសម្របសម្រួលបញ្ចប់ទំនាស់ពុំរ៉ៃ បានជាច្រើនករណី

ការតាមដានការអនុវត្តច្បាប់ ការកែលម្អចំណុចខ្វះខាតរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈ លើកិច្ចការរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ ជម្រុញប្រសិទ្ធិភាព ផលិតភាព និងគុណភាពសេវាសាធារណៈ ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ។ លើសពីនេះក្រសួងក៏មានភារកិច្ចធ្វើការអប់រំ បង្ការ ទប់ស្កាត់ និងកែលម្អកំហុសឆ្គង ក្នុងការអនុវត្តការងាររបស់ក្រសួង-ស្ថាប័ន អង្គភាព គ្រឹះស្ថានសាធារណៈ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីកែលម្អ ជម្រុញលើកកម្ពស់អភិបាលកិច្ចល្អដែលជាស្នូល នៃយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាលពីដំណាក់កាលទី១ ដល់ទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ **ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** ដែលមានបួនដំណាក់កាល។ ដោយឡែក រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាបានប្រកាសដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលជារបៀបវារៈគោលនយោបាយសម្រាប់ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍប្រទេសជាតិសម្រាប់រយៈពេល៥ឆ្នាំជាបន្តទៀត។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ មានអភិបាលកិច្ចល្អជាស្នូល និងមានមុំបួនគឺ ១) ការអភិវឌ្ឍន៍ធនធានមនុស្ស ២) ការធ្វើពិពិធកម្មសេដ្ឋកិច្ច ៣) ការអភិវឌ្ឍន៍វិស័យឯកជន និងការងារ និង ៤) ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបរិយាប័ន្ន។ យុទ្ធសាស្ត្រថ្មីនេះបានពង្រីកនូវវិសាលភាព សម្រិតសម្រាំងបន្ថែម និងធ្វើអាទិភាពរូបនីយកម្មមុំនីមួយៗនៃចតុកោណយុទ្ធសាស្ត្រទាំង៤ ព្រមទាំងកែលម្អរបៀបវារៈ គោលនយោបាយ និងយន្តការអនុវត្តមួយចំនួនឲ្យកាន់តែល្អប្រសើរឡើង ដើម្បីកសាងមូលដ្ឋានគ្រឹះចាំបាច់ទាំងឡាយ ក្នុងចក្ខុវិស័យប្រែក្លាយឋានៈរបស់ប្រទេសកម្ពុជា ពីប្រទេសមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ព្រមទាំងនាំប្រទេសជាតិយើង ឆ្ពោះទៅកាន់ឋានៈជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ខាងមុខ។

ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាលបានដាក់ចេញផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយមានកំណត់នូវអាទិភាព សូចនាករ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់ សម្រាប់អនុវត្ត និងយន្តការសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃផ្អែកលើលទ្ធផលការងារ ព្រមទាំងមានកំណត់ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន ទៅតាមមុំ ឬវិស័យនីមួយៗ ដើម្បីទទួលបានជោគជ័យទៅតាមផែនការ។ លើសពីនេះទៀត រាជរដ្ឋាភិបាលក៏បានធ្វើការកែទម្រង់នានា ក្នុងគោលបំណងពង្រឹងសមត្ថភាពមន្ត្រីរាជការស៊ីវិល និងវិស័យឯកជន ដើម្បីទទួលបានផលចំណេញជាអតិបរិមា ពីការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់កម្ពុជាទៅក្នុងសហគមសេដ្ឋកិច្ចអាស៊ាន ក្នុងតំបន់ផ្សេងទៀត និងក្នុងសកលលោក។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏មានសង្គតិភាពផងដែរ ជាមួយនឹងឯកសារគោលនយោបាយ តាមវិស័យដ៏ទៃទៀត របស់រាជរដ្ឋាភិបាល ដូចជា៖ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥និងក្របខ័ណ្ឌគោលនយោបាយ សម្រាប់អភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ២០២០-២០៤០ ជាដើម។

ដោយឡែក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានរួមចំណែកក្នុងការអនុវត្ត យុទ្ធសាស្ត្រចតុកោណ សំដៅពង្រឹង អភិបាលកិច្ចល្អ និងរួមចំណែកប្រយុទ្ធប្រឆាំងអំពើពុករលួយដែលពិតជា ស្របតាមគោលដៅយុទ្ធសាស្ត្រទី ៤ នៃ"**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**" គឺ

"បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ច នៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ សំដៅបំរើប្រជាជនឱ្យបានកាន់តែប្រសើរឡើង ក៏ដូចជាលើកកម្ពស់បរិយាកាសធុរកិច្ច និងស្ថានភាពអំណោយផលសម្រាប់វិនិយោគ។

ជារួម នៅឆ្នាំ ២០២២ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចសម្រេចបានជោគជ័យ និងសមិទ្ធផលជាច្រើន ក្នុងការបំពេញភារកិច្ចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន ដូចដែលបានលើកឡើងក្នុងរបាយការណ៍ដែលបានចែកជូនអង្គសន្និបាត។ យើងពិតជាមានមោទនភាព និងអំណរសាទរចំពោះលទ្ធផលការងារគ្រប់ផ្នែក គ្រប់វិស័យ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ខិតខំសម្រេចបាន ហើយយើងប្តេជ្ញានឹងបន្តការងារឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យថ្មីៗថែមទៀត។

ជាការពិតណាស់ សមិទ្ធផលទាំងនេះ កើតឡើងចេញជាផ្លែផ្កាបាន ដោយសារការមានការដឹកនាំដ៏ត្រឹមត្រូវ ដោយមានផែនការ និងយុទ្ធសាស្ត្រច្បាស់លាស់ រួមនឹងការចូលរួមយ៉ាងសកម្មពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង ដែលសុទ្ធតែជាតួអង្គសំខាន់ៗមិនអាចខ្វះបាន និងការគាំទ្រ និងកិច្ចសហការពីក្រសួង ស្ថាប័ន និងអង្គភាព នានា។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !*

ខ្ញុំពិតជាមានមោទនភាព និងសូមកោតសរសើរថ្នាក់ដឹកនាំ និងជាមន្ត្រីរាជការក្នុងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រួមទាំងមន្ទីររាជធានី ខេត្តទាំងអស់ ដែលបានខិតខំបំពេញការងារយ៉ាងសកម្ម ប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងឆ្នាំ ២០២២កន្លងទៅ ដោយទទួលនូវជោគជ័យជាទីពេញចិត្ត។ ខ្ញុំក៏សូមអរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅបណ្តាក្រសួង-ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានខិតខំរួមចំណែកក្នុងកិច្ចសហការជាមួយក្រសួង ដើម្បីបំពេញការងារជូនរាជរដ្ឋាភិបាល និងបំរើប្រជាជន លើវិស័យការងារទំនាក់ទំនង សម្របសម្រួលជាមួយរដ្ឋសភា ព្រឹទ្ធសភា ការងារផ្សព្វផ្សាយច្បាប់ ការងារអធិការកិច្ច ការតាមដានការអនុវត្តច្បាប់ និងការទទួល និងដោះស្រាយបណ្តឹងនានា ដើម្បីរួមចំណែកពង្រឹងអភិបាលកិច្ចល្អ ដែលជាឧត្តមប្រយោជន៍របស់សង្គមជាតិទាំងមូល។

ក្នុងឱកាសសន្និបាតរយៈពេលពេញមួយថ្ងៃនេះ ខ្ញុំសូមអំពាវនាវសូមឯកឧត្តម លោកជំទាវ លោក លោកស្រីដែលចូលរួមទាំងអស់ត្រូវបង្កើនស្មារតី យកចិត្តទុកដាក់ ប្រើប្រាស់ពេលវេលាដ៏មានប្រយោជន៍នេះដើម្បីផ្លាស់ប្តូរបទពិសោធន៍ លើកឡើងពីចំណុចល្អៗ និងចំណុចមិនទាន់បានកែលម្អ បញ្ហាប្រឈមទាំងឡាយ ព្រមទាំងលើកនូវដំណោះស្រាយដ៏សមស្រប និងប្រកបដោយប្រសិទ្ធភាព ដើម្បីដាក់ផែនការ និងសកម្មភាព សម្រាប់អនុវត្តបន្ត។

មុននឹងបញ្ចប់ ខ្ញុំសូមជូនពរដល់ឯកឧត្តម លោកជំទាវ ជាគណៈអធិបតី និងសមាជិក សមាជិកានៃអង្គសន្និបាត ទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងពិធី នាពេលនេះសូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាតឃ្លៀងឡើយ និងសូមឲ្យអង្គសន្និបាតសម្រេចបានជោគជ័យ។

**ខ្ញុំសូមប្រកាសបើក**សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២៣ របស់**ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចាប់ពីពេលនេះតទៅ។**

*សូមអរគុណ !*

## ឧបសម្ព័ន្ធ ទី៥. សុន្ទរកថាបិទសន្និបាត

**សុន្ទរកថា**

លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២៣
របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
សណ្ឋាគារ សុខា វិថីកែវចិន្ដា ភូមិ១ សង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ
ថ្ងៃ អង្គារ ២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹង ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣

**ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយក្រៃលែង ដោយបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងពិធីបិទសន្និបាតប្រចាំឆ្នាំ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលបានបូកសរុបលទ្ធផលការងារក្រសួងបានសម្រេចក្នុងឆ្នាំ ២០២២កន្លងមក និងដាក់ចេញនូវទិសដៅសម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២៣។

ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ រួមមានថ្នាក់ដឹកនាំ មន្ត្រីរាជការ ទាំងនៅថ្នាក់កណ្តាល ទាំងថ្នាក់រាជធានី ខេត្ត ដែលបានចូលរួមក្នុងសន្និបាតនេះដោយការយកចិត្តទុកដាក់ខ្ពស់។

សន្និបាត ដែលមានរយៈពេលពេញមួយថ្ងៃនេះបានប្រព្រឹត្តទៅ ដោយរលូនទៅតាមកម្មវិធី ដែលបានគ្រោងទុក ដោយមានការចូលរួមយ៉ាងសកម្មពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការ និងភ្ញៀវកិត្តិយសដែលមកពីស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយសម្រេចបានលទ្ធផលគួរជាទីមោទនៈ ដូចដែលបានគ្រោងទុក។ អង្គសន្និបាតបានលើកឡើងនូវបទពិសោធន៍ល្អៗ ការប្រឈមនានា និងដំណោះស្រាយ ប្រកបដោយភាពជាក់ស្តែង និងទទួលបាននូវលទ្ធផលជាផ្លែផ្កាគួរឱ្យកោតសរសើរ។ នេះបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ ពីស្មារតីទទួលខុសត្រូវ និងការខិតខំបំពេញការងាររបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជា ថ្នាក់ ដឹកនាំ និងមន្ត្រីរាជការ ទាំងថ្នាក់ជាតិ និងរាជធានី-ខេត្ត ដែលបានខិតខំ ប្រឹងប្រែងបំពេញការងារស្នូលតាមតួនាទីរៀងៗខ្លួន។

ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលបានប្រឹងប្រែងបំពេញភារកិច្ច ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងដោយមានកិច្ចសហការ ការគាំទ្រ និងទទួលស្គាល់ពីស្ថាប័នពាក់ព័ន្ធ ដោយទទួលបានលទ្ធផលគួរជាទីពេញចិត្ត។ នេះជាមោទនភាព និងកិត្តិយសដ៏ធំធេង ដោយក្រសួងយើងទទួលបានជោគជ័យលើការងារជាច្រើនក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់ខ្លួន។

ខ្ញុំក៏សូមថ្លែងនូវអំណរគុណ និងការកោតសរសើរដោយស្មោះ ចំពោះគណៈកម្មការរៀបចំសន្និបាត ដែលដឹកនាំដោយឯកឧត្តមរដ្ឋលេខាធិការប្រចាំការ **ឆេខ សារឿន** រួមជាមួយលោកជំទាវ **សុភ័ក្ត ថាវី** ឯកឧត្តម **ហួត ហាក់** និងឯកឧត្តម **ចាប សុថារិទ្ធ** ដែលជាអនុប្រធាន និងជាប្រធានអនុគណៈកម្មាធិការ រួមជាមួយសមាជិកគណៈកម្មាធិការ ទាំងអស់ដែលបានបំពេញការងារយ៉ាងសកម្ម ធ្វើឱ្យសន្និបាតឆ្នាំនេះប្រព្រឹត្តទៅបានល្អប្រសើរ។

ខ្ញុំសូមអបអរសាទរ និងគាំទ្រទាំងស្រុងនូវរបាយកាណ៍បូកសរុបការងារ ឆ្នាំ២០២២ និងទិសដៅសម្រាប់ឆ្នាំ២០២៣ ដែលអង្គសន្និបាតបានពិភាក្សា និងសម្រេច។

*អង្គពិធីទាំងមូលជាទីមេត្រី*

នៅឆ្នាំ ២០២២ កន្លងទៅ ក្រោយពីប្រយុទ្ធទប់ទល់នឹងវិបត្តិដ៏ធ្ងន់ធ្ងរនៃការរាលដាល នៃជំងឺកូវីដ១៩ ពីឆ្នាំ២០២០ ដល់ឆ្នាំ ២០២១ ដែលបានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ លើគ្រប់សកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច កម្ពុជាយើងបានជំនះឧបសគ្គ និងអាចគ្រប់គ្រងបានស្ទើរតែទាំងស្រុងនូវការរាលដាលដ៏សាហាវ នៃជំងឺកូវីដ១៩ និងអាចទទួលធ្វើជាម្ចាស់ផ្ទះនិងជាប្រធានប្តូរវេននៃ **កិច្ចប្រជុំកំពូលអាស៊ានលើក ទី ៤០-៤១** ព្រមទាំង កិច្ចប្រជុំកំពូលពាក់ព័ន្ធ និង **មហាសន្និបាតអន្តរសភាអាស៊ាន (អាយប៉ា AIPA) លើកទី ៤៣**។ ព្រឹត្តិការណ៍ទាំងនោះបានរុញច្រានកិត្យានុភាព កម្ពុជា ឱ្យកាន់តែលេចធ្លោ និងខ្ពស់ត្រដែត លើឆាកអន្តរជាតិ។ ជោគជ័យខាងលើបានមក ក៏ដោយសារកត្តាសន្តិភាព សន្តិសុខ និងស្ថិរភាពនៅប្រទេសយើង ផងដែរ។

ដោយឡែក នៅឆ្នាំ ២០២២ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភាបានទទួលជោគជ័យយ៉ាងធំធេងលើគ្រប់ភារកិច្ចដែលរដ្ឋប្រគល់ជូន ដូចបានរៀបរាប់ក្នុងរបាយការណ៍សន្និបាត។

ក្រសួងយើងបានវិវត្តបណ្ដើរៗ និងប្រែប្រួលមុខមាត់កាន់តែប្រសើរ ពីមួយឆ្នាំទៅមួយឆ្នាំ។ ក្រសួងយើងដែលធ្លាប់មានទីតាំងតូចចង្អៀត និងអគារចាស់ទ្រុឌទ្រោម ដែលឥឡូវយើងមានទីតាំងល្អបំផុតមួយនៅកណ្ដាលរាជធានីភ្នំពេញ មានអគារធ្វើការសមរម្យ។ ដោយឡែក ថវិកាក្រសួងក៏ត្រូវបានកើនជាលំដាប់ ដោយសារយើងខិតខំបំពេញការងារ ដោយទទួលបានជោគជ័យ និងសមិទ្ធផលកាន់តែច្រើន។ ជាក់ស្ដែង ក្រសួងបានបង្កើតវិទ្យាស្ថានជាតិអធិការកិច្ច ដែលកំពុងកសាងសមត្ថភាពឈានទៅមុខជាជំហានៗ ពីបណ្ដុះបណ្ដាលមន្ត្រីរាជការក្រសួងយើង និងឈានទៅបណ្ដុះបណ្ដាលមន្ត្រីរាជការដែលពាក់ព័ន្ធនឹងការងារអធិការកិច្ចមកពីក្រសួង ស្ថាប័ន ដទៃថែមទៀត។

ទោះជាយើងទទួលបានជោគជ័យ ជាច្រើនក្នុងការងារក្ដី ក៏ក្រសួងនៅមានការប្រឈមជាច្រើនដូចជា៖ ទី១) កង្វះកិច្ចសហការពីក្រសួង ស្ថាប័នមួយចំនួន ទី២) នៅមានភាពស្រពិចស្រពិលអំពីតួនាទី និង ភារកិច្ចដែលស្រដៀងគ្នា ឬជាន់គ្នា ជាមួយស្ថាប័នមួយចំនួន ទី៣) កង្វះធនធាន ទាំងធនធានមនុស្ស និងធនធានថវិកា ទី៤) ការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ មន្ត្រីអធិការកិច្ចនៅមានចន្លោះប្រហោង និង ទី៥) ការទទួល ស្រាវជ្រាវ និងដោះស្រាយពាក្យបណ្ដឹងខ្លះមិនអាចដោះស្រាយបាន និងខ្លះអូសបន្លាយ ដោយសារភាពស្មុគស្មាញ ភាពរសើប និងភាពចំរូងចម្រាស់។

ទោះជាមានការប្រឈមខ្លះយ៉ាងណាក្តី ក្រសួងបានអនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម និងដោយការទទួលខុសត្រូវ ក្នុងការងារទទួលពាក្យបណ្តឹង (បណ្តឹងតវ៉ា និងបណ្តឹងបរិហារ) ការងារស៊ើបអង្កេតករណីបណ្តឹងពាក់ព័ន្ធទំនាស់ដីធ្លី ការងារសម្របសម្រួលបញ្ចប់ទំនាស់រ៉ាំរ៉ៃ បានជាច្រើនករណី ការងារតាមដានការអនុវត្តច្បាប់ ការកែលម្អរចំណុចខ្វះខាតរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈ លើកិច្ចការរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ ជម្រុញប្រសិទ្ធិភាព ផលិតភាព និងគុណភាពសេវាសាធារណៈ ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ។ លើសពីនេះក្រសួងក៏បានអប់រំ ណែនាំ បង្ការ ទប់ស្កាត់ និងកែលម្អរកំហុសឆ្គង ក្នុងការអនុវត្តការងាររបស់ក្រសួង-ស្ថាប័ន អង្គភាព គ្រឹះស្ថានសាធារណៈ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមួយចំនួន ដើម្បីកែលម្អរ និងលើកកម្ពស់អភិបាលកិច្ចល្អដែលជាស្នូល នៃយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាលរបស់រាជរដ្ឋាភិបាលកម្ពុជា។

លើសពីនេះទៀត ក្រសួងបានចុះផ្សព្វផ្សាយច្បាប់ គ្រប់ខេត្ត រាជធានី ដើម្បីលើកតម្កើងការយល់ដឹងអំពីច្បាប់សំខាន់ៗនានា ជូនប្រជាពលរដ្ឋ ជាពិសេសយុវជន និងសិស្ស។ ក្រសួងក៏បានបណ្តុះបណ្តាលមុខជំនាញ ទាក់ទងនឹងអធិការកិច្ចដល់មន្ត្រីរាជការ ក្រសួង និងមន្ត្រីអធិការកិច្ចតាមក្រសួងស្ថាប័នផ្សេងៗផងដែរ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី !**

ដើម្បីសម្រេចបាននូវគោលដៅអនាគត ឆ្នាំ២០២៣ ខ្ញុំសូមស្នើឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗដូចខាងក្រោមនេះ៖

១. ត្រូវខិតខំបំពេញការងារ ទៅតាមតួនាទី ដោយទទួលខុសត្រូវខ្ពស់ ដើម្បីបង្កើតសមិទ្ធផលជូនក្រសួង ។

២. ត្រូវអនុវត្តអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ ២០២០ ស្តីពីក្របខ័ណ្ឌមុខងាររបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ចដូចខាងក្រោម៖

- ចុះធ្វើអធិការកិច្ចលើអង្គភាពណា ដែលមានហានិភ័យខ្ពស់ ដូចជាអង្គភាពរកចំណូល និងចំណាយថវិការដ្ឋច្រើនដែលអាចទាក់ទងនឹងអំពើពុករលួយ ឬការកិបកេងថវិការដ្ឋ។
- ផ្នែកដ៏ទៃទៀត ជាពិសេសការផ្សព្វផ្សាយច្បាប់ ការទទួល និងដោះស្រាយពាក្យបណ្តឹង និងការតាមដានការអនុវត្តច្បាប់ត្រូវធ្វើបន្តជាធម្មតា។

៣. ត្រូវពង្រឹងវិន័យការងារ ដោយត្រូវវត្តមានឱ្យបានជាប់ជាប្រចាំ និងបន្តបំពេញការងារជាធម្មតា ដោយត្រូវតាមដានព័ត៌មាន និងស្រាវជ្រាវឯកសារ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធនឹងការងារក្រសួង ដើម្បីពង្រឹងសមត្ថភាពជំនាញទៅតាមតួនាទី និងភារកិច្ច។

៤. ត្រូវអនុវត្តឱ្យបានល្អ តាមអភិក្រមទាំងប្រាំ របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** គឺ៖ "**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**" និងបាវនា ២ គឺ "**កែទម្រង់ខាងក្នុង និងបង្កើតមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ**"។

៥. ក្នុងពេលបំពេញបេសកកម្មចុះធ្វើអធិការកិច្ច មន្ត្រី ឬភ្នាក់ងារអធិការកិច្ចត្រូវគោរពឱ្យបានខ្ជាប់ខ្ជួន និងម៉ឺងម៉ាត់ ទៅតាមក្រមសីលធម៌មន្ត្រីរាជការអធិការកិច្ច ដែលបានដាក់ចេញរួចហើយតាមប្រកាស

លេខ ០៧៨ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៨ ដែលក្នុងនោះតម្រូវឲ្យមន្ត្រីអធិការកិច្ចត្រូវឈរលើគោលការណ៍គ្រឹះ សុចរិតភាព ភាពមិនលំអៀង សមត្ថភាពវិជ្ជាជីវៈ ឯករាជ្យភាព ត្រូវមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ ដោយយកច្បាប់ជាធំ និងត្រូវមានឯកសណ្ឋានសមរម្យ ដូចដែលក្រសួងបានណែនាំរួចហើយ។ ត្រូវពង្រឹងប្រសិទ្ធភាព ក្នុងបេសកកម្មចុះធ្វើអធិការកិច្ច ការអង្កេត ស្រាវជ្រាវពាក្យបណ្ដឹង និងការតាមដានការអនុវត្តច្បាប់ តាមរយៈការរកព័ត៌មានឲ្យមានតុល្យភាពច្បាស់លាស់ មានភស្តុតាង និងឯកសារសំអាងគ្រប់គ្រាន់។

៦. ពង្រឹងការផ្សព្វផ្សាយច្បាប់ ឲ្យបានទូលំទូលាយ គ្រប់២៥ រាជធានី-ខេត្ត ជាពិសេសទៅតាមសាលារៀន ទីប្រជុំជន និងជនបទដាច់ស្រយ៉ាល ដោយមានការចូលរួមពីមន្ត្រីជំនាញ ដែលទាក់ទងនឹងច្បាប់ ពីក្រសួង ស្ថាប័ន ឬមន្ទីជំនាញ និងត្រូវសហការជាមួយរដ្ឋអំណាចមូលដ្ឋាន។

៧. ត្រូវបន្តពិភាក្សាសេចក្តីព្រាងច្បាប់អធិការកិច្ច ដែលក្រសួងបានតាក់តែងរួច ដោយបន្តសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យច្បាប់នេះត្រូវបានអនុម័ត។ លើសពីនេះក្រុមការងារតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តត្រូវតាក់តែងសេចក្តីប្រកាសរបស់ក្រសួង ដើម្បីតម្រង់ទិសការងារដោយមិនបាច់រង់ចាំច្បាប់អធិការកិច្ចដូចជាៈ ស្តង់ដារអធិការកិច្ច នីតិវិធីអធិការកិច្ច ក្រមសីលធម៌មន្ត្រីអធិការកិច្ច (ដោយធ្វើបច្ចុប្បន្នភាព ប្រកាសលេខ០៧៨ ឆ្នាំ២០០៨ និងបទបញ្ជាផ្ទៃក្នុង លេខ៥៩៦ ឆ្នាំ ២០១៤) នីតិវិធី នៃការតាមដានការអនុវត្តច្បាប់ នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹង និងនីតិវិធី នៃការផ្សព្វផ្សាយច្បាប់ ។ល។

៨. ត្រូវអនុវត្តបន្តនូវកម្មវិធី ទទួលពាក្យបណ្ដឹងអនឡាញ និងជម្រុញបណ្ណាល័យ អេឡិចត្រូនិក (e-Library) ដែលតាមរយៈកម្មវិធីទាំងនោះ ប្រជាពលរដ្ឋ អាចដាក់ពាក្យបណ្ដឹង និងអាចមើលឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានាតាមកុំព្យូទ័រ និងទូរស័ព្ទដៃបានយ៉ាងងាយស្រួល និងចំណេញពេលវេលា។ ការអនុវត្តកម្មវិធីទាំងនេះ គឺជាការរួមចំណែកសម្រួលការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

៩. វិទ្យាស្ថានជាតិអធិការកិច្ច ត្រូវពង្រឹងគុណភាពបណ្តុះបណ្តាល ជាពិសេសពង្រឹងសមត្ថភាពគ្រូបង្គោល។ ដោយសារក្រសួងយើងជាស្ថាប័នស្នូលលើវិស័យអធិការកិច្ច ដូច្នេះយើងត្រូវតែយល់ច្បាស់ និងមានសមត្ថភាពខ្ពស់ជាងគេលើវិស័យនេះ។ វិទ្យាស្ថានត្រូវរៀបចំខ្លឹមសារ កម្មវិធីបណ្តុះបណ្តាល លើជំនាញអធិការកិច្ច និងជំនាញពាក់ព័ន្ធឱ្យបានល្អ និងស្របទៅតាមបរិបទកម្ពុជា។

១០. ត្រូវបន្តធ្វើការកែទម្រង់ផ្ទៃក្នុងក្រសួងជាបណ្តើរៗ ជាពិសេសពង្រឹងសមត្ថភាពអង្គភាពថវិកា ដើម្បីត្រៀមអនុវត្តថវិកាកម្មវិធីពេញលេញ និងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

១១. ទោះជាមានស្ថាប័នច្រើន មានភារកិច្ចស្រដៀងគ្នា ឬត្រួតគ្នាក៏ដោយ យើងត្រូវតែពន្យល់ពីសារៈសំខាន់នៃការងារអធិការកិច្ច ដែលជាស្ថាប័នត្រួតពិនិត្យ ជម្រុញអភិបាលកិច្ច និងពង្រឹងប្រសិទ្ធភាពការងារ ដល់ស្ថាប័នផ្សេងៗទៀតឱ្យយល់ និងត្រូវកែទស្សនៈដែលខុសឆ្គងពី "**ការងារត្រួតគ្នា**" ទៅជា "**ការងារបំពេញបន្ថែមគ្នាទៅវិញទៅមក**" ដើម្បីបុព្វហេតុអភិបាលកិច្ចល្អ និងការរួមចំណែកប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយរបស់រាជរដ្ឋាភិបាលតែមួយ។

ជាថ្មីម្តងទៀត ខ្ញុំសូមកោតសរសើរ ចំពោះថ្នាក់ដឹកនាំ និងសមាជិកនៃ ក្រុមការងារនៃគណៈកម្មការរៀបចំសន្និបាត ដែលបានខិតខំបំពេញការងារយ៉ាងសកម្ម និងដោយស្មារតីទទួលខុសត្រូវខ្ពស់ធ្វើ

ឱ្យសន្និបាតក្រសួងឆ្នាំនេះបានទទួលជោគជ័យគួរជាទីពេញចិត្ត។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបណ្ដាក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានអញ្ជើញមកចូលរួមក្នុងសន្និបាតនេះ។

មុននឹងបញ្ចប់ ខ្ញុំសូមអបអរសាទរចំពោះលទ្ធផល ដែលអង្គសន្និបាតសម្រេចបានក្នុងរយៈពេលពេញមួយថ្ងៃនេះ និងជឿជាក់យ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់នឹងបន្តអនុវត្តភារកិច្ច ដោយយកចិត្តទុកដាក់ខ្ពស់ ដើម្បីបង្កើតសមិទ្ធផលថ្មីៗថែមទៀត ជូនរាជរដ្ឋាភិបាល ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍របស់ជាតិ។

ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ ខ្ញុំសូមប្រកាសបិទ**សន្និបាត ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឆ្នាំ២០២២-២០២៣។**

**សូមអរគុណ**

# ឧបសម្ព័ន្ធ ទី៦. កម្រងរូបថតអនុស្សាវរីយ៍



សន្និបាតបូកសរុបការងារក្រសួង
ឆ្នាំ ២០២២-២០២៣ នៅ
សណ្ឋាគារសុខាភ្នំពេញ កាលពី
ថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០២៣










SOKHA


សន្និបាត
SOKHA


















អនុរដ្ឋលេខាធិការ

























ចងក្រង និងបោះពុម្ពផ្សាយដោយ
ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា -ព្រឹទ្ធសភា និងអធិការកិច្ច